មង្គលកថា

មង្គលទី ៣៤

រៀបរៀងដោយ

ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី

ព.ស.២៥៥៧

ពុទ្ធប្បវត្តិសង្ខេប

ព្រះពុទ្ធមានព្រះនាមថាព្រះសទ្ធត្ថជាបុគ្គលប្រសើរបំផុតក្នុងលោក។ បិតាព្រះនាម សុទ្ធោទន:, មាតាព្រះនាម សិរិមហាមយា, ព្រះនគរឈ្មោះ កបិលពស្តុ, សព្វថ្ងៃជាប្រទេសនេប៉ាល បែកចេញពីឥណ្ឌា, ប្រសូតនៅថ្ងៃ សុក្រ ១៥ កើត ខែវិសាខ ឆ្នាំ ច, ត្រកូលជាក្សត្រ សក្យវង្ស តំណពីព្រះបាទ ឱក្កាកវាជ ប្អូនរួមបិតាព្រះនាម ព្រះនន្ទ មាតាផ្សេងគ្នាព្រះជន្ម ១៦ព្រះវស្សា មានអគ្គមហេសី ព្រះនាមពិម្ពាយសោធរា ព្រះជន្ម ២៩ ព្រះវស្សា រាហុល ជាបុត្រប្រសូត និងទ្រង់ចេញសាងផ្នួសព្រះជន្ម ២៩ ព្រះវស្សា ត្រាស់ជា ព្រះពុទ្ធព្រះជន្ម ៣៥ ព្រះវស្សា ព្រះនាមថា សមណគោតម ។

ស្ថានទីគង់ចាំព្រះវស្សា

១-ឥសិបតនមិគទាយវ័ន, ២-៤ វត្តវេឡុវ័ន, ៥-កូដាគារសាលាមហាវ័ន ៦-មកុដបព៌តដែនមគធ:, ៧-ឋានតាវត្តិង្ស, ៨-កេសកទ្ធាវ័ន កគ្គរាជ-ជនបទ, ៩-ឃោសិតារាម, ១០-ព្រៃបាលិលេយ្យ ១១-ដងព្រៃជិតស្រុក សាលា លេយ្យក:,១២-ក្រោមដើមស្តៅជិតស្រុកវេរញ្ជា,១៣-ចាលិកប-ពត៌, ១៤-វត្តជេតពន ១៥- វត្តនិគ្រោធារាម, ១៦-ស្រុកអាឡវី, ១៧-វត្ត វេឡុវ័ន ១៨-១៩-ចាលិកបពត៌ ២០- វេឡុវ័ន, ២១-៤៤ វត្តជេតពន, ៤៥- ស្រុកវេឡុវគ្រាម ។

ព្រះជន្ម ៨០ ព្រះវស្សា ដាក់ព្រះជន្មាយុ និងបរិញ្ញានក្នុងនគរ កុសិនារា នៅថ្ងៃអង្គារ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ ក្នុងវេលាជិតភ្លឺ ។ ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនា ៥.០០០ ព្រះវស្សា រហូតរៀងមក ។

ទេវតាមួយម៉ឺនចក្រវាឡ ចុះមកអារាធនាសូមឱ្យព្រះអង្គសម្តែងមង្គល

រឿងមង្គលនេះទេវតាមួយម៉ឺនចក្រវាឡប្រើពេលអស់ ១២ឆ្នាំ រកមង្គលតែរកមិនឃើញលុះដល់ព្រះអង្គបានត្រាស់ដឹងក៏នាំគ្នាចុះមកទូលសួរព្រះអង្គ ។ ព្រះអង្គបានសម្តែងមង្គលទាំង ៣៨ ប្រការមានកិរិយាមិនសេពគប់បុគ្គលពាលជាដើមរហូតដល់មានចិត្តក្សេមក្សាន្ត កាលចប់ ***ទេវតាសម្រេចជាព្រះអរហន្តរាប់សែនកោដិ ។ សម្រេចជាសោតាបត្តិផលសកទាគាមិផលអនាគាមិផលរាប់ប្រមាណមិនបាន ។***

មង្គលកថា

មង្គលទី ៣៤

រៀបរៀងដោយ

ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី

វត្តនិគ្រោធវន គល់ទទឹង

ព.ស.២៥៥៧

-ឈ្មោះសៀវភៅ មង្គលកថាមង្គលទី ៣៤

-រៀបរៀងដោយ ភិក្ខុសីលបញ្ញោ ឆែ សុផល្លី

-អនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័រដោយ **អគ្គឆីរោ គង់ សុមិត្ត**

-ចេញផ្សាយ លើកទី ១

-កាលបរិច្ឆេទ ព.ស. ២៥៥៧

- ទីកន្លែងធ្វើ វត្តនិគ្រោធវ័ន"គល់ទទឹង" ភូមិកោះក្របី

សង្កាត់ព្រែកថ្មី ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

អារម្ភកថា

មនុស្សនៅលើសកលលោកយើងនេះ សុទ្ធតែជាអ្នកប្រាថ្នានូវសេចក្តីសុខចម្រើន សិរីសួស្តី សុភមង្គល ភាពសុខដុមរមនាគ្រប់គ្នា ៗទាំងអស់មិនចំពោះថា ជាតិសាសន៍ណាឡើយ មានអ្នកខ្លះព្រោះតែចង់បានសេចក្តីសុខ ចម្រើន សិរីសួស្តី សុភមង្គលដល់ជីវិតខ្លាំងពេកទៅ រហូតដល់ថ្នាក់ បន់ស្រន់បួងសួង អារក្សអ្នកតាទេវតា ព្រៃភ្នំ មន្តអាគមអូមអាមផ្សេង ៗនិងមានអ្នកខ្លះទៀតយល់ថា ទាល់តែមានទ្រព្យ សម្បត្តិស្តុកស្តម្ភ មានយសសក្តិខ្ពង់ខ្ពស់ មានគេគោរពលើកតម្កើង បរិវារ បៃហាម ចោមរោម ការពារគ្រប់ជំហានជាដើម ទើបជីវិតមាននៅសិរី សួស្តីសុភមង្គល ។ ទង្វើទាំងអស់នេះ វាផ្ទុយស្រឡះអំពីគន្លងនៃព្រះពុទ្ធសាសនាទាំងស្រុង ។

នៅក្នុងព្រះធម៌របស់ព្រះអង្គទាំង ៨៤,០០០ ព្រះធម្មខន្ធ ដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកទាំង ១១០ ក្បាល ដោយព្រះអង្គសម្តែងអស់រយៈពេល ៤៥ ព្រះវស្សានោះ ទាំងសម្តែងឋានទេវតា ឋានមនុស្សគ្រប់ស្រុកតំបន់ផ្សេង ៗនោះ មានព្រះសូត្រមួយឈ្មោះថា **មង្គលសូត្រ** ដែលជាព្រះសូត្រសម្តែងអំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ខ្ពង់ខ្ពស់ត្រឹមត្រូវនៃជីវិត ។ និងជាព្រះសូត្រដែលព្រះអង្គសម្តែងបើកបង្ហាញដល់មនុស្សនិង

ទៅតានាសម័យនោះ ។ ព្រះសូត្រនេះសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលប្រាថ្នានូវសិរីសួស្តីដល់ខ្លួនឯង ក្រុមគ្រួសារ ញាតិមិត្ត បងប្អូន និងសង្គមជាតិទាំងមូល ។ ព្រោះព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងចំតែម្តង អំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ឧត្តមនៃជីវិត ។

នៅក្នុងអដ្ឋកថា **មង្គលជាតក** បានពោលអំពីព្រាហ្មណ៍ម្នាក់អ្នកនៅក្នុងក្រុងនគរពារាណសីគ្រឹះ ជាអ្នកប្រកាន់មង្គលភ្ជាក់ផ្អើលមិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាបុគ្គលមិច្ឆាទិដ្ឋិ មានភោគសម្បត្តិច្រើន ។

ក្នុងកាលនោះកណ្តុរបានកាត់នូវសម្ពត់សាដកមួយគូរបស់គាត់ ។ ដល់ពេលគាត់ត្រូវការឱ្យគេយកសំពត់នោះមក ទើបដឹងថាត្រូវកណ្តុរកាត់ដាច់ជាអន្លើ ៗទៅហើយ ។ ព្រាហ្មណ៍គិតថា សំពត់នេះជាអពមង្គល បើទុកនៅនឹងផ្ទះនាំឱ្យមានការវិនាសយ៉ាងក្រៃលែង គឺវាដូចជាកាឡកណ្ណីមួយអ៊ីចឹង ទាំងមិនអាចឱ្យដល់បុត្រធីតាឬទាសកម្មករផង ព្រោះសេចក្តីវិនាសនឹងកើតដល់អ្នកទទួលសំពត់នោះទៅគ្រប់គ្នា ត្រូវយកទៅចោលក្នុងព្រៃខ្មោចទើបបាន ។

ព្រាហ្មណ៍មិច្ឆាទិដ្ឋិ មិនឱ្យពួកទាសកម្មករយកទៅចោលទេ ដោយខ្លាចពួកទាសកម្មករ នាំយកនូវសំពត់នោះទៅប្រើប្រាស់បណ្តាលឱ្យវិនាសត ៗគ្នា ។ ទើបព្រាហ្មណ៍ប្រាប់ឱ្យកូនប្រុសរបស់គាត់យកឈើឆ្កឹះទាក់នូវសំពត់នោះ នាំទៅចោលនៅព្រៃខ្មោច ហើយត្រូវងូតទឹកមុជឱ្យលិចក្បាលសឹមត្រឡប់មកផ្ទះវិញ ។

ព្រះបរមសាស្តាសម្មាសម្ពុទ្ធគង់ប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ជ្រាបឧបនិស្ស័យនៃព្រាហ្មណ៍ពីរនាក់ឪពុកនិងកូន ព្រះអង្គបានយាងទៅកាន់ព្រៃខ្មោចនោះ ហើយទ្រង់កាន់យកនូវសំពត់សាជកដែលកូនប្រុសរបស់ព្រាហ្មណ៍បានចោលហើយ ទាំងដែលកូនប្រុសនោះឃាត់ព្រះអង្គមិនឱ្យចាប់ ដោយអាងថា ជារបស់ចង្រៃ ។ ព្រះបរមសាស្តាទ្រង់កាន់យកនូវសំពត់មួយគូរនោះ រួលត្រឡប់មកកាន់វត្តវេឡុវ័នវិញ ។

កាលដែលកូនប្រុសត្រឡប់មកជម្រាបរឿងរ៉ាវ ដល់ឪពុកហើយ ឪពុកនិងកូនក៏ប្រញាប់នាំគ្នាទៅវត្តវេឡុវ័ន ដើម្បីសូមឱ្យព្រះសម្មាសម្ពុទ្ធចោលនូវសំពត់នោះទៅវិញ ។ ព្រាហ្មណ៍គិតថា បើព្រះសមណគោតម ប្រើសំពត់នេះទៅ វាត្រូវធ្វើឱ្យលំបាកដល់ព្រះអង្គផង ត្រូវវិនាសវត្តវេឡុវ័នផង ម្ល៉ោះហើយគេនិងនិន្ទាស្តីថា

មកដល់យើងជាពិតប្រាជក ដូច្នេះ យើងត្រូវយកសំពត់សាជក ថ្មី ៗទៅថ្វាយដល់ព្រះសមណគោតម ដើម្បីសូមឱ្យព្រះសមណ គោតម ចោលនូវសំពត់ចង្រៃនោះ ។

នៅពេលដែលព្រាហ្មណ៍ឪពុកនិងកូនប្រុសបានទៅដល់វត្ត ហើយ ព្រាហ្មណ៍ជាឪពុកបានក្រាបទូលព្រះសម្មាសម្ពុទ្ធដោយ សព្វគ្រប់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួក យើងមានឈ្មោះថាជាបព្វជិតដូច្នេះសំពត់ចាស់ ៗដែលគេចោល នៅព្រៃខ្មោច ឬគំនរសម្រាមជាដើម រមែងសមគួរដល់ពួកយើង ឯចំណែកព្រាហ្មណ៍ឯង មិនមែនទើបតែឥឡូវនេះទេ ពីជាតិមុន មក ក៏ធ្លាប់ប្រកាន់នូវលទ្ធិដូច្នេះដែរ ។

កាលដែលព្រាហ្មណ៍អារាធនាហើយ ព្រះអង្គទ្រង់ត្រាស់ សម្តែងនូវរឿងរ៉ាវអតីតជាតិ មានសេចក្តីប្រហែលគ្នានឹងបច្ចុប្បន្ន ដែរគ្រាន់តែកាលណោះ ព្រះបរមពោធិសត្វជាតាបសបានឈាន ហើយប្រោសព្រាហ្មណ៍ឯព្រាហ្មណ៍ក៏បានយកព្រះបរមពោធិសត្វ ជាសរណៈ ។

នៅក្នុងបិដកលេខ ៥៨ ទំព័រ ៣៨ **មង្គលជាតក** ព្រះ បរមសាស្តាទ្រង់ត្រាស់ថា ៖

មង្គលទាំង៦ប្បាយក្តី ឧត្បាតទាំង៦ប្បាយក្តី សុបិនទាំង៦ប្បាយក្តី លក្ខណៈទាំង៦ប្បាយក្តី ដែលបុគ្គលណាបានផ្តាច់បង់ហើយ បុគ្គលនោះឈ្មោះថា អ្នកកន្ថង់ផុតនូវទោសនៃមង្គល(ភ្ជាក់ផ្អើល) ។ ជាអ្នកគ្របសង្កត់នូវយុគក្លិសៈ(ក្រោធ ១ ការចងគំនុំ ១ ការមិលគុណ ១ និងការវាយឫកស្មើ ១ ទាំង ៤ នេះ ហៅថា យុគក្លិសៈ)និងយោគក្លិសៈ(កាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ១អវិជ្ជាយោគ ១)រមែងមិនមកកើតទៀតឡើយ ។

ដោយសេចក្តីថា បុគ្គលណាមិនប្រកាន់មង្គលភ្ជាក់ផ្អើល មិនប្រកាន់ឧត្បាត មិនប្រកាន់ការយល់សប្តិ មិនប្រកាន់លក្ខណៈជោគល្អ ឬជោគអាក្រក់ បុគ្គលនោះឈ្មោះថា ជាអ្នកកន្ថង់ផុតនូវទោសនៃការប្រកាន់មង្គលភ្ជាក់ផ្អើល ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ឱ្យព្រាហ្មណ៍ឪពុក និងកូនបានសម្រេចសោតាបត្តិផល ។

នៅក្នុងអដ្ឋកថា**នក្ខត្តជាតក** បានពោលអំពីត្រកូលមួយនៅក្រៅក្រុងសាវត្ថី បានទៅស្តីដណ្តឹងកុលធីតាម្នាក់នៅក្នុងក្រុងសាវត្ថី ដើម្បីជាប្រយោជន៍ដល់កូនប្រុសរបស់ខ្លួន ។ គេបានសន្យាថ្ងៃកំណត់មកទទួលយកកូនកូនស្រីទៅកាន់ត្រកូលខាងប្រុសប៉ុន្តែ

លុះដល់ថ្ងៃកំណត់ ត្រកូលខាងប្រុសគេបានសួរអាជីវកម្នាក់ដែលបានចូលទៅកាន់ត្រកូលរបស់ខ្លួនថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើនូវមង្គលមួយ តើនក្ខត្តឫក្សល្អដែរទេ ?

អាជីវកមានការខឹងក្រោធជាខ្លាំង ព្រោះគិតថាពួកអស់នេះមិនសួរយើងពីដំបូង ឥឡូវដល់ថ្ងៃទៅហើយទើបតែសួរ យើងនឹងផ្តល់មេរៀនឱ្យគេម្តង ដូច្នេះហើយក៏ពោលថា ថ្ងៃនេះមិនល្អទេ អ្នកទាំងអស់គ្នាកុំធ្វើមង្គលឡើយ បើចេះតែធ្វើនឹងមានការវិនាសធំ ។ ពួកមនុស្សក្នុងត្រកូលក៏ជឿអាជីវកនោះ ហើយក៏មិនបានទៅទទួលយកកូនស្រីក្នុងថ្ងៃហ្នឹងឡើយ ។

ចំណែកត្រកូលខាងស្រី បានចាត់ការមង្គលរៀបចំទទួលភ្ញៀវខាងប្រុស លុះមិនឃើញពួកគេមកតាមសន្យា ក៏លើកធីតាឱ្យទៅត្រកូលដទៃសម្រេចស្រេចបាច់ក្នុងថ្ងៃនោះដែរទៅ ។

ថ្ងៃស្អែកឡើង ត្រកូលក្រៅក្រុងក៏បាននាំគ្នាមកដល់សូមយកកូនស្រីពួកអ្នកក្នុងក្រុងក៏ពោលតិះដៀលថា ពួកអ្នកឯងសមនឹងឈ្នោះ អ្នកក្រៅក្រុងមែនហើយ ជាមនុស្សខ្វះសម្បត្តិរបស់មនុស្សល្អ ជាមនុស្សអាក្រក់ សន្យាគ្នាហើយ មើលងាយពាក្យសន្យា មិនមកតាមកំណត់ អញ្ជើញទៅតាមផ្លូវដែលអ្នករាល់គ្នា

មកនោះវិញទៅ ពួកយើងលើកកូនស្រីយើងឱ្យអ្នកផ្សេង ៗទៅ
ហើយ ។

ពួកអ្នកក្រៅក្រុង ខំប្រឹងឈ្លោះនឹងអ្នកក្រុងអស់មួយសន្ទុះ
ធំ លុះដឹងប្រាកដថា មិនបានកូនក្រមុំពិតហើយ ក៏នាំគ្នាត្រឡប់
ទៅវិញតាមផ្លូវដែលមកនោះឯង ។

រឿងទាំងអស់នេះបានជ្រាបដល់ព្រះមានព្រះភាគ ព្រះអង្គ
ទ្រង់ត្រាស់ព្រះជាតក ពីអាជីវកនោះធ្លាប់បំផ្លាញមង្គលរបស់គេ
តាំងពីជាតិមុនមកហើយ ។

ក្នុងជាតិមុននោះ អ្នកក្រុងពារាណសី ទៅស្តីដណ្តឹងកូនស្រី
អ្នកជនបទហើយមិនទៅតាមសន្យា ព្រោះថាជឿតាមពាក្យកុហក
របស់អាជីវក ។ រឿងរ៉ាងមានទំនងដូចគ្នា ខុសត្រង់ថាអ្នកជនបទ
បានតិះដៀលអ្នកក្រុងពារាណសីថា ពួកអ្នករាល់គ្នាឈ្មោះថាជា
អ្នកក្រុង ប៉ុន្តែខ្វះនូវសម្បត្តិរបស់មនុស្សល្អ ព្រោះមិនគោរពាក្យ
សន្យា ។ ក្នុងកាលណោះ ព្រះបរមពោធិសត្វជាបណ្ឌិត បាន
ពោលថា ផ្តាយទាំងឡាយនិងមានប្រយោជន៍អ្វី ព្រោះការបាន
កូនស្រីក្រមុំជាឫក្សស្អាតស្រេចទៅហើយ មិនមែនទេ ? រួចហើយ
ទើបព្រះបរមពោធិសត្វពោលនូវគាថា ៖

នៅក្នុងបិដកលេខ៥៨ទំព័រ ២២ **នក្ខត្តជាតក** បណ្ឌិតបុរសពោធិសត្វពោលថា ៖

នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា

អត្ថោ អត្តស្ស នក្ខត្តំ កិំ ករិស្សន្តិ តារកាតិ ។

ប្រែថា៖ ប្រយោជន៍រមែងកន្ធងបង់នូវមនុស្សល្ងង់ដែលរាប់អាននូវនក្ខត្តឫក្ស ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

បណ្តាបទទាំងនោះ បទថា **បដិមានេ្តន** ដោយសេចក្តីថា អ្នករង់ចាំមើលអធិប្បាយថា រង់តែរង់ចាំមើល នក្ខត្តឫក្សនឹងមានក្នុងពេលនេះ នឹងមានក្នុងកាលឥឡូវនេះ ។

បទថា **អត្ថោពាលំឧបច្ចគា** ដោយសេចក្តីថា ប្រយោជន៍ពោលគឺការបាននូវកូនក្រមុំ កន្ធងផុតនូវមនុស្សល្ងង់ដែលជាអ្នកក្រងពាពាណាសីនោះ ។

បទថា **អត្ថោអត្តស្ស នក្ខត្តំ** ដោយសេចក្តីថា បុគ្គលស្វែងរកនូវប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯង ឈ្មោះថាជានក្ខត្តឫក្សរបស់ប្រយោជន៍ ។

បទថា **កិំ ករិស្សន្តិ តារកា** ដោយសេចក្តីថា តើដួងផ្កាយ

ទាំងឡាយក្នុងអាកាសក្រៅអំពីនេះ នឹងញុំាងប្រយោជន៍ដូចម្តេច ឱ្យសម្រេចបាន ។

ម្យ៉ាងទៀត នៅក្នុងបិដកលេខ ៤១, ទំព័រ ៤៧៥ ត្រង់ **មគ្គលវគ្គ** ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងវេលាបុព្វណ្ហសម័យ(ពេលព្រឹក) សត្វទាំងនោះ ឈ្មោះថា **មានបុព្វណ្ហសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាមជ្ឈន្តិកសម័យ(ពេលថ្ងៃ) សត្វទាំងនោះឈ្មោះថា **មានមជ្ឈន្តិកសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចាប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាសាយណ្ហសម័យ(ពេលល្ងាច) សត្វទាំងនោះឈ្មោះថា សាយណ្ហសម័យដ៏ល្អ ។

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ ។

ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជា) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថា ជាគ្រឿងបូជាល្អ ។

បឋក្ខិណំ កាយកម្មំ វាចាកម្មំ បឋក្ខិណំ

បឋក្ខិណំ មនោកម្មំ បណិធី តេ បឋក្ខិណា ។

(ក្នុងថ្ងៃនោះ) កាយកម្មឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន មនោកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នារបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន ។

បឋក្ខិណានិ កត្វាន លភន្តត្ថេ បឋក្ខិណេ ។

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្មគួរដល់សេចក្តីចម្រើនហើយ រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។

នៅក្នុង**មង្គល**សូត្រនេះ ព្រះអង្គបានសម្តែងមានទាំងអស់ ១០ ព្រះគាថា ។ ក្នុងមួយគាថា មាន ៣ ក៏មាន ៤ ក៏មាន ៥ ក៏មាន ។ ព្រោកជាមាតិកា មានទាំងអស់ ៣៨ ប្រការ ដែលខាង

ដើម ព្រះអង្គទ្រង់ត្រាស់សម្តែងថា **អាសេវនា ច ពាលានំ** មិនឱ្យសេពគប់បុគ្គលពាល រហូតដល់ខាងចុងថា **ខេមំ** ធ្វើចិត្តឱ្យឃ្លាតចាកអំពីកិលេស ដែលហៅថា **ចិត្តក្បែរមក្សាន្ត** ។

សរុបមក បើបុគ្គលណាប្រាថ្នានូវសិរីសួស្តី សុភមង្គល ភាពសុខដុមរមនាដល់ខ្លួនដល់ក្រមគ្រួសារជាដើមនោះត្រូវព្យាយាមបដិបត្តិទៅតាមមង្គលទាំង ៣៨ ប្រការនេះចុះ, ឬថា ត្រូវប្រព្រឹត្តឱ្យល្អទៅតាមផ្លូវកាយ វាចា ចិត្ត ឱ្យបានជានិច្ចចុះ នុ៎ះសិរីសួស្តី សុភមង្គល សេចក្តីសុខចម្រើន នឹងកើតមានដល់បុគ្គលនោះឯង ។

សៀវភៅ **មង្គលកថា** ដែលនិយាយអំពីមង្គលទាំង ៣៨ ប្រការនេះ ខ្ញុំព្រះករុណាសង្ឃឹមថា នឹងបានជួយតម្រែតម្រង់មាគ៌ាជីវិតនៃពុទ្ធបរិស័ទគ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈទាំងអស់ ឱ្យដើរឈានទៅរកសេចក្តីសុខ និងការកែចម្រើននៃជីវិតទាំងនៅក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកនាយ រហូតដល់អស់នូវអាសវៈកិលេស ។

ម្យ៉ាងទៀត សៀវភៅនេះ បើសិនជាមានខុសត្រង់អក្ខរៈព្យញ្ជនៈកាសាបាលីសេចក្តីអធិប្បាយត្រង់ចំណុចណាមួយនោះ

សូមមេត្តាខន្តី អភ័ព្វទោសផង ។

ដោយអំណាចមហាកុសលចេតនា ដែលខ្ញុំមានចិត្តជ្រះថ្លា ក្នុងព្រះសទ្ធម្មរបស់ព្រះអង្គ ទិតទំាកសាងសន្សំព្យាយាមធ្វើសៀវ-ភៅនេះ សូមបានជាឧបនិស្ស័យដ៏ល្អបានពាល់ត្រូវនូវព្រះនិព្វានក្នុងពេលដ៏ខ្លីខាងមុខនេះផងចុះ តែបើមិនទាន់បានសម្រេចទេ សូមកើតជាតិណា ៗក៏ដោយ សូមកុំឱ្យស្គាល់ពាក្យថាអត់ ពាក្យថាគ្មាន ពាក្យថាក្រ ពាក្យថាលំបាក និងសូមឱ្យមានតែសិរីសួស្តី មិនមានសេចក្តីប្រមាទក្នុងជីវិត និងសូមឱ្យខ្ញុំមានបញ្ញាមោះមុតឆាប់ចាក់ធ្លុះនូវអរិយសច្ចធម៌ បានដល់នូវអមតដ្ឋាន **ក្នុងសាសនានៃព្រះសិរីអារ្យមេត្រីយ៍** កុំបីអាក់ខានឡើយ,ម្យ៉ាងទៀតសូមឧទ្ទិសបុណ្យកុសលនេះ ជូនដល់បុព្វការីជនទាំងឡាយ ដែលបានបែកធ្លាយរាងកាយទៅ និងពួកសត្វទាំងឡាយផង សូមបាននូវសេចក្តីសុខ ចូរជាអ្នកបានសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ មួយអន្ទើយដោយព្រះកុរុណាគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទ ។

សូមអនុមោទនា !!!

ថ្ងៃ១៣កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧

ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី

បញ្ជីមាតិកា

មាតិកា	មគ្គលកថា	ទំព័រ
អារម្ភកថា		ក
មគ្គលធី ៣៤ ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ...		១
ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន		១
ព្រះនិព្វាន		៤
បឋមនិព្វានសូត្រ		៦
ពាហិយសូត្រ		២១
បដិបទាដើម្បីធ្វើព្រះនិព្វានឱ្យជាក់ច្បាស់		៨៣
និព្ពិទាសូត្រ		៨៤
អាសវក្ខយសូត្រ		៨៥
បធានសូត្រ		៨៦
ទិដ្ឋិសូត្រ		៨៧
និទ្ទាតន្ទិសូត្រ		៨៨
សាវត្ថីសូត្រ		៩១
សមាធិសូត្រ		៩៥
វិរិយារម្ភាទិវគ្គទី ៧		១០៤
វិធីបដិបត្តិធ្វើព្រះនិព្វានឱ្យជាក់ច្បាស់		១២៥
ភាវនាសូត្រ		១២៥

មាតិកា **ទំព័រ**

បុញ្ញវិបាកសូត្រ ១៣៩
បច្ឆិមសូត្រ ១៤៦
អគ្គិសូត្រ ១៤៨
បឋមធម្មវិហារកសូត្រ ១៥២
បឋមអនាគតសូត្រ ១៥៦
បឋមសេក្ខសូត្រ ១៦១
កីសីលសូត្រ ១៦៤
រឿងបរិនិព្វានបស់ព្រះគោធិកត្ថេរ ១៦៦
ឱដ្ឋានសូត្រ ១៧៣
សូត្រទី ៥ ... ... ១៧៤
អដ្ឋកថាមហាសតិប្បដ្ឋានសូត្រ ១៨១
គុណសម្បត្តិបុគ្គលធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ ១៩១
វិត្ថារសូត្រ ១៩២
សេនាសនៈសូត្រ ២០១
និព្វាននៅឯណា ២០៥
និព្វានអត់កើតតើសុខនៅឯណា ២០៦
ប្រភេទរបស់ព្រះនិព្វាន ២០៦
និព្វានដោយអាការដែលចូលដល់ ២០៨

មាតិកា ទំព័រ

អនិមិត្តនិព្វាន … … … … … … … … … … … … ២០៨
អប្បណិហិតនិព្វាន … … … … … … … … … … ២០៩
សុញ្ញតនិព្វាន … … … … … … … … … … … … ២១០
គុណនាមរបស់និព្វាន … … … … … … … … … ២១១
គុណរបស់ព្រះនិព្វានមាន ២៩ យ៉ាង … … … ២១៥
អ្នកដែលអាចធ្វើនិព្វានឱ្យច្បាស់បាន … … … … ២១៨
ខ្លួនរបស់យើងអាចចូលទៅនិព្វានបានឬទេ … … ២១៩
និព្វានប្រៀបលក្ខណៈអាកាស ១០ ប្រការ … ២១៩
សភាពរបស់និព្វាន … … … … … … … … … … ២២២
បុគ្គលដល់ព្រះនិព្វានរមែងមិនកន្លងឋានៈ ៩ … ២២៨
តួយ៉ាងអ្នកដែលធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ … ២២៩
មោគ្គល្លានសូត្រ … … … … … … … … … … … ២៣០
គយាសូត្រ … … … … … … … … … … … … … ២៤៧
បរិនិព្វាន ៣ យ៉ាង … … … … … … … … … … ២៥៤
អានិសង្សការធ្វើនិព្វានឱ្យជាក់ច្បាស់ … … … … ២៥៦
សរុបសេចក្តីនៃព្រះគាថាក្នុងអដ្ឋកថា … … … … ២៥៨
គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ ២៦២

មង្គលទី ៣៥ ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន

តើទីណាខ្លះនៅក្នុងលោកនេះ ដែលទុក្ខចូលទៅមិនដល់... បើមិនមានហេតុអ្វីបានជាព្រះសិទ្ធត្ថចេញបួស និងរកទីណាដែលទុក្ខចូលទៅមិនដល់ ហើយជួបទេ...ជួបហើយនៅទីណា ... និព្វាន

មានអ្នកណាតាមព្រះអង្គទៅខ្លះទេ...ច្រើនណាស់ ហើយនិព្វាននៅទីណា... ដូច្នេះទើបត្រូវមកសិក្សាជាមួយគ្នា ។

ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន

និព្វាន *គឺជាអ្វី ?*

ពាក្យថា **និព្វាន** *ប្រែបានច្រើនបែបណាស់ តែសូមលើកយកមកពោលខ្លះ ៗ ដូចជា ៖*

បើពោលយ៉ាងធម្មតាសាមញ្ញបំផុតនោះថា **និព្វាន** *ជាទីរលត់ស្ងិតនៃតណ្ហា ។ ពាក្យថា* ***រលត់ស្ងិត*** *មានសេចក្តីថាការរលត់ទៅហើយ មិនមានកើតឡើងទៀតបាន ។*

ន័យមួយទៀតថា កិលេសរលត់អស់ទៅកាលណា កាលនោះឯង គឺដល់នូវ **និព្វាន** *។ ពាក្យថា* ***រលត់ អស់*** *គឺ*

សំដៅដល់ រលត់ស្និត ។

សេចក្តីសំគាល់មិនបានស្ថិតនៅលើតណ្ហា ឬកិលេស រលត់ទេ តែសំគាល់នៅត្រង់ការមិនកើត, បើអ្វី ៗមិនកើតទៀត ហើយ នុ៎ះឯង **និព្វាន** ។

នៅក្នុងគម្ពីរធម្មសង្គណី អធិប្បាយសព្ទទុកថា **និព្វាន** មកអំពីពាក្យថា **និ** ដែលប្រែថា **ផុតចាក** ។

និងពាក្យថា **វាន** ប្រែថា **តណ្ហា** ។

ដូច្នេះ ពាក្យថា **និព្វាន** ទើបប្រែថា **ធម្មជាតដែលផុតចាកតណ្ហា** ។

ឬ **និព្វាន** ប្រែថា **រលត់, សូន្យ, គឺរលត់កិលេសរលត់ទុក្ខ, សូន្យចាកកិលេស, សូន្យចាកទុក្ខ** ។

ឬ**និព្វាន** ប្រែថា**សេចក្តីផុត គឺផុតទុក្ខ ផុតចាកភពបី** ។

នៅក្នុងអភិធម្មត្ថសង្គហៈបាលី សម្តែងថា វានសង្ខាតាយ តណ្ហាយ និក្ខន្តត្តា និព្វានំ= **ធម្មជាតដែលផុតចាកតណ្ហាគ្រឿងស្រោចនោះ** ហៅថា **និព្វាន** ។

នៅក្នុងបរមត្ថទីបនីដីកា សម្តែងថា ន‌ត្ថិ វានំ ឯត្ថាតិ

និព្វានំ= **ធម្មជាតរបស់សេចក្តីស្ងប់ស្ងាត់ ដែលកើតដោយការផុតចាកតណ្ហានោះ** ហៅថា **និព្វាន** ។

នៅក្នុងគម្ពីរវិសុទ្ធិមគ្គ សម្តែងថា តយិទំ សន្តិ លក្ខណំ **និព្វានមានតែសេចកីសុខ ដោយផុតចាកកិលេស ជាលក្ខណៈ** ។

សុខ
- **វេទយិតសុខ,** សុខកើតអំពីវេទនា
- **សន្តិសុខ,** សុខកើតផុតចាកវេទនា ។

<u>វេទយិតសុខ</u> សុខដែលកើតអំពីវេទនានោះ ជាសុខដែលកើតអំពីការសោយអារម្មណ៍ ជាទុក្ខសច្ច ។

<u>សន្តិសុខ</u> សុខដែលកើតដោយផុតចាកវេទនានោះ ជាសុខ ដែលមិនបានកើតអំពីការសោយអារម្មណ៍ទេ ជានិរោធ-សច្ច ។

សុខ និងមានបានយ៉ាងណាក្នុងព្រះនិព្វាន ព្រោះ

និព្វានមិនមានការសោយអារម្មណ៍ ។

នៅក្នុង **សុត្តន្តបិដក** លេខ ៣៣ មានសម្តែងទុកថា **ការមិនសោយអារម្មណ៍នោះឯង ជាសេចក្តីសុខដ៏ពិតប្រាកដ ជាសេចក្តីសុខយ៉ាងក្រៃលែង ព្រោះសុខដែលកើតអំពីការសោយអារម្មណ៍នោះ ជាសុខដែលមិនទៀង ក៏គឺជាទុក្ខនោះឯង ។**

ដូច្នេះ ទើបចាត់ជា **សុខវេទនា** ឬថាជា **វិបរិណាមទុក្ខ** គឺសេចក្តីសុខនោះ នឹងត្រូវវិបរិត្តផ្លាស់ប្តូរទៅជាទុក្ខយ៉ាងពិតប្រាកដ ។

ចំណែក **សុខក្នុងនិព្វាន** មិនមែនសុខវេទនា តែថាជា **សន្តិសុខ** ទើបមិនប្រែប្រួលទៅជាយ៉ាងដទៃ ។

និព្វាន ពេលដោយសេចក្តីមាន ២ នយធំ ៗគឺ

- សំដៅដល់ **សភាពនៃចិត្តដែលអស់កិលេស**
- សំដៅដល់ **ខេត្តដែនដែលអ្នកអស់កិលេស ទៅសោយសុខ ដែលជាសុខអមតៈនៅទីនោះ ៗ ។**

ព្រះនិព្វាន

ធម្មតាព្រះនិព្វាន បុគ្គលឃើញបានដោយក្រ និព្វានសច្ចៈមិនមែនសម្រាប់ឃើញបានដោយងាយទេ កិលេសជាគ្រឿងកង្វល់

រមែងមិនមានដល់បុគ្គលកាលដឹង កាលឃើញតណ្ហា ព្រោះត្រាស់ដឹង(នូវសច្ចៈ) ។ (ខុ. ៥២ ទំព័រ ៣២១) ។

ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា **អជាតៈ** ឈ្មោះ **អភូតៈ** ឈ្មោះថា **អកតៈ** ឈ្មោះថា **អសង្ខតៈ** មានប្រាកដ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើព្រះនិព្វាននោះឈ្មោះថា **អជាតៈ** ឈ្មោះ អភូតៈឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈមិនមានទេ ការរលាស់ចេញនូវកិលេស ដែលនាំឱ្យកើតមហាភូតរូប ដែលប្រាកដនូវហេតុដែលធ្វើនូវបច្ច័យ ដែលតាក់តែងក្នុងលោកនេះក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា **អជាតៈ** ឈ្មោះ អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ រមែងមានប្រាកដ ព្រោះហេតុណា ហេតុនោះ ការរលាស់ចេញនូវកិលេសដែលនាំឱ្យកើតមហាភូតរូបដ៏ប្រាកដ នូវហេតុដែលគួរធ្វើនូវបច្ច័យជាទីតាក់តែង ក៏រមែងប្រាកដ ។ (ខុ. ៥២ ទំ៣២២) ។

ការញាប់ញ័ររបស់បុគ្គលអ្នកអាស្រ័យ(ដោយតណ្ហានឹងទិដ្ឋិ)រមែងមាន ការញាប់ញ័ររបស់បុគ្គលអ្នកមិនអាស្រ័យ(ដោយតណ្ហានឹងទិដ្ឋិ)មិនមាន កាលបើសេចក្តីញាប់ញ័រមិនមានបស្សទ្ធិ

(សេចក្តីស្ងប់) ក៏កើតមានឡើង កាលបើបស្សទ្ធិមាន(សេចក្តីស្ងប់)ក៏កើតមានឡើង កាលបើបស្សទ្ធិមាន តម្រេកក៏រមែងមិនមាន កាលបើតម្រេកមិនមាន ដំណើរមកនឹងដំណើរទៅ ក៏មិនមានកាលបើដំណើរមក ដំណើរទៅមិនមានការច្យុតិនឹងការកើតក៏មិនមាន កាលបើការច្យុតិនឹងការកើតមិនមាន ដំណើរទៅមកក្នុងឥធលោកនឹងបរលោកក៏មិនមាន ទាំងមិនមានក្នុងរវាងនៃលោកទាំងពីរ នេះជាទីបំផុតនៃទុក្ខ ។ (បិ ៥២ ទំព័រ ៣២៣) ។

បឋមមនិព្វានសូត្រ

នៅក្នុងបិដកលេខ ៥២ ទំព័រ ៣២០ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពី **[ការត្រាស់ដឹងដល់ទីបំផុតទុក្ខ]** មានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគទ្រង់ពន្យល់ភិក្ខុទាំងឡាយឱ្យយល់ច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ពួកភិក្ខុទាំងនោះបានធ្វើឱ្យជា

ប្រយោជន៍ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់ ដោយចិត្ត ផ្តង់ត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្ទឺឧទាននេះក្នុងវេលានោះថា ៖

អត្ថិ ភិក្ខវេ តទាយតនំ យត្ថ នេវ បឋវី ន អាបោ ន តេជោ ន វាយោ ន អាកាសានញ្ចាយតនំ ន វិញ្ញានញ្ចាយតនំ ន អាកិញ្ចញ្ញាយតនំ ន នេវសញ្ញានាសញ្ញាយតនំ នាយំលោកោ ន បរលោកោ ន ឧភោ ឥន្ទិមសុរិយា តមហំ ភិក្ខវេ នេវ អាគតំ វទាមិ ន គតឹ ន ឋិតឹ ន ចុតឹ ន ឧបបត្តឹ អប្បតិដ្ឋំ អប្បវត្តំ អនារម្មណមេវតំ ឯសេវន្តោ ទុក្ខស្សាតិ ។

ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះ រមែងមានពិត ដីមិនមាន ទឹកមិនមាន ភ្លើងមិនមាន ខ្យល់មិនមាន អាកាសានញ្ចាយនៈមិនមាន នេវសញ្ញានាសញ្ញាយតនៈមិនមាន លោកនេះមិនមាន លោកមុខមិនមាន ព្រះចន្ទនិងព្រះអាទិត្យទាំងពីរក៏មិនមាន ក្នុងព្រះ

និព្វានណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលព្រះនិព្វាននោះថា មិនមានដំណើរមក មិនមានដំណើរទៅ មិនមានការតាំងនៅ មិនមានការច្យុតិ មិនមានការកើត មិនមានទី ជាទីតាំង មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍ ព្រះនិព្វាននោះជាទីបំផុតនៃទុក្ខតែម្យ៉ាង ។

អដ្ឋកថា

បទថា និព្វានបដិសំយុត្តាយ សេចក្តីថា អសង្ខតធាតុ ដែលអាស្រ័យអមតធាតុ ប្រព្រឹត្តទៅដោយអំណាចការប្រកាសឱ្យដឹង ។ បទថា ធម្មិយា កថាយ ប្រែថា ដោយធម៌ទេសនា ។ បទថា សន្ទស្សេតិ បានដល់ សម្តែងដល់ព្រះនិព្វាន ដោយលក្ខណៈនៃសភាវៈព្រមដោយកិច្ច ។ បទថា សមាទបេតិ បានដល់ ឱ្យភិក្ខុទាំងនោះ ប្រកាន់យកអត្ថនោះឯង ។ បទថា សមុត្តេជេតិ បានដល់កាលឱ្យឧស្សាហ៍កើតក្នុងកាលប្រកាន់ប្រយោជន៍ នោះឈ្មោះថា រមែងឱ្យអប់កំដៅ គឺឱ្យរុងរឿង ។

បទថា សម្បហំសេតិ បានដល់ រមែងឱ្យត្រេកអរដោយគុណគឺព្រះនិព្វានដោយប្រពៃតែម្តង គឺដោយប្រការទាំងពួង ។ ម្យ៉ាងទៀត ។ បទថា សន្ទស្សេតិ សេចក្តីថា ទ្រង់សម្តែងដោយ

ប្រពៃ ដែលសមរម្យដល់អធ្យាស្រ័យរបស់ភិក្ខុទាំងនោះ ។ ដោយប្រការទាំងពួង គឺដោយបរិយាយនោះ ។ ដោយន័យមានជាដើមថា ធម៌ជាទីអស់តណ្ហា ជាទីបំបាត់រាគៈ ជាទីរលត់ដែលជាគ្រឿងស្ងប់សង្ខារទាំងពួង ដែលជាឧបធិទាំងពួងនោះ ។ បទថា **សមាទបេតិ** សេចក្តីថា ទ្រង់ធ្វើឱ្យភិក្ខុទាំងឡាយ បង្អោនទៅ ជ្រាយទៅ ជ្រោយទៅក្នុងធម៌នោះ ព្រមដោយបដិបទាគ្រឿងសម្រេច ឈ្មោះថា ទ្រង់បបួល គឺឱ្យភិក្ខុកាន់យកដោយប្រពៃថា លោកគប្បីសម្រេចព្រះនិព្វាននោះ ដោយអរិយមគ្គនេះ ។ បទថា **សមុត្តេជេតិ** សេចក្តីថា ទ្រង់ធ្វើភិក្ខុទាំងនោះឱ្យអាចហ៊ាន ក្នុងការសម្រេចព្រះនិព្វាន ឬឱ្យធ្វើចិត្តឱ្យផ្សេងក្នុងព្រះនិព្វាននោះ ដោយព្រះតម្រាស់ថា ពួកលោកកុំដល់សេចក្តីប្រមាទគឺ ដល់សេចក្តីឈប់ក្នុងចន្លោះ ក្នុងសម្មាបដិបត្តិថា ព្រះនិព្វាននេះ ធ្វើបានលំបាក មានសេចក្តីត្រេកអរបានលំបាក ព្រោះព្រះនិព្វាននេះ ដែលអ្នកសម្បូរណ៌ដោយឧបនិស្សយមានសេចក្តីព្យាយាម មិនមែនធ្វើបានលំបាក ព្រោះដូច្នោះ ពួកលោកគប្បីក្រោកឡើងព្យាយាមដើម្បីបដិបទាដែលហ្មត់ចត់មានសីលវិសុទ្ធិជាដើម ។ បទថា **សម្បហំ-**

សេតិ សេចក្តីថា កាលទ្រង់ធ្វើចិត្តរបស់ភិក្ខុទាំងនោះ ឱ្យត្រេកអរ ឱ្យរីករាយ ដោយការប្រកាសអានិសង្សនៃព្រះនិព្វាន ដោយន័យមានជាដើមថា នេះធម៌ជាទីបន្ទយនូវការស្រេវឆ ជាទីកម្ចាត់សេចក្តីក្តៅក្រហាយជាទីដកសេចក្តីអាល័យ និងដោយន័យមានជាដើមថា ធម៌នេះជាទីអស់រាគៈ ទោសៈ មោហៈ និងថា នេះជាអសង្ខតធម៌ និងថាអមតធម៌ សន្តិធម៌ដូច្នេះ ឈ្មោះថា ញុំាងភិក្ខុឱ្យរីករាយឱ្យស្រាលចិត្ត ។ បទថា តេ ច ភិក្ខូ អដ្ឋិកត្វា សេចក្តីថា ភិក្ខុទាំងឡាយ កំណត់យ៉ាងនេះថា វត្ថុអ្វី ។ មានន័យប្រយោជន៍នេះពួកយើងគួរសម្រេចហើយ ជាអ្នកមានសេចក្តីត្រេកអរដោយទេសនានោះ ។ បទថា មនសិកត្វា សេចក្តីថា ដាក់ទុកក្នុងចិត្ត មិនបញ្ជូនចិត្តទៅក្នុងទីដទៃគឺធ្វើទេសនានោះ ឱ្យនៅក្នុងចិត្តរបស់ខ្លួនប៉ុណ្ណោះ ។ បទថា សព្វំ ចេតសោ សមន្នាហរិត្វា សេចក្តីថា នឹកដល់ទេសនាដោយចិត្តដែលជាតួនាំទាំងពួង តាំងពីដើមដរាបដល់ទីបំផុតគឺ ធ្វើសេចក្តីរពឹងឱ្យនៅក្នុងទេសនានោះឯង ។

ម្យ៉ាងទៀត ។ បទថា សព្វំ ចេតសោ សមន្នាហរិត្វា សេចក្តីថា នាំមករឿយ ៗ ដោយប្រពៃនូវទេសនា បើចិត្តទាំង

អស់ ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះថា កាលអ្នកសម្តែងធ្វើទេសនាដោយចិត្តណា មិនឱ្យទេសនាដែលប្រព្រឹត្តទៅអំពីចិត្តទាំងពួង ចេញទៅខាងក្រៅហើយនាំមកដោយរឿយ ៗ ដោយប្រពៃ គឺមិនខុសប្លែក ហើយនាំចិត្តសន្តានរបស់ខ្លួនមកទ្រង់ទុកដោយល្អ នូវទេសនាតាមដែលសម្តែងហើយ ៗ ។ បទថា ឱហិតសោតា បានដល់ ផ្ទៀងសោតចុះស្តាប់ គឺតាំងសោតទុកដោយល្អ ។

ម្យ៉ាងទៀត បទថា ឱហិតសោតា បានដល់ មានសោតបសាទដែលអ្វី ៗ មិនរុកកួន ។ ពិតមែនបុគ្គលសូម្បីកាលបានសោតបសាទ ដែលមិនមានអ្វីរុកកួននោះឯង ទើបមិនរវើរវាយទៅក្នុងការស្តាប់ ដូចសតិសំវរៈ គួរនឹងពោលបានថា ក្នុងចក្ខុន្ទ្រិយជាដើមខ្លះ ក្នុងសោតិន្ទ្រិយខ្លះ ។ ក៏ក្នុងទីនេះ ដោយបទទាំង ៤ មានបទថា អដ្ឋិកត្វា ជាដើមទ្រង់សម្តែងដល់ការដែលភិក្ខុទាំងនោះ ស្តាប់ដោយគោរព ដោយសម្តែងការអើពើក្នុងការស្តាប់ដោយមិនជាជំទៃទៅចាកពីនោះ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួង នូវការៈដែលភិក្ខុទាំងនោះ មានការធ្វើអើពើក្នុងការស្តាប់ធម្មកថាដែលជាប់ដោយព្រះនិព្វាននោះ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់ឧទាននេះ ដោយប្រកាសការៈដែលព្រះនិព្វានមាននៅដោយបរមត្ថ ដោយមុខគឺ ព្រះធម៌ទេសនាដែលខុសផ្សេងគ្នាចាកពីធម៌នោះ ។

បណ្តាបទទាំងនោះបទថា **អត្ថិ** ប្រែថាមាននៅ អធិប្បាយថា កើតដោយបរមត្ថ ។ បទថា **ភិក្ខវេ** ជាពាក្យហៅភិក្ខុទាំងនោះ ។ សួរថា ក៏ការបន្ទឺឧទានញ៉ាំងបីតិនិងសោមនស្សឱ្យតាំងឡើងក្តី ដែលញ៉ាំងធម៌សង្វេគឱ្យតាំងឡើងក្តី មិនប្រាថ្នាដល់អ្នកទទួលធម៌ ឈ្មោះថា ឧទាន និងឧទាននោះមកក្នុងសូត្រមានប្រមាណប៉ុណ្ណេះ ដូច្នោះដែរមិនមែនឬ តែព្រោះហេតុអ្វី ក្នុងទីនេះ ព្រះមានព្រះភាគកាលទ្រង់បន្ទឺឧទាន ទើបត្រាស់ហៅភិក្ខុទាំងនោះ ? ឆ្លើយថា ព្រោះព្រះមានព្រះភាគទ្រង់សម្តែងធម៌ដល់ភិក្ខុទាំងនោះដែលជាប់ដោយព្រះនិព្វាន ដើម្បីឱ្យភិក្ខុទាំងនោះយល់ក៏ទ្រង់កើត

បីតិសោមនស្សឡើង ដោយវិលរលឹកដល់គុណរបស់ព្រះនិព្វាន ទើបទ្រង់បន្ទឺឧទាន ។ ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីបរិវិតក្ក នៃចិត្តរបស់ភិក្ខុទាំងនោះថា សភាវធម៌ទាំងអស់ក្នុងព្រះសាសនានេះ រៀរព្រះនិព្វាន ដែលប្រព្រឹត្តទៅជាប់នឹងបច្ច័យប៉ុណ្ណោះកើតឡើងបាន បើប្រាសចាកបច្ច័យ មិនមានកើតឡើងទេ តែនិព្វានធម៌នេះកើតក្នុងបច្ច័យណា និងព្រះអង្គមានប្រាថ្នា នឹងឱ្យព្រះភិក្ខុទាំងនោះយល់ ទើបត្រាស់ពាក្យមានជាដើមថា ភិក្ខវេ តថា-យតនំ ដូច្នេះ ។ គប្បីជ្រាបថា មិនមែនធ្វើឱ្យភិក្ខុទាំងនោះ ជាអ្នកទទួលដោយចំណែកតែមួយប៉ុណ្ណោះទេ ។ បទថា តថាយតនំ បានដល់ហេតុនោះ ។ ន អក្សរធ្វើការភ្ជាប់បទពិតមែន ព្រះនិព្វានលោកហៅថា អាយតនៈ ព្រោះអត្ថថា ជាហេតុដោយអារម្ម-ណប្បច្ច័យដល់មគ្គញ្ញាណ និងផលញ្ញាណជាដើម ដូចរូបារម្មណ៍ជាដើម ជាអារម្មណប្បច្ច័យដល់ចក្ខុវិញ្ញាណជាដើម ។ ក៏ពាក្យត្រឹមតែប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់ប្រកាសដល់សង្ឃត-ធាតុថា មាននៅដោយបរមត្ថដល់ភិក្ខុទាំងនោះ ។

ក្នុងសេចក្តីនោះ មានន័យសេចក្តីដូចតទៅនេះ ៖

ព្រោះសង្ខតធម៌មាននៅ សូម្បីអសង្ខតធាតុក៏មាន ព្រោះមានសេចក្តីជាគូចំពោះសភាវធម៌ ដូចយ៉ាងថាកាលទុក្ខ មាននៅ សូម្បីសុខដែលជាគូនិងទុក្ខនោះ ក៏មាននៅដូចគ្នាយ៉ាងណា កាលសេចក្តីក្តៅមាននៅ សូម្បីសេចក្តីត្រជាក់ក៏មាននៅ កាលបាបធម៌មាននៅ សូម្បីកល្យាណធម៌ក៏មាននៅដូចគ្នា ។ សមពិតដូចពាក្យដែលលោកពោលទុកថា ៖

កាលទុក្ខមាន ឈ្មោះថា សុខ ក៏មានយ៉ាងណា កាលភពមាន វិភវសភាវៈ ដែលប្រាសចាកភព ក៏ចាំត្រូវប្រាថ្នាដូច្នោះ កាលសេចក្តីក្តៅមាន សេចក្តីត្រជាក់ក៏មាន សូម្បីយ៉ាងណា កាលភ្លើង ៣ កងមាន ព្រះនិព្វានក៏ចាំត្រូវប្រាថ្នា ដូច្នោះ កាលបាបធម៌មាន កល្យាណធម៌ក៏មានយ៉ាងណា កាលការកើតមាន សេចក្តីមិនកើត ក៏ចាំត្រូវប្រាថ្នាដូច្នោះ ។

ម្យ៉ាងទៀត ការពន្យល់សេចក្តីដល់ព្រះនិព្វានថាមាននៅដោយបរមត្ថ នឹងមានច្បាស់ខាងមុខ ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងដល់អសង្ខតធាតុថា មាននៅដោយបរមត្ថ ដោយព្រមមូលដោយប្រការដូច្នេះហើយ ឥឡូវ

នេះ ដើម្បីនឹងទ្រង់សម្តែងសភាវៈដែលព្រះនិព្វាននោះ មាននៅ ដោយមុខគឺ សេចក្តីផូរផង់នៃធម៌ដែលខុសត្រង់ផុយចាកពីអសង្ខតធាតុនោះ ទើបត្រាស់ថា **យត្ថ នេវ បឋវី ន អាបោ** ជួច្នេះជាដើម ។

ក្នុងសេចក្តីនោះ ព្រោះហេតុតែព្រះនិព្វាន មានសភាវៈខុសផុយគ្នាអំពីសង្ខារទាំងពួង មិនមានបណ្តាសង្ខតធម៌ណា ៗ យ៉ាងណា សូម្បីក្នុងព្រះនិព្វាននោះ ក៏មិនមានសង្ខតធម៌ទាំងអស់ ដូច្នោះ ព្រោះសង្ខតធម៌និងអសង្ខតធម៌រួមគ្នាមិនបាន ។ ក្នុងសេចក្តីនោះ មានការធ្វើអធិប្បាយអត្ថដូចតទៅនេះ ៖

បឋវីធាតុ មានសេចក្តីរឹងជាលក្ខណៈ ***អាបោធាតុ*** មានការហូរទៅជាលក្ខណៈ ***តេជោធាតុ*** មានសេចក្តីអប់កំដៅជាលក្ខណៈ ***វាយោធាតុ*** មានការឃ្លាតញ៉ែជាលក្ខណៈមិនមានក្នុងព្រះនិព្វានណា គឺអសង្ខតធាតុណាដូចនោះ ក្នុងធាតុទាំងនោះ កាលពោលអំពីសេចក្តីមិនមាននៃមហាភូតរូប ៤ ក៏ជាការពោលដល់សេចក្តីមិនមាននៃឧបាទាយរូបសូម្បីទាំងអស់ ព្រោះអាស្រ័យមហាភូតរូបនោះយ៉ាងណា កាមភពនិងរូបភពក៏យ៉ាងនោះ ជាការ

ពោលថា មិនមានក្នុងព្រះនិព្វាននោះដោយអស់រលីង ព្រោះមានសេចក្តីប្រព្រឹត្តទៅមិនជាប់នឹងព្រះនិព្វាននោះ ព្រោះបញ្ចវោការភព ឬជាវោការភពវៀរចាកការអាស្រ័យមហាភូតរូបហើយ ក៏មិនអាចមានដោយខ្លួនឯង ។

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងធម៌ដែលរាប់ជាប់ក្នុងអរូបភព មិនមានក្នុងព្រះនិព្វាននោះ សូម្បីក្នុងកាលព្រះនិព្វានមានសភាវៈជាអរូប (ជានាម) ទើបត្រាស់ពាក្យមានជាដើមថា ន អាកាសានញ្ចាយតនំ ច ។បេ ។ននេវសញ្ញានាសញ្ញាយតនំ ជួច្នេះ ។

បណ្តាបទទាំងនោះ បទថា ន អាកាសនញ្ចាយតនំ សេចក្តីថា ចិត្តុប្បាទ ពោលគឺ អាកាសានញ្ចាយតនៈទាំង ៣ យ៉ាង ផ្សេងដោយកុសលចិត្ត វិបាកចិត្ត និងកិរិយាចិត្ត ព្រមទាំងអារម្មណ៍ រមែងមិនមាន ។ សូម្បីក្នុងបទដែលនៅសល់ ក៏នយនេះដូចគ្នា ។

ក៏កាមលោកមិនមានក្នុងព្រះនិព្វាន ដោយអារម្មណ៍ណា សូម្បីឥធលោក និងបរលោកក៏មិនមានក្នុងព្រះនិព្វាននោះដោយអារម្មណ៍នោះ ព្រោះហេតុនោះ លោកទើបពោលថា លោកនេះមិន

មាន លោកខាងមុខមិនមាន ដូច្នេះជាដើម ។ ពាក្យនោះ មានអធិប្បាយដូចតទៅនេះ ៖

ខន្ធលោកនេះណា ដែលបានហៅហាវថា សេចក្តីជាយ៉ាងនេះ បច្ចុប្បន្នធម៌ និងថាលោកនេះ និងខន្ធលោកដែលបាន ហៅ-ហាវថា លោកដទៃចាកពីលោកនោះ បរលោកនិងអភិសម្បរាយភពណា ទាំងពីរនោះ មិនមានក្នុងទីណា ។ បទថា ន ឧភោ ចន្ទិមសុរិយា សេចក្តីថា ព្រោះហេតុដែលកាលរូបមានឈ្មោះថា សេចក្តីងងឹតក៏គប្បីមាន និងដើម្បីកម្ចាត់សេចក្តីងងឹត ព្រះច័ន្ទ និងព្រះអាទិត្យក៏វិលវល់ទៅ តែមួយជួងដោយប្រការទាំងពួង មិនមាន ក្នុងទីណា សេចក្តីងងឹតក្នុងទីនោះនឹងមានក្នុងទីណា ។ ម្យ៉ាងទៀត ការកម្ចាត់សេចក្តីងងឹតក៏គឺ ព្រះច័ន្ទនិងព្រះអាទិត្យ ដូច្នោះ ព្រះច័ន្ទនិងព្រះអាទិត្យទាំងពីរ រមែងមិនមានក្នុងព្រះនិព្វានណា ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ព្រះនិព្វានមានសេចក្តីស្វាងស្វៃជាសភាវៈនុ៎ះឯង ។

ក៏ពាក្យត្រឹមតែប៉ុណ្ណោះ ព្រះធម្មរាជា កាលនឹងទ្រង់ប្រកាសអមតនិព្វាន ដែលមិនធ្លាប់មានក្នុងសង្សារ ដែលរកខាងដើម ដឹង

មិនបាន សូម្បីទីបំផុតដោយសេចក្តីយល់សប្តិដែលជ្រៅដោយបរមត្ថ ឃើញបានលំបាកយ៉ាងក្រៃលែង ល្អិតល្អន់ សុខុមនឹកដោយខ្លួនឯងមិនបាន ស្ងប់ទីបំផុតជាទីបញ្ចេញផលចំពោះខ្លួនប្រណីតក្រៃលែងណាស់ ដល់ភិក្ខុទាំងឡាយអ្នកមិនទាន់បានសម្រេចទើបឱ្យភិក្ខុទាំងនោះ កម្ចាត់សេចក្តីល្ងង់ជាដើមចេញ ព្រោះព្រះនិព្វាននោះមាននៅខាងមុនតែម្តង ដូចបាលីថា **អត្ថិ ភិក្ខវេ តទាយតនំ** ដូច្នេះជាដើម ទើបទ្រង់ប្រកាសព្រះនិព្វាននោះដោយមុខ គឺសេចក្តីមិនល្ងង់ក្នុងធម៌ដទៃចាកពីព្រះនិព្វាននោះថា **យត្ថ ជ្រោះ បឋវី ។បេ។ ន ឧភោ ចន្ទិមសុរិយា** ដូច្នេះជាដើម ។ ដោយពាក្យនោះ ជាការសម្តែងថា អសង្ខតធាតុដែលមានសេចក្តីផុយគ្នាពីសង្ខតធម៌ទាំងពួង មានបឋវីជាដើមថា ព្រះនិព្វាន ។ ដោយហេតុនោះឯង ព្រះអង្គទើបត្រាស់ថា **តត្រ-ចាហំ ភិក្ខវេ នេវ អនាគតឹ វទាមិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **តត្រ** ប្រែថា ក្នុងនិព្វាននោះ ។ **អបិ** សព្ទប្រើក្នុងអត្ថសមុច្ចយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលការមករបស់អ្វី ៗអំពីទីណា ៗ ដែលប្រព្រឹត្តទៅតាម

សង្ខារ ព្រោះហេតុត្រឹមតែថាធម៌កើតក្នុងព្រះនិព្វាននោះ តាមបច្ចុយមួយទៀត តថាគតមិនពោលអនាគតំ គឺការមកអំពីទីណា ៗ ក្នុងអាយតន:គឺព្រះនិព្វាននោះយ៉ាងនេះព្រោះនិព្វានមិនមានហាន: ដែលនឹងគប្បីមក ។ បទថា ន គតិ សេចក្តីថាតថាគតមិនពោលការទៅណាទីណា ៗ ព្រោះហាន:ដែលព្រះនិព្វាននឹងគប្បីដល់មិនមាន ។ ព្រោះការមក និងការទៅរបស់សត្វទាំងឡាយ រៀរការធ្វើឱ្យជាអារម្មណ៍ដោយញាណ មិនមានក្នុងព្រះនិព្វាននោះ ។ មួយទៀត តថាគតមិនពោលដល់ឋិតិ ចុតិ និងឧប្បត្តិ ។ បាលីថា ឥទមបិ ដូច្នេះក៏មាន ។ សេចក្តីរបស់ព្រះបាលីនោះមានដូច្នេះ អាយតន: សូម្បីនោះ ឈ្មោះថា មិនមានការមក ព្រោះជាហាន:ដែលមិនគួរមកដូចអំពីលង្វែកស្រុកមកកាន់លង្វែកស្រុក ។ ឈ្មោះថា មិនមានការទៅ ព្រោះមិនជាហាន:ដែលនិងគួរទៅ ឈ្មោះថា មិនមានឋិតិ ព្រោះមិនមានហាន:ដែលនិងតាំងនៅ ដូចផែនដីនិងភ្នំជាដើម ។ មួយទៀត ឈ្មោះថា មិនមានការកើត ព្រោះមិនមានបច្ចុយឈ្មោះថាមិនមានចុតិព្រោះមិនមានការស្លាប់ជាសភាវ:នោះ ។ តថាគតមិនពោលឋិតិ ចុតិ និងឧប្បត្តិ ព្រោះមិនមានការកើតនិងការរលត់និងព្រោះមិនមានការតាំងនៅទីកំណត់ដោយការកើត និងការរលត់

ទាំង ២ នោះ ។ មួយទៀត ព្រះនិព្វាននោះសុទ្ធតែឈ្មោះថា មិនតាំងនៅក្នុងទីណា ។ ព្រោះមានសភាវៈជាអរូប និងព្រោះមិនមានបច្ច័យ ព្រោះហេតុនោះទើបឈ្មោះថា មិនមានទីតាំង ឈ្មោះថាមិនប្រព្រឹត្តទៅ ព្រោះមិនមានសេចក្តីប្រព្រឹត្តទៅព្រម និងព្រោះជាបដិបក្ខចំពោះការប្រព្រឹត្តទៅក្នុងព្រះនិព្វាននោះឈ្មោះថា មិនមានអារម្មណ៍ ព្រោះមិនមានអារម្មណ៍អ្វី ។ ជាទីគាង់ស្ថិត និងព្រោះមិនប្រាថ្នាដល់អារម្មណ៍ដែលឧបត្ថម្ភ ដូចសម្បយុត្តធម៌ មានវេទនាជាដើមសូម្បីដែលមានសភាវៈជាអរូប (ជានាម)ដូច្នោះ ព្រះនិព្វាននោះ លោកទើបពោលថាអាយតនៈ ។ ក៏ **ឯវ** សព្ទនេះ គប្បីប្រកបដោយបទទាំងពីរគឺ **អប្បតិដ្ឋមេវ អប្បវត្តមេវ** ។ បទថា **ឯសេវន្តោ ទុក្ខស្ស** សេចក្តីថា ព្រះនិព្វានមានលក្ខណៈតាមដែលពោលហើយដែលព្រះមានព្រះភាគត្រាស់សរសើរ ដោយពាក្យមានជាដើមថា **អប្ប តិដ្ឋំ** ដូច្នេះនុ៎ះឯង ឈ្មោះថា ជាទីបំផុត គឺជាទីបំផុតនៃវដ្តទុក្ខទាំងអស់ ព្រោះកាលមានការសម្រេចព្រះនិព្វានទុក្ខ ទាំងអស់ក៏មិនមានព្រោះហេតុដូច្នោះ ទើបទ្រង់សម្តែងថា ព្រះនិព្វាននោះ មានសភាវៈជាដូច្នេះថា ជាទីបំផុតនៃទុក្ខនុ៎ះឯង ។

ពាហិយសូត្រ

នៅក្នុងបិដកលេខ ៥២ ទំព័រ ១២៦ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពី **[ការត្រាស់ដឹងដល់ទីបំផុតទុក្ខ]** មានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ។ សម័យនោះឯង ពាហិយទារុចីរិយបុរស (អ្នកស្លៀកដណ្តប់សំពត់សម្បកឈើ ឈ្មោះពាហិយ) អាស្រ័យនៅទៀបឆ្នេរសមុទ្រ ឈ្មោះសុប្បារកៈ ជាអ្នកដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បាននូវចីវរ បិណ្ឌបាត សេនាសនៈ នឹងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ កាលពាហិយទារុចីរិយបុរស ពួនសម្ងំក្នុងទីស្ងាត់ ស្រាប់តែមានសេចក្តីត្រិះរិះឡើងយ៉ាងនេះថា ពួកជនណាមួយក្នុងលោក ជាព្រះអរហន្ត ឬសម្រេចអរហន្តមគ្គ បណ្តាអរហន្តទាំងនេះ ខ្ញុំនេះអញជាអរហន្តមួយដែរ ។ លំដាប់នោះ ទេវតាដែលជាសាលោហិតអំពីដើម របស់ពាហិយទារុចីរិយបុរសជាអ្នកអនុគ្រោះ ប្រាថ្នាប្រយោជន៍ បានដឹងច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត ដោយចិត្តរបស់ពាហិយទារុចីរិយបុរស បានចូលទៅរកពាហិយចីរិយបុរស លុះ

ចូលទៅដល់ហើយ ក៏និយាយនឹងពាហិយទារុចីរិយបុរសយ៉ាងនេះថា នែ**ពាហិយៈអ្នកមិនមែនជាព្រះអរហន្តទេ** ទាំងមិនទាន់សម្រេចអរហន្តទេ ខ្លួនអ្នកមិនមានបដិបទាដែលនាំឱ្យបានជាព្រះអរហន្ត ឬសម្រេចអរហន្តមគ្គទេ ។ ពាហិយទារុចីរិយៈ សួរថា បើដូច្នោះ ក្នុងកាលឥឡូវនេះ ក្នុងលោកព្រមទាំងទេវលោក តើជនណា ជាអរហន្ត ឬបានសម្រេចអរហន្តមគ្គ មានដែរឬ ។ ទេវតាឆ្លើយថា ម្នាលពាហិយៈ មានខាងជនបទឯជើង មានក្រុងមួយឈ្មោះសាវត្ថី ឥឡូវនេះព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងក្រុងសាវត្ថីនោះ ។ ម្នាលពាហិយៈ ព្រះមានព្រះភាគអង្គនោះឯង ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ដើម្បីអរហន្តផង ។ លំដាប់នោះ ពាហិយៈទារុចីរិយបុរសដែលទេវតានោះធ្វើឱ្យតក់ស្លុត ក៏ស្រាប់តែចេញអំពីឆ្នេរសមុទ្រឈ្មោះ សុប្បារកៈក្នុងខណៈនោះភ្លាម ដោយការនៅតែក្នុងផ្លូវទាំងពួងអស់ ១ យប់ ក៏បានទៅដល់ ព្រះមានព្រះភាគ ដែលកំពុងគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ ។ ម្នាលពាហិយៈ ព្រះមានព្រះភាគអង្គនោះឯង ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ផង ដើម្បីអរហន្តផង ។ លំដាប់នោះ ពាហិយទារុចីរិ-

យបុរស ដែលទេវតានោះធ្វើឱ្យតក់ស្លុត ក៏ស្រាប់តែគេចចេញអំពីឆ្នេរសមុទ្រឈ្មោះ សុប្បារកៈក្នុងខណៈនោះភ្លាម ដោយការនៅតែក្នុងផ្លូវទាំងពួងអស់ ១ យប់ ក៏បានទៅដល់ព្រះមានព្រះភាគ ដែលកំពុងគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

សម័យនោះ គាប់ជួនភិក្ខុច្រើនរូប កំពុងដើរចង្រ្កមក្នុងទីវាល ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏ឆៀងចូលទៅរកពួកភិក្ខុ លុះចូលទៅដល់ហើយ ក៏បានសួរភិក្ខុទាំងនោះដូច្នេះថា បពិត្រលោកដ៏ចម្រើនទាំងឡាយ ឥឡូវនេះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធគង់នៅទីណា យើងមានបំណងនឹងចូលទៅដើម្បីមានបំណងនឹងចូលទៅដើម្បីជួបព្រះមានព្រះភាគជាអរហន្តអង្គនោះ ។ ពួកភិក្ខុតបថា ម្នាលពាហិយៈ ព្រះមានព្រះភាគចូលកាន់ចន្លោះភូមិ ដើម្បីបិណ្ឌបាតទៅហើយ ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏មានដំណើរម្តើម្នាចេញពីវត្តជេតពន ចូលទៅនគរសាវត្ថី ជាទីនាំមកនូវសេចក្តីប្រាថ្នា គួរជ្រះថ្លា មានឥន្ទ្រិយស្ងប់ មានព្រះទ័យស្ងប់ ទ្រង់បានដល់នូវការហាត់ពត់ នឹងការស្ងប់រម្ងាប់ដ៏ឧត្តម ទ្រង់បានទូន្មាន គ្រប់គ្រង សង្រួមឥន្ទ្រិយ ជាពុទ្ធនាគ

គឺជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ មានសិរ្សៈឱនចុះទៀបព្រះបាទនៃព្រះមានព្រះភាគ ហើយអារាធនាព្រះមានព្រះភាគនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់រាត្រីវែង ដល់ខ្ញុំព្រះអង្គឱ្យទាន ។

កាលពាហិយទារុចីរិយអារាធនាយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពាហិយទារុចីរិយបុរសដូច្នេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ដ្បិតតថាគតចូលទៅកាន់ចន្លោះភូមិបិណ្ឌបាត ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគជាគម្រប់ពីរដងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ជំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយ របស់ព្រះមានព្រះភាគ ឬជីវិតន្តរាយរបស់ខ្ញុំព្រះអង្គ ជីឯបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ដើម្បីសេចក្តីសុខ អស់វារៈពីរដងយ៉ាងនេះថា ម្នាលពាហិយៈឈប់សិន កាលនេះជាកាល

មិនគួរ ដូច្នេះតថាគតចូលទៅកាន់ចន្លោះភូមិ បិណ្ឌបាតសិន ។ ពាហិយទារុចីរិយបុរសទូលព្រះមានព្រះភាគអស់វារៈ៣ ដងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយរបស់ព្រះមានព្រះភាគ ឬជីវិតន្តរាយរបស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់រាត្រីវែង ដល់ខ្ញុំព្រះអង្គឱ្យទាន ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលពាហិយៈ ព្រោះហេតុនោះអ្នកត្រូវសិក្សាយ៉ាងនេះថា រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែជាសទ្ធារម្មណ៍ដែលឃើញហើយ សទ្ធារម្មណ៍ដែលអ្នកឮហើយ គ្រាន់តែជាសទ្ធារម្មណ៍ដែលឮហើយ គន្ធៈ រសៈ ផោដ្ឋព្វារម្មណ៍ដែលប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលដឹងហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលប៉ះពាល់ហើយធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលដឹងហើយ ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះឯង ។ ម្នាលពាហិយៈ រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែជារូបា-

វម្មណ៍ដែលឃើញហើយ សទ្ធាវម្មណ៍ដែលអ្នកឮហើយ គ្រាន់តែជាសទ្ធាវម្មណ៍ដែលឮហើយ គន្ធៈ រសៈ ផោដ្ឋព្វាវម្មណ៍ដែលអ្នកប៉ះពាល់ហើយ គ្រាន់តែជាអាវម្មណ៍ដែលប៉ះពាល់ហើយ ធម្មាវម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មាវម្មណ៍ដែលដឹងហើយ ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកនឹងលែងមាន ម្នាលពាហិយៈ អ្នកនឹងលែងមាន ព្រោះហេតុនោះ អ្នកនឹងមិនមានក្នុងភពនេះ នឹងភពមុខ នឹងមិនមានក្នុងចន្លោះនៃលោកទាំងពីរ នេះឯងជាទីបំផុតនៃទុក្ខ ។ គ្រានោះ ចិត្តនៃពាហិយទារុចីរិយបុរស ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានឧបាទានក្នុងខណៈនោះឯង ដោយធម្មទេសនាសង្ខេបរបស់ព្រះមានព្រះភាគនេះ ។ លុះព្រះមានព្រះភាគ ទ្រង់ទូន្មាន ពាហិយទារុចីរិយបុរសដោយឱវាទសង្ខេបនេះហើយ ស្តេចចៀសចេញទៅ ។

កាលដែលព្រះមានព្រះភាគ ស្តេចចេញផុតទៅមិនយូរប៉ុន្មាន មេគោមានកូនខ្ចី បុះផ្តួសពាហិយទារុចីរិយបុរស ឱ្យដាច់ចាកជីវិតទៅ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី រួចត្រឡប់អំពីបិណ្ឌបាតវេលាខាងក្រោយភត្ត ចេញអំពី

នគរជាមួយភិក្ខុច្រើនរូប បានទតឃើញពាហិយទារុចីរិយបុរសធ្វើមរណកាព លុះទតឃើញហើយ ទើបត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកសរីរៈពាហិយទារុចីរិយបុរសលើកដាក់លើគ្រែនាំទៅជុតផង ធ្វើស្តូបដល់សរីរៈនោះផង ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) សព្រហ្មចារីរបស់អ្នកទាំងឡាយ ធ្វើមរណកាពហើយ ។ ពួកភិក្ខុទាំងនោះទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយលើកសរីរៈពាហិយ-ទារុចីរិយបុរស ដាក់លើគ្រែតូចនាំទៅរំលាយ ទាំងធ្វើស្តូបដល់សរីរៈនោះ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សរីរៈពាហិយទារុចីរិយបុរស រំលាយហើយ ទាំងស្តូបសម្រាប់បញ្ចុះសរីរៈនោះក៏ធ្វើហើយ គតិរបស់គាត់ តើដូចម្តេច ដំណើរក្នុងលោកខាងមុខ តើដូចម្តេច ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាហិយ-ទារុចីរិយបុរស ជាបណ្ឌិតបានប្រតិបត្តិគួរដល់ព្រះនិព្វានហើយ

មិនបៀតបៀនតថាគត ព្រោះហេតុសម្តែងធម៌ទេ ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយបុរស បរិនិព្វានហើយ ។

លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបបន្ទឺនូវឧទាននេះក្នុងវេលានោះថា ៖

យត្ត អាបោ ច បថវី តេជោ វាយោ ន គាធតិ
ន តត្ថ សក្កា ជោតន្តិ អាទិច្ចោ នប្បកាសតិ
ន តត្ថ ចន្ទិមា ភាតិ តមោ តត្ថ ន វិជ្ជតិ ។
យទា ច អត្តនាវេទិ មុនិ មោនេន ព្រាហ្មណោ
អថ រូបា អរូបា ច សុខទុក្ខា បមុច្ចតីតិ ។

ទឹក ដី ភ្លើង ខ្យល់ រមែងមិនតាំងនៅក្នុងនិព្វានជាតុណា ពួកផ្កាយមានឈ្មោះថា សុក្ក (មានពន្លឺ) រមែងមិនតាំងនៅក្នុងនិព្វានជាតុនោះ ទាំងងងឹតក៏មិនមាន ក្នុងនិព្វានជាតុនោះទេ ។ ព្រាហ្មណ៍មានឈ្មោះថា មុនី ព្រោះមានប្បដិបត្តិដ៏ឆ្ងាស់នូវព្រះនិព្វាន ដោយខ្លួនឯង ក្នុងកាលណា រមែងរួចចាករូបផង អរូបផង សុខទុក្ខផង ក្នុងកាលនោះ ។

អដ្ឋកថា

បទថា ពាហិរយោ ជាឈ្មោះរបស់លោក ។ បទថា ទារុ-ចីរិយោ បានដល់ សំពត់ឈ្នាងដែលធ្វើដោយឈើ ។ បទថា សុប្បារកេ បានដល់នៅត្រង់កំពង់ឈ្មោះយ៉ាងនោះ ។ ក៏ពាហិយៈនេះ គឺអ្នកណា ។ និងយ៉ាងណាទើបជាអ្នកទ្រង់សំពត់ឈ្នាងធ្វើដោយឈើ, យ៉ាងណាទើបនៅអាស្រ័យនៅកំពង់សុប្បារកៈ, ក្នុងសេចក្តីនោះមានអនុបុព្វីកថាដូចតទៅនេះ ៖

បានឮថាក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមថាបទុមុត្តរៈក្នុងទីបំផុតសែនកប្បពីភទ្រកប្បនេះកុលបុត្រម្នាក់កំពុងស្តាប់ព្រះធម៌ទេសនារបស់ព្រះទសពលដែលហង្សវតីនគរ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ នៃភិក្ខុអ្នកជាវិបស្សាភិញ្ញា គិតថា ដូចម្តេចហ្ន៎ ក្នុងអនាគត យើងនឹងបួសក្នុងព្រះសាសនារបស់ព្រះសម្មាសម្ពុទ្ធបែបនេះហើយ គប្បីជាអ្នកដែលព្រះសាស្តាស្ថាបនាទុកក្នុងតំណែងឯតទគ្គៈដូច្នេះ ដូចភិក្ខុរូបនេះបានប្រាថ្នាតំណែងនោះ ទើបបំពេញបុញ្ញាធិការដែលសមគួរដល់តំណែងនោះ បំពេញបុណ្យនៅរហូតអស់មួយជីវិត មានសួគ៌ជា

ទីទៅក្នុងខាងមុខ អន្ទោលទៅក្នុងទេវតា និងមនុស្សបួសក្នុងព្រះសាសនារបស់ព្រះកស្សបទសពល មានសីលបរិបូរណ៌ចំពេញសមណធម៌ ដល់អស់ជីវិតហើយកើតក្នុងទេវលោក ។ គេនៅក្នុងទេវលោកអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះចាប់បដិសន្ធិក្នុងត្រកូលនៅក្នុងពាហិយរដ្ឋ ជនទាំងឡាយចាំគេបានថា ពាហិយៈ ព្រោះកើតក្នុងពាហិយរដ្ឋ ។ គេចម្រើនវ័យហើយនៅគ្រប់គ្រងផ្ទះ យកទូកបន្ទុកទំនិញច្រើនណាស់ត្រាច់ទៅកាន់សមុទ្រ ត្រឡប់ទៅត្រឡប់មកសម្រេចសេចក្តីប្រាថ្នា ៧ ដង ទើបត្រឡប់មកនគរវិញ គ្រាទី ៨ គិតនិងទៅសុវណ្ណភូមិ ទើបដឹកទំនិញចេញទូកទៅ ។ ទូកចូលមហាសមុទ្រមិនទាន់ដល់ទីកន្លែងដែលប្រាថ្នាផង ក៏ក្រឡាប់ពាក់កណ្តាលសមុទ្រ ។ មនុស្សទាំងឡាយដែលនៅលើទូក ក៏បានក្លាយជាចំណីរបស់ត្រីនិងអណ្តើក ចំណែកលោកពាហិយៈបានក្តារផែន មួយសន្លឹកនៅហើយ ត្រូវរលកបក់ទៅម្តងបន្តិចម្តង ៗក្នុងថ្ងៃទី ៧ ក៏បានដល់ត្រើយជិតកំពង់សុប្បារកៈ ។ គេដេកនៅត្រង់ឆ្នេរសមុទ្រ ដោយរូបកាយអាក្រាត ព្រោះសំពត់របួតធ្លាក់ទៅក្នុងសមុទ្រ កាលបន្ទោបង់សេចក្តីនឿយហត់ហើយដកដង្ហើមបាន ក្រោកឡើងចូលទៅ

កាន់ចន្លោះគុម្ពឈើដោយសេចក្តីខ្វាស ដោយមិនឃើញរបស់អ្វី ៗសម្រាប់បិទបាំងនូវរាងកាយ ទើបយកសំបកឈើព័ទ្ធ (កាយ)ធ្វើជាគ្រឿងស្លៀកដណ្តប់បិទបាំងទុក ។ តែអាចារ្យពួកខ្លះពោលថា ចោះផ្ចាំងក្តារធ្វើជាសំបកឈើធ្វើជាគ្រឿងស្លៀកដណ្តប់បិទបាំងកាយ ។ គេប្រាកដឈ្មោះថា ទារុចីរៈ ព្រោះស្លៀកសំពត់ឃ្នាងធ្វើដោយឈើ និងថា ពាហិរៈ តាមឈ្មោះពីដើម សូម្បីដោយប្រការទាំងពួងដូច្នេះ ។ គេកាន់ក្បឿងមួយដើរសូមដុំបាយនៅត្រង់កំពង់សុប្បារកៈ ដោយទំនងដូចពោលហើយ ពួកមនុស្សទាំងឡាយឃើញហើយ ទើបគិតថា បើឈ្មោះថា ព្រះអរហន្តនៅមានក្នុងលោកសោត លោកគប្បីជាយ៉ាងនេះ លោកម្ចាស់អង្គនេះ នឹងកាន់យកសំពត់ដែលគេឱ្យ ឬមិនកាន់យកព្រោះសេចក្តីប្រាថ្នាតិច ដូច្នេះ កាលនឹងសាកល្បង ទើបបង្ហោនសំពត់ពីទីផ្សេង ៗចូលទៅ ។ គេគិតថា បើយើងនឹងមិនមកដោយទំនងនេះសោត កាលជាដូច្នេះ ពួកមនុស្សទាំងនេះនឹងមិនជ្រះថ្លានឹងយើង ដូចម្តេចហ្ន៎ យើងគប្បីហាមសំពត់ទាំងនេះចេញហើយ នៅដោយទំនងបែបនេះឯង កាលបើជាដូច្នេះ លាភសក្ការៈក៏នឹងកើតឡើងដល់យើង ។ គេគិតយ៉ាងនេះហើយ

ទើបតាំងនៅក្នុងហាន:ជាអ្នក បញ្ឆោត បន្លំមិនទទួលសំពត់ ។ ពួកមនុស្សគិតថា គួរអស្ចារ្យ លោកម្ចាស់នេះប្រាថ្នាតិចពិត ទើបមានចិត្តជ្រះថ្លាយ៉ាងក្រៃលែងធ្វើសក្ការ: និង សម្មាន:ជាច្រើន ។ ចំណែកពាហិយ:ទទួលអាហារហើយ បានទៅកាន់ទេវស្ថានមួយកន្លែងក្នុងទីមិនឆ្ងាយ ។ មហាជនជាប់តាមទៅជាមួយលោកដូចគ្នា ហើយបានជុំសជុំលទេវស្ថាននោះឱ្យ ។ គេគិតថាអ្នកទាំងនេះជ្រះថ្លាក្នុងហាន: ត្រឹមតែយើងទ្រទ្រង់សំពត់សំបកឈើ ទើបនាំគ្នាធ្វើសក្ការ:និងសម្មាន:យ៉ាងនេះ យើងគួរនិងមានការប្រព្រឹត្តយ៉ាងខ្ពង់ខ្ពស់សម្រាប់អ្នកទាំងនេះ ទើបជាអ្នកមានបរិក្ខារស្រាល ៗជាអ្នកប្រាថ្នាតិច ។ ចំណែកលោក កាលត្រូវអ្នកទាំងនោះលើកតម្កើងថាជាព្រះអរហន្ត ក៏សម្គាល់ខ្លួនថា ជាព្រះអរហន្ត មួយទៀត ការធ្វើសក្ការ:និងធ្វើសេចក្តីគោរព ក៏ចម្រើនក្រៃលែង ៗឡើង និងលោកក៏បានមានបច្ច័យច្រើន ៗឡើង ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាដើមថា ក៏សម័យនោះឯង លោកពាហិយទារុចីរិយ: អាស្រ័យនៅត្រង់កំពង់សុប្បារក:ជិតត្រើយសមុទ្រ ជាអ្នកដែលមហាជនធ្វើសក្ការ:បូជា ។

បណ្តាបទទាំងនោះ បទថា **សក្ការោ** សេចក្តីថា ជាអ្នកដែលមហាជនធ្វើសក្ការៈ ដោយការបម្រុងដោយសេចក្តីគោរពគឺអើពើ ។ បទថា **គរុការោ** សេចក្តីថា អ្នកដែលមហាជនធ្វើឱ្យធ្ងន់ ដោយការធ្វើឱ្យធ្ងន់ដូចឆត្រថ្ម ដោយសេចក្តីប្រាថ្នាថា ជាអ្នកប្រកបដោយគុណវិសេស ។ បទថា **មានិការោ** សេចក្តីថា អ្នកដែលមហាជនបូជាហើយដោយការបូជា ដោយការធ្វើសក្ការៈមានផ្តាំឈើនិងរបស់ក្រអូបជាដើម ។ បទថា **អបចិការោ** បានដល់ អ្នកដែលមហាជនកោតក្រែងហើយដោយការឱ្យផ្លូវ និង ការនាំអាសនៈមកឱ្យជាដើម ដោយចិត្តជ្រះថ្លាយ៉ាងក្រៃលែង ។ បទថា **លាភី ចីវរ ។បេ។ បរិក្ខារានំ** សេចក្តីថា ជាអ្នកបានដោយការបានបច្ច័យ ៤ មានចីវរជាដើម ដ៏ប្រណីតដែលមហាជននាំចូលទៅ ។ ន័យមួយទៀត បទថា **សក្ក** តោ បានដល់ បានទទួលសក្ការៈ ។ បទថា **គរុកតោ** បានដល់ បានទទួលសេចក្តីគោរព ។ បទថា **មានិតោ** បានដល់ ដែលមហាជនរាប់អានដោយការលើកសរសើរដោយទឹកចិត្ត ។ បទថា **បូជិតោ** បាន

ដល់ ដែលមហាជនបូជាហើយដោយការបូជាយ៉ាងក្រៃលែង ដោយបច្ច័យ ៤ ។ បទថា **អបច្ចិតោ** បានដល់ បានទទួល សេចក្តីបង្អោនបន្ទាបបន្ទន់ខ្លួន ។

ពិតមែន ជនទាំងឡាយ រមែងធ្វើសក្ការៈដោយបច្ច័យ ៤ តាក់តែងយ៉ាងល្អ ធ្វើឱ្យសែនប្រណីតប្រគល់ឱ្យអ្នកណា អ្នកនោះ ឈ្មោះថា **ដែលគេធ្វើសក្ការៈ** ។ អ្នកទាំងឡាយធ្វើសេចក្តីគោរពឱ្យ ប្រាកដហើយប្រគល់ឱ្យក្នុងអ្នកណា អ្នកនោះឈ្មោះថា ដែលគេធ្វើការគោរព, ជនទាំងឡាយ រមែងមានចិត្តប្រព្រឹត្តស្រឡាញ់និងរាប់អានច្រើន អ្នកនោះឈ្មោះថា **ដែលគេបូជា,** ជនទាំងឡាយ រមែងធ្វើការគោរពសំពះយ៉ាងក្រៃលែង ដោយការអភិវាទ ការទទួលនិងអញ្ជលីកម្មជាដើមដល់អ្នកណា អ្នកនោះ ឈ្មោះថា **ដែលគេធ្វើការកោតក្រែង** ។ ក៏អ្នកទាំងនោះ បានធ្វើវត្តនោះ គ្រប់យ៉ាងដល់ពាហិយៈ ។ ដោយហេតុនោះ លោកទើបពោល ពាក្យមានជាដើមថា លោកពាហិយទារុចីរិយៈ ដែលគេធ្វើសក្ការៈ ហើយអាស្រ័យនៅត្រង់កំពង់សុប្បារកៈ ។ ក៏ក្នុងទីនេះ លោក ពាហិយទារុចីរិយៈ សូម្បីកាលមិនទទួលចីវរ

គេក៏ពោលថា ជាអ្នកបានសូម្បីចីវរដូចគ្នា ដោយការបង្អោនចូលទៅថា មកចុះព្រះករុណា ចូរទទួលសំពត់នេះ ។

បទថា រហោគតស្ស បានដល់ នៅក្នុងទីកំបាំង ។ បទថា បដិសល្លីនស្ស បានដល់ ជាអ្នកនៅឯកកោ ។ កាលត្រូវពួកមនុស្សជាច្រើនពោលថា លោកជាព្រះអរហន្ត លោកក៏កើតសេចក្តីបរិវិតក្កនៃចិត្ត គឺកើតសេចក្តីត្រិះរិះខុសនៃចិត្តដោយអាការដែលពោលឥឡូវនេះ ។ កើតសេចក្តីបរិវិតក្កយ៉ាងណា, កើតសេចក្តីបរិវិតក្កឡើងថា ពួកណាមួយដែលជាព្រះអរហន្ត ឬលោកអ្នកសម្រេចអរហត្តមគ្គក្នុងលោក យើងជាម្នាក់ដៃក្នុងចំនួនព្រះអរហន្ត ឬលោកអ្នកសម្រេចអរហត្តមគ្គនោះ សេចក្តីនោះមានអធិប្បាយដូច្នេះ ជនពួកណាឈ្មោះថាជាព្រះអរហន្ត ព្រោះកម្ចាត់សត្រូវគឺ កិលេសក្នុងសត្វលោកនេះ និងព្រោះជាអ្នកគួរដល់ការបូជានិងសក្ការៈជាដើម ឬពួកណាឈ្មោះថា សម្រេចព្រះអរហត្តមគ្គ ព្រោះសម្លាប់សត្រូវគឺ កិលេសទាំងនោះ បណ្តាអ្នកទាំងនោះយើងជាម្នាក់ដៃរ ។

បទថា ឥោភាណសាលោហិតា បានដល់ ទេវតាអ្នកបំពេញ

សមណធម៌រួមគ្នា ហាក់បីដូចជារួមខ្សែលោហិតគ្នាក្នុងភពមុន ។ តែអាចារ្យពួកខ្លះពោលថា បទថា **បុរាណសា លោហិតា** បានដល់ ទេវតាមួយអង្គ ដែលត្រូវជាមាតារួមខ្សែលោហិតក្នុងកាលមុន គឺក្នុងភពដទៃ ។ ក្នុងអដ្ឋកថាលោកបដិសេធពាក្យនោះ បានកាន់យកសេចក្តីជាដំបូងប៉ុណ្ណោះ ។

បានឮថា កាលមុន សាសនារបស់ព្រះកស្សបទសពល បានសាបសូន្យ ភិក្ខុ ៧ រូប ឃើញប្រការដែលប្លែករបស់សហ-ធម្មិកមានសាមណេរជាដើម កើតសេចក្តីតក់ស្លុតគិតថាសាសនាមិនទាន់អន្តរធានដរាបណា យើងនឹងធ្វើទីពឹងរបស់ខ្លួនដរាបនោះ ទើបសំពះចេតិយមាសហើយចូលព្រៃ ឃើញកូនភ្នំមួយទើបពោលថា អ្នកមានសេចក្តីអាល័យក្នុងជីវិតចូរត្រឡប់ទៅ អ្នកមិនមានសេចក្តីអាល័យចូរឡើងភ្នំនេះ ហើយនាំគ្នាចងជណ្តើរឡើងភ្នំនោះទាំងអស់ រួចក៏ច្រានជណ្តើរចុះ ធ្វើសមណធម៌ ។ បណ្តាភិក្ខុទាំងនោះ ព្រះសង្ឃត្តេរសម្រេចព្រះអរហត្តដោយកន្លងទៅតែមួយរាត្រីប៉ុណ្ណោះ ។ លោកនាំបិណ្ឌបាតមកពីឧត្តរកុរុទ្វីប ហើយពោលនឹងភិក្ខុទាំងនោះថា លោកអ្នកមានអាយុទាំងឡាយ មេត្តា

ឆាន់បិណ្ឌបាតពីទីនេះចុះ ។ ភិក្ខុទាំងនោះពោលថា លោកដ៏ចម្រើន លោកបានធ្វើយ៉ាងនេះដោយអានុភាពរបស់ខ្លួន បើសូម្បីពួកខ្ញុំនឹងញុំាងគុណវិសេសឱ្យកើតឡើងបានដូចលោកសោតនឹងនាំចង្ហាន់មកដោយខ្លួនឯងតែម្តង ទើបមិនប្រាថ្នានឹងឆាន់ ។ តាំងពីថ្ងៃទីពីរទៅ ព្រះថេរៈទី២ក៏សម្រេចអនាគាមិផល ។ សូម្បីលោកក៏កាន់យកបិណ្ឌបាតដូចយ៉ាងនោះទៅកាន់ទីនោះ ហើយនិមន្តភិក្ខុក្រៅនេះ(ឆាន់) ។ ចំណែកភិក្ខុទាំងនោះក៏បានបដិសេធដូចយ៉ាងនោះឯង ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុអ្នកសម្រេចព្រះអរហត្តក៏បរិនិព្វានទៅ ។ ព្រះអនាគាមីក៏ទៅកើតក្នុងជាន់សុទ្ធាវាស ។ ចំណែកភិក្ខុ ៥ រូបក្រៅនេះ សូម្បីព្យាយាមយ៉ាងណា ក៏មិនអាចធ្វើគុណវិសេសឱ្យកើតឡើងបានដែរ ។ ភិក្ខុទាំងនោះកាលមិនអាច (នឹងធ្វើអ្វីបាន) ក៏ស្តមស្តាំងស្លាប់ក្នុងទីនោះទៅ ហើយកើតក្នុងទេវលោក អន្ទោលទៅក្នុងទេវលោកនុ៎ះឯងអស់មួយពុទ្ធន្តរៈ ក្នុងពុទ្ធុប្បាទកាលនេះ បានចុតិពីទេវលោកកើតក្នុងត្រកូលនោះ ។ ក៏បណ្តាអ្នកទាំងនោះ ម្នាក់បានជាព្រះរាជាព្រះនាមថា **បុក្កុសៈ**, ម្នាក់ជាកុមារកស្សបៈ, ម្នាក់ជាទព្វមល្លបុត្រ, ម្នាក់ជាសភិយៈ

បរិព្វាជក, ម្នាក់ជាពាហិយៈទារុចីរិយៈ ។ បណ្តាអ្នកទាំងនោះ ព្រះអនាគាមីអ្នកដែលកើតក្នុងព្រហ្មលោក ដែលលោកសំដៅយកពោលពាក្យនេះទុកថា **បុរាណសាលោហិតា ទេវតា** ទេវតាអ្នករួមសាលោហិត ដូច្នេះ ។ ពិតមែន សូម្បីទេវបុត្រក៏ហៅថាទេវតា ព្រោះអធិប្បាយថា ទេវតាក៏គឺ **ទេវ** ដូចទេពធីតា ដូចក្នុងប្រយោគមានជាដើមថា **អថ ខោ អញ្ញតរា ទេវតា** គ្រានោះឯងទេវតាមួយអង្គ ។ តែក្នុងទីនេះ**ព្រហ្ម**លោកប្រាថ្នាយកថា**ទេវតា** ។

ក៏កាលព្រហ្មនោះ ត្រួតមើលព្រហ្មសម្បត្តិហើយនឹកដល់ស្ថានទីខ្លួនមក ក្នុងលំដាប់ដែលកើតក្នុងព្រហ្មលោកនោះតែម្តង ការដែលពួកជនទាំង ៧ នាក់ឡើងភ្នំធ្វើសមណធម៌ ភាវៈនៃខ្លួនសម្រេចអនាគាមិផលហើយកើតក្នុងព្រហ្មលោកក្តីប្រាកដហើយ ។ ព្រហ្មនោះរំពឹងថា ចំណែកជនទាំង ៥ កើតនៅទីណាហ្ន៎ ទើបដឹងថា ជនទាំងនោះកើតក្នុងទេវលោកជាន់កាមាវចរ គ្រាតមកតាមវេលាដែលសមគួរ បានត្រួតមើលប្រវត្តិរបស់ជនទាំងនោះថា ធ្វើយ៉ាងណាហ្ន៎ ។ តែក្នុងវេលានេះកាលរំពឹងថាពួកទាំងនោះនៅទីណាហ្ន៎ ទើបបានឃើញពាហិយៈអាស្រ័យកំពង់សុប្បារកៈ

ស្លៀកសំពត់ក្រងដោយសំបកឈើចិញ្ចឹមជីវិតដោយការបញ្ឆោតបន្ទំ ទើបគិតថា កាលមុនអ្នកនេះនឹងយើង ចងជណ្តើរឡើងភ្នំធ្វើសមណធម៌ ដោយមិនអាល័យក្នុងជីវិត ព្រោះប្រព្រឹត្តតឹងរឹងយ៉ាងក្រៃលែង សូម្បីព្រះអរហន្តនឹងនាំបិណ្ឌបាតមកឱ្យក៏មិនឆាន់ឥឡូវនេះប្រាថ្នាឱ្យគេលើកតម្កើង មិនជាព្រះអរហន្តឡើយ ថែមទាំងដើរប្តូរជ្រោះខ្លួនថា ជាព្រះអរហន្ត មានសេចក្តីប្រាថ្នាលាភសក្ការៈ និងឈ្មោះ សម្លេង ទាំងមិនដឹងថា ព្រះទសពលឧប្បត្តិឡើងហើយ ណ្លើយចុះ យើងនឹងធ្វើគេឱ្យតក់ស្លុតហើយឱ្យដឹងថា ព្រះពុទ្ធឧប្បត្តិឡើងហើយ ភ្លាមនោះឯង ទើបចុះចាកពីព្រហ្មលោកមកប្រាកដចំពោះមុខទាវុចរិយៈ ត្រង់កំពង់សុប្បារកៈពេលយប់ ។ ពាហិយៈ ឃើញពន្លឺរុងរឿងក្នុងទីនៅរបស់ខ្លួនទើបគិតថា នេះអ្វីហ្ន៎ ហើយបានចេញទៅខាងក្រៅត្រួតមើល ឃើញមហាព្រហ្មនៅក្នុងអាកាស ទើបផ្គងអញ្ជលីសួរថា លោកជាអ្នកណា, លំដាប់នោះ ព្រហ្មបានពោលដល់លោកថា យើងជាសម្លាញ់ចាស់របស់លោក គ្រានោះយើងសម្រេចអនាគាមិផល កើតក្នុងព្រហ្មលោក តែលោកមិនអាចនឹងធ្វើគុណវិសេសអ្វី ឱ្យកើតបានអ្នកមិនជាព្រះ

អរហន្តទ្បើយ ថែមទាំងកាន់លទ្ធិនេះថា យើងជាព្រះអរហន្ត (យើង)ដ៏ងដូច្នេះទើបបានមក ម្នាលពាហិយៈ លោកមិនជាព្រះអរហន្តទេ លោកចូរលះបង់ទិដ្ឋិដ៏លាមក ដូច្នោះចេញចុះលោក កុំបានប្រព្រឹត្តទៅដើម្បីវិនាស ដើម្បីទុក្ខវហូតដល់អស់កាលយូរទ្បើយ ព្រះសម្មាសម្ពុទ្ធឧប្បត្តិទ្បើង ហើយក្នុងលោកសេចក្តីពិតព្រះមានព្រះភាគព្រះអង្គនោះជាព្រះអរហន្ត លោកចូលទៅគាល់ព្រះអង្គចុះ ។

ដោយហេតុនោះ លោកទើបពោលពាក្យមានជាដើមថា គ្រានោះឯង ទេវតាអ្នកជាខ្សែរលោហិតរបស់ពាហិយៈ ទារុចរិយៈដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អនុកម្បិកោ បានដល់ អ្នកមានប្រក្រតីអនុគ្រោះ ។ គឺអ្នកក្រៃលែងដោយករុណា ។ បទថា អត្តកាមោ បានដល់ អ្នកប្រាថ្នាប្រយោជន៍ គឺអ្នកក្រៃលែងដោយមេត្តា ។ ក៏ក្នុងទីនេះដោយបទដំបូង លោកសម្តែងដល់សេចក្តីដែលទេវតានោះប្រាថ្នានឹងបំបាត់ទុក្ខរបស់ពាហិយៈ, ដោយបទក្រោយ សម្តែងដល់ការនាំប្រយោជន៍ជួយសង្គ្រោះចូលទៅ ។

បទថា **ចេតសា** បានដល់ ដោយចិត្តរបស់ខ្លួន ។ ក៏ក្នុងទីនេះគប្បីជ្រាបថា លោកកាន់យកចេតោបរិយញ្ញាណ ដោយលើកចិត្តឡើងជាប្រធាន ។ បទថា **ចេតោបរិវិតក្កំ** បានដល់ ការប្រព្រឹត្តទៅនៃចិត្តរបស់លោក ។ បទថា **អញ្ញាយ** ប្រែថា ដឹងហើយ ។ បទថា **តេនុបសង្កមិ** សេចក្តីថា បុរសអ្នកមានកម្លាំងលូកដៃដែលបត់ចូលឬគូដៃដែលលាចេញ ឈ្មោះសូម្បីយ៉ាងណា ព្រហ្មអន្តរធានចាកពីព្រហ្មលោក ចូលទៅជ្រាកដត្រង់មុខពាហិយៈក៏ដូច្នោះដែរ ។ បទថា **ឯតទវោ** ច សេចក្តីថា មិនមែនព្រះអរហន្តទេ ដូច្នេះក៏ពាហិយៈអ្នកមិច្ឆាបរិវិតក្ក ដែលប្រព្រឹត្តទៅ មានជាដើមថា អ្នកណាម្នាក់នឹងជាព្រះអរហន្តឬ ដូច្នេះ ដូចចាប់ចោរព្រមទាំងរបស់មក ។ ដោយបទថា **នេវ ខោ តុំ ពាហិយ អរហា** នេះ ព្រហ្មបដិសេធថា លោកពាហិយៈ មិនមែនព្រះអសេក្ខៈក្នុងកាលនោះ ។ ដោយបទថា **នាបិ អរហត្តមគ្គំ វាសមាបន្នោ** នេះ សម្តែងថាលោកពាហិយៈនៅជាសេក្ខបុគ្គល ។ សូម្បីដោយបទទាំងពីរនោះ សម្តែងថា លោកពាហិយៈមិនមែនព្រះអរិយបុគ្គលទេ ។ ក៏ដោយពាក្យថា **សាបិ តេបដិបន្ន**

ឆត្តិ យាយ ពាហិយ តុំ អរហា វា អស្សសិ អរហត្តមគ្គំ វាសមាបន្នោ នេះ ព្រហ្មបដិសេធថា លោកពាហិយៈជាត្រឹមតែកល្យាណបុថុជ្ជន ។

បណ្តាបទទាំងនោះ បទថា បដិបន្នា បានដល់ វិសុទ្ធិ ៦ (ខាងដើម)មានសីលវិសុទ្ធិជាដើម ។ ដែលឈ្មោះថា បដិបទា ព្រោះជាគ្រឿងដំណើរទៅក្នុងអរិយមគ្គ ។ បទថា អស្សសិ ប្រែថា គប្បីជា ។

សួរថា ក៏សេចក្តីសម្គាល់ខ្លួនថា ជាព្រះអរហន្តនេះ កើតឡើងដល់លោក ព្រោះអាស្រ័យអ្វី, ឆ្លើយថា អាចារ្យពួកខ្លះពោលថា សេចក្តីសម្គាល់ខ្លួនថាជាព្រះអរហន្តកើតឡើងដល់លោក ព្រោះលោកកម្ចាត់កិលេសបាន ដោយតទង្គបហានហេតុ បានសាងបុញ្ញាធិការទុកហូតដល់អស់កាលយូរ ដោយសេចក្តីដែលលោកជាអ្នកប្រាថ្នាតិច សន្តោសនឹងជាអ្នកដុសខាត់ ។ តែអាចារ្យមួយពួកទៀតពោលថា លោកពាហិយៈបានឈាន ៤ មានបឋមឈានជាដើមព្រោះដូច្នោះសេចក្តីសម្គាល់ខ្លួនថាជាព្រះអរហន្តទើបកើតឡើងដល់លោក ព្រោះកិលេសមិនហុយឡើងដោយវិក្ខម្ភនប-

ហាន ។ ពាំងពីរយ៉ាងនោះជាត្រឹមតែមតិរបស់កេចិអាចារ្យប៉ុណ្ណោះ ព្រោះមកក្នុងអដ្ឋកថាថា លោកប្រាថ្នាតែសេចក្តីលើកតម្កើងខ្លួន និងថា លោកមិនប្រាថ្នាលាភសក្ការៈ និងការសរសើរ ។ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីក្នុងន័យនេះ ដោយន័យដូចពោលហើយនុ៎ះឯង ។

លំដាប់នោះ លោកពាហិយៈក្រឡេកមើលមហាព្រហ្មអ្នកឈរពោលនៅក្នុងអាកាស ទើបគិតថា ឱ! ចំណុចដែលយើងយល់ថា ជាព្រះអរហន្ត ជាកម្មជ្ឈន់ពិត និងព្រហ្មនេះពោលថា សូម្បីបដិបទា ជាគ្រឿងសម្រេចព្រះអរហត្តក៏មិនមានដល់លោកអ្នកជាព្រះអរហន្តក្នុងលោកមាននៅឬហ្ន៎ ។ លំដាប់នោះ ទើបសួរមហាព្រហ្មនោះដោយហេតុនោះ លោកទើបពោលថា អថ កេ ចរហិ នេវតេ លោកេ អរហាន្តោ វា អរហត្តមគ្គំ វា សមាបន្នា ។

បណ្តាបទទាំងនោះសព្ទថា អថ ជានិបាតប្រើក្នុងអត្ថផ្តើមពាក្យសួរ ។

បទថា កេ ចរហិ តែជាជា កេ ឯត្ថរហិ ។ បទថា

លោកេ បានដល់ ក្នុងឱកាសលោក ។ ក៏ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះ ៖

គ្រានោះ ក្នុងផែនដីជម្ពូទ្វីបទាំងអស់ដែលជាទីទទួលទ្រឥឡូវនេះ ព្រះអរហន្ត ឬអ្នកសម្រេចអរហត្តមគ្គមាននៅក្នុងទីណា ដែលជាទីពួកយើងចូលទៅរកលោកទាំងនោះ តាំងនៅក្នុងឱវាទរបស់លោកហើយ នឹងផុតពីវដ្តទុក្ខ ។

បទថា ឧត្តរេសុ លោកពោលសំដៅយកទិសខាងកើតឆៀងកំពង់សុប្បារកៈ ។ បទថា អរហំ បានដល់ ឈ្មោះថាជាព្រះអរហន្ត ព្រោះជាអ្នកឆ្ងាយ (ចាកពីកិលេស) ។ ពិតមែន ព្រះអរហន្តនោះ ឈ្មោះថា ជាអ្នកឆ្ងាយ គឺតាំងនៅក្នុងទីឆ្ងាយសែនឆ្ងាយចាកពីកិលេស ។ (និង)ឈ្មោះថា ព្រះអរហន្ត ព្រោះកម្ចាត់កិលេសព្រមទាំងវាសនាដោយមគ្គ ឬសម្លាប់កិលេសដូចសត្រូវចេញបាន ។ ពិតមែន សត្រូវគឺកិលេសទាំងឡាយដែលព្រះមានព្រះភាគសម្លាប់ គឺដកចេញហើយ ដោយអរហត្តមគ្គអស់រលីង ។ មួយទៀត ឈ្មោះថា ជាព្រះអរហន្ត ព្រោះកម្ចាត់កាំគឺកិលេសចេញបាន ។ ពិតមែនព្រះមានព្រះភាគនោះទ្រង់ឈរនៅ

លើផែនដីគឺសីល ដោយព្រះយុគលបាទគឺ វិរិយៈ ទ្រង់ប្រើព្រះហស្ត គឺសទ្ធា ចាប់ ពូថៅគឺញាណដែលជាហេតុធ្វើកម្មឱ្យអស់ ហើយ ទ្រង់ប្រហារគឺកម្ចាត់កាំទាំងអស់នៃសង្សារចក្រដែលមានដុំសម្រេច ដោយអវិជ្ជា និងតណ្ហា មានបុញ្ញាភិសង្ខារជាដើមជាកាំ មានជរា និងមរណៈជាកង់សឹកជាក់ភ្លៅដែលសម្រេចដោយអាសវៈ សមុទ័យប្រកបចូលក្នុងរថគឺ ភព ៣ ប្រព្រឹត្តទៅរហូតដល់អស់ កាលមិនមានខាងដើម ។ ម្យ៉ាងទៀត ឈ្មោះថា ព្រះអរហន្ត ព្រោះជាអ្នកគួរ ។ សេចក្តីពិត ព្រះមានព្រះភាគរមែងគួរដល់ បច្ច័យមានចីវរជាដើម ដែលក្រៃលែង និងបូជាពិសេស ព្រោះ ព្រះអង្គជាព្រះទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក ព្រមទាំង ទេវលោក ។ មួយទៀត ឈ្មោះថាព្រះអរហន្ត ព្រោះមិនមាន សេចក្តីកំបាំង (ក្នុងការធ្វើបាប) ពិតមែនព្រះតថាគតលោកហៅ ថាព្រះអរហន្ត ព្រោះមិនមានសេចក្តីកំបាំងក្នុងការធ្វើបាបដោយ កិលេសលាមកមិនមាន ព្រោះព្រះអង្គដកកិលេសមានរាគៈជាដើម បានដោយប្រការទាំងពួង ។

ឈ្មោះថា សម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយ

ប្រពៃនិងដោយព្រះអង្គឯង ។ ពិតមែន ព្រះមានព្រះភាគទ្រង់
ត្រាស់ដឹងក្រៃលែងនូវធម៌ដែលគួរដឹងក្រៃលែងនូវធម៌ ដែលគួរ
កំណត់ដឹង ជាធម៌ដែលគួរកំណត់ដឹង នូវធម៌ដែលគួរលះដោយ
ជាធម៌ដែលគួរលះនូវធម៌ដែលគួរធ្វើឱ្យច្បាស់ ជាធម៌ដែលគួរធ្វើ
ឱ្យច្បាស់ដែលធម៌ដែលគួរចម្រើនដោយជាធម៌ដែលគួរចម្រើន ។
សមពិតដូចដែលត្រាស់ទុកថា ៖

**អភិញ្ញេយ្យំ អភិញ្ញាតំភាវេតព្វញ្ច ភាវិតំបហាតព្វំ
បហីនមញ្ញេម តស្មា ពុទ្ធោស្មិព្រាហ្មណា ។**

***ធម៌ដែលគួរដឹងក្រៃលែង តថាគតដឹងក្រៃលែងហើយ
ធម៌ដែលគួរចម្រើន តថាគតចម្រើនហើយ ធម៌ដែលគួរ
លះយើងលះបានហើយ ព្រោះដូច្នោះឯង ព្រាហ្មណ៍ តថាគតទើប
ជាព្រះពុទ្ធ ។***

*ម្យ៉ាងទៀត គប្បីណែនាំអត្ថនេះដោយធម៌ពួកបីនិងពីរទាំង
ពួងជាដើម ដោយន័យមានជាដើមថា ធម៌ ឈ្មោះថា ជាកុសល
ព្រោះមិនមានទោសមានសុខជាផល ធម៌ ឈ្មោះថា ជាអកុសល*

ព្រោះមានទោស មានទុក្ខជាផល ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបដូច្នេះថា ឈ្មោះថា សម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងក្រៃលែងនូវធម៌ទាំងពួង ដោយអាការទាំងពួងដោយសយម្ភូញ្ញាណដែលមិនវិបរិតដោយប្រការដូច្នេះ ។ ចំណែកសេចក្តីពិស្តារគប្បីជ្រាបដោយនយដែលមកក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។

បទថា **អរហត្តតាយ** បានដល់ ដើម្បីបានអរហត្តផល ។ បទថា **ធម្មំ ទេសេតិ** សេចក្តីថា រមែងអាង គឺសម្តែងធម៌ គឺបដិបទាមានសីលជាដើម ដែលគួរដល់គុណពិសេសមានពីរោះក្នុងខាងដើមជាដើម ឬធម៌គឺ សមថៈនិងវិបស្សនាដែលសមគួរដល់អធ្យាស្រ័យរបស់វេនេយ្យសត្វនុ៎ះឯង ។ បទថា **សំវេជនីយោ** សេចក្តីថា ឱ្យដល់សេចក្តីតក់ស្លុតថា អ្នកដ៏ចម្រើន គួរតិះដៀលពិត សេចក្តីជាបុថុជ្ជន ដែលជាហេតុឱ្យយើងអ្នកមិនជាព្រះអរហន្តឡើយ សម្គាល់ថាជាព្រះអរហន្តនិងមិនដឹងព្រះសម្មាសម្ពុទ្ធអ្នកស្តេចឧប្បត្តិឡើងក្នុងលោកទ្រង់សម្តែងធម៌ ក៏សេចក្តីវស់នៅដឹងបានលំបាក សេចក្តីស្លាប់ក៏ដឹងបានលំបាក ។ អធិប្បាយថា មានចិត្តស្លុតដោយអាការតាមដែលពោលហើយដោយពាក្យនិយាយរបស់ទេវតា ។ បទថា

តាវទេវ ប្រែថា ក្នុងខណៈនោះឯង ។

បទថា **សុប្បារកោ បក្កាមិ** សេចក្តីថា អ្នកមានបីតិដោយមានព្រះពុទ្ធជាអារម្មណ៍ដែលកើតឡើង ព្រោះបានឮព្រះនាមថា **ពុទ្ធោ** និងត្រូវសេចក្តីសង្វេគជាស់តឿន ទើបបានអំពីកំពង់សុប្បារកៈចេញទៅ ឆ្ពោះទៅកាន់ក្រុងសាវត្ថី ។ បទថា **សព្ពត្ថ ឯកវត្តិបរិវារសេន** សេចក្តីថា បានទៅដោយនៅស្នាក់សម្រាកតែមួយរាត្រីក្នុងផ្លូវទាំងពួង ។ ពិតមែន ពីក្រុងសាវត្ថីទៅកំពង់សុប្បារកៈ មានរយៈផ្លូវ ១២០ យោជន៍ តែពាហិយៈនេះបានទៅកាន់ក្រុងសាវត្ថីនោះ ដោយឈប់សម្រាកតែមួយរាត្រីអស់រយៈផ្លូវប៉ុណ្ណោះ ។ លោកបានដល់ក្រុងសាវត្ថីក្នុងថ្ងៃទីចេញអំពីកំពង់សុប្បារកៈនុ៎ះឯង ។ សួរថា ក៏យ៉ាងណា ពាហិយៈនេះទើបបានទៅយ៉ាងនោះ, ឆ្លើយថា ព្រោះអានុភាពរបស់ទេវតា ។ អាចារ្យពួកខ្លះពោលថា ព្រោះពុទ្ធានុភាពក៏មាន ។ ជាការលោកសម្តែងអធិប្បាយទុកដូច្នេះថា ក៏ព្រោះលោកពោលថា ដោយស្នាក់នៅតែមួយរាត្រីក្នុងទីគ្រប់កន្លែង និងព្រោះផ្លូវមានរយៈ ១២០ យោជន៍ ក្នុងចន្លោះផ្លូវ លោកមិនឱ្យអរុណទី ២ តាំងឡើង

ក្នុងទីដែលខ្លួនសម្រាកពេលយប់ ក្នុងគ្រាម និគម និងរាជធានី ទើបទៅដល់ក្រុងសាវត្ថី ដោយស្នាក់សម្រាកតែមួយរាត្រីក្នុងទីគ្រប់កន្លែង ។ ប្រការនេះ មិនគប្បីឃើញយ៉ាងនេះថា លោកនៅក្នុងផ្លូវនោះទាំងអស់ត្រឹមតែរាត្រីតែមួយ ព្រោះប្រាថ្នាយកសេចក្តីនេះថា ដោយការសម្រាកលះចោលនូវរាត្រីក្នុងផ្លូវទាំងអស់ មានរយៈផ្លូវ ១២០ យោជន៍ ក្នុងថ្ងៃចុងបង្អស់នាវេលាល្ងាច ទើបដល់ក្រុងសាវត្ថី ។

ចំណែកព្រះមានព្រះភាគទ្រង់ជ្រាបថា ពាហិយៈមកដល់ទ្រង់ត្រិះរិះជាន់ដំបូងថា ឥន្ទ្រិយរបស់ពាហិយៈមិនទាន់ចាស់ក្លា តែក្នុងរវាងចាំមួយស្របក់នឹងដល់សេចក្តីចាស់ក្លា ដូច្នេះហើយ រង់ចាំឱ្យលោកមានឥន្ទ្រិយចាស់ក្លា ទើបហៅមក ដោយភិក្ខុសង្ឃជាច្រើន ស្តេចបិណ្ឌបាតនៅក្នុងក្រុងសាវត្ថីក្នុងខណៈនោះឯង ។ និងពាហិយៈនោះក៏ចូលទៅកាន់វត្តជេតពន ឃើញភិក្ខុជាច្រើនឆាន់កត្តាហារព្រឹកហើយ ចង្រ្កមនៅក្នុងអព្ភោកាសទីវាល ដើម្បីបន្ទោសបង់សេចក្តីខ្វិលច្រអូសកាយ ទើបសួរថា ឥឡូវនេះ ព្រះមានព្រះភាគប្រថាប់នៅទីណា ។ ភិក្ខុទាំងឡាយពោលថា ព្រះមានព្រះភាគទ្រង់ស្តេចនិម្តបិណ្ឌបាតក្នុងក្រុងសាវត្ថី ភិក្ខុទាំងឡាយ

បានសួរថា លោកមកពីណា ? គេឆ្លើយថា មកពីកំពង់សុប្បារកៈ ។ ភិក្ខុទាំងឡាយពោលថា លោកមកពីឆ្ងាយ អញ្ជើញអង្គុយសិន ចូរលាងជើង លាបប្រេង ហើយសម្រាកមួយភ្លែត ពេលដែលព្រះអង្គត្រឡប់មកវិញ លោកនឹងឃើញព្រះសាស្តា ។ ពាហិយៈពោលថា លោកម្ចាស់ ខ្ញុំមិនដឹងនូវសេចក្តីអន្តរាយនៃជីវិតរបស់ខ្លួនទេ ដោយហើយឡើយ ខ្ញុំមិនឈរ មិនអង្គុយសូម្បីក្នុងទីណា ៗឡើយ ខ្ញុំមកអស់រយៈផ្លូវ ១២០ យោជន៍ ចូលគាល់ព្រះសាស្តាហើយ ទើបសម្រាក គ្រានោះពាហិយក៏បានទៅកាន់ក្រុងសាវត្ថី ឃើញព្រះមានព្រះភាគអ្នកវុងវឿងដោយពុទ្ធសិរីរកអ្វីប្រៀបផ្ទឹមមិនបាន ។ ដោយហេតុនោះ លោកទើបពោលថា ក៏សម័យនោះឯង ភិក្ខុជាច្រើនចង្រ្កមនៅក្នុងទីវាល ។ លំដាប់នោះឯង ពាហិយទារុចីរិយៈបានចូលទៅរកភិក្ខុទាំងនោះ ដល់ទីនៅ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា កហំ ជាកត្ត ប្រែថាទីណា ។ សព្ទថា នុ ប្រើក្នុងអត្ថថាសង្ស័យ ។ សព្ទថា **ខោ** ប្រើក្នុងអត្ថថាធ្វើបទឱ្យពេញ ។

អធិប្បាយថា ក្នុងប្រទេសណាហ្ន៎ ។ បទថា ឧស្សុកាមា ប្រែថា ជាអ្នកប្រាថ្នានឹងឃើញ ។ កំពង់សម្តែងទុកថា ក៏យើងប្រាថ្នានឹងគាល់និងចូលទៅជិតព្រះមានព្រះភាគនោះ ដូចមនុស្សខ្វាក់ប្រាថ្នាចក្ខុប្រសាទ,ដូចមនុស្សថ្លង់ប្រាថ្នាសោតបសាទ, ដូចមនុស្សគប្រាថ្នាការពោលឱ្យដឹងរឿង, ដូចមនុស្សមានដៃជើងវិការប្រាថ្នាដៃជើង,ដូចមនុស្សក្រីក្រប្រាថ្នាទ្រព្យសម្បត្តិ, ដូចមនុស្សធ្វើដំណើរកន្តារប្រាថ្នាកន្លែងដែលរួចផុតភ័យ, ដូចមនុស្សត្រូវរោគគ្រូបសង្កត់ប្រាថ្នាជារោគ, ដូចមនុស្សត្រូវទូកក្រឡាប់ក្នុងមហាសមុទ្រប្រាថ្នាក្បូនធំដូច្នោះ ។

បទថា តរមានរូបោ បានដល់ ជាអ្នកមានអាការប្រញាប់ប្រញាល់ ឬអ្នកមានការសង្រ្គោះដែលគួរសរសើរ ។

បទថា ថាសាធិកំ សេចក្តីថា នាំមកនូវសេចក្តីជ្រះថ្លាចំពោះដល់ជនអ្នកខ្វល់ខ្វាយក្នុងការឃើញព្រះរូបកាយ ព្រោះសេចក្តីសម្បូរណ៌ ដោយសេចក្តីល្អនៃសរីរៈរបស់ព្រះអង្គ ដែលនាំមកនូវសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង ដែលប្រដាប់ដោយ

មហាបរិសលក្ខណៈ៣២,អនុព្យញ្ជនៈ៨០,ព្រះរស្មីប្រមាណមួយ
ព្យាមនិងព្រះកេតុមាលារស្មីដែលបពោ្ញញលើព្រះសិរសោ ។ បទថា
បសាទនីយំ សេចក្តីថា ជាទីតាំងនៃសេចក្តីជ្រះថ្លា សមគួរនិង
ជ្រះថ្លា ឬគួរដល់សេចក្តីជ្រះថ្លារបស់អ្នកមានបញ្ញាឃើញប្រចក្ស
ព្រោះធម្មកាយសម្បត្តិ ដែលប្រកបដោយចំនួនព្រះគុណរក
ប្រមាណមិនបាន មានទសពលញ្ញាណ ១០ វេសារជ្ជញ្ញាណ ៤
អសាធារណញ្ញាណ ៦ អាវេណិយពុទ្ធធម៌ ១៨ ជាដើម ។ បទថា
សន្តិន្ទ្រិយំ បានដល់ ឥន្ទ្រិយ ៥ ដែលស្ងប់រម្ងាប់ ព្រោះប្រាសចាក
សេចក្តីញាប់ញ័រក្នុងឥន្ទ្រិយស្មៅហ្មង មានចក្ខុន្ទ្រិយជាដើម ។
បទថា **សន្តមានសំ** បានដល់ មានចិត្តស្ងប់រម្ងាប់ ព្រោះចូលដល់
ភាវៈដែលជាមនិន្ទ្រិយ ៦អស់អស្មិមានៈ ។ បទថា **ឧត្តមទមញ្ច-**
ថសមថមនុប្បត្តំសេចក្តីថាដល់ដោយលំដាប់គឺសម្រេចសេចក្តី
ទូន្មាន និងសេចក្តីស្ងប់ដែលខ្ពស់បំផុត ពោលគឺបញ្ញាវិមុត្តិ និង
ចេតោវិមុត្តិដែលជាលោកុត្តរៈតាំងនៅ ។ បទថា **ឧត្តំ** សេចក្តីថា
ឈ្មោះថា ទូន្មានកាយ ព្រោះមានកាយសមាចារបរិសុទ្ធិល្អ និង

ព្រោះមិនមានការលេង ដោយមិនមានការឃ្លើសឃ្នង់ដៃឃ្លើសឃ្នង់ជើងជាដើម ។ បទថា គុត្តំ សេចក្តីថា ឈ្មោះថា ឃុំគ្រង វាថា ព្រោះមានវចីសមាចារបរិសុទ្ធិ្ឍ និង ព្រោះមិនមានការលេង ដោយមានវាចាគ្មានប្រយោជន៍ជាដើម ។ បទថា យតិន្ទ្រិយំ បានដល់ ឈ្មោះថា មានឥន្ទ្រិយសង្រួមហើយ ដោយការប្រកបឫទ្ធិ ដែលជារបស់ព្រះអរិយៈ ព្រោះមានមនោសមាចារបរិសុទ្ធិ្ឍ និង ដោយអំណាចមនិន្ទ្រិយ ព្រោះមានសេចក្តីប្រងើយក្នុងការមិនខ្វល់ខ្វាយនិងការមិនពិចារណា ។ បទថា ឥតិ សេចក្តីថា ឈ្មោះថា អ្នកប្រសើរព្រោះហេតុទាំងនេះ គឺការមិនលុះក្នុងអំណាចឆន្ទាគតិជាដើម កិលេសមានរាគៈជាដើម ដែលលះបានហើយ មិនត្រឡប់កើតទៀត គឺមិនវិលត្រឡប់មក ជាបសូម្បីមានប្រមាណតិចតួចក៏មិនធ្វើសូម្បីដោយប្រការទាំងពួងនិងមិនទៅកាន់ភពថ្មី ។

ក៏ដោយបទថា ឥាសាធិកំ នេះ ក្នុងអធិការនេះ លោកសម្តែងដល់សេចក្តីសម្គាល់របស់ព្រះមានព្រះភាគ ដោយរូបកាយ ។ ដោយបទថា បសាធនីយំ នេះ សម្តែងដល់សេចក្តី

សម្គាល់របស់ព្រះមានព្រះភាគដោយធម្មកាយ ។ ដោយបទមានជាដើមថា សន្តិន្ទ្រិយំ នេះ សម្តែងដល់សេចក្តីសម្គាល់របស់ព្រះគុណដ៏សេស ។ ព្រោះហេតុនោះ គប្បីជ្រាបថា លោកប្រកាសសេចក្តីសម្គាល់របស់ព្រះមានព្រះភាគដល់ពួកសត្វ ក្នុងលោកសន្និវាសដែលជឿប្រតិបត្តិតាម ៤ ពួក ។

ក៏ពាហិយៈ បានឃើញព្រះមានព្រះភាគដែលជាយ៉ាងនោះ កំពុងស្តេចទៅក្នុងថ្នល់ រីករាយត្រេកអរថា យូរណាស់ហើយយើងទើបបានឃើញព្រះមានព្រះភាគ គេមានសរីរៈត្រូវបីតិ ៥ ប្រការពាល់ត្រូវហើយកែវភ្នែកក៏ស្ងប់ព្រោះបីតិជ្រួតជ្រាប យើងបង្អោនសរីរៈចុះតាំងតែពី ៗ បានឃើញព្រះមានព្រះភាគហើយ ក៏ធ្លាក់ចុះកណ្តាលរស្មីព្រះវរកាយរបស់ព្រះមានព្រះភាគ លិចចុះក្នុងព្រះរស្មីនោះ ចូលទៅជិតព្រះមានព្រះភាគថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ប្របាច់ផ្ទៃព្រះយុគលបាទរបស់ព្រះមានព្រះភាគចម្ងិតនិងថើបនៅបណ្តើរ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាសម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។ ព្រោះ

ហេតុនោះ ទើបពោលថា លោកក្រាបចុះទៀបព្រះឃុគលបាទរបស់ព្រជ័មានព្រះភាគ ដោយសិរសាហើយក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាសម្តែងធម៌ដល់ខ្ញុំព្រះអង្គ សូមព្រះសុគតមេត្តាសម្តែងធម៌ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ដើម្បីសុខដល់ខ្ញុំព្រះអង្គអស់កាលយូរចុះ ។

បណ្តាបទទាំងនោះ បទថា **សុគតោ** សេចក្តីថា ឈ្មោះថា សុគត ព្រោះស្តេចទៅ គឺស្តេចទៅកាន់ទីដែលល្អ ស្តេចទៅដោយប្រពៃ មានព្រះវាចាប្រពៃ ។

ពិតមែន ការទៅ លោកហៅថា **គត** ។ ក៏ការទៅនោះរបស់ព្រះមានព្រះភាគល្អ គឺបរិសុទ្ធិមិនមានទោស ។ សួរថា ក៏ការទៅគឺអ្វី, ឆ្លើយថា គឺអរិយមគ្គ ។ ពិតមែន ព្រះមានព្រះភាគនោះស្តេចទៅកាន់ទិសក្សេមមិនជាប់ជំពាក់ដោយការទៅនោះ ។ សូម្បីអ្នកដទៃព្រះអង្គក៏ឱ្យដំណើរទៅផង ព្រោះដូច្នោះ ទើបឈ្មោះថាសុគត ព្រោះស្តេចទៅល្អ ។ ក៏ព្រះអង្គស្តេចទៅកាន់ទីដែលល្អ គឺអមតនិព្វាន ព្រោះដូច្នោះ ទើបឈ្មោះថា **សុគត** ព្រោះស្តេចទៅកាន់ទីដែលល្អ ។ ព្រះអង្គ ឈ្មោះថា **សុគត** ព្រោះស្តេចទៅប្រពៃ

មិនវិលត្រឡប់មកកាន់កិលេស ដែលព្រះអង្គប្រហារដោយមគ្គនោះ ។ ។ សមពិតដូចព្រះតម្រាស់ដែលត្រាស់ថា ឈ្មោះថាសុគត ព្រោះមិនមកទៀត មិនត្រឡប់មក មិនវិលត្រឡប់មកកាន់កិលេសដែលព្រះអង្គប្រហារបានដោយសោតាបត្តិមគ្គ ។ ឈ្មោះថា ***សុគត*** *ព្រោះមិនវិលត្រឡប់មកកាន់កិលេសដែលព្រះអង្គប្រហារបានដោយសកទាគាមិមគ្គ ។ល ។ ដោយអរហត្តមគ្គ ។ ម្យ៉ាងទៀត បទថា* ***សម្មាគតត្តា*** *សេចក្តីថា ព្រោះស្តេចទៅគឺជំណើរទៅដោយល្អដោយសម្មាបដិបត្តិ សូម្បីក្នុងការកំណត់ទាំង ៣ យ៉ាង ។ ពិតមែន ឈ្មោះថា* ***សុគត*** *ព្រោះស្តេចទៅដោយប្រពៃ សូម្បីដោយអាការយ៉ាងនេះថា ព្រះអង្គទ្រង់សម្រេចទីបំផុត* ***ញាតត្ថចរិយា លោកត្ថចរិយា ពុទ្ធត្ថចរិយា*** *ដោយសម្មាបដិបត្តិដែលបរិបូរណ៌ដោយព្រះបារមី ៣០ គត់ ចាប់ផ្តើមតាំងពីបាទមូលព្រះពុទ្ធទីបង្ករជរាបដល់មហាពោធិមណ្ឌលទ្រង់កំពូនចំពោះហិតសុខដល់លោកទាំងពួង តអំពីនោះ ទើបស្តេចទៅគឺ ជំណើរទៅដោយការជាធំក្នុងធម៌ដែលព្រះអង្គទ្រង់សម្រេចក្នុងអរិយសច្ច ៤ ដោយមជ្ឈិមាបដិបទា ពោលគឺពោជ្ឈង្គភាវនាដែលកំពូលឆ្ងើម មិនជំពាក់ឆៀងចូលទីបំផុតទាំងនេះ គឺសស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិ កាមសុខល្លិ-*

កានុយោគអត្តកិលមថានុយោគនិងដោយសម្មាបដិបត្តិដែលមិនមែនវិស័យក្នុងសត្វទាំងពួង ។ ក៏ព្រះមានព្រះភាគនេះត្រាស់ដោយប្រពៃគឺ ត្រាស់ព្រះវាចាចំពោះរបស់គួរ ក្នុងហានៈដែលគួរ ព្រោះហេតុនោះ ឈ្មោះថា **សុគត** ។ សមពិតដូចព្រះតម្រាស់ដែលត្រាស់ថា យើងតថាគតជាកាលវាទី និយាយតាមកាលភូតវាទី និយាយតាមហេតុជាពិត អត្ថវាទី និយាយតាមអត្ថធម្មវាទី និយាយតាមធម៌ វិនយវាទី និយាយតាមវិនយ និយាយវាចាដែលមានគោលហាន មានគ្រឿងអាង មានទីបំផុតប្រកបជាយប្រយោជន៍តាមកាលដែលគួរ ។ ព្រះអង្គទ្រង់ត្រាស់ទុកទៀតមានជាដើមថា វាចាណាមិនជាពិតមិនពិត មិនប្រកបដោយប្រយោជន៍និងវាចានោះ មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់ជនពួកជទៃតថាគតមិនត្រាស់វាចានោះ ។ ឈ្មោះថា **សុគត** សូម្បីព្រោះត្រាស់ប្រពៃ ដោយប្រការដូច្នេះ ។ បទថា **យំ មមស្ស ឱឃរត្តំ ហិតាយ សុខាយ** សេចក្តីថា ការសម្តែងអាងដល់កម្មណា គប្បីប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ឈាននិងវិមោក្ខជាដើម និងដើម្បីសុខដែលនឹងគប្បីសម្រេចឈាននិងវិមោក្ខជាដើមនោះ ដល់ខ្ញុំព្រះអង្គរហូតដល់អស់កាលយូរ ។

បទថា អកាលោ ខោ តាវ សេចក្តីថា ម្នាលពាហិយៈ មិនមែនកាលដើម្បីសម្តែងធម៌ដល់លោកទេ ។ អធិប្បាយថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបមិនមានកាលក្នុងការបដិបត្តិដើម្បីប្រយោជន៍ដល់សត្វហ្ន៎ ? ព្រោះព្រះមានព្រះភាគជាកាលវាទី ។ ក៏ក្នុងពាក្យថា កាលោ នេះ ប្រាថ្នាយកកាលដែលពួកវេនេយ្យសត្វ មានឥន្ទ្រិយចាស់ក្លា ។ ដោយថា ព្រោះហេតុតែក្នុងខណៈនោះដឹងបានលំបាក ឥន្ទ្រិយទាំងឡាយរបស់ពាហិយៈចាស់ក្លាឬមិនខ្លាំងក្លាដូច្នោះទើបព្រះមានព្រះភាគ មិនត្រាស់ទេសនានោះ កាលទ្រង់អាងហេតុដល់គេថា ព្រះអង្គប្រថាប់ឈរនៅក្នុងចន្លោះផ្លូវ ទើបត្រាស់ថា **អន្តរឃរំ បវិដ្ឋម្ហា** ដូច្នេះ ។

បទថា ទុជ្ជានំ ប្រែថា គប្បីដឹងបានលំបាក ។ ដោយបទថា **ជីវិតន្តរាយានំ** ពាហិយៈប្រាថ្នានឹងពោលថា ការប្រព្រឹត្តទៅ ឬមិនប្រព្រឹត្តទៅនៃធម៌ដែលធ្វើអន្តរាយចំពោះជីវិត ទើបពោលថា **ជីវិតន្តរាយានំ** ដូច្នេះ ដោយអំណាចការវិល ។ ពិតយ៉ាងនោះ ជីវិតគឺការប្រព្រឹត្តទៅជាប់ដោយបច្ច័យជាច្រើន និងអន្តរាយចំពោះជីវិតនោះក៏មានច្រើន ។ សមពិតដូចដែលត្រាស់ថា

អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។

គប្បីប្រញាប់ធ្វើសេចក្តីព្យាយាមក្នុងថ្ងៃនេះឯង អ្នកណាហ្ន៎ នឹងដឹងសេចក្តីស្លាប់ក្នុងថ្ងៃស្អែក ព្រោះថា ការតទល់ចំពោះមច្ចុរាជ ដែលមានសេនាដ៏ច្រើននោះ រមែងមិនមានដល់យើងទាំងឡាយ ។

ក៏ព្រោះហេតុអ្វី ពាហិយៈនេះ និយាយតែពីអន្តរាយជីវិត ជាប្រការរលត់ដំបូង ។ អាចារ្យពួកខ្លះឆ្លើយថា ព្រោះលោកដឹងតែពីអារម្មណ៍ដែលជានិមិត្ត ឬឆ្ងាតក្នុងវត្ថុដែលខ្លួនមិនឃើញ ។ អាចារ្យមួយពួកទៀតពោលថា ព្រោះលោកបានឮពីអន្តរាយនៃជីវិតក្នុងសំណាក់របស់ទេវតា ។ ក៏លោកត្រូវឧបនិស្ស័យសម្បត្តិជាស់តឿន ទើបពោលយ៉ាងនោះ ព្រោះជាអ្នកមានភពចុងបង្អស់ ។ ពិតមែន លោកទាំងនោះមិនទាន់សម្រេចព្រះអរហត្ត ទើបមិនអស់ជីវិត ។ ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគមានព្រះអង្គប្រាថ្នានឹងទ្រង់សម្តែងធម៌ដល់គេនុ៎ះឯង ទើបហាមដល់ទៅ ២ ដង, បានឮថា ព្រះអង្គមានព្រះតម្រិះរិះយ៉ាងនេះថា តាំងពីវេលាដែលពាហិយៈនេះឃើញតថាគត សរីរៈទាំងអស់របស់គេប្រកបដោយ

បីតិពាល់ត្រូវមិនដាច់ បីតិមានសេចក្តីខ្លាំងក្លា សូម្បីនឹងស្តាប់ធម៌ហើយ ក៏មិនអាចត្រាស់ដឹងបាន ទើបទ្រង់ហាមទុកដរាបដល់មជ្ឈត្តុបេក្ខានឹងតាំងឡើងមុន សូម្បីសេចក្តីខ្វល់ខ្វាយក្នុងកាយរបស់លោក ក៏មានកំលាំង ព្រោះលោកមកអស់រយៈផ្លូវ ១២០ យោជន៍ សូម្បីលោករម្ងាប់សេចក្តីខ្វល់ខ្វាយហើយក៏ដោយ ព្រោះហេតុនោះ ទើបទ្រង់បដិសេធដល់ ២ ដង ។ តែអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគបានជាទ្រង់ធ្វើយ៉ាងនោះ ដើម្បីឱ្យកើតសេចក្តីអើពើក្នុងការស្តាប់ធម៌ ។ តែព្រះអង្គត្រូវសូមអង្វរដល់គ្រាទី ៣ ទ្រង់ឃើញ មជ្ឈត្តុបេក្ខាជាគ្រឿងរម្ងាប់សេចក្តីខ្វល់ខ្វាយ និងអន្តរាយជីវិតដែលប្រាកដដល់ពាហិយៈ ទ្រង់ត្រិះរិះថា ឥឡូវនេះ ជាកាលដើម្បីសម្តែងធម៌ ទើបផ្តើមសម្តែងធម៌ដោយន័យមានជាដើមថា តស្មា តិហ តេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា តស្មា សេចក្តីថា ព្រោះលោកជាអ្នកកើតសេចក្តីខ្វល់ខ្វាយអង្វរតថាគតយ៉ាងក្រៃលែង ឬព្រោះលោកពោលថា អន្តរាយជីវិតដ៏ធំបានលំបាក និងឥន្ទ្រិយរបស់ពាហិយៈចាស់ក្លាហើយ ។ សព្ពំ តិហ ត្រឹមតែជានិបាត ។

បទថា តេ ប្រែថា ដែលលោក ។ ដោយពាក្យថា ឯវំ នេះ គ្រាស់ដល់អាការដែលនឹងពោលក្នុងឥទ្ធវារនេះ ។ បទថា សិក្ខិតព្វំ សេចក្តីថា គប្បីធ្វើការសិក្សាដោយសិក្ខា សូម្បីទាំង ៣ មានអធិសីលសិក្ខាជាដើម ។ តែកាលព្រះអង្គនឹងទ្រង់សម្តែងអាការដែលនឹងគប្បីសិក្សា ទើបត្រាស់ពាក្យមានជាដើមថា ឯដ្ឋេ ឯដ្ឋមត្តំ ភវិស្សតិ កាលឃើញក៏ត្រឹមតែជាការឃើញ ។

បណ្តាបទទាំងនោះបទថា ឯដ្ឋេ ឯដ្ឋមត្តំ បានដល់ ត្រឹមតែថាការឃើញរូបជាយតនៈ ដោយចក្ខុវិញ្ញាណ ។ អធិប្បាយថា លោកគប្បីសិក្សាថា ចក្ខុវិញ្ញាណដែលឃើញរូបក្នុងរូបប៉ុណ្ណោះ មិនរកឃើញសភាពលក្ខណៈមានអនិច្ចលក្ខណៈជាដើមទេយ៉ាងណា រូបដ៏សេស ត្រឹមតែតថាគតឃើញដោយវិញ្ញាណ ដែលប្រព្រឹត្តទៅផ្លូវចក្ខុទ្វារនោះប៉ុណ្ណោះ ។ ម្យ៉ាងទៀត អធិប្បាយថា ការដឹងច្បាស់នូវរូបក្នុងរូបដោយចក្ខុវិញ្ញាណ ឈ្មោះថា ឃើញរូបក្នុងរូបដែលឃើញ ។ បទថា មត្តា ប្រែថាប្រមាណ ។ ប្រមាណនៃរូបនេះដែលឃើញហើយ ព្រោះដូច្នោះ ទើបឈ្មោះថា ឯដ្ឋមត្ត ។

អធិប្បាយថា ចិត្តត្រឹមតែជាចក្ខុវិញ្ញាណជាប្រមាណប៉ុណ្ណោះ ។ លោកអធិប្បាយទុកថា ចក្ខុវិញ្ញាណ រមែងមិនតម្រេក ជំទាស់ វង្វេងក្នុងរូបដែលមកប្រាកដយ៉ាងណា យើងនឹងតាំងជវនចិត្តទុក ដោយប្រមាណនៃចក្ខុវិញ្ញាណយ៉ាងនេះថា ជវនចិត្តរបស់យើង នឹងត្រឹមតែជាចក្ខុវិញ្ញាណប៉ុណ្ណោះ ព្រោះវៀរចាកភាគៈជាដើម ។

ម្យ៉ាងទៀតរូបដែលចក្ខុវិញ្ញាណឃើញ ឈ្មោះថា ឥដ្ឋ ។ ចិត្ត ៣ដួង គឺសម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត និងវោដ្ឋព្វនចិត្តដែលកើតឡើងដូចយ៉ាងនោះឯង ឈ្មោះថា ឥដ្ឋមត្តៈ ។ គប្បីជ្រាបសេចក្តីក្នុងសេចក្តីនេះយ៉ាងនេះថា ចិត្ត៣ដួងនេះរមែងមិនតម្រេកជំទាស់ ឈ្លក់វង្វេងយ៉ាងណា កាលរូបមកប្រាកដ យើងក៏នឹងឱ្យជវនចិត្តកើតឡើងដោយប្រមាណសម្បដិច្ឆន្នចិត្តជាដើមនុ៎ះឯង យើងនឹងមិនឱ្យឈានកន្លងប្រមាណនោះកើតឡើង ដោយសេចក្តីតម្រេកជាដើមដូច្នោះ ។ ក្នុងសុតៈ និងមុតៈក៏នយនេះដូចគ្នា ។ ក៏បទថា មុតំ គប្បីជ្រាបគន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈនឹងដោយវិញ្ញាណ ដែលមានគន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈនោះជាអារម្មណ៍ ។ ក៏ក្នុងពាក្យថា វិញ្ញោតេ វិញ្ញាណមត្តំ

នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា **វិញ្ញាត** បានដល់អារម្មណ៍ដែលជាមនោទ្វារវ-ជ្ជនចិត្តច្បាស់ហើយ ហេតុនោះ ទើបឈ្មោះថា មានអាវជ្ជនចិត្តជាប្រមាណ ។ ក្នុងសេចក្តីនេះមានអធិប្បាយដូច្នេះថា អាវជ្ជនចិត្តរមែងមិនកំណត់ ជំទាស់ ឈ្លក់វង្វេងយ៉ាងណា យើងនឹងសម្រាកចិត្តដោយប្រមាណនៃអាវជ្ជនចិត្តប៉ុណ្ណោះ មិនព្រមឱ្យកើតឡើងដោយសេចក្តីតម្រេកជាដើម ដូច្នោះ ។ បទថា **ឯវញ្ហិ តេ ពាហិយ សិក្ខិតព្ពំ** សេចក្តីថា ពាហិយៈលោកគប្បីសិក្សាដោយបណ្តាយតាមសិក្ខាទាំង ៣ ដោយបដិទាយ៉ាងនេះ ។ ដូច្នេះ ព្រះមានព្រះភាគទើបទ្រង់ចែកអារម្មណ៍ដែលបែកផ្សេង ដោយប្រភេទអារម្មណ៍ ៦ព្រមដោយវិញ្ញាណកាយ ៦យ៉ាងសង្ខេប និងតាមសេចក្តីពេញចិត្តរបស់ពាហិយៈ ដោយវិបស្សនានៃកោដ្ឋាសៈទាំង ៤ មានរូបដែលខ្លួនឃើញហើយជាដើម ទើបទ្រង់សម្តែងញាតបរិញ្ញា និងតីរណបរិញ្ញាក្នុងសេចក្តីនោះដល់លោក ។ យ៉ាងណា ព្រោះថាក្នុងសេចក្តីនេះរូបារម្មណ៍ដែលជាឈ្មោះថា **ទិដ្ឋ** ព្រោះអត្ថថាដែលចក្ខុវិញ្ញាណគប្បីឃើញ ។ ចំណែកចក្ខុវិញ្ញាណព្រមដោយ

វិញ្ញាណដែលប្រព្រឹត្តទៅផ្លូវចក្ខុទ្វារនោះ ឈ្មោះថា ទិដ្ឋៈ ព្រោះអត្ថថា ឃើញ ។ សូម្បីទាំងពីរយ៉ាងនោះត្រឹមតែជាធម៌ដែលប្រព្រឹត្តទៅតាមបច្ច័យប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះអ្នកណា ៗនឹងធ្វើខ្លួនឯងឬឱ្យអ្នកដទៃធ្វើក៏មិនបានទេ ។ ពិតមែន ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា ចក្ខុវិញ្ញាណនោះឈ្មោះថា មិនទៀង ព្រោះមានហើយត្រឡប់ជាមិនមាន ឈ្មោះថា ជាទុក្ខ ព្រោះត្រូវកើតឡើងនិងរលត់ទៅបៀតបៀន ឈ្មោះថា ជាអនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាចហេតុនោះ ក្នុងសេចក្តីនោះ នឹងចាត់ជាឱកាសរបស់ធម៌មានសេចក្តីកំណត់ជាដើមនៃបណ្ឌិតពីទីណា ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងសុតៈជាដើម ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងបហានបរិញ្ញាព្រមទាំងហេតុខាងដើម ដល់បណ្ឌិតអ្នកតាំងនៅក្នុងញាតបរិញ្ញានិងតីរណបរិញ្ញា ទើបផ្តើមពាក្យមានជាដើមថា **យតោ ខោ តេ ពាហិយ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យតោ** បានដល់ ក្នុងកាលណាឬព្រោះហេតុអ្វី ។ បទថា **តេ** បានដល់ **តវ** ដល់លោក ។ បទថា **តតោ** បានដល់ ក្នុងកាលនោះ ឬព្រោះហេតុនោះ ។

បទថា តេន សេចក្តីថា ដោយរូបដែលលោកឃើញហើយជាដើម ឬដោយកិលេសមានរាគៈជាដើម ជាប់នឹងរូបដែលលោកឃើញហើយជាដើម ។ ត្រាស់ពាក្យនេះទុកថា ពាហិយៈ ក្នុងកាលណា ឬព្រោះហេតុអ្វី ត្រឹមតែរូបដែលលោកឃើញហើយជាដើម នឹងមានដល់អ្នកបដិបត្តិតាមវិធីដែលតថាគតពោលហើយ ក្នុងរូបដែលឃើញហើយជាដើម ដោយការយល់ដឹងសភាពដែលមិនវិបរិត្តក្នុងកាលនោះ ឬព្រោះហេតុនោះលោក នឹងមិនមានព្រមដោយកិលេសមានរាគៈជាដើម ដែលជាប់ដោយរូបដែលលោកឃើញហើយជាដើម លោកនឹងជាអ្នកមិនកំណត់ ជំទាស់ឬឈ្លក់វង្វេង ឬនឹងមិនជាអ្នកជាប់នឹងរូប ដែលលោកឃើញហើយជាដើមនោះ ព្រោះលះរាគៈជាដើមបានហើយ ។

បទថា តតោ ត្វំ ពាហិយ ន តត្ថ សេចក្តីថា ក្នុងកាលណា ឬព្រោះហេតុអ្វីលោកនឹងជាអ្នកតម្រេកព្រោះរាគៈនោះ ជំទាស់ព្រោះទោសៈ ឬឈ្លក់វង្វេង ព្រោះមោហៈក្នុងកាលនោះ ព្រោះហេតុនោះ លោកនឹងមិនមានក្នុងរូបដែលឃើញហើយជាដើម

នោះ ឬកាលរូបនោះដែលឃើញហើយ ឬសម្លេងនិងអារម្មណ៍ដែលដឹងហើយ លោកនឹងមិនជាអ្នកជំពាក់តាំងនៅដោយតណ្ហាមានះនិងទិដ្ឋិថា នុ៎ះរបស់យើង យើងជានោះ នុ៎ះជាខ្លួនរបស់យើង ។ ដោយពាក្យត្រឹមតែប៉ុណ្ណោះ ព្រះអង្គទ្រង់ឱ្យបហានបរិញ្ញាដល់ទីបំផុត ហើយសម្តែងនូវណាសវភូមិ ។ បទថា **តតោ តុំ ពាហិយ នេវិធ នហុរំ ន ឧភយមន្តរេន** សេចក្តីថា ពាហិយៈក្នុងកាលណា លោកមិនជាអ្នកជាប់នៅក្នុងរូបដែលឃើញហើយ ដោយកិលេសមានរាគៈជាដើមនោះ ក្នុងកាលនោះលោកនឹងមិនមានក្នុងលោកនេះ ក្នុងលោកមុខនិងក្នុងលោកទាំងពីរ ។ បទថា **ឯសេវន្តោទុក្ខស្ស** សេចក្តីថា ពិតមែន ក្នុងសេចក្តីនេះមានអធិប្បាយត្រឹមតែប៉ុណ្ណោះថា ក៏ទីបំផុតដែនកំណត់និងសេចក្តីវិល ៗនៃកិលេស ទុក្ខនិងវដ្តទុក្ខប៉ុណ្ណោះ ។ ក៏អាចារ្យពួកណាកាន់បទថា ឧភយមន្តរេន ហើយទើបប្រាថ្នាឈ្មោះចន្លោះភពពាក្យរបស់អាចារ្យទាំងនោះខុស ។ ពិតមែន ភាវៈចន្លោះភព លោកជំទាស់ហើយក្នុងព្រះអភិធម្មតែម្តង ។ ក៏ពាក្យថា អន្តរេន ជាការសម្តែងវិកប្បដែរ ។ ព្រោះហេតុនោះក្នុងសេចក្តីនេះ មានអធិ-

ប្បាយដូច្នេះថាក៏វិកប្បដទៃមិនមានក្នុងលោកនេះ លោកមុខ ឬ ទាំងពីរ ។

ម្យ៉ាងទៀត ពាក្យថា **អន្តរេន** ជាការសម្តែងសេចក្តីមិនមានវិកប្បដទៃ ។ ពាក្យនោះមានអធិប្បាយដូច្នេះថា ក៏ទីតាំងដទៃមិនមានក្នុងលោកនេះលោកមុខ ដល់ចន្លោះកពក៏មិនមាន ។

មួយទៀតអាចារ្យសូម្បីពួកណាកាន់យកដោយមិនឧបាយនៃប្រាជ្ញានូវអត្ថសុត្តបទទាំងនេះថា ***អន្តរាភវិនិព្វាយី*** និងជា ***សម្ភវេសី*** ហើយពោលថា កពដទៃនៅមានដូចគ្នា អាចារ្យសូម្បីទាំងនោះ ព្រោះត្រូវជំទាស់ថា អត្ថសុត្តបទដើមថា ឈ្មោះថា អន្តរាភវិនិព្វាយី ព្រោះមិនកន្លងកណ្តាលអាយុក្នុងភូមិនោះ មានអរិហាព្រហ្មជាដើម ហើយបរិនិព្វានដោយកិលេស បរិនិព្វានអស់ហើយ ព្រោះសម្រេចអរហត្តមគ្គក្នុងចន្លោះ មិនបានមានក្នុងកពដទៃទេ និងត្រូវជំទាស់អត្ថសុត្តបទក្រោយថា សត្វពួកណានឹងមិនជាយ៉ាងនោះ សត្វទាំងនោះនឹងជាអ្នកអស់អាសវៈ មានក្នុងកពមុន អធិប្បាយថា ឈ្មោះថា សម្ភវេសី ព្រោះស្វែងរកកពថ្មីខុស នឹងអន្តរាភវិនិព្វាយីបុគ្គលនោះនិងឈ្មោះថា សេក្ខបុថុជ្ជន ព្រោះមិន

ទាន់លះភវសញ្ញោជន:មិនបាន មួយទៀត បណ្តាកំណើត ៤ គឺ អណ្ឌជសត្វ និងជលាពុជសត្វមិនទាន់ធ្វើឆួត សំបកពង ឬសំបក ក្បាលពោះវៀននៅជរាបណា ក៏ឈ្មោះថា ភូត សំសេទជសត្វ និង ឧប្បាតិកសត្វ ឈ្មោះថា **សម្ភវេសី** ក្នុងខណ:ចិត្តដួងដំបូងតាំងពី ខណ:ចិត្តដួងទី ២ ទៅ ឈ្មោះថា ភូត មួយទៀត សត្វទាំងឡាយ កើតដោយឥរិយាបថណា មិនទាន់ដល់ឥរិយាបថដទៃចាកពីនោះ ជរាបណា ក៏នៅឈ្មោះថា **សម្ភវេសី** នៅជរាបនោះ តពីនោះចាត់ ជាភូត ព្រោះហេតុនោះ ទើបត្រូវជំទាស់ថា មិនមានដូច្នេះ ។ ក៏កាល មានអត្ថដែលបណ្តាយតាមបាលីត្រង់ ៗ និងជាប្រយោជន៍អ្វីណា ដោយអត្ថ ដែលកំណត់ដោយភពដទៃដែលមិនអាចនឹងពង្រីក បានដោយឯង ។ ក៏អាចារ្យពួកណាពោលប្រការយុតិថា និង យើញ្ញធម៌ ដែលប្រព្រឹត្តទៅដោយបន្តប្រាកដក្នុងចំណែកដទៃ មិន ជាប់ខ្សែ ប្រការនោះគប្បីប្រាកដសូម្បីក្នុងសេចក្តីបន្តនៃវិញ្ញាណ- កទ្រព្យ មានអង្គរជាដើមយ៉ាងណា សូម្បីក្នុងសេចក្តីបន្តនៃ សវិញ្ញាណកសង្ខារ ក៏គប្បីប្រាកដក្នុងចំណែកដទៃដោយមិនជាប់ ខ្សែដូច្នោះ មួយទៀត នយនេះ រមែងសមគួរក្នុងកាលមានភព

ជនៃ មិនមែនដោយប្រការដទៃទេ ។

ក៏ព្រោះហេតុនោះ លោកអ្នកមានឫទ្ធិសម្រេចការស្មាត់ជំនាញផ្លូវចិត្ត អធិដ្ឋានកាយបណ្តាយតាមចិត្ត គប្បីជំទាស់ប្រការយុតិ ដោយការចាកពីព្រហ្មលោកមកកាន់លោកនេះ ឬចាកពីលោកនេះទៅកាន់ព្រហ្មលោកឯណាៈជាមួយគ្នា បើប្រជ្ញាការប្រព្រឹត្តទៅរបស់ធម៌ក្នុងចំណែកដែលមិនជាប់ខ្សែក្នុងទីគ្រប់ស្ថានសោត សូម្បីលោកអ្នកមានឫទ្ធិទាំងឡាយនឹងគប្បីមាន ឥទ្ធិវិស័យជាអចិន្តេយ្យសោត ពាក្យនោះនឹងគប្បីស្មើគ្នា សូម្បីក្នុងទីនេះព្រោះព្រះបាលីថា **កម្មវិបាកោ អចិន្តេយ្យោ** ផល កម្ម ជាអចិន្តេយ្យ ព្រោះហេតុនោះ ពាក្យនោះត្រឹមតែជាមតិរបស់អាចារ្យទាំងនោះប៉ុណ្ណោះ ។ ព្រោះថា សភាវធម៌មានសភាពជាអចិន្តេយ្យ សភាវធម៌ទាំងនោះកន្លែងខ្លះ ទើបប្រាកដក្នុងចំណែកដែលជាប់ខ្សែដោយបច្ច័យ កន្លែងខ្លះប្រាកដក្នុងចំណែកដែលមិនជាប់ខ្សែ ។ ពិតយ៉ាងនោះវត្ថុដែលកើតឡើង ព្រោះបច្ច័យមានរូបប្រៀបផ្ទឹម និងសម្លេងជះត្រឡប់ជាដើម រមែងកើតប្រាកដក្នុងចំណែកមួយមានចំណែកនៃកញ្ចក់និងភ្នំជាដើមអំពីពីរបច្ច័យ មានសម្លេងគឹកកងខាងមុខជាដើម ។

ព្រោះហេតុនោះ ទើបមិនគប្បីបង្អោនវត្ថុទាំងអស់ក្នុងទីគ្រប់កន្លែង ។ ក្នុងសេចក្តីនេះមានសេចក្តីសង្ខេបប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ មានការពិចារណារឿងរបស់ភពដទៃដែលឱ្យសម្រេចឧទាហរណ៍ជាដើមរបស់រូបប្រៀបផ្ទឹម គប្បីមើលក្នុងដីកាកថាវត្ថុបកវណ៌ចុះ ។

ចំណែកអាចារ្យមួយពួកទៀតពោលថា បទថា ឥធ លោកពោលសំដៅយកកាមភព ។

បទថា ហុរំ ពោលសំដៅយកអរូបភព ។ បទថា ឧភយមន្តរេន ពោលសំដៅយករូបភព ។ អាចារ្យពួកដទៃពោលថា បទថា ឥធបានដល់អាយតនៈខាងក្នុង ។ ចិត្តនិងចេតសិក ។ ម្យ៉ាងទៀត អាចារ្យមួយពួកទៀតពោលថាបទថា ឥធ ពោលថាបច្ចុយធម៌ ។ បទថា ហុរំ ពោលថា បច្ចុប្បន្នធម៌ ធម៌កើតពីបច្ច័យ ។ បទថា ឧភយមន្តរេន ពោលថា បញ្ញត្តិធម៌ ។ ពាក្យនោះទាំងអស់មិនមានក្នុងអដ្ឋកថា ។ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គប្បីសង្គ្រោះដោយអាការ ៤ ដោយរូបដែលចក្ខុវិញ្ញាណឃើញហើយជាដើម

ដោយពាក្យមានជាដើមថា ឥដ្ឋេ ឥដ្ឋមត្តំ ភវិស្សតិ កាលចក្ខុ-
វិញ្ញាណឃើញរូប ក៏ត្រឹមតែឃើញយ៉ាងនេះ ក្នុងធម៌ទាំងនោះ
លោកសម្តែងដល់អសុភភាវនា ទុក្ខានុបស្សនា អនិច្চានុបស្សនា
និងអនត្តានុបស្សនាដោយប្រមុខគឺការវៀរចាកការប្រកាន់ថា ល្អ
ជាសុខ ជារបស់ទៀងនិងជាតួខ្លួនឯង ។ កាលពោលដោយសង្ខេប
លោកសំដៅយកវិបស្សនានីងវិសុទ្ធិខាងក្រោម ។ ដោយពាក្យថា
តតោ តំ ពាហិយ ន តេន នេះ ត្រាស់ដល់មគ្គ ព្រោះប្រាថ្នា
អាការៈកាត់កិលេសមានរាគៈជាដើមបានដាច់ខាត ។ ដោយពាក្យ
ថា តតោ តំ ពាហិយ ន តត្ថ នេះ ត្រាស់ដល់ផលចិត្ត ។
ដោយពាក្យថា នេវិធ ជាដើម គប្បីឃើញថា ត្រាស់ដល់អនុបា-
ទិសេសនិព្វានធាតុ ។ ព្រោះហេតុនោះ លោកទើបពោលថា អថ
ខោ ពាហិយ ។បេ។ អាសវេហិ ចិត្តំ វិមុច្ចតិ ដូច្នេះ ។
ចិត្តរបស់ពាហិយៈរួចផុតចាកពីអាសវៈ ដោយការសម្តែង
បទសង្ខេបនេះ ។ បទថា តាវហោទេវ បានដល់ ក្នុងខណៈនោះ
ឯងមិនមែនកាលដទៃ ។ បទថា អនុច្ចាធាយ ប្រែថា មិនប្រកាន់

មាំ ។ បទថា អាសវេហិ សេចក្តីថា ចាកកាមរាគៈជាដើម ដែលមានឈ្មោះថា **អាសវៈ** ព្រោះហូរទៅគឺ ប្រព្រឹត្តទៅចាកពីភវគ្គព្រហ្មជរាបដល់គោត្រភូ និងដូចជាគ្រឿងត្រាំមានសុរាជាដើម ដោយអត្ថថា ត្រាំទុកយូរ ។ បទថា វិមុច្ចតិ សេចក្តីថា រួចផុតគឺរលាស់ចេញ(កាមរាគៈជាដើម) សមុច្ឆេទវិមុត្តិនិងបដិបស្សទ្ធិវិមុត្តិ ។

ក៏ពាហិយៈនោះ លុះស្តាប់ធម៌របស់ព្រះសាស្តាប៉ុណ្ណោះ ជម្រះសីលឱ្យហ្មត់ចត់ អាស្រ័យសមាធិចិត្តដែលបានហើយ ផ្តើមវិបស្សនាជាទិព្វាភិញ្ញាបុគ្គលឱ្យអាសវៈទាំងពួងអស់ ទៅសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ខណៈនោះឯង ។ លោកកាត់កិលេសដូចក្រសែទឹកក្នុងសង្ឃរ ធ្វើទីបំផុតនៃវដ្តទុក្ខទ្រង់រាងកាយជាតិចុងក្រោយ ប្រព្រឹត្តទៅដោយបច្ចវេក្ខណញ្ញាណ ១៩ យ៉ាង ជាសត្តៀន ទើបទូលសូមបួសក្នុងសំណាក់ព្រះមានព្រះភាគ ត្រូវព្រះអង្គត្រាស់សួរថា លោកមានបាត្រនិងចីវរបរិបូរណ៌ ហើយឬ ពាហិយៈក្រាបទូលថាមិនទាន់បរិបូរណ៌ទេ ព្រះអង្គ លំដាប់នោះ ព្រះសាស្តាត្រាស់ចំពោះគេថា បើដូច្នោះលោកចូរស្វែងរក បាត្រនិងចីវរដូច្នេះ ហើយស្តេចយាងទៅ ។ ព្រោះហេតុនោះ ទើប

ពោលថា **អថ ខោ ភគវា ។បេ។ បក្កាមិ** ដូច្នេះ ។

បានឮថា ពាហិយៈនោះ កាលធ្វើសមណធម៌អស់ ២០,០០០ឆ្នាំ ក្នុងព្រះសាសនារបស់ព្រះកស្សបទសពល គិតថា ធម្មតាថា ភិក្ខុ កាលខ្លួនបានបច្ច័យហើយធ្វើទានតាមសមគួរមុនហើយទើបគួរ ដូច្នេះហើយមិនបានធ្វើការសង្គ្រោះដោយបាត្រ ឬចីវរសូម្បីដល់ភិក្ខុមួយរូបណា ។ ហេតុនោះលោកទើបមិនមានឧបនិស្សយឯហិភិក្ខុឧបសម្បទា ។ តែអាចារ្យពួកខ្លះពោលថា បានឮថា លោកជាចោរគ្រាជាក់ព្រះពុទ្ធ ចង់រឹតធ្វើតាំងខ្លួន ជាចោរក្នុងព្រៃឃើញព្រះបច្ចេកពុទ្ធមួយអង្គ ព្រោះសេចក្តីលោភក្នុងបាត្រ និងចីវរ ទើបប្រើឆ្កួបាញ់លោកហើយកាន់យកបាត្រនិងចីវរទៅ ដោយហេតុនោះ បាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ បព្វជ្ជាដោយឯហិភិក្ខុ ។ កាលលោកកំពុងត្រាច់ស្វែងរកបាត្រនិងចីវរ មេគោមួយរត់មកដោយរហ័សវាត់លោកឱ្យអស់ជីវិត ដែលលោកសំដៅពោលថា **អថ ខោ អចិរបក្កន្តស្ស ភគវតោ ពាហិយំ ទារុចីរិយំ គាវី តរុណវច្ឆាអភិបតិត្វា ជីវិតា វោរោបេសិ** គ្រានោះឯង កាលព្រះមានព្រះភាគស្តេចជៀសទៅមិនយូរ មេគោកូនខ្ចីវាត់

ពាហិយទារុចីរិយៈឱ្យដួលចុះអស់ជីវិត ។

បណ្តាបទទាំងនោះ បទថា **អចិរបក្កន្តិតស្សេ** ប្រែថា កាលព្រះមានព្រះភាគស្តេចយាងទៅមិនយូរ ។ បទថា **អាវីតរុណវច្ឆា** បានដល់នាងយក្ខិណីក្លែងជាមេគោកូនខ្ចី ។ បទថា **អធិបតិត្វា** បានដល់ សង្កត់សង្កិន គឺញាំញី ។

បទថា **ជីវិតា វោរោបេសិ** សេចក្តីថា មេគោនោះ បានកើតចិត្តបង្កៀរឡើងដោយហេតុត្រឹមតែបានឃើញ ព្រោះមានសេចក្តីអាឃាតក្នុងអត្តភាពមុន ទើបវាត់គេឱ្យអស់ជីវិត ។ ព្រះសាស្តាទ្រង់បាត្រហើយសោយព្រះក្រយាហារសម្រេចហើយជាមួយនឹងភិក្ខុសង្ឃច្រើនអង្គស្តេចចេញពីនគរ ទតព្រះនេត្រឃើញពាហិយៈធ្លាក់នៅត្រង់គំនរសម្រាម ទើបទ្រង់បញ្ជាភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយលោកចូរទៅទ្វារផ្ទះណាមួយ ជួយគ្នានាំគ្រែចេញមក ហើយនាំសពនេះចេញពីព្រះនគរ ធ្វើឈាបនកិច្ចសាងសពបទុក ។ ភិក្ខុទាំងឡាយបានធ្វើយ៉ាងនោះ ។ ក៏ឯគ្រាធ្វើហើយទៅកាន់វិហារគាល់ព្រះសាស្តា ក្រាបទូលកិច្ចដែលខ្លួនធ្វើហើយ ទើបទូលសួរដល់អភិសម្បរាយភពរបស់ពាហិយៈ ។

លំដាប់នោះព្រះមានព្រះភាគ ទើបត្រាស់ប្រាប់ដល់ភិក្ខុទាំងនោះថា ពាហិយៈបរិនិព្វានហើយ ។ ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ពាហិយទារុចីរិយៈ សម្រេចព្រះអរហត្តហើយឬ លោកសម្រេចព្រះអរហត្តទើណា ។ និងកាលត្រាស់ថា ក្នុងវេលាដែលស្តាប់ធម៌របស់តថាគត ពួកភិក្ខុ ទើបទូលសួរថា ក៏ព្រះអង្គសម្តែងធម៌ដល់លោកក្នុងវេលាណា ។ ព្រះសាស្តាត្រាស់ថា កាលតថាគតកំពុងបិណ្ឌបាទឈរក្នុងចន្លោះផ្លូវ ថ្ងៃនេះឯង ។ ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គឈរត្រាស់ក្នុងចន្លោះផ្លូវនោះ មានប្រមាណតិច គេធ្វើគុណវិសេសឱ្យកើតដោយហេតុត្រឹមតែប៉ុណ្ណោះបានយ៉ាងណា ។ ព្រះសាស្តាកាលទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ លោកកុំប្រមាណធម៌របស់តថាគតថាមានតិច ឬច្រើន សូម្បីគាថាតាំងច្រើនពាន់ តែមិនប្រកបដោយប្រយោជន៍ មិនប្រសើរឡើយ ចំណែកបទគាថា សូម្បីតែមួយបទដែលប្រកបដោយប្រយោជន៍ ប្រសើរជាង ទើបត្រាស់គាថានេះក្នុងធម្មបទថា ៖

សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា

ឯកំគាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើគាថាសូម្បីតាំងពាន់ តែប្រកបដោយបទដែលមិនជាប្រយោជន៍បទគាថាតែមួយដែលបុគ្គលស្តាប់ហើយ រមែងស្ងប់រម្ងាប់បានប្រសើរជាង ដូច្នេះ ។

កាលទ្រង់សម្តែងថា លោកជាអ្នកគួរដល់ការបូជាដោយហេតុត្រឹមតែបរិនិព្វានម្យ៉ាងក៏ទេ ដោយដែលពិតលោកជាអ្នកសមគួរដល់ការបូជា សូម្បីដោយការៈដែលប្រសើរជាងភិក្ខុសាវ័ករបស់ពាហិយៈ អ្នកជាទិប្បាភិញ្ញា ទើបទ្រង់ស្តាបនាលោកទុកក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសាវ័កអ្នកជាទិប្បាភិញ្ញា ពាហិយទារុចីរិយៈជាកំពូលលើស ដែលលោកសំដៅពោលទុកថា **អថ ខោ ភគវា សាវត្ថិយំបិណ្ឌាយ ចរិត្វា ។ បេ ។ បរិនិព្វុតោ ភិក្ខវេ ពាហិយោ ទារុចីរិយោ ដូច្នេះ ។**

បណ្តាបទទាំងនោះ បទថា **បច្ឆាភត្តំ** *បានដល់ ក្រោយចាកពីសោយព្រះក្រយាហារសម្រេចហើយ ។ បទថា* **បិណ្ឌរ កតបដិក្កន្តោ** *បានដល់ ស្តេចត្រឡប់ពីបិណ្ឌបាត ។ សូម្បីបទទាំងពីរ លោកក៏អធិប្បាយថា សោយព្រះក្រយាហារសម្រេច*

ហើយ ។ បទថា **នីហរិត្វា** សេចក្តីថា ឱ្យនាំចេញទៅខាងក្រៅព្រះនគរ ។ បទថា **ឈាបេថ** ប្រែថា ចូរធ្វើឈាបនកិច្ច ។ បទថា **ថូបញ្ចសុ្ស កោវេ** សេចក្តីថា និងចូរនាំសរីរធាតុរបស់ពាហិយៈមកសាងព្រះចេតិយទុក ។ ក្នុងសេចក្តីនោះ ព្រះអង្គត្រាស់ហេតុទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សព្រហ្មចារីរបស់ពួកអ្នកបរិនិព្វានហើយ ។ សេចក្តីនោះមានអធិប្បាយថា ពាហិយៈនោះបានប្រព្រឹត្តធម៌ គឺ-ខបដិបត្តិមានអធិសីលជាដើម ដែលពួកលោកប្រព្រឹត្តហើយ និងកំពុងប្រព្រឹត្ត ឈ្មោះថា ព្រហ្ម ព្រោះអត្ថថា ប្រសើរ បានប្រសើរស្មើនឹងពួកលោក ព្រោះហេតុនោះ ទើបឈ្មោះថា សព្រហ្មចារីបានធ្វើមរណកាលហើយ តាមប្រក្រតីនៃមរណកាល ព្រោះហេតុនោះ ទើបព្រមានព្រះភាគត្រាស់ថា ពួកលោកចូរយកគ្រែសែងសរីរៈរបស់ពាហិយៈទៅធ្វើឈាបនកិច្ច និងសាងសពូបរបស់លោកទុក ។ បទថា **តស្ស កា គតិ** សេចក្តីថា បណ្តាគតិទាំង ៥ មានគតិឧប្បត្តិភពជាយ៉ាងណា ។ មួយទៀត បទថា **គតិ** ប្រែថា កើត អធិប្បាយថា គតិរបស់លោកធ្លាក់ចុះយ៉ាងណា

ថា ជាព្រះអរិយៈឬបុថុជ្ជន ។ បទថា **អភិសម្បរាយោ** បានដល់លោកធ្វើមរណកាលហើយកើតក្នុងភពឬរលត់ក្នុងភព ។ ពោលអំពីអត្ថ ជាការទ្រង់ប្រកាសថា លោកបរិនិព្វានដោយការត្រាស់បង្គាប់ឱ្យសាងសព្វបទុកក៏ពិត តែទោះជាយ៉ាងនោះ ពួកភិក្ខុអ្នកមិនដឹងដោយហេតុត្រឹមតែប៉ុណ្ណោះក៏នឹងទូលសួរថា គតិរបស់លោកជាយ៉ាងណា ឬអ្នកប្រាថ្នានឹងឱ្យធ្វើឱ្យប្រាកដច្បាស់ ទើបទូលសួរព្រះមានព្រះភាគយ៉ាងនោះ ។

បទថា **បណ្ឌិតោ** សេចក្តីថា ឈ្មោះថា បណ្ឌិត ព្រោះទៅគឺដំណើរទៅ បានដល់ ប្រព្រឹត្តទៅដោយបញ្ញា ឈ្មោះថា បណ្ឌ ព្រោះសម្រេចដោយបញ្ញា ដែលសម្បយុត្តដោយអរហត្តមគ្គ ។ បទថា **បថុបាធិ** ប្រែថា ដំណើរទៅ ។ បទថា **ធម្មស្ស** បានដល់លោកុត្តរធម៌ ។ បទថា **អនុធម្មំ** បានដល់ និព្វាន បដិបទាមានសីលវិសុទ្ធិជាដើម ។ ម្យ៉ាងទៀត បទថា **ធម្មស្ស** បានដល់និព្វានធម៌ ។ បទថា **អនុធម្មំ** បានដល់ធម៌ គឺ អរិយមគ្គនិងអរិយផល ។ បទថា **ន ច មំ ធម្មាធិករណំ** សេចក្តីថា ក៏ហេតុ

នៃការសម្តែងធម៌ មិនធ្វើយើងឱ្យលំបាក ព្រោះបដិបត្តិតាមដែលទ្រង់ទូន្មាន ។ ពិតមែន លោកស្តាប់ធម៌ ឬ រៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្តា មិនបដិបត្តិធម៌តាមដែលទ្រង់ទូន្មាន ឈ្មោះថា ធ្វើព្រះសាស្តាឱ្យទ្រង់លំបាកដែលលោកសំដៅពោលទុកថា **វិហឹសសញ្ញី បគុណំ ន ភាសីធម្មំ បណីតំ មនុជេសុ** [ព្រោះតថាគតមានសេចក្តីសម្គាល់ក្នុងការលំបាក ទើបមិនពោលធម៌ឱ្យរហ័សរហួន ឱ្យប្រណីតក្នុងពួកជនក្នុងពួកព្រហ្ម ។

ម្យ៉ាងទៀត បទថា **ន ច មំ ធម្មាធិការណា** សេចក្តីថា នឹងជាហេតុនៃធម៌នេះក៏មិនមែន ។ លោកអធិប្បាយពាក្យនេះទុកថា ឈ្មោះថា មិនធ្វើយើងឱ្យលំបាក ព្រោះបដិបត្តិសាសនធម៌របស់តថាគតដោយល្អ ដែលជាហេតុនាំសព្វសត្វចេញចាកវដ្តទុក្ខ ។ ក៏អ្នកបដិបត្តិអាក្រក់ ទម្លាយសាសនធម៌ ឈ្មោះថា ឱ្យការប្រហារសរីរៈគឺ ធម៌របស់ព្រះសាស្តា ។ តែពាហិយៈនេះធ្វើសម្មាបដិបត្តិឱ្យដល់ទីបំផុតហើយបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ដោយហេតុនោះ ព្រះអង្គទើបត្រាស់ថា **បរិនិព្វុតោ ភិក្ខវេ**

ពាហិយោ ធារុចីរិយោ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបថា ព្រះពាហិយត្ថេរបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ និងថា គតិរបស់ព្រះខីណាស្រពតាំងឡាយបរិនិព្វានហើយដូច្នោះ ដែលមនុស្សចំនួនច្រើនដងបានលំបាក ដោយអាការតាំងពួង ។ បទថា* **ឥមំ** *ឧទានំ បានដល់ ទ្រង់បន្ទឺឧទានសម្តែងអានុភាពនៃការបរិនិព្វាន ដែលមិនប្រតិស្ថាននៅហើយនេះ ។*

បណ្តាបទទាំងនោះ បទថា **យត្ថ** *សេចក្តីថា* **អាបោធាតុ** *បឋវីធាតុ តេជោធាតុ និងវាយោធាតុមិនទាន់ចុះគឺ មិនប្រតិស្ថាននៅក្នុងនិព្វានធាតុណា ។ ព្រោះហេតុអ្វី, ព្រោះព្រះនិព្វានមានសភាវៈជាអសង្ខតធម៌ ។ ពិតមែន សូម្បីវត្ថុបន្តិចបន្តួចនៃសង្ខតធម៌ក៏មិនមានក្នុងព្រះនិព្វាននោះ ។ បទថា* **សុក្កា** *សេចក្តីថា ផ្កាយព្រះគ្រោះ និងផ្កាយនក្ខត្តឫក្សដែលបានឈ្មោះថា* **សុក្កៈ** *ព្រោះមានរស្មី មិនរុងរឿងគឺ មិនស្វាងស្វៃ ។ បទថា* **អាធិច្ចោ ឧប្ប-កាសតិ** *សេចក្តីថា សូម្បីព្រះអាទិត្យដែលអាចផ្សាយ ពន្លឺទៅ*

ខណៈតែមួយ៣ទ្វីបក៏មិនឮសម្លេងដោយអំណាចវស្សី ។ បទថា ន តត្ថ ចន្ទិមា ភាតិ សេចក្តីថា សូម្បីកាលព្រះអាទិត្យមានវស្សីខ្លាំងក្លា ចំណែកព្រះច័ន្ទមានវស្សីត្រជាក់គួរជ្រាប្ជា ក៏មិនរុងរឿង ព្រោះកម្ចាត់វស្សីដែលភ្លឺរបស់ខ្លួន ហេតុដែលមិនមានក្នុងព្រះនិព្វាននោះ ។ ព្រះអង្គត្រាស់ថា តមោ តត្ថ ន វិជ្ជតិ សេចក្តីងងឹតមិនមានក្នុងព្រះនិព្វាននោះ ដូច្នេះ ទ្រង់សំដៅយកសេចក្តីសង្ស័យថា បើព្រះច័ន្ទនិងព្រះអាទិត្យមិនមានក្នុងព្រះនិព្វាននោះសោត ព្រះនិព្វាននោះក៏នឹងគប្បីងងឹតតែម្តង ដូចលោកន្តរក ។ ពិតមែន រូបមានភាពងងឹតក៏មាន ។ បទថា យថា ច អត្តនា វេទិមុនិ មោនេន ព្រាហ្មណោ សេចក្តីថា ព្រាហ្មណ៍អ្នកជាព្រះអរិយសាវ័កដែលបាននាមថា មុនី ព្រោះប្រកបដោយមគ្គញ្ញាណដែលបានឈ្មោះថា មោនៈ ព្រោះដឹងសច្ចៈ ៤ និងប្រកបដោយមោនេយ្យបដិបទាផ្លវកាយជាដើម លះអាការមានការស្តាប់តាម ៗ គ្នាមកជាដើមដោយខ្លួនគឺ ខ្លួនឯង ក្នុងខណៈអរហត្តមគ្គ ក្នុងកាលណាគឺក្នុងវេលាណាដោយបដិវេធញ្ញាណ

ពោលគឺ មោនៈនោះឯងជីវិតគឺ ជីវិតប្បាស់នូវព្រះនិព្វានធ្វើឱ្យប្រចក្ស
ដល់ខ្លួន ។ បាឋៈថា អវេធិដូច្នេះក៏មាន ។ អធិប្បាយថា បានជីវិត
ទូទៅ ។ សព្ទថា អច ក្នុងពាក្យថា **អច រូបា អរូបា ច
សុខទុក្ខា បមុច្ចតិ** ប្រែថា ខាងក្រោយពីការត្រាស់ជីវិតព្រះនិព្វាន
នោះ ។ បទថា **រូបា** បានដល់ រូបធម៌ ។ ដោយបទថា **រូបា** នោះ
ជាការលោកកាន់យកបញ្ចវោការភព និងឯវោការភព ។ បទថា
អរូបា បានដល់ អរូបធម៌ ។ ដោយបទថា **អរូបា** នោះ ជាការ
លោកកាន់យកអរូបភព ព្រោះមិនលាយជាមួយនឹងរូបដែលហៅ
ថា ចតុវោការភពក៏មាន ។ បទថា **សុខទុក្ខា** សេចក្តីថា ចាកពី
វដ្តៈ សូម្បីដែលមានទាំងសុខទាំងទុក្ខដែលកើតឡើងក្នុងទីគ្រប់
កន្លែង ។

ម្យ៉ាងទៀត បទថា **រូបា** បានដល់ ព្រោះបដិសន្ធិក្នុងរូប-
លោក ។ បទថា **អរូបា** បានដល់ ព្រោះបដិសន្ធិក្នុងអរូបលោក ។
បទថា **សុខទុក្ខា** បានដល់ ព្រោះបដិសន្ធិក្នុងកាមាវចរភូមិ ។
ពិតមែន កាមភពមានទាំងសុខនិងទុក្ខលាយគ្នា ។ ព្រហ្មណ៍នោះ

រមែងរួចផុតពីវដ្ត សូម្បីទាំងអស់នោះដោយអស់តែម្តង ដោយប្រការដូច្នេះឯង ។

សូម្បីដោយគាថា ២ គាថា ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រះនិព្វានបែបនេះ ជាគតិនៃពាហិយៈអ្នកជាបុត្ររបស់តថាគត ។

បដិបទាដើម្បីធ្វើព្រះនិព្វានឱ្យជាក់ច្បាស់

បដិបទាដ៏ប្រសើរបំផុត ដែលអាចធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ថា បានដល់អរិយមគ្គប្រកបដោយអង្គ ៨ ប្រការដែលជាផ្លូវបរិសុទ្ធ ផ្លូវផង់សម្រាប់ធ្វើដំណើរទៅកាន់បរមសុខ ។ អរិយមគ្គប្រកបដោយអង្គ ៨ នោះគឺ ៖

១-សម្មាទិដ្ឋិ បញ្ញាយល់ឃើញប្រពៃ គឺឃើញអរិយ-សច្ច ៤ ។

២- សម្មាសង្កប្ប ត្រិះរិះប្រពៃ គឺត្រិះរិះនឹងចេញចាកកាម ១ ត្រិះរិះក្នុងការមិនជាហេតុឱ្យកើតព្យាបាទ ១ ត្រិះរិះក្នុងការមិនជាហេតុបៀតបៀន ១ ។

៣- សម្មាវាចា វាចាប្រពៃ គឺវៀរចាកវចីទុច្ចរិត ៤ ។

៤-សម្មាកម្មន្ត ការងារប្រពៃ គឺវៀរចាកកាយទុច្ចរិត ៣

៥-សម្មាអាជីវ ចិញ្ចឹមជីវិតប្រពៃ គឺវៀរចាកការចិញ្ចឹមជីវិតខុស ។

៦-សម្មាវាយាម ព្យាយាមប្រពៃ គឺព្យាយាមក្នុងទី ៤ ស្ថាន មានព្យាយាមការពារមិនឱ្យបាបអកុសលកើតឡើងក្នុងសន្តាន ជាដើម ។

៧-សម្មាសតិ រលឹកប្រពៃគឺរលឹកក្នុងសតិប្បដ្ឋាន ៤ ។

៨-សម្មាសមាធិ តាំងចិត្តខ្ជាប់ប្រពៃគឺចំរើនឈាន ៤ ។

និងមានព្រះសូត្រច្រើនទៀតដូចជា ៖

ឥទ្ធិសូត្រ

នៅក្នុងបិដកលេខ ៤៤ ទំព័រ ១៦៩ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី **[ធម៌ដែលអំណោយផលឱ្យសម្រេចនូវព្រះនិព្វាន]** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ដែលភិក្ខុបានចម្រើនបានធ្វើឱ្យរឿយ ៗហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់ដោយមិនសល់

ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីព្រះនិព្វាន ។ **ធម៌ ៥ យ៉ាង តើដូចម្តេច ។**

⇨. ម្នាលភិក្ខុទាំងឡាយភិក្ខុក្នុងសាសនានេះជាអ្នកឃើញរឿយ ៗថា មិនស្អាតក្នុងកាយ ១

⇨. សម្គាល់ថា គួរខ្ពើមក្នុងអាហារ ១

⇨. សម្គាល់ថាមិនគួរត្រេកត្រអាលក្នុងលោកទាំងពួង ១

⇨. ឃើញរឿយ ៗថា មិនទៀងក្នុងសង្ខារទាំងពួង ១

⇨.ទាំងមរណសញ្ញា ក៏ប្រាជកឡើងខាងក្នុងចិត្តរបស់ភិក្ខុនោះដោយប្រពៃ ១ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់មិនសល់ ដើម្បីរម្ងាប់ដើម្បីដឹងច្បាស់ ដើម្បីព្រះនិព្វាន ។

អាសវក្ខយសូត្រ

នៅក្នុងបិដកលេខ ៤៤ ទំព័រ ១៧០ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី [**ធម៌ដែលអំណោយផលឱ្យអស់អាសវៈ**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយធម៌៥យ៉ាងនេះដែលភិក្ខុបានចម្រើនបានធ្វើឱ្យរឿយ ៗហើយ រមែងប្រព្រឹត្តទៅដើម្បីអស់ទៅនូវអាសវៈទាំងឡាយ ។ **ធម៌ ៥យ៉ាង តើដូចម្តេច ។**

⇨. ម្នាលភិក្ខុទាំងឡាយភិក្ខុក្នុងសាសនានេះជាអ្នកឃើញរឿយ ៗថា មិនស្អាតក្នុងកាយ ១

⇨. សម្គាល់ថា គួរខ្ពើមក្នុងអាហារ ១

⇨. សម្គាល់ថាមិនគួរត្រេកត្រអាលក្នុងលោកទាំងពួង ១

⇨. ឃើញរឿយ ៗថា មិនទៀងក្នុងសង្ខារទាំងពួង ១

⇨. ទាំងមរណសញ្ញាក៏ប្រាជកឡើងខាងក្នុងចិត្តរបស់ភិក្ខុនោះដោយប្រពៃ ១ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ រមែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

បឆាឆសូត្រ

នៅក្នុងបិដកលេខ៤២ទំព័រ១៨៩ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី **[ធម៌ជាហេតុអស់អាសវៈ៤ប្រការ]** មានសេចក្តីថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការឈ្មោះ

ថា ជាអ្នកប្រតិបត្តិចំពោះអបណ្ណកបដិបទា **គឺប្រតិបត្តិមិនខុសផង** ភិក្ខុនោះឈ្មោះថា ជាអ្នកប្រាព្ធហេតុ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។ **ធម៌ ៤ ប្រការដូចម្តេចខ្លះ ។**

- ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ **ម្នាលភិក្ខុទាំងឡាយ** ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ១
- ពហុស្សុតោ ហោតិ ជាអ្នកចេះដឹងច្រើន ១
- អារទ្ធវីរិយោ ហោតិ ជាអ្នកមានព្យាយាមប្រារព្ធ ១
- បញ្ញវា ហោតិ ជាអ្នកមានប្រាជ្ញា ១ ។

ទិដ្ឋិសូត្រ

នៅក្នុងបិដកលេខ៤២ទំព័រ១៨៩ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី [**ធម៌ជាហេតុអស់អាសវៈ៤ប្រការ**]មានសេចក្តីថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថា ជាអ្នកប្រតិបត្តិនូវអបណ្ណកប្បដិបទា ភិក្ខុនោះឈ្មោះថា ជាអ្នកប្រាព្ធហេតុ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។ **ធម៌ ៤ ប្រការដូចម្តេចខ្លះ ។**

-នេក្ខម្មវិតក្កេន **គឺសេចក្តីត្រិះរិះក្នុងការចេញចាកកាម ១**

-អព្យាបាទវិតក្កេន សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ ១

-អវិហឹសាវិតក្កេន សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ១

-សម្មាធិដ្ឋិយា សេចក្តីយល់ឃើញត្រូវ ១ ។

➪. ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការនេះ ឈ្មោះថា **ជាអ្នកប្រតិបត្តិនូវអបណ្ណកប្បដិបទាផង** ភិក្ខុនោះឈ្មោះថា ជាអ្នកប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។

ឥទ្ធានន្ទិសូត្រ

នៅក្នុងបិដកលេខ ២៩ ទំព័រ ១៦ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី **[មគ្គប្រាកជនិងមិនប្រាកជ]** ដោយទៅតាទូលសួរថា ៖

ឋិតេ មជ្ឈន្តិ កាលេ សន្និសិន្នេសុ បក្ខិសុ

បលាតេវ មហារញ្ញេ តំ ភយំ បដិភាតិ មន្តិ ។

ក្នុងកាលកំពុងថ្ងៃត្រង់ ហ្វូងសត្វបក្សីទំសម្រាកព្រៃធំហាក់ដូចឮសូរព្រៃងងឹងខ្លាំង សូរសន្ធឹកនោះឯង ជាភ័យប្រាកដជាក់ស្តែងដល់ខ្ញុំព្រះអង្គ ។

ព្រះអង្គត្រាស់ថា ៖

ឋិតេ មជ្ឈន្តិ កាលេ សន្និសិន្នេសុ បក្ខិសុ

បលាតេវ មហារញ្ញេ សា រតី បដិភាតិ មន្តិ ។

ក្នុងកាលកំពុងថ្ងៃត្រង់ ហ្វូងសត្វបក្សីទំសម្រាកព្រៃធំហាក់ដូចឮសូរពពងខ្លាំង ការអង្គុយម្នាក់ឯងនោះ ជាសេចក្តីត្រេកអរប្រាកដដល់តថាគត ។

អដ្ឋកថា

បទថា **និទ្ទា** អធិប្បាយថា ព្រះមានព្រះភាគត្រាស់ថា ម្នាលអគ្គិវេសន: តថាគតរមែងជ្រាបក្នុងខែចុងគិម្ហន្តរដូវ(រដូវក្តៅ) តថាគតឈានចុះកាន់សេចក្តីលក់ ដូច្នេះ ព្រោះសេចក្តីលក់ដែលជាអព្យាកត:បែបនេះ ថីនមិទ្ធ:ទើបកើតឡើងក្នុងអកុសលចិត្តដែលជាសសង្ខារិករបស់ព្រះសេក្ខ: និងបុថុជ្ជនទាំងឡាយ ទាំងក្នុងចំណែកខាងដើមនិងខាងចុង ។

បទថា **តន្តិ** សេចក្តីវិលច្រអូស បានដល់ សេចក្តីវិលច្រអូសដែលសព្វមកកើតឡើងក្នុងវេលាហៅវាត់ និងត្រជាក់

ជាដើម ។ ពាក្យនេះ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "កតមាតញ្ចិ...បណ្តាធម៌ទាំងនោះសេចក្តីរំលឹកច្រអូស តើដូចម្តេច ។ ការច្រអូស អាការច្រអូស សេចក្តីច្រអូសនៃចិត្ត ការរំលឹក អាការរំលឹក ភាពនៃចិត្តរំលឹកណានេះថា សេចក្តីរំលឹកច្រអូស" ១ ដូច្នេះ ។

បទថា **កាយទិដ្ឋិតា** ប្រែថា សេចក្តីពត់កាយ ។

បទថា **អរតិ** បានដល់ សេចក្តីមិនពេញចិត្តក្នុងធម៌ផ្នែកកុសល ។

បទថា **ភត្តសម្មទោ** ប្រែថា សេចក្តីស្រវឹង ព្រោះអាហារ សេចក្តីលំបាកចិត្តព្រោះអាហារ ។ ក៏សេចក្តីពិស្តារនៃពាក្យទាំងនេះមកហើយក្នុងព្រះអភិធម្មដោយនយជាដើមថា **តត្ថ កតមា កាយទិដ្ឋិតា យា កាយស្ស កាយទិដ្ឋិតា** ប្រែថា បណ្តាពាក្យទាំងនោះ ពាក្យថា សេចក្តីពត់កាយ តើដូចម្តេច សេចក្តីទម្រេតនៃកាយ ... ណា ។

បទថា **ឯតេន** សេចក្តីថា សេចក្តីសៅហ្មងដោយឧបក្កិលេសមានសេចក្តីលក់ជាដើមនេះជាប្រាកដការណ៍ដែលហាមបាន ។

បទថា **ឧប្បកាសតិ** បានដល់ មិនបំភ្លឺពន្លឺ គឺមិនប្រាកដ ។

បទថា **អរិយមគ្គោ** បានដល់ លោកុត្តរមគ្គ ។

បទថា **ឥធ** ប្រែថា ក្នុងលោកនេះ ។

បទថា **បាណិនំ** ប្រែថា ដល់សត្វទាំងឡាយ ។

បទថា **វីរិយេន** បានដល់ សេចក្តីព្យាយាមដែលកើតព្រមនឹងមគ្គ ។

បទថា **នំ បណាមេត្វា** នេះ បានដល់ នាំកិលេសចេញហើយ ។

បទថា **អរិយមគ្គោ** បានដល់ លោកិយៈនិងលោកុត្តរមគ្គ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មគ្គវ័មង បរិសុទ្ធិ ព្រោះនាំឧបក្កិលេសចេញហើយដោយមគ្គនុ៎ះឯង ដូច្នេះឯង ។

សាវត្ថីសូត្រ

នៅក្នុងបិដកលេខ ៣៥ ទំព័រ ២៥០ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី **[ហេតុបច្ច័យដែលនាំឱ្យសត្វមិនបរិនិព្វាន និងបរិនិព្វាន]** ដោយទៅតាទូលសួរថា ៖

*សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារ-សាលា នាមហាវ័ន ជិតក្រុងសាវត្ថី ។ គ្រានោះ ឧគ្គគហបតី អ្នកក្រុងវេសាលី ចូលទៅគាល់ព្រះមានព្រះភាគ (លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះមានព្រះភាគ រួចឋិតនៅក្នុងទីសមគួរ) ។ លុះឧគ្គគហបតីអ្នកក្រុងសាវេលី អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឱ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ**មិនបរិនិព្វានក្នុងបច្ចុប្បន្ន** ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឱ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ**បរិនិព្វានក្នុងបច្ចុប្បន្ន** ។*

*ព្រះអង្គត្រាស់ថា ម្នាលគហបតី មានរូបដែលគប្បីដឹងដោយភ្នែក ជារូបគួរជ្រាប គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុត្រេកអរ សរ-សើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរូបនោះ កាលភិក្ខុនោះត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវរូបនោះក៏មាន សេចក្តីប្រកាន់មាំចំពោះរូបនោះក៏មាន ។ ម្នាលគហបតី **ភិក្ខុដែលមានសេចក្តីប្រកាន់មាំ មិនបរិនិព្វានទេ** ។*

ម្នាលគហបតី មានរសដែលគប្បីដឹងច្បាស់ដោយអណ្តាត (ជារសគួរជ្រាប គួរត្រេកអរជាទីគាប់ចិត្ត ជាទីស្រឡាញ់ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរបើភិក្ខុត្រេកអរសរសើរឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរសនោះ កាលភិក្ខុនោះ ត្រេកអរសរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវរូបនោះក៏មាន សេចក្តីប្រកាន់មាំចំពោះរសនោះក៏មាន ។ ម្នាលគហបតី **ភិក្ខុដែលមានសេចក្តីប្រកាន់មាំ មិនបរិនិព្វានទេ) ។**

ម្នាលគហបតី មានធម្មារម្មណ៍ដែលគប្បីដឹងច្បាស់ដោយចិត្ត ជាធម្មារម្មណ៍គួរជ្រាប គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះធម្មារម្មណ៍នោះ កាលភិក្ខុនោះ ត្រេកអរសរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះក៏មាន សេចក្តីប្រកាន់មាំចំពោះរសនោះក៏មាន ។ ម្នាលគហបតី **ភិក្ខុដែលមានសេចក្តីប្រកាន់មាំមិនបរិនិព្វានទេ) ។**

ម្នាលគហបតី មានរូបដែលគប្បីដឹងដោយភ្នែក ជារូបគួរ

ជ្រាប គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនបិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរូបនោះ កាលភិក្ខុនោះមិនត្រេកអរ មិនសរសើរ មិនបិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវរូបនោះក៏មិនមាន សេចក្តីប្រកាន់មាំចំពោះរូបនោះក៏មិនមាន ។ ម្នាលគហបតី **ភិក្ខុមិនមានសេចក្តីប្រកាន់មាំ រមែងបរិនិព្វាន ។**

ម្នាលគហបតី មានរសដែលគប្បីដឹងច្បាស់ដោយអណ្តាត (ជារសគួរជ្រាប គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនបិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរសនោះ កាលភិក្ខុនោះ មិនត្រេកអរ មិនសរសើរ មិនបិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវរូបនោះក៏មិនមាន សេចក្តីប្រកាន់មាំចំពោះរសនោះក៏មិនមាន ។ ម្នាលគហបតី **ភិក្ខុមិនមានសេចក្តីប្រកាន់មាំ រមែងបរិនិព្វាន**) ។

ម្នាលគហបតី មានធម្មារម្មណ៍ដែលគប្បីដឹងច្បាស់ដោយចិត្ត ជាធម្មារម្មណ៍គួរជ្រាប គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់

ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះធម្មារម្មណ៍នោះ កាលភិក្ខុនោះ មិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះក៏មិនមាន សេចក្តីប្រកាន់មាំចំពោះវិសោះក៏មិនមានដែរ ។ ម្នាលគហបតី **ភិក្ខុមិនមានសេចក្តីប្រកាន់មាំរមែងបរិនិព្វាន ។**

ម្នាលគហបតី នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឱ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ **មិនបរិព្វានក្នុងបច្ចុប្បន្ន ។**

សមាធិសូត្រ

នៅក្នុងបិដកលេខ ៤២ ទំព័រ ១០៨ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី(**សមាធិភាវនា៤យ៉ាង**) មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ សមាធិភាវនានេះមាន ៤ យ៉ាង ។ **សមាធិភាវនា ៤ យ៉ាង តើដូចម្តេចខ្លះ ។**

⇨. ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ១ ។

⇨. ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបាន

ចំរើនបានធ្វើឱ្យរឿយ ៗ ហើយប្រព្រឹត្តទៅដើម្បីបាននូវញាណ-ទស្សនៈ ១ ។

⇨. ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីសតិនិងសម្ប-ជញ្ញៈ ១ ។

⇨. ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអា-សវៈទាំងឡាយ ១ ។

សេចក្តីអធិប្បាយសមាធិភាវនាឆាំង ៥ យ៉ាង

ម្នាលភិក្ខុទាំងឡាយ **ចុះសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ១** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ជាអកុសលទាំងឡាយហើយ បានដល់នូវបឋមជ្ឈានប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ សម្រេចសម្រាន្តនៅ

ព្រោះរម្ងាប់នូវវិតក្កៈនឹងវិចារៈ ក៏ចូលទៅកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺ សទ្ធា មានសភាពជាចិត្តខ្ពស់ឯង មិនមានវិតក្កៈមិនមានវិចារៈមាន តែបីតិនឹងសុខកើតអំពីសមាធិគឺបឋមជ្ឈាន សម្រេចសម្រាន្តនៅ

ព្រោះប្រាសចាកបីតិផង ជាបុគ្គលព្រងើយកន្តើយផង មានសតិនឹងសម្បជញ្ញៈផង ទទួលយកនូវសុខដោយនាមកាយផង ព្រះអរិយទាំងឡាយតែងសរសើរនូវព្រះអរិយបុគ្គល ដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បាននូវតតិយ-ជ្ឈាននោះ សម្រេចសម្រាន្តនៅ ព្រោះលះបង់នូវសុខផង លះបង់នូវសេចក្តីទុក្ខផង មានសោមនស្សនឹងទោមនស្សអស់ទៅក្នុងកាលមុនផង ក៏បានដល់នូវចតុត្ថជ្ឈាន ជាធម្មតាមានអារម្មណ៍ មិនមែនជាទុក្ខ មិនមែនជាសុខគឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅ ។

➪.ម្នាលភិក្ខុទាំងឡាយនេះ ជាសមាធិភាវនាដែលបុគ្គលបានចំរើនបានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខ

ក្នុងបច្ចុប្បន្ន ។

ម្នាលភិក្ខុទាំងឡាយ **ចុះសមាធិភាវនាដែលបុគ្គលបានចំរើនបានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវអាលោសញ្ញា(សេចក្តីសម្គាល់ក្នុងពន្លឺ)អធិដ្ឋាននូវទិវាសញ្ញា(សេចក្តីសម្គាល់ក្នុងវេលាថ្ងៃ) គឺថាក្នុងវេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ ក្នុងវេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះដែរ ។ ភិក្ខុមានចិត្តស្ងប់ស្ងាត់មិនមានកិលេសជាគ្រឿងរួបរឹតតែងចំរើនចិត្តដែលប្រកបដោយពន្លឺដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ **នេះហៅថា សមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ ។**

⇨. ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីសតិនិងសម្បជញ្ញៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វេទនារបស់ភិក្ខុទាំងឡាយក្នុងសាសនានេះ តែងកើតឡើងប្រាកដ តែងឋិតនៅប្រាកដ

តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ សញ្ញា(ទាំងឡាយ តែងកើតឡើងប្រាកដ តែងឋិតនៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ) វិតក្កៈទាំងឡាយ តែងកើតឡើងប្រាកដ តែងឋិតនៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ **នេះជាសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយប្រព្រឹត្តទៅដើម្បីសតិនិងសម្បជញ្ញៈ ។**

⇨. ម្នាលភិក្ខុទាំងឡាយ **ចុះសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយ ៗនូវទីកើតនិងទីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ សេចក្តីអស់ទៅនៃរូបដូច្នេះ ទេវទនាដូច្នេះ ការកើតឡើងនៃវេទនាដូច្នេះ សេចក្តីអស់ទៅនៃវេទនាដូច្នេះ សញ្ញាដូច្នេះ ការកើតឡើងនៃសញ្ញាដូច្នេះ សេចក្តីអស់ទៅនៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ការកើតឡើងនៃសង្ខារទាំងឡាយដូច្នេះ សេចក្តីអស់ទៅនៃសង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តី

អស់ទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនាដែលបុគ្គលបានចំរើន បានធ្វើឱ្យរឿយ ៗហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ តថាគតបានពោលហើយក្នុងបុណ្ណប្បញ្ញា ត្រង់បរាយនវគ្គ ព្រោះសំដៅយកសមាធិភាវនានុ៎ះ ។

សច្ចាយ លោកស្មឹ បភោបភានិ
យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ
សន្តោ វិធូមោ អនិឃោ និរាសោ
អតារិ សោ ជាតិជរន្តិ ព្រូមីតិ ។

បុគ្គលបានពិចារណានូវសភាពធម៌ដ៏ថោកទាប នឹងឧត្តមក្នុងលោក សេចក្តីរំភើបចិត្តបន្តិចបន្តួចរបស់បុគ្គលណាមិនមានក្នុងលោក តថាគតពោលថា បុគ្គលនោះជាអ្នករម្ងាប់(នូវសឹកសត្រូវគឺកិលេស) មិនមានផ្សែងគឺសេចក្តីក្រោធ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ឈ្មោះថា ឆ្លងនូវជាតិនឹងជរាបាន ។

អដ្ឋកថា

បទថា ញាណទស្សនបដិលាភាយ សេចក្តីថា ដើម្បីបានញាណទស្សនៈ គឺទិព្វចក្ខុ ។

បទថា ឯវ សញ្ញំ អធិដ្ឋាតិ សេចក្តីថា រមែងតាំងសេចក្តីកំណត់សំដៅយ៉ាងនេះថា ពេលថ្ងៃ ដូច្នេះ ។

បទថា យថា ឯវ តថា រត្តិ សេចក្តីថា ធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញា សេចក្តីកំណត់សំដៅថា ភ្លឺស្វាងក្នុងវេលាថ្ងៃយ៉ាងណា រមែងធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញានោះ សូម្បីក្នុងវេលាយប់ក៏ដូច្នោះនុ៎ះឯង ។ សូម្បីក្នុងបទទីពីរក៏នយនេះដូចគ្នា ។

បទថាសប្បភាស បានដល់ មានភ្លឺស្វាងគឺទិព្វចក្ខុញាណ សូម្បីធ្វើចិត្តឱ្យដូចជាពន្លឺបានហើយក៏ពិត ទោះជាយ៉ាងនោះបណ្ឌិតក៏គប្បីកំណត់សេចក្តីយ៉ាងនេះ ។ តែក្នុងទីនេះលោកប្រាថ្នាពន្លឺ គឺទិព្វចក្ខុញាណ ។

បទថាវិទិតាបានដល់ប្រាកដហើយ ។ សួរថាយ៉ាងណាវេទនាដែលដឹងហើយឈ្មោះថា កើតឡើងដឹងហើយឈ្មោះថា

រលត់ទៅ ។ ឆ្លើយថា ភិក្ខុក្នុងធម្មវិន័យនេះ រមែងកំណត់វត្ថុ រមែងកំណត់អារម្មណ៍ ព្រោះភិក្ខុនោះកំណត់វត្ថុនិងអារម្មណ៍ហើយ វេទនាដែលដឹងយ៉ាងនេះថា វេទនាកើតឡើងយ៉ាងនេះ តាំងនៅយ៉ាងនេះ រលត់ទៅយ៉ាងនេះ ឈ្មោះថា កើតឡើងដែលដឹងហើយ ឈ្មោះថា តាំងនៅដែលដឹងហើយ ឈ្មោះថា រលត់ទៅ ។ សូម្បីក្នុងសញ្ញានិងវិតក្កក៏នយនេះដូចគ្នា ។

បទថា ឧភយព្ភយានុបស្សី ប្រែថា ពិចារណាឃើញការកើតនិងសេចក្តីសាបសូន្យ ។

បទថា ឥតិ រូបំ សេចក្តីថា រូបជាយ៉ាងនេះ រូបមានប៉ុណ្ណេះ រូបដទៃក្រៅនេះមិនមាន ។

បទថា ឥតិ រូបស្ស សមុទយោ សេចក្តីថា ការកើតឡើងនៃរូបជាយ៉ាងនេះ ។ ចំណែកបទថា អត្ថង្គមោ លោកសំដៅដល់សេចក្តីបែករលត់ ។ សូម្បីក្នុងវេទនាជាដើមក៏នយនេះដូចគ្នា ។

បទថា ឥទញ្ហិ បន មេ តំ ភិក្ខវេ សង្ឃាយ ភាសិតំ សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ពាក្យជាដើមថា សច្ចាយលោក-ស្មិំ ណាតថាគតពោលហើយក្នុងបុណ្ណកប្បញ្ហា (សោឡ-

សប្ប) ។ ពាក្យនោះតថាគតពោលសំដៅដល់ផលសមាបត្តិនេះ ។ ក្នុងបទទាំងនោះ បទថា សច្ឆាយ បានដល់ ដឹងដោយញាណ ។

បទថា លោកស្មិ បានដល់ ក្នុងលោកគឺ ពួកសត្វ ។

បទថា បភេទកានិ បានដល់ សេចក្តីក្រៃលែង និងខ្វះគឺខ្ពស់ និងក្រោម ។

បទថា ឥញ្ជិតំ បានដល់ សេចក្តីញាប់ញ័រ ។

បទថា ឧត្តិ កុហិញ្ចិលោកេ សេចក្តីថា សេចក្តីញាប់ញ័របស់អ្នកណាក្នុងទីណា ៗ មិនថានីវរណ៍ក្នុងខន្ធមួយក្តីអាយតនៈមួយក្តី ធាតុមួយក្តីអារម្មណ៍មួយក្តី រមែងមិនមានក្នុងលោក ។

បទថា សន្តោ សេចក្តីថា អ្នកនោះជាអ្នកស្ងប់ ព្រោះស្ងប់កិលេសដែលជាសត្រូវ ។

បទថា វិធូមោ សេចក្តីថា ជាអ្នកប្រាសចាកកិលេសដូចផ្សែង ព្រោះផ្សែងគឺសេចក្តីក្រោធ ។

ក្នុងព្រះសូត្រនេះ ត្រាស់ដល់ឯកគ្គតាក្នុងមគ្គ ក្នុងគាថាត្រាស់ផលសមាបត្តិតែម្យ៉ាងដោយប្រការដូច្នេះឯង ។

ទីឃារម្ភោទិវគ្គទី ៧

នៅក្នុងបិដកលេខ ៤០ ទំព័រ ២២ ព្រះមានព្រះភាគជាម្ចាស់ទ្រង់គ្រាស់អំពី [**ហេតុកើតឡើងនិងវិនាសសាបសូន្យទៅនៃកុសលធម៌ និងអកុសលធម៌**] ដោយមានសេចក្តីថា ៖

សូត្រទី ១

៦. ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើង ឱ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើង ឱ្យសាបសូន្យទៅក្តី **ដូចការផ្គងព្យាយាមនេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលផ្គងព្យាយាមហើយ ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

បទថា **វីរិយារម្ភោ** បានដល់ សេចក្តីផ្ដួចផ្ដើម សេចក្តីព្យាយាម គឺសម្មប្បធាន ដែលមានកិច្ច ៤ អធិប្បាយថា ភាពជាអ្នកមានសេចក្តីព្យាយាមដែលផ្គងទុកបរិបូណ៌ ។

សូត្រទី ២

๒. ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង ឱ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងឱ្យសាបសូន្យទៅក្តី **ដូចសេចក្តីប្រាថ្នាច្រើននេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសេចក្តីប្រាថ្នាច្រើន ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

បទថា **មហិច្ឆតា** បានដល់ សេចក្តីប្រាថ្នាធំ ដែលលោកពោលទុកថា ក្នុងធម៌ទាំងនោះ សេចក្តីប្រាថ្នាច្រើនដូចម្តេច ? សេចក្តីប្រាថ្នាក្រៃលែង ។ ឡើងទៅនៃភិក្ខុដែលមិនសន្តោសដោយចីវរបិណ្ឌបាត សេនាសនៈ ភេសជ្ជៈបរិក្ខារដែលជាថ្នាំដល់អ្នកជម្ងឺក្រៃលែងឡើង ។ឬដោយកាមគុណ ៥ សេចក្តីប្រាថ្នាភាពជាអ្នកមានសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាច្រើន សេចក្តីតម្រេក សេចក្តីតម្រេកច្រើននៃចិត្តណា នេះហៅថា **មហិច្ឆតា** ភាពជាអ្នកប្រាថ្នាធំ ។

សូត្រទី ៣

๖. ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើងឱ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងឱ្យសាបសូន្យទៅក្តី **ដូចសេចក្តីប្រាថ្នាតិចនេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសេចក្តីប្រាថ្នាតិច ពួកកុសលធម៌ដែលមិនទាន់កើតឡើងក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

បទថា **អប្បិច្ឆតា** បានដល់ សេចក្តីមិនលោភ ។ បទថា **អប្បិច្ឆស្ស** បានដល់ អ្នកមិនប្រាថ្នា ក៏ក្នុងទីនេះ ព្យញ្ជនៈបីដូចជានៅមានចំណែកសេសសល់គឺនៅមានខ្លះ ៗ ចំណែកអត្ថមិនមានចំណែកសេសសល់ គឺមិនប្រាថ្នាឡើយ ។ ពិតមែន បុគ្គលនោះលោកហៅថា អ្នកមានសេចក្តីប្រាថ្នាតិច ព្រោះភាវៈដែលមានសេចក្តីប្រាថ្នាមានប្រមាណតិចក៏ទេ តែលោកហៅថា មានសេចក្តី

ប្រាថ្នាតិច (ប្រាថ្នាតិច) ព្រោះមិនមានសេចក្តីប្រាថ្នា គឺភាវៈដែលមិនមានសេចក្តីលោភ ដែលគេត្រូវសេពវើយ ។ន៎ុះឯង ។

ម្យ៉ាងទៀត ក្នុងទីនេះ គប្បីជ្រាបសេចក្តីផ្សេងគ្នាដូច្នេះថា **អតិច្ឆតា** សេចក្តីប្រាថ្នាក្រៃពេក **បាបិច្ឆតា** សេចក្តីប្រាថ្នាលាមក **មហិច្ឆតា** សេចក្តីប្រាថ្នាធំ ។ បណ្តាបទទាំង ៣ យ៉ាងនោះ គឺសេចក្តីមិនឆ្អែតក្នុងលាភរបស់ខ្លួន នៅប្រាថ្នាក្នុងលាភរបស់អ្នកដទៃ ឈ្មោះថា សេចក្តីប្រាថ្នាក្រៃពេក ។ សម្រាប់អ្នកប្រកបដោយសេចក្តីប្រាថ្នាក្រៃពេកនោះ សូម្បីនំឆ្ងិនក្នុងភាជនៈមួយ គេដាក់ទុកក្នុងភាជនៈរបស់ខ្លួន រមែងប្រាកដដូចនំដែលឆ្ងិនមិនល្អ និងដូចមានតិចជាងនំនោះន៎ុះឯង គេដាក់ក្នុងភាជនៈរបស់អ្នកដទៃប្រាកដដូចឆ្ងិនល្អនិងដូចមានច្រើន ។ សេចក្តីប្រកាសគុណដែលមិនមាននៅនិងសេចក្តីមិនស្គាល់ប្រមាណក្នុងការទទួលឈ្មោះថាសេចក្តីប្រាថ្នាលាមក ។ សេចក្តីប្រាថ្នាលាមកសូម្បីនោះ មកហើយក្នុងអភិធម្ម ដោយនយមានជាដើមថា អ្នកខ្វះក្នុងលោកនេះជាអ្នកមិនមានសទ្ធា រមែងប្រាថ្នាថា សូមជនចូរស្គាល់យើងថា ជាអ្នកមានសទ្ធា ។ បុគ្គលដែលប្រកបដោយសេចក្តីប្រាថ្នាលាមកនោះ រមែង

តាំងនៅក្នុងសេចក្តីបញ្ឆោតលួងលោម ។ ចំណែកសេចក្តីប្រកាសគុណដែលមាន និងភាពជាអ្នកមិនស្គាល់ប្រមាណក្នុងការទទួលឈ្មោះថា ជាអ្នកមានសេចក្តីជ្រះថ្លាច្រើន ។ សេចក្តីជ្រះថ្លាច្រើនសូម្បីនោះ ក៏មកហើយដោយនយនេះដូចគ្នាថា អ្នកខ្លះក្នុងលោកនេះ ជាអ្នកមានសទ្ធា រមែងជ្រះថ្លាថា ជនចូរដឹងយើងថា ជាអ្នកមានសទ្ធា ។ អ្នកខ្លះជាអ្នកមានសីល រមែងជ្រះថ្លាថា សូមជនដឹងយើងថា ជាអ្នកមានសីល ។ បុគ្គលដែលប្រកបដោយសេចក្តីជ្រះថ្លាច្រើននោះជាអ្នកឆ្អែតបានលំបាក ។ សូម្បីមាតាអ្នកបង្កើតក៏មិនអាចនឹងតោងចិត្តគេបាន ។

ដោយហេតុនោះ ទើបលោកពោលពាក្យនេះទុកថា ៖

អគ្គិក្ខន្ធោ សមុទ្ទោ ច មហិច្ឆោ ចាបិ បុគ្គលោ
សកដេនបច្ចយេ ឧត្តុ តយោបេតេ អតប្បិយា ។

គំនរភ្លើង ១ សមុទ្រ ១ អ្នកជ្រះថ្លាច្រើន ១ ឱ្យបច្ច័យទាំងរនេះ ទាំង ៣ ប្រភេទនោះ មិនចេះឆ្អែត ។

ចំណែកការលាក់បាំងគុណដែលមាន ភាពជាអ្នកស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ភាពជាអ្នកជ្រះថ្លាតិច ។ បុគ្គល

ដែលប្រកបដោយភាពជាអ្នកប្រាថ្នាតិចនោះ រមែងប្រាថ្នាថា សូមជនចូរដឹងយើងថា ជាអ្នកមានសទ្ធា ជាអ្នកមានសីល ចូលចិត្តភាពស្ងប់ស្ងាត់ ជាពហុស្សូត ជាអ្នកប្រារព្ធសេចក្តីព្យាយាម ដល់ព្រមដោយសមាធិ ជាអ្នកមានបញ្ញា ជាព្រះខីណាស្រព រមែងមិនប្រាថ្នាថា សូមជនចូរដឹងយើងថា ជាព្រះខីណាស្រព ដូចព្រះមជ្ឈន្តិកត្ថេរដូច្នោះ ។

បានឮថា ព្រះថេរៈ បានជាព្រះខីណាស្រព ។ តែបាត្រនិងចីវររបស់លោក មានតម្លៃត្រឹមតែមួយបាទប៉ុណ្ណោះ ។ លោកបានជាព្រះសង្ឃត្ថេរ ក្នុងថ្ងៃឆ្លងវិហាររបស់ព្រះបាទធម្មាសោករាជ ។ គ្រានោះមនុស្សទាំងឡាយឃើញថា "លោកជាមនុស្សក្រខ្សត់" ទើបពោលថា "លោកម្ចាស់សូមលោកនៅខាងក្រៅមួយភ្លេចចុះ" ។ ព្រះថេរៈគិតថា "ជាព្រះខីណាស្រពដូចយើង មិនធ្វើការសង្គ្រោះព្រះរាជាអ្នកណាហ្ន៎នឹងធ្វើបាន"ដូច្នេះហើយទើបមុជចុះក្នុងផែនដី ហើយងើបឡើងទទួលដុំបាយដែលគេលើកឡើង ដើម្បីព្រះសង្ឃ-ត្ថេរបានល្មម ។ លោកជាព្រះខីណាស្រព រមែងមិនប្រាថ្នាថា សូម

មនុស្សដឹងយើងថា ជាព្រះខីណាស្រព ដោយប្រការយ៉ាងនេះ ។

ក៏ឯភិក្ខុដែលប្រាថ្នាតិចយ៉ាងនេះ រមែងធ្វើលាភដែលនៅមិនកើតឡើងឱ្យកើតឡើងឬរមែងធ្វើលាភដែលកើតឡើងហើយឱ្យរឹងរឹទ្ធិតែកើតឡើងទៀត រមែងធ្វើចិត្តរបស់ទាយក ឱ្យត្រេកអរ ។ ភិក្ខុនោះ រមែងកាន់យកតែបន្តិច ព្រោះខ្លួនជាអ្នកប្រាថ្នាតិចដោយប្រការណា ។ មនុស្សទាំងឡាយជ្រះថ្លាក្នុងវត្តរបស់លោក ដោយប្រការនោះ ។ រមែងថ្វាយជាច្រើន ។

សេចក្តីដូចគ្នាសូម្បីដទៃទៀត មាន ៤ ប្រការគឺ ប្រាថ្នាតិចក្នុងបច្ចយ ១ ប្រាថ្នាតិចក្នុងធុតង្គ ១ ប្រាថ្នាតិចក្នុងបរិយត្តិ ១ ប្រាថ្នាតិចក្នុងអធិគម ១, បណ្តាសេចក្តីប្រាថ្នាតិច ៤ ប្រការនោះ សេចក្តីប្រាថ្នាតិចក្នុងបច្ចយ ៤ ឈ្មោះថា ប្រាថ្នាតិចក្នុងបច្ចយ ។ ភិក្ខុនោះ រមែងដឹងកម្លាំងរបស់ទាយក រមែងដឹងកម្លាំងរបស់ទេយ្យធម៌ រមែងដឹងកម្លាំងរបស់ខ្លួន បើទេយ្យធម៌មានច្រើន ទាយកប្រាថ្នានឹងថ្វាយតិច រមែងទទួលតិច ដោយអំណាចទាយក, ទេយ្យធម៌មានតិច ទាយកប្រាថ្នានឹងថ្វាយច្រើន រមែងទទួលតែបន្តិច ដោយ

អំណាចទេយ្យធម៌ សូម្បីទេយ្យធម៌មានច្រើន ទាំងទាយកក៏ជ្រះថ្លា នឹងថ្វាយច្រើន រមែងជឿនកម្លាំងរបស់ខ្លួនហើយទទួលតែល្មមប្រមាណ ។ ភិក្ខុដែលមិនជ្រះថ្លា នឹងឱ្យអ្នកដទៃជឿនការសមាទានធុតង្គជាក់ច្បាស់ គប្បីជ្រាបរឿងទាំងនេះ ជាឧទាហរណ៍ ៖

ឮថា ព្រះមហាកុមារកស្សបត្ថេរ អ្នកកាន់សោសានិកង្គធុតង្គ នៅក្នុងព្រៃជាទីចោលសាកសពមកហួតជល់អស់ ៦០ ឆ្នាំ ។ ភិក្ខុដទៃសូម្បីតែមួយរូប ក៏មិនជឿន ដោយហេតុនោះឯង ទើបលោកពោលថា ៖

យើងនៅក្នុងព្រៃជាទីចោលសាកសពមកអស់ ៦០ឆ្នាំជាប់តគ្នា ភិក្ខុដែលជាសម្ងាញ់ក៏មិនជឿយើង ឱ! យើងជាកំពូលរបស់អ្នកកាន់ការនៅព្រៃជាទីចោលសាកសពជាវត្ត ។

ព្រះថេរៈពីរូបបងប្អូននឹងគ្នា នៅក្នុងចេតិយបព៌ត ។ ប្អូនប្រុសកាន់យកកំណាត់អំពៅដែលឧបដ្ឋាកបញ្ជូនទៅថ្វាយ ទៅកាន់សំណាក់របស់បងប្រុសពោលថា លោកម្ចាស់និមន្តឆាន់ចុះ ។ វេលាដែលនិយាយជាវេលាដែលព្រះថេរៈធ្វើកត្តកិច្ចសម្រេចហើយ

ខ្ញុំមាត់ ។ ព្រះថេរៈពោលថា កុំឡើយ ។ បុនប្រុសពោលថា លោកម្ចាស់កាន់ឯកាសនិកង្គធុតង្គឬ ។ ព្រះថេរៈពោលថា យកកំណាត់អំពៅមកចុះ សូម្បីកាន់ឯកាសនិកង្គធុតង្គជល់ ៥០ ឆ្នាំ ក៏នៅបិទបាំងធុតង្គទុក ធ្វើការឆាន់ហើយ ខ្ញុំមាត់ អធិដ្ឋានធុតង្គថ្មីហើយទៅ ។ ក៏ភិក្ខុណា ដូចជាព្រះសាកេតិសរ្វត្ថេរ មិនប្រាថ្នានឹងឱ្យអ្នកដទៃដឹងថា ខ្លួនជាពហុស្សុតភិក្ខុឈ្មោះថា ជាអ្នកប្រាថ្នាតិចក្នុងបរិយត្តិ ។

បានឮថា ព្រះថេរៈគិតថា វេលាមិនមាន ទើបមិនធ្វើឱកាសក្នុងខុទ្ទេស (រៀន) និងបរិបុច្ឆា (សាកសួរ) ត្រូវសព្រហ្មចារីសួរថា លោកម្ចាស់កាលណាលោកនឹងបានមរណខណៈ (វេលាស្លាប់) ទើបលះបង់ពួក ទៅកាន់កណិការវាលិកសមុទវិហារ ។ ក្នុងទីនោះ លោកមានឧបការៈដល់ព្រះថេរៈ ព្រះនវកៈនិងព្រះមជ្ឈិមៈ រហូតខាងក្នុងវស្សា បវារណាក្នុងថ្ងៃឧបោសថ ។ ឱ្យអ្នកជនបទភ្ញាក់ផ្អើលដោយធម្មីកថាហើយក៏ទៅ ។

ចំណែកភិក្ខុណា ជាព្រះអរិយៈថ្នាក់ណាមួយមានព្រះសោ-

តាបន្នជាដើមមិនប្រាថ្នាឱ្យអ្នកដទៃដឹងថា ខ្លួនជាព្រះសោតាបន្ន ជាដើម ភិក្ខុនេះ ឈ្មោះថា អ្នកមានសេចក្តីប្រាថ្នាតិចក្នុងអធិគម ដូចកុលបុត្រ ៣ នាក់ ដូចជាងឆ្នាំងឈ្មោះថា ឃដីការៈ។ ក៏ក្នុងអត្ថនេះ សូម្បីបុថុជ្ជនអ្នកសិក្សាប្រកបដោយសេចក្តីមិនលោភ មានកំលាំងខ្លាំងក្លា បានអាសេវនៈហើយ ក៏គប្បីជ្រាបថា ជាអ្នកប្រាថ្នាតិច ។

សូត្រទី ៤

៦. ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង ឱ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងឱ្យសាបសូន្យទៅក្តី **ដូចសេចក្តីមិនសន្តោសនេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមិនមានសេចក្តីសន្តោស ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

បទថា **អសន្តុដ្ឋិតា** បានដល់ សេចក្តីលោភពោលគឺ សេចក្តីមិនសន្តោសដែលកើតដល់បុគ្គលដែលសេពគប់រក ចូលទៅអង្គុយជិត បុគ្គលដែលមិនសន្តោស ។

សូត្រទី ៥

[๖] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ๑ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើងឱ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងឱ្យសាបសូន្យទៅក្តី **ដូចការធ្វើទុកក្នុងចិត្តខុសទំនងនេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តខុសទំនង ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

បទថា **សន្តុដ្ឋិតា** បានដល់ សេចក្តីសន្តោសពោលគឺ សេចក្តីមិនលោភដែលកើតដល់បុគ្គលដែលសេពគប់រក ចូលទៅអង្គុយជិត

បុគ្គលដែលសន្តោស ។

បទថា សន្តុដ្ឋស្ស បានដល់ អ្នកប្រកបដោយសេចក្តីសន្តោសក្នុងបច្ច័យតាមមានតាមបាន សេចក្តីសន្តោសនោះមាន ១២ យ៉ាងគឺ សេចក្តីសន្តោសក្នុងចីវរ ៣ យ៉ាង គឺ **យថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ។** ក្នុងបិណ្ឌបាតជាដើមក៏ដូចគ្នា ។ សន្តោសនោះមានការពណ៌នាតាមប្រភេទដូចតទៅនេះ ។

⇨. ភិក្ខុក្នុងព្រះសាសនានេះបានចីវរល្អ ឬមិនល្អក៏ដោយ លោកញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយចីវរនុ៎ះឯង មិនប្រាថ្នាចីវរដទៃដែលបានក៏មិនទទួលនេះឈ្មោះថា **យថាលាភសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។**

⇨. ចំណែកភិក្ខុមួយរូបទៀត ជាអ្នកមានកម្លាំងទុព្វលភាពតាមប្រក្រតី ឬត្រូវអាពាធនិងជរាគ្របសង្កត់ ដណ្តប់ចីវរធ្ងន់ រមែងលំបាក លោកផ្លាស់ចីវរនោះនឹងភិក្ខុដែលពេញចិត្តល្មមគ្នា ដល់នឹងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយចីវរស្រាល ក៏ជាអ្នកសន្តោស ។

នេះឈ្មោះថា **យថាពលសន្តោសក្នុងចីវរបស់ភិក្ខុនោះ ។**

➪. ភិក្ខុមួយរូបទៀត ជាអ្នកបានបច្ច័យដែលប្រណីត បានសំពត់ចីវរថ្មីដែលនាំមកអំពីក្រុងសោមារជាដើម យ៉ាងណាមួយដែលមានតម្លៃក៏ឬថាបានចីវរជាច្រើនឱ្យទៅដោយគិតថាចីវរនេះសមគួរដល់ព្រះថេរៈដែលបួសយូរ នេះសមគួរដល់ភិក្ខុដែលជាពហុស្សូតេ នេះសមគួរដល់ភិក្ខុដែលមានជម្ងឺ នេះសមគួរដល់ភិក្ខុដែលមានលាភតិច ហើយទើបជ្រើសរើសយកចីវរចាស់របស់ភិក្ខុទាំងនោះ ឬសំពត់ប្រឡាក់ពីគំនរសម្រាមជាដើម (ឬសំពត់ធ្លាក់តាមវាលផ្សារ) ធ្វើជាសង្ឃាដិដោយសំពត់ទាំងនោះ សូម្បីគ្រងសំពត់នោះឯង ក៏ជាអ្នកសន្តោសតែម្តង នេះឈ្មោះថា **យថាសារុប្បសន្តោសរបស់ភិក្ខុនោះ ។**

➪. មួយទៀត ភិក្ខុក្នុងសាសនានេះបានបិណ្ឌបាតដែលសៅហ្មងឬប្រណីត លោកវៃមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះឯង មិនប្រាថ្នាបិណ្ឌបាតដទៃ ដល់បានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោសរបស់ភិក្ខុនោះ ។**

⇨. មួយទៀត ភិក្ខុណាបានបិណ្ឌបាតដែលទាស់ចំពោះប្រក្រតីរបស់ខ្លួនឬទាស់ដល់ជម្ងឺបរិភោគហើយមិនជាសុខលោកឱ្យបិណ្ឌបាតនោះដល់ភិក្ខុដែលពេញចិត្តគ្នា ហើយឆាន់ភោជនដែលជាសប្បាយអំពីដៃរបស់ភិក្ខុនោះ សូម្បីធ្វើសមណធម៌ក៏ជាអ្នកសន្តោសពិតនេះឈ្មោះថា **យថាពលសន្តោសក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។**

⇨. ភិក្ខុមួយរូបទៀត បានបិណ្ឌបាតដែលប្រណីតជាច្រើន លោកថ្វាយបិណ្ឌបាតនោះ ដល់ព្រះថេរៈអ្នកបួសយូរ អ្នកជាពហុស្សូត អ្នកមានលាភតិចនិងអ្នកឈឺ មានន័យដូចចីវរ សូម្បីឆាន់អាហារអំពីសំណាក់របស់ភិក្ខុទាំងនោះ ឬអាហារដែលលាយគ្នា ព្រោះត្រាច់បិណ្ឌបាតមក ក៏ឈ្មោះថា ជាអ្នកសន្តោសពិត ។ នេះ**ឈ្មោះថា យថាសារុប្បសន្តោសក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។**

⇨. មួយទៀត ភិក្ខុក្នុងព្រះសាសនានេះ បានសេនាសនៈដែលគួរពេញចិត្ត ឬមិនគួរពេញចិត្ត ។ លោកមិនឱ្យសេចក្តីសប្បាយចិត្តកើតឡើង មិនឱ្យសេចក្តីទាស់ចិត្តកើតឡើង រមែង

ត្រេកអរដោយសេនាសនៈ តាមដែលបានប៉ុណ្ណោះ ដោយហោច
ទៅសូម្បីកម្រាលធ្វើដោយស្មៅ នេះឈ្មោះថា **យថាលាភសន្តោ-
សក្នុងសេនាសនៈរបស់ភិក្ខុនោះ ។**

⇨. មួយទៀត ភិក្ខុបានសេនាសនៈ តាមលំដាប់ប្រក្រតី
របស់ខ្លួន ឬតាមលំដាប់អ្នកឈឺរបស់ខ្លួន ដែលលោកនៅមិនមាន
សេចក្តីជាសុខ លោកឱ្យសេនាសនៈនោះដល់ភិក្ខុដែលពេញចិត្តគ្នា
សូម្បីនឹងនៅក្នុងសេនាសនៈដែលជាសប្បាយ ក៏ជាអ្នកសន្តោស
ពិត នេះឈ្មោះថា **យថាពលសន្តោសក្នុងសេនាសនៈរបស់ភិក្ខុ
នោះ ។**

⇨. ភិក្ខុមួយរូបទៀត មានបុណ្យច្រើន បានសេនាសនៈ
ដែលប្រណីត ជាច្រើនមានល្អាងមណ្ឌប និងផ្ទះកំពូលជាដើម
លោកថ្វាយសេនាសនៈ សូម្បីទាំងនោះដល់ព្រះថេរៈអ្នកបួសយូរ
អ្នកពហុស្សូត អ្នកមានលាភតិច និងអ្នកជាឈឺដូចដូចចីវរ ដល់
នឹងនៅក្នុងទីណាមួយ ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា **យថា-
សារុប្បសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។**

⇨. សូម្បីភិក្ខុណា ពិចារណាថា ធម្មតាថា សេនាសនៈដែលល្អទីបំផុត ជាទីតាំងនៃសេចក្តីប្រមាទ ចីនមិទ្ធៈ រមែងគ្របសង្កត់សម្រាប់អ្នកអង្គុយក្នុងទីនោះ សម្រាប់អ្នកដេកលក់ហើយក្លាក់ឡើង វិតក្កៈដ៏លាមក រមែងប្រាកដ លោកមិនទទួលសេនាសនៈដូច្នោះសូម្បីដែលមកដល់ហើយលោកបដិសេធសេនាសនៈនោះ ដល់នឹងនៅក្នុងទីវាល មាននៅគល់ឈើជាដើមក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា **យថាសារុប្បសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។**

⇨. មួយទៀត ភិក្ខុក្នុងព្រះសាសនានេះ បានភេសជ្ជៈដែលសៅហ្មង ឬប្រណីត លោករមែងត្រេកអរដោយភេសជ្ជៈ ដែលខ្លួនបាននោះឯង មិនប្រាថ្នាភេសជ្ជដទៃដល់នឹងបានក៏មិនទទួល នេះឈ្មោះថា**យថាលាភសន្តោសក្នុងគិលានបច្ច័យរបស់ភិក្ខុនោះ ។**

⇨.មួយទៀត ភិក្ខុណាត្រូវការប្រេងត្រឡប់បានទឹកអំពៅសូម្បីលោកថ្វាយទឹកអំពៅនោះ ដល់ភិក្ខុដែលពេញចិត្ត កាន់យកប្រេងពីដៃរបស់ភិក្ខុដែលពេញចិត្តនោះ ឬស្វែងរកប្រេងដទៃ ធ្វើ

ភេសជ្ជៈ ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា **យថាពលសន្តោស** ក្នុងគិលានបច្ចយរបស់ភិក្ខុនោះ ភិក្ខុមួយរូបទៀតមានបុណ្យច្រើន បានភេសជ្ជៈដែលប្រណីត មានប្រែងនិងទឹកអំពៅជាដើមជាច្រើន លោកថ្វាយភេសជ្ជៈនោះដល់ព្រះថេរៈអ្នកបួសយូរ ជាពហុស្សុត អ្នកមានលាភតិចនិងអ្នកជម្ងឺ មានន័យដូចចីវរ សូម្បីនឹងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយភេសជ្ជៈយ៉ាងណាមួយ ដែលគេនាំមកហើយដើម្បីភិក្ខុទាំងនោះ ក៏ជាអ្នកសន្តោសពិត ។

➪. មួយទៀត ភិក្ខុណាកាលគេដាក់សម័ត្រាំទឹកមូត្រចុះក្នុងភាជនៈមួយ ដាក់វត្ថុមានរសឆ្ងាញ់ ៤ ចុះក្នុងភាជនៈមួយ ហើយនិយាយថាលោកម្ចាស់លោកត្រូវការវត្ថុណា ចូរកាន់យកវត្ថុនោះទៅចុះ បើរោគរបស់លោកស្ងប់ទៅ សូម្បីដោយភេសជ្ជៈទាំងពីរប្រភេទណាមួយសោតកាលបើជូនថ្នោះឈ្មោះថា សម័ត្រាំទឹកមូត្រ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ទើបបដិសេធរបស់មានរសឆ្ងាញ់ ៤ យ៉ាង សូម្បីធ្វើភេសជ្ជៈដោយសម័ត្រាំទឹកមូត្រក៏ជាអ្នកសន្តោសយ៉ាងក្រៃលែងនេះឈ្មោះថា **យថា**-

សារុប្បសន្តោសក្នុងគិលានបច្ចយរបស់ភិក្ខុនោះ ។

ក៏បណ្តាសន្តោស ៣ ក្នុងបច្ចយចំពោះនីមួយ ៗ នេះ **យថាសារុប្បសន្តោស** ជាសន្តោសដ៏ប្រសើរ ។

សូត្រទី ៦

៦. ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើង ឱ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងឱ្យសាបសូន្យទៅក្តី **ដូចការធ្វើទុកក្នុងចិត្តត្រូវទំនងនេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តត្រូវទំនង ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងជុនផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

អយោនិសោមនសិការ និងយោនិសោមនសិការ មានលក្ខណៈដូចពោលហើយក្នុងកាលមុន និងពាក្យដែលនៅសល់ក្នុងសូត្រនេះមានសេចក្តីងាយយល់ទាំងអស់នោះ ដូច្នេះឯង ។

សូត្រទី ៨

๘. ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង ឱ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងឱ្យសាបសូន្យទៅក្តី **ដូចអសម្បជញ្ញៈ (សេចក្តីមិនដឹងខ្លួន)នេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានអសម្បជញ្ញៈ ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

បទថា អសម្បជញ្ញំ បានដល់ សេចក្តីមិនដឹងខ្លួន ។

ពាក្យថា អសម្បជញ្ញំ នេះ ជាឈ្មោះរបស់មោហៈ ។

បទថា អសម្បជានស្ស បានដល់ អ្នកមិនដឹងខ្លួន គឺ អ្នកវង្វេង ។

សូត្រទី ៩

[៦]. ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើង ឱ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងឱ្យសាបសូន្យទៅក្តី **ដូចសម្បជញ្ញៈ (សេចក្តីដឹងខ្លួន)នេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសម្បជញ្ញៈ ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

បទថា សម្បជញ្ញំ បានដល់ សេចក្តីដឹងខ្លួន ។ បទថា សម្បជញ្ញំ នេះជាឈ្មោះនៃបញ្ញា ។ បទថា សម្បជានស្ស បានដល់ អ្នកដឹងខ្លួន ។

សូត្រទី ១០

[៦]. ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើត

ឡើង ឱ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងឱ្យសាបសូន្យទៅក្តី **ដូចជាការមានបាបមិត្តនេះសោះឡើយ** ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានបាបមិត្ត ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

អដ្ឋកថា

បទថា **បាបមិត្តតា** សេចក្តីថា មិត្តអាក្រក់គឺលាមក មានដល់អ្នកណាអ្នកនោះឈ្មោះថា មានមិត្តអាក្រក់ ។ ការមានមិត្តអាក្រក់ ឈ្មោះថា **បាបមិត្តតា** ភាពជាអ្នកមានមិត្តអាក្រក់ ។ ពាក្យថា **បាបមិត្តតា** នេះ ជាឈ្មោះរបស់ខន្ធ ៤ ដែលប្រព្រឹត្តទៅដោយអាការនោះ ។ សមដូចពាក្យដែលលោកពោលទុកថា ក្នុងបណ្តាធម៌ទាំងនោះ ភាពជាអ្នកមានមិត្តអាក្រក់តើដូចម្តេច ? បុគ្គលសេពគប់អ្នកណា ជាអ្នកមិនមានសទ្ធា ជាអ្នកទ្រុស្តសីល ជាអ្នកមានសុខតិច ជាអ្នកកំណាញ់ ជាអ្នកគ្មានបញ្ញា ការសេព ការអាស្រ័យសេព ការគប់រក ការសេពគប់ សេចក្តីភក្តី សេចក្តីចូរ

ស្រឡាញ់បុគ្គលទាំងនោះ សេចក្តីមានបុគ្គលទាំងនោះជាសម្លាញ់ នេះ ហៅថា ភាពជាអ្នកមានមិត្តអាក្រក់ ។

វិធីបដិបត្តិធ្វើព្រះនិព្វានឱ្យជាក់ច្បាស់

បើយើងនិយាយអំពីវិធីបដិបត្តិ ដើម្បីធ្វើព្រះនិព្វានឱ្យជាក់ច្បាស់នោះ មានច្រើនប្រការ ដែលជាវិធីលះបង់កិលេសបន្តិចម្តងៗ នោះគឺ **អាសវៈ**លះបានដោយការឃើញ, **អាសវៈ**លះបានដោយការសង្រួម, **អាសវៈ**លះបានដោយការពិចារណា, **អាសវៈ**លះបានដោយការអត់ធន, **អាសវៈ**លះបានដោយការវៀរចាក, **អាសវៈ**លះបានដោយការបន្ទោបង់, **អាសវៈ**លះបានដោយការអប់រំ ។ តែបើសរុបឱ្យខ្លី ៗនោះមាន ២គឺ ៖

ក-ការចម្រើនភាវនា

ភាវនាសូត្រ

នៅក្នុងបិដកលេខ ៤៧ ទំព័រ ២២៦ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី [**ភិក្ខុព្យាយាមចំរើនភាវនារមែងរួចផុតទុក្ខ**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយភិក្ខុដែលមិនប្រកបរឿយ ៗនូវភាវនា បើទុកជាមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំជួច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ មិនផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះហេតុមិនប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុមិនបានចំរើន ។ ព្រោះមិនបានចំរើនអ្វី ។ ព្រោះតែមិនបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចពងមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងឡាយនោះ ដែលមេមាន់មិនក្រាបដោយប្រពៃ មិនបានធ្វើឱ្យកក់ក្តៅដោយប្រពៃ មិនបានឱ្យជាប់ក្លិនវាជាមេដោយប្រពៃ បើទុកជាមេមាន់នោះ មានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ កូនទាំងឡាយរបស់អញគប្បីទម្លាយសំបកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួល ដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះ មិនអាចនឹងទម្លាយនូវសម្បកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ

ហើយញាស់ចេញមកដោយស្រួលបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពងទាំងនោះដែលមេមាន់មិនបានក្រាបដោយប្រពៃ មិនបានធ្វើឱ្យកក់ក្តៅដោយប្រពៃ មិនបានឱ្យជាប់ក្លិនវាជាមេដោយប្រពៃ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនប្រកបរឿយ ៗនូវភាវនា បើទុកជាមានសេចក្តីប្រាថ្នាយ៉ាងនេះ ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់ តែចិត្តរបស់ភិក្ខុនោះមិនផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះ តែមិនបានប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែមិនបានចំរើន ។ ព្រោះមិនបានចំរើនអ្វី ។ ព្រោះតែមិនបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយ ៗ នូវភាវនា បើទុកជាមិនមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ

ព្រោះមិនប្រកាន់មាំ ដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចំរើន ។ ព្រោះបានចំរើនអ្វី ។ ព្រោះតែបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចពងមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងឡាយនោះ ដែលមេមាន់ក្រាបដោយប្រពៃហើយ បានធ្វើឱ្យកក់ក្តៅដោយប្រពៃហើយ បានឱ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ មេមាន់នោះ បើទុកជាមិនមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ កូនទាំងឡាយរបស់អញគប្បីទម្លាយសំបកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួល ដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះ អាចទម្លាយទូវសម្បកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលបាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពងទាំងនោះដែលមេមាន់ បានក្រាបដោយប្រពៃបានធ្វើឱ្យកក់ក្តៅដោយប្រពៃហើយ បាន

ឱ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយ ៗ នូវភាវនា បើទុកជាមិនមានសេចក្តីប្រាថ្នាយ៉ាងនេះ ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញ គប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនបានប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចំរើន ។ ព្រោះបានចំរើនអ្វី ។ ព្រោះតែបានចំរើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ក៏យ៉ាងនោះដែរ ។

➪.ម្នាលភិក្ខុទាំងឡាយ ដូចជាងឈើឬកូនសិស្សរបស់ជាងឈើ យកម្រាមដៃនឹងមេជើង ទៅចាប់កាន់ត្រង់មៀនកាំបិតប៉ុន្តែជាងឈើ ឬកូនសិស្សរបស់ជាងឈើនោះមិនដឹងយ៉ាងនេះថា មៀនកាំបិតរបស់អញនោះ ថ្ងៃនេះសឹកអស់ប៉ុណ្ណេះ ឬថ្ងៃមិញសឹកអស់ប៉ុណ្ណេះ ឬក៏មិញម្ល៉ៃសឹកអស់ប៉ុណ្ណេះ ដូច្នេះទេ លុះដល់មៀនកាំបិតនោះសឹកអស់ហើយ ទើបបានដឹងថា អស់

ហើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រកបរឿយ ៗនូវភាវនា បើទុកជាមិនបានដឹងយ៉ាងនេះថា ថ្ងៃនេះ អាសវៈទាំងឡាយរបស់អាត្មាអញអស់ទៅប៉ុណ្ណេះ ឬក៏ម្សៀលម្ង៉ៃសឹកអស់ប៉ុណ្ណេះ ដូច្នេះទេ លុះអាសវៈនោះអស់ទៅ ទើបបានដឹងថាអស់ហើយ ក៏យ៉ាងនោះដែរ ។

➪. ម្នាលភិក្ខុទាំងឡាយ ដូចជាសំពៅសមុទ្រដែលគេចងនឹងផ្តៅ ត្រាំនៅក្នុងទឹកអស់ ៦ ខែ ដល់ហេមន្តរដូវគេលើកឡើងជាក់លើកគោក ចំណងទាំងឡាយត្រូវខ្យល់នឹងកំដៅថ្ងៃ ចំណងទាំងនោះ ត្រូវភ្លៀង បង្អុរស្រោច ក៏ខូចពុកផុយបានដោយងាយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុបានក្របកឬរឿយ ៗ នូវភាវនា សំយោជនៈទាំងឡាយ ក៏សូន្យរម្ងាប់បានដោយងាយ ក៏យ៉ាងនោះដែរ ។

អដ្ឋកថា

បទថា អនន្តរយុត្តស្ស សេចក្តីថា កាលភិក្ខុមិនប្រកបរឿយ ៗនិងមិនប្រកបទូទៅហើយនៅ ។

ពាក្យថា សេយ្យថាបិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ

សេចក្តីថា ព្រះមានព្រះភាគត្រាស់ឧបមានេះទុកជាពីរប្រការគឺ ធម៌ខ្មៅនិងធម៌ស (អកុសលនិងកុសល)បណ្តាឧបមា ២ យ៉ាងនោះ ឧបមានៃធម៌ចំណែកខ្មៅ មិនធ្វើប្រយោជន៍ឱ្យសម្រេចធម៌ចំណែកសធ្វើប្រយោជន៍ឱ្យសម្រេច ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបប្រយោជន៍ ដោយឧបមានៃធម៌ចំណែកសនុ៎ះឯង ។ សព្ទថា សេយ្យថា ជានិបាតប្រើក្នុងអត្ថនៃឧបមា ។ សព្ទថា អបិ ជានិបាតប្រើក្នុងអត្ថនៃសម្ភាវនៈលើកតម្កើង ព្រះមានព្រះភាគទ្រង់សម្តែងថា សេយ្យាថាបិ ឆាម ភិក្ខវេ ដូច្នេះ ។ ក៏ក្នុងព្រះបាលីនេះថា កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា មានវិនិច្ឆ័យដូចតទៅនេះ ៖

មេមាន់នឹងមានពងខ្វះ ឬលើសដោយប្រការដែលត្រាស់ទុកហើយក៏ពិត ទោះជាយ៉ាងនោះ ព្រះអង្គក៏ត្រាស់ពាក្យនេះទុក ក៏ដើម្បីឱ្យមានរបៀបរៀបរយ ។

បទថា តានស្ស កាតព្ពធជា តានិ អស្ស សេចក្តីថា ពងទាំងនោះគប្បីមាន ។

បទថា កុក្កុដិយា សម្មា អធិសយិតានិ សេចក្តីថា កាល

មាន់ដែលជាមេនោះ ទម្រេតស្លាបដេកក្រាបលើពងទាំងនោះ ឈ្មោះថា ក្រាបហើយដោយប្រពៃ ។

បទថា **សម្មាបរិសេចិតានិ** សេចក្តីថាកាលមេមាន់មានរដូវតាមកំណត់វេលា ឈ្មោះថា ឱ្យឆ្អិនហើយដោយជុំវិញដោយល្អ អធិប្បាយថា ធ្វើឱ្យកំដៅហើយ ។

បទថា **សម្មា បរិភាវិតានិ** សេចក្តីថា អប់ដោយជុំវិញដោយល្អតាមកំណត់វេលា អធិប្បាយថា ពងបានទទួលចំហាយក្តៅរបស់មេមាន់ ។

ពាក្យថា **កិញ្ចាបិតស្សា កុក្កុដិយា** សេចក្តីថា ព្រោះមេមាន់នោះ ធ្វើសេចក្តីមិនប្រមាទ ដោយការធ្វើកិរិយា ៣ យ៉ាងនេះ មិនគប្បីកើតសេចក្តីប្រាថ្នាយ៉ាងនោះពិត ។

បទថា **អថខោ សព្ភាវ តេ** សេចក្តីថាដែលពិតកូនមាន់ទាំងនោះគួរចោះចេញទៅដោយសួស្តី ដោយន័យដូចពោលហើយក៏ព្រោះហេតុដែលពងទាំងនោះ មេមាន់នោះឱ្យសេចក្តីឃុំគ្រងដោយអាការ៣ យ៉ាងនេះ ទើបមិនស្អុយ ពងទាំងនោះនៅមាន

ជ័រស្រស់ ជ័រស្រស់នោះតោងកោះសម្បកពង់ខ្លះ ចុងក្រចកជើង និងចុងនៃចំពុះជារបស់រឹង កូនមាន់ទាំងឡាយ រមែងទម្លាយបានដោយខ្លួនឯង ព្រោះសម្បកពង់ជារបស់ខ្លះពន្លឺខាងក្រៅ រមែងប្រាកដចូលដល់ខាងក្នុង ដូច្នោះ កូនមាន់ទាំងនោះនាំគ្នាគិតថា ពួកយើងដេកកោងដៃកោងជើង នៅក្នុងទីចង្អៀតជាវេលាយូរណាស់ហើយហ្ន៎ ក៏ពន្លឺនេះ រមែងប្រាកដនៅខាងក្រៅឥឡូវនេះ ពួកយើងនឹងនៅជាសុខក្នុងទីនេះ ដូច្នេះប្រាថ្នានឹងចេញទៅ ទើបយកជើងចក់សម្បកពង់អើតកចេញទៅខាងក្រៅ ។ បន្ទាប់ពីនោះ សម្បកពង់នោះ ក៏បែកចេញជា ២ បន្ទះ ។ កូនមាន់ទាំងនោះ រលាស់**ស្លាបបណ្តើរបញ្ចេញសំឡេង** ស្រែកចេញទៅតាមសមគួរដល់វេលានោះ និងកាលចេញទៅក៏បានដើរធ្វើខេត្តស្រុកឱ្យល្អ

ពាក្យថា **ឯវមេវ ខោ** នេះ លោកពោលទុកជាពាក្យឧបមា ។ ពាក្យនោះគប្បីជ្រាបបានក៏ព្រោះប្រៀបធៀបសេចក្តីយ៉ាងនេះ ។ ពិតមែនការធ្វើអនុបស្សនា ៣ ថា បញ្ចខន្ធមិនទៀង ជាទុក្ខ ជាអនត្តា ក្នុងចិត្តសន្តានរបស់ខ្លួន របស់ភិក្ខុនេះ ប្រៀបដូចការធ្វើកិរិយា ៣ មានការដេកក្រាបពង់ជាដើមរបស់មេមាន់នោះការមិន

ធ្វើវិបស្សនាញាណឱ្យសាបសូន្យ ដោយការធ្វើវិបស្សនា ៣ ឱ្យដល់ព្រមរបស់ភិក្ខុដែលប្រកបរឿយ ៗ នូវវិបស្សនា ប្រៀបដូចសេចក្តីមិនស្អុយនៃពង ដោយការធ្វើកិរិយា ៣ យ៉ាង ឱ្យដល់ព្រមរបស់មេមាន់ ។ ការតោងជាវស្ថិតគឺ សេចក្តីប្រាថ្នាដែលជាប់តាមទៅកាន់ភព ៣ ដោយការធ្វើអនុបស្សនា ៣ ឱ្យដល់ព្រមរបស់ភិក្ខុនោះ ប្រៀបដូចជាវស្ថិតស្រស់នៃពងទាំងឡាយ ដោយការធ្វើកិរិយា ៣ របស់មេមាន់នោះ ។ សេចក្តីថា ដែលសម្បកពងគឺអវិជ្ជា ព្រោះការធ្វើអនុបស្សនា ៣ ឱ្យដល់ព្រមរបស់ភិក្ខុ ប្រៀបដូចសេចក្តីដែលសម្បកពង ដោយការធ្វើកិរិយា ៣ របស់មេមាន់ សេចក្តីនូវវិបស្សនាញាណ ជាធម្មជាតិខ្លាំងក្លា ថ្លាផូរផង់និងខ្លាក្លារឹង ព្រោះការធ្វើអនុបស្សនា ៣ ឱ្យដល់ព្រមរបស់ភិក្ខុ ប្រៀបដូចក្រចកនឹងចំពុះរបស់កូនមាន់ ជារបស់រឹង ដោយការធ្វើកិរិយា ៣ របស់មេមាន់ កាលវេលាដែលផ្ចាស់ប្តូរ កាលចម្រើនធំធាត់កាលដែលកាន់យកនូវបន្ទប់នៃវិបស្សនាញាណ ដោយធ្វើអនុបស្សនា ៣ ឱ្យដល់ព្រមរបស់ភិក្ខុ ប្រៀបដូចការដែលកូនមាន់ផ្ចាស់ប្តូរទៅដោយការធ្វើកិរិយា ៣ របស់មេមាន់ កាលដែលភិក្ខុនោះ ញ៉ាំងចិត្តកាន់យកនូវបន្ទប់នៃវិបស្សនាញាណ អង្គុយលើអាសនៈ

គ្រាច់ទៅនៅ ។ រមែងអស់ហើយទើបគ្រាច់ទៅបានឧតុសប្បាយ ភោជនសប្បាយ បុគ្គលសប្បាយ ធម្មសប្បាយ ដែលសមគួរដល់វិបស្សនាញាណនោះ អង្គុយលើអាសនៈតែមួយចម្រើនវិបស្សនា ទម្លាយសម្បកពងគឺអវិជ្ជា ដោយអរហត្តមគ្គដែលខ្លួនសម្រេចហើយដោយលំដាប់ ហើយត្រដាងស្ងាបគឺ អកិញ្ចាហើយសម្រេចព្រះអរហត្តដោយសួស្តី គប្បីជ្រាបប្រៀបដូចកាលដែលកូនមាន់ទាំងឡាយ ទម្លាយសម្បកពងដោយចុងក្រចកជើង ឬដោយជំពូកមាត់ ហើយត្រដាងស្ងាបចោះចេញទៅដោយសួស្តី ដោយការធ្វើកិរិយា ៣ឱ្យដល់ព្រមរបស់មេមាន់ ។ ដូចយ៉ាងថា មេមាន់ជីងថា កូនមាន់ទាំងឡាយផ្ងាស់ប្តូរហើយ រមែងទម្លាយសម្បកពង យ៉ាងណា សូម្បីព្រះសាស្តាក៏ដូច្នោះ ទ្រង់ជ្រាបថាភិក្ខុបែបនោះមានញាណចាស់ក្លាហើយ ទ្រង់ផ្សាយព្រះវស្មីទម្លាយសម្បកពងគឺអវិជ្ជា ដោយគាថាពោលអំពីន័យមានជាដើមថា ៖

លោកចូរដកចេញនូវសេចក្តីហួងហែងរបស់ខ្លួន ដូចបុគ្គលយកដៃដកគុម្ពកោមុខ:ក្នុងសារទកាលដូច្នោះ លោកចូរកពូនផ្លូវដែលស្ងប់ដោយថា ព្រះនិព្វាន ព្រះសុគតសម្តែងទុកហើយ ។

ចប់គាថា ភិក្ខុនោះ ទម្លាយសម្បកពងគឺ អវិជ្ជាហើយ ក៏សម្រេចអរហត្ត ។ តាំងពីនោះមក កូនមាន់ទាំងនោះក៏ធ្វើដែនស្រុកឱ្យស្រស់ល្អ ត្រាច់នៅក្នុងដែនស្រុកនោះយ៉ាងណា ព្រះមហាខីណាស្រពសូម្បីនេះក៏ដូច្នោះចូលផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ហើយ ធ្វើសង្ឃារាមឱ្យល្អត្រាច់នៅ ។

បទថា ពលភណ្ឌសប្ប បានដល់ ជាងឈើ ក៏ជាងឈើនោះទ្រទ្រង់ទុកនូវកំលាំង ពោលគឺ ជន្លល់រមែងនាំយកគ្រឿងឈើទៅបាន ព្រោះហេតុនោះ លោកហៅថា **ពលភណ្ឌៈ** ។

បទថា វាសិដ្ឋេ បានដល់ ក្នុងទីដងកាំបិតសម្រាប់ដៃចាប់ ។

បទថា **ឯត្តកំ វា មេ អជ្ជ អាសវានំ ខីណំ** សេចក្តីថា ក៏អាសវៈទាំងឡាយរបស់បព្វជិត រមែងអស់ទៅរហូតដល់អស់កាលជានិច្ច ដោយឧទ្ទេស ដោយបរិបុច្ឆា ដោយយោនិសោមនសិការ ដោយវត្តបដិបត្តិ ដោយសង្ខេបថាការបព្វជ្ជាអធិប្បាយថា ក៏កាលអាសវៈទាំងឡាយអស់ទៅយ៉ាងនេះ ភិក្ខុនោះ រមែងមិនដឹងយ៉ាងនេះថា ថ្ងៃនេះ(អាសវៈ)អស់ទៅប៉ុណ្ណេះ ថ្ងៃមិញ

(អាសវៈ)អស់ទៅប៉ុណ្ណោះ ដូច្នេះ ។ អានិសង្សនៃវិបស្សនា លោកសម្តែងដោយឧបមាយ៉ាងនេះ ។

បទថា **ហេមន្តិកេន** សេចក្តីថា ដោយហេមន្តសម័យ គឺ រដូវត្រជាក់ ។

បទថា **បដិប្បស្សម្ភន្តិ** បានដល់ រមែងសាបសូន្យទៅ ដូចយ៉ាង**ថាវរ** ។

ក្នុងបទថា**ឯវមេវ ខោ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ព្រះសាស្តា (ពាក្យទូន្មាន)គប្បីឃើញដូចមហាសមុទ្រ ព្រះយោគាវចរដូចទូក ការគ្រាច់ទៅក្នុងសំណាក់របស់អាចារ្យនិង ឧបជ្ឈាយ៍ក្នុងវេលាដែលខ្លួនមានវស្សាខ្ទះ ៥ របស់ភិក្ខុនេះដូចទូក គ្រាច់ទៅមក នៅក្នុងមហាសមុទ្រ ។ សេចក្តីដែលសញ្ញោជនៈ ទាំងឡាយស្រាលចុះដោយការគឺបព្វជ្ជា ដោយកិច្ច មានឧទ្ទេស និងបរិបុច្ឆាជាដើមនុ៎ះឯង ដោយសង្ខេបថា បព្វជ្ជារបស់ភិក្ខុ ដូច គ្រឿងចងទូកដែលទឹកក្នុងមហាសមុទ្រ កាត់ឱ្យស្រាលខ្លះទៅដូច្នោះ កាលភិក្ខុដែលជាទិស្សយមុត្តកៈត្រូវផុតនិស្សយ កំណត់កម្មដ្ឋាន នៅក្នុងព្រៃ ដូចវេលាដែលទូក ត្រូវគេលើកឡើងទុកលើគោក

សរសៃជ័រគឺតណ្ហា ស្ងួតហួតហែងទៅដោយវិបស្សនាញាណ ដូចខ្សែស្ងួតក្រោះទៅដោយខ្យល់និងកំដៅថ្ងៃ ក្នុងពេលថ្ងៃដូច្នោះ ការត្រជាក់សប្បាយនៃចិត្តដោយបីតិនិងបាមោជ្ជៈ ដែលអាស្រ័យកម្មដ្ឋានកើតឡើង ដូចខ្សែសើមជោកដោយតំណក់ទឹកសន្សើមក្នុងពេលយប់ សេចក្តីដែលសញ្ញោជនៈទាំងឡាយ មានកំលាំងខ្សោយចុះជាយ៉ាងក្រៃលែង ដោយបីតិនិងបាមោជ្ជដែលសម្បយុត្តដោយវិបស្សនាញាណ គប្បីឃើញដូចគ្រឿងចងទូក ដែលត្រូវកំដៅថ្ងៃដុតរោលក្នុងពេលថ្ងៃ និងត្រូវតំណក់ទឹកសន្សើមសើមជោកនៅក្នុងពេលយប់ធ្វើឱ្យសាបសូន្យទៅ ។ អរហត្តមគ្គញាណដូចពពកភ្លៀងដែលធ្លាក់ចុះមក ។ ភិក្ខុដែលប្រារព្ធវិបស្សនាចម្រើនវិបស្សនាដោយអំណាចនៃអារម្មណ៍មានរូប ៧ ពួកជាដើម កាលកម្មដ្ឋានប្រាកដជាក់ច្បាស់នៅ បានឧតុសប្បាយជាដើមក្នុងថ្ងៃមួយ អង្គុយដោយបល្ល័ង្កក៏ក្រាបសម្រេចព្រះអរហត្តផលដូចកាលដែលទូកផុតទៅខាងក្នុង ព្រោះទឹកភ្លៀងដែលធ្លាក់ចុះមកនិងទឹកក្នុងមហាសមុទ្រ ព្រះអរហន្តអ្នកអស់សញ្ញោជនៈហើយ អនុគ្រោះមហាជន ឲ្យតាំងនៅរហូតដល់អស់អាយុ ដូចទូកដែលមានគ្រឿងចងតាំងនៅមិនល្អកាលមួយរយៈ កាលព្រះខីណាស្រព

បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ព្រោះការបែក
នៃខុបាទិន្នខន្ធ សង្ខារដែលមានចិត្តគ្រប់គ្រងក៏ដល់នូវសេចក្តីរក
បញ្ញត្តិមិនបាន គប្បីឃើញដូចទូកដែលគ្រឿងចងពុកក៏រលាយទៅ
ដោយលំដាប់រកបញ្ញត្តិមិនបានដូច្នោះ ។ ដោយឧបមានេះ ព្រះមាន
ព្រះភាគ ទ្រង់សម្តែងសេចក្តីដែលសញ្ញោជនៈទាំងឡាយ មាន
កំលាំងខ្សោយចុះ ។

បុញ្ញវិបាកសូត្រ

នៅក្នុងបិដកលេខ ៤៧, ទំព័រ ១៦៤ ព្រះអង្គទ្រង់ត្រាស់
សម្តែង (**អានិសង្សរបស់ការចម្រើនមេត្តាភាវនា**) ជាមួយ
និងភិក្ខុទាំងឡាយថា ៖

ម្នាលភិក្ខុទាំងឡាយ **អ្នកទាំងឡាយ កុំខ្លាចបុណ្យឡើយ** ម្នាល
ភិក្ខុទាំងឡាយ ពាក្យថា **បុណ្យនេះជាឈ្មោះនៃសេចក្តីសុខ ។**
ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់ តថាគតបានចំរើនមេត្តា
ចិត្តដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាផលដែលបុគ្គល
ទទួលរឿយ ៗ អស់ឆ្នាំ ៧ ជាយូរអង្វែង លុះតថាគតចំរើននូវ
មេត្តាចិត្តអស់ ៧ ឆ្នាំហើយ ក៏មិនបានមកកាន់លោកនេះទៀត អស់

សំវដ្តកប្បនឹងវិដ្តកប្ប ៧ ម្នាលភិក្ខុទាំងឡាយ កាលដែលលោកវិនាសទៅ តថាគតបានទៅកើតក្នុងអាភស្សរព្រហ្ម កាលដែលលោកចំរើនឡើងតថាគតបានទៅកាន់ព្រហ្មវិមានដែលសូន្យ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងព្រហ្មវិមាននោះ តថាគតជាព្រហ្ម ជាមហាព្រហ្ម គ្របសង្កត់ព្រហ្មឯទៀត ព្រហ្មឯទៀតមិនអាចគ្របសង្កត់តថាគតបានទេ តថាគតជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើព្រហ្មទាំងពួងឱ្យលុះក្នុងអំណាចខ្លួន ។

ម្នាលភិក្ខុទាំងឡាយ តថាគតបានកើតជាសក្កទេវរាជ ៣៦ ដង ។ តថាគតបានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាធម្មរាជ ជាឥស្សរៈក្នុងផែនដី មានព្រំប្រទល់ក្នុងទីបំផុតនៃសមុទ្រទាំង ៤ មានជ័យជំនះដល់នូវភាវៈមាំមួនក្នុងជនបទ បរិបូណ៌ដោយរតនៈទាំង៧ប្រការ ជាច្រើនរយដង ។

ម្នាលភិក្ខុទាំងឡាយ រតនៈ ៧ ប្រការនេះកើតដល់តថាគតនោះ គឺចក្ករតនៈ ១ ហត្ថិរតនៈ ១ អស្សរតនៈ ១ មណិរតនៈ ១ ឥត្ថីរតនៈ ១ គហបតិរតនៈ ១ បរិនាយករតនៈ ១ ជាគម្រប់ ៧ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានកូនច្រើនពាន់ ជាអ្នកក្លៀវក្លា

មានសភាពជាអ្នកមានសេចក្តីព្យាយាម អាចញ៉ាំញីនូវសេនានៃស្តេចដទៃបាន ។ តថាគតបានឈ្នះហើយ នៅគ្រប់គ្រងនូវផែនដីនេះដែលមានសាគរជាទីបំផុត ដោយធម៌មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាទេ ។

ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញនូវផលនៃបុណ្យជាកុសលហើយក៏បានប្រាប់ពួកសត្វដែលជាអ្នកស្វែងរកសេចក្តីសុខ ហើយចំរើននូវមេត្តាចិត្តអស់ ៧ ឆ្នាំ មិនបានមកកាន់លោកនេះទៀត អស់សំវដ្តកប្បទី៦វិវដ្តកប្ប ៧ ជង កាលដែលលោកវិនាស តថាគតទៅកើតអាភស្សរព្រហ្ម កាលដែលលោកចំរើនតថាគតចូលទៅកាន់ព្រហ្មលោកដែលសូន្យ ក្នុងកាលនោះតថាគតបានជាមហាព្រហ្ម ជាអ្នកធ្វើព្រហ្មឯទៀតឱ្យលុះក្នុងអំណាចនៃខ្លួនអស់ ៧ ជង បានជាស្តេចនៃទេវតា ជាកំពូលនៃទេវតាអស់ ៣៦ ជង បានជាស្តេចចក្រពត្តិ ជាធំក្នុងជម្ពូទ្វីប ។ បានជាក្សត្រដែលបានមុទ្ធាភិសេក ជាអធិបតីរបស់មនុស្ស បានឈ្នះនូវផែនដីនេះដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រា មិនបាច់កំហែងកំហាល់ទេ បានប្រៀនប្រដៅដោយធម៌ដ៏ស្មើ ហើយបាន

សោយរាជសម្បត្តិនោះលើមណ្ឌលនៃផែនដីនេះ ដោយធម៌ តែងបានកើតក្នុងត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន បរិបូណ៌ដោយកាមទាំងពួងផង ដោយរតនៈទាំង ៧ ផង ព្រះពុទ្ធទាំងឡាយជាអ្នកសង្គ្រោះពួកសត្វលោក ព្រះពុទ្ធទាំងនោះ ទ្រង់សម្តែងដោយប្រពៃនូវហេតុនុ៎ះ នេះជាហេតុហៅថា ជាម្ចាស់នៃផែនដីរបស់ជនដ៏ច្រើន តថាគតជាស្តេច មានទ្រព្យសម្បត្តិច្រើន ជាអ្នកអង់អាចជាអ្នកមានឫទ្ធិ មានយស ជាឥស្សរៈក្នុងជម្ពូទ្វីប ។ ***បុគ្គលណាស្តាប់ហើយមិនជ្រះថ្លា ចាត់ជាកណ្ហជាតិ*** ព្រោះហេតុនោះ បុគ្គលមានប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវការៈជាធំ រលឹកនូវព្រះពុទ្ធសាសនា គប្បីធ្វើនូវសេចក្តីគោរពនូវព្រះសទ្ធម្មចុះ ។

អដ្ឋកថា

ពាក្យថា មា ភិក្ខវេ បុញ្ញានំ ភាយិត្ថ សេចក្តីថា ពួកលោកកាលនឹងធ្វើបុណ្យកុំបានខ្លាចចំពោះបុណ្យទាំងនោះឡើយ ។

ដោយពាក្យថា មេត្តចិត្តំ ភាវេសិ ព្រះមានព្រះភាគទ្រង់សម្តែងថា យើងអប់រំចិត្តធ្វើឱ្យប្រណីតប្រកបដោយមេត្តាដែលប្រកបដោយឈានពួក ៣ និងពួក ៤ ។ ពាក្យថា សំវដ្តមានេ

សុធាហំ កាត់បទជា **សំវដ្តមានេ សុធំ អហំ** ។

បទថា **សំវដ្តមានេ** សេចក្តីថា កាលលោកត្រូវភ្លើងឆេះនៅ គឺត្រូវភ្លើងធ្វើឱ្យវិនាសហើយ ។

បទថា **ធម្មិកោ** បានដល់ ប្រកបដោយកុសលធម៌ ១០ ប្រការ ។

បទថា **ធម្មរាជា** នេះជាវេវចនៈរបស់បទថា **ធម្មរាជា** នោះ ។ ម្យ៉ាងទៀត ឈ្មោះថា ជាធម្មរាជា ព្រោះទ្រង់បានរាជសម្បត្តិដោយធម៌ ។

បទថា **ចាតុរន្តោ** បានដល់ មានសេចក្តីជាធំក្នុងផែនដីដែលឈ្មោះថាចាតុរន្ត ដោយអំណាចមានមហាសមុទ្រទាំង ៤ មានក្នុងទិសបូព៌ាជាដើម ។ បទថា **វិជិតាវី** ប្រែថា អ្នកឈ្នះសង្គ្រាម ។ ជនបទក្នុងព្រះបាទចក្រពត្តិនោះ ដល់សេចក្តីវឹងមាំ **ថាវរ** ព្រោះហេតុនោះ ទើបឈ្មោះថា អ្នកមានជនបទដល់សេចក្តីវឹងមាំ **ថាវរ** ។

បទថា **បភោសហស្សំ** ប្រែថា មានព្រះឱរសច្រើនលើស ១,០០០ព្រះអង្គ ។

បទថា សូរភាបានដល់អ្នកមិនក្រាល ។ ក្នុងបទថា **វិរទ្ធរូបា** មានរូបវិគ្រោះដូចតទៅនេះ ៖

អង្គរបស់អ្នកក្លៀវក្លា ឈ្មោះ**ថា វិរទ្ធៈ**, វិរទ្ធៈអង្គអ្នកខ្លាំងក្លាមិនជារូបរបស់ឱរសទាំងនោះ ហេតុនោះ ឱរសទាំងនោះ ឈ្មោះថា **វិរទ្ធរូបា** អ្នកមានអង្គនៃអ្នកខ្លាំងក្លាមិនជារូប ។ លោកអធិប្បាយទុកថា ឱរសទាំងនោះមិនខ្វិលច្រអូសដូចអ្នកមានសេចក្តីព្យាយាមជាប្រក្រតី មានសេចក្តីព្យាយាមជាសភាវៈ និងមានសេចក្តីព្យាយាមច្រើន ។ លោកអធិប្បាយថា សូម្បីទាំងថ្ងៃក៏មិននឿយហត់ ។

បទថា **សាគរបរិយន្តំ** សេចក្តីថា មានមហាសមុទ្រទីងភ្នំខ្ពស់ ចក្រវាឡជាព្រំដែនលោមព័ទ្ធជុំវិញ ។

បទថា **អធណ្ឌេន** បានដល់ វៀរចាកអាជ្ញា គឺការពិន័យតម្លៃទ្រព្យដោយទ្រព្យខ្លះ ចុះអាជ្ញាផ្សេងទៀតបញ្ញត្តិ ដោយបង្គាប់ឱ្យកាត់ដៃជើងនិងប្រហារជីវិត បទថា **អសត្ថេន** បានដល់ វៀរចាកប្រើសស្ត្រាបៀតបៀនអ្នកដទៃ សស្ត្រាមានមុតតែមួយជា

ដើម, បទថា ធម្មេន អភិវិជយ សេចក្តីថា ទ្រង់ឈ្នះរហូតដល់អស់ផែនដីមានប្រការដូចពោលហើយដោយធម៌តែម្យ៉ាងដោយន័យមានជាដើមថា មិនគប្បីសម្លាប់បាណៈសត្វដែលព្រះរាជាជាសត្រូវទទួលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គមេត្តាស្តេចមកចុះ ។

បទថា សុខេសិនំ សេចក្តីថា រមែងហៅសត្វទាំងឡាយអ្នកស្វែងរកសេចក្តីសុខ ។

បទថា សុញ្ញព្រហ្មបគោ សេចក្តីថា អ្នកចូលដល់វិមានរបស់ព្រហ្មដែលទទេ ។

បទថាបឋវឹ ឥមំ សេចក្តីថា ផែនដីធំ ដែលមានសាគរលោមព័ទ្ធជុំវិញ ។

បទថា អសាហសេន ពោលអំពីកម្មដែលមិនបានប្រញាប់គិត ។

បទថា សមេន សុទេសិតំ សេចក្តីថា ទូន្មានដោយកម្មដ៏ស្មើ ។

បទថា តេហិ ឯតំ សុនេសិតំ សេចក្តីថា ហាន:នេះ គឺមានប្រមាណប៉ុណ្ណេះ ដែលព្រះពុទ្ធទាំងឡាយសម្តែងល្អហើយ ត្រាស់ល្អហើយ ។

បទថា បញ្ញោ ប្រែថា អ្នក គឺជាផែនដី ។

ចក្កមសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៥៦ ព្រះអង្គទ្រង់ត្រាស់សម្តែង (**អានិសង្សនៃការចង្រ្កម ៥ប្រការ**)ជាមួយនឹងភិក្ខុទាំងឡាយថា ៖

ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការចង្រ្កមនេះ មាន ៥ យ៉ាង ។ **អានិសង្ស ៥ យ៉ាងតើអ្វីខ្លះ ។**

១- អទ្ធានក្ខមោ ហោតិ គឺជាអ្នកអត់ធន់ក្នុងដំណើរផ្លូវឆ្ងាយ

២- បធានក្ខមោ ហោតិ អត់ធន់ក្នុងការព្យាយាម

៣- អប្បាពាធោ ហោតិ មិនមានជម្ងឺ

៤- អសិតំ បីតំ ខាទិតំ សាយិតំ សម្មាបរិណាមំ គច្ឆតិ ភោជនដែលបរិភោគ ផឹក ទំពាស៊ី លិទ្ធិភ្លក្សហើយ រមែ

រលួយដោយស្រួល

៥- ចត្តមាធិកតោ សមាធិ ចិរដ្ឋិតិកោ ហោតិ សមាធិដែលកើតអំពីការចង្រ្កម រមែងតាំងនៅអស់កាលយូរ ។

➪. ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការចង្រ្កមមាន ៥ យ៉ាងនេះឯង ។

អដ្ឋកថា

បទថា **អទ្ធានក្ខមោ ហោតិ** បានដល់ កាលដើរផ្លូវឆ្ងាយ ក៏ដើរបានធន់ គឺអត់ធន់បាន ។

បទថា **បធានក្ខមោ** បានដល់ ព្យាយាមបាន ។

បទថា **ចត្តមាធិកតោ ច សមាធិ** បានដល់ សមាធិនៃសមាបត្តិ ៨ យ៉ាងណាមួយ ដែលបុគ្គលអធិដ្ឋានចង្រ្កមហើយ ។

បទថា**ចិរដ្ឋិតិកោ ហោតិ** ប្រែថា តាំងនៅបានយូរ ។

ដោយថា និមិត្តដែលបុគ្គលឈរកាន់យកកាលអង្គុយក៏សាបសូន្យទៅនិមិត្តដែលបុគ្គលអង្គុយកាន់យកកាលដេកក៏សាប

សូន្យទៅ ចំណែកនិមិត្តដែលបុគ្គលអធិដ្ឋានចង្រ្កមកាន់យកក្នុងអារម្មណ៍ដែលញាប់ញ័រហើយកាលឈរក្តី អង្គុយក្តី ដេកក្តី រមែងមិនសាបសូន្យទៅ ។

២.សេចក្តីព្យាយាមក្នុងការបដិវ្តិធម៌

អង្គសូត្រ

នៅក្នុងបិដកលេខ ៤៤ ទំព័រ ១៣៣ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី **[អង្គរបស់ភិក្ខុអ្នកមានសេចក្តីព្យាយាម ៥ ប្រការ]** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ **អង្គនៃសេចក្តីព្យាយាមនេះមាន** ៥ យ៉ាង ។ **អង្គ ៥ តើដូចម្តេច ។**

๑.ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធាជឿ ញាណគ្រឿងត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាងអរហន្ត ជាសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ជាបុគ្គលប្រសើរជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ១ ។

៦. ជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយធាតុភ្លើងសម្រាប់ដុតកំដៅយ៉ាងល្មម មិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាងកណ្តាល គួរនឹងធ្វើព្យាយាម ១ ។

៦. ជាអ្នកមិនអួតអាង មិនមានមាយា ជាអ្នកធ្វើខ្លួនឱ្យប្រាកដតាមពិតក្នុងសំណាក់គ្រូ នឹងពួកសព្រហ្មចារីជាវិញ្ញូជន១ ។

៦. ជាអ្នកប្រារព្ធព្យាយាមដើម្បីលះបង់អកុសលធម៌ ធ្វើកុសលធម៌ឱ្យសម្រេចមានកម្លាំងប្រឹងសង្វាត មិនដាក់ចុះនូវធុរៈក្នុងកុសលធម៌ ១,

៦. ជាអ្នកមានបញ្ញាប្រកបដោយបញ្ញា អាចកំណត់នូវការកើតនឹងការរលត់ដ៏ប្រសើរ ជាគ្រឿងទំលុះទំលាយ(កិលេស) អាចកំណត់នូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃបាន ១ ។

ម្នាលភិក្ខុទាំងឡាយអង្គនៃសេចក្តីព្យាយាមមាន៥នេះឯង ។

អដ្ឋកថា

ក្នុងបទថា បធានិយង្គានិ **ការៈ**គឺការតាំងសេចក្តីព្យាយាម លោកហៅថា **បធាន ។** សេចក្តីព្យាយាមរបស់ភិក្ខុនោះមាន ហេតុនោះ ភិក្ខុនោះឈ្មោះថា អ្នកមានសេចក្តីព្យាយាម អង្គរបស់ភិក្ខុអ្នកមានសេចក្តីព្យាយាម ព្រោះហេតុនោះ ឈ្មោះថា

បធានិយង្គៈ ។

បទថា សទ្ទោ ប្រែថា អ្នកប្រកបដោយសទ្ធា ។ ក៏សទ្ធានោះមាន ៤ យ៉ាងគឺ **អាគមសទ្ធា ១ អធិគមសទ្ធា ១ ឯកប្បនសទ្ធា ១ បសាទសទ្ធា ១ ។**

⇨. បណ្តាសទ្ធាទាំង ៤ នោះ សទ្ធារបស់ព្រះសព្វញ្ញុពោធិសត្វ ឈ្មោះថា **អាគមសទ្ធា** ព្រោះផ្តើមមានមកតាំងពីការបំពេញបារមីមក ។

⇨. ដែលឈ្មោះថា **អធិគមសទ្ធា** ព្រោះសម្រេចដោយការចាក់ធ្លុះរបស់ព្រះអរិយសាវកទាំងឡាយ ។

⇨. សេចក្តីជឿយ៉ាងមុតមាំ ព្រោះមិនញាប់ញ័រ កាលពោលថា **ពុទ្ធោ ធម្មោ សង្ឃោ** ដូច្នេះ ឈ្មោះថា **ឯកប្បនសទ្ធា ។**

⇨. **ការកើតឡើងនៃសេចក្តីជ្រះថ្លា** ឈ្មោះថា **បសាទសទ្ធា ។**

ក្នុងព្រះសូត្រលោកជ្រាប់ថ្លាយក **ឯកប្បនសទ្ធា ។** បទថា ពោធិ បានដល់ មគ្គញ្ញាណ ៤ ។ ភិក្ខុរមែងជឿថា មគ្គញ្ញាណ ៤

នោះដែលព្រះតថាគតចាក់ធ្លុះដោយល្អហើយ ។ ក៏ពាក្យនោះត្រឹមតែជាប្រធាននៃទេសនាប៉ុណ្ណោះ ។ ក៏សទ្ធាក្នុងរតនៈសូម្បីទាំង ៣ លោកប្រាថ្នាយកដោយអង្គនេះ ព្រោះភិក្ខុណាមានសេចក្តីជ្រះថ្លាមានកម្លាំងខ្លាំងក្លាក្នុងព្រះពុទ្ធជាដើម សេចក្តីព្យាយាមគឺបធានរមែងសម្រេចដល់ភិក្ខុនោះ ។

បទថា **អប្បាពាធោ** គឺមិនមានរោគ ។ បទថា **អប្បាតង្កោ** គឺមិនមានទុក្ខ ។ បទថា **សមវេបាកិនិយា** ប្រែថា មានការប្រព្រឹត្តស្មើ ។ បទថា **គហណិយា** ប្រែថា កាលភ្លើងធាតុកើតដល់កម្ម ។ បទថា **ឆាតិសីតាយ ឆាថុណ្ហាយ** សេចក្តីថា ពិតមែន ភិក្ខុអ្នកមានភ្លើងធាតុត្រជាក់កើតហើយ រមែងខ្លាចរងាអ្នកមានភ្លើងធាតុក្តៅកើតហើយ រមែងខ្លាចក្តៅ សេចក្តីព្យាយាមរមែងមិនសម្រេចផលដល់ភិក្ខុទាំងនោះ (តែ)រមែងសម្រេចផលដល់ភិក្ខុអ្នកមានភ្លើងធាតុល្មម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ជាសភាពសមល្មមដល់សេចក្តីព្យាយាម ។ បទថា **យថាភូតំ អត្តានំ អាវិកត្តា** គឺប្រកាសគុណរបស់ខ្លួនតាមសេចក្តីពិត ។ បទថា **ឧឧយត្ត** **គាមិនិយា** គឺ

ដែលអាចដល់ គឺកំណត់ដឹងការកើតនឹងការរលត់ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ឧទយព្យញ្ញាណដែលកំណត់ដឹងលក្ខណៈ៥០ ប្រការ ដោយបទនេះ ។ បទថា **អរិយោ** គឺបរិសុទ្ធ ។ បទថា **ឯកន្តេកាយ** គឺ ដែលអាចជម្រះកង់កិលេសមានកង់លោភៈជាដើម ដែលបុគ្គលនៅមិនធ្លាប់ឈ្នះ ។ បទថា **សម្មាទុក្ខក្ខយគាមិនិយោ** គឺដែលឱ្យដល់សេចក្តីអស់ទុក្ខ ព្រោះលះកិលេសទាំងឡាយបានដោយអំណាច **តង្គបជាន** (លះមួយគ្រា) ។ ដោយបទទាំងនេះសូម្បីទាំងអស់ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ដល់វិបស្សនាញ្ញាណប៉ុណ្ណោះ ដោយប្រការដូច្នោះ ព្រោះសេចក្តីព្យាយាម រមែងមិនសម្រេចផលដល់បុគ្គលអ្នកមានបញ្ញាទន់ខ្សោយ ។

បឋមឆឌ្ឍវិហារកសូត្រ

នៅក្នុងបិដកលេខ ៤៤,ទំព័រ ១៧៨ ព្រះអង្គទ្រង់ត្រាស់នូវ **[បុគ្គលអ្នកតាំងនៅក្នុងធម៌]** មានសេចក្តីថា ៖

គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយ

ក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា ភិក្ខុមានប្រក្រតីនៅដោយធម៌ ភិក្ខុមានប្រក្រតីនៅដោយធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុមានប្រក្រតីនៅដោយធម៌ ដោយហេតុប៉ុន្មានយ៉ាង ។

⇨. ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។ ភិក្ខុនោះញុំាងថ្ងៃឱ្យកន្លងទៅដោយការរៀននូវធម៌នោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់មិនបានប្រកបរឿយ ៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ***ជាអ្នកច្រើនដោយបរិយត្តិធម៌ មិនហៅថា ជាអ្នកមានប្រក្រតីនៅដោយធម៌ទេ ។***

⇨. ***មួយទៀត*** ភិក្ខុសម្តែងធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដល់បុគ្គលទាំងឡាយដទៃដោយសេចក្តីពិស្តារ ភិក្ខុញុំាងថ្ងៃឱ្យកន្លងទៅដោយការបញ្ញត្តិនូវធម៌នោះ លះបង់នៅការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយ ៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ***ជាអ្នកច្រើនដោយបញ្ញត្តិ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។***

⇨. **មួយទៀត** ភិក្ខុធ្វើនូវការស្វាធ្យាយនូវធម៌តាមទំនង ដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដោយសេចក្តីពិស្តារ ។ ភិក្ខុនោះញុំាងថ្ងៃឱ្យកន្លងទៅ ដោយការស្វាធ្យាយនោះ លះបង់នៅការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រក្រតីរឿយ ៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា **ជាអ្នកច្រើនដោយការស្វាធ្យាយ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។**

⇨. **មួយទៀត** ភិក្ខុត្រិះរិះពិចារណាដោយចិត្ត ជញ្ជឹងដោយចិត្តចំពោះធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ។ ភិក្ខុនោះញុំាងថ្ងៃឱ្យកន្លងទៅ ដោយការត្រិះរិះនូវធម៌ទាំងនោះ លះបង់នៅការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយ ៗនូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះ ហៅថា **ជាអ្នកច្រើន ដោយសេចក្តីត្រិះរិះនូវធម៌ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។**

⇨. ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ។ ភិក្ខុនោះមិនបានញុំាងថ្ងៃឱ្យកន្លងទៅ ដោយការរៀននូវធម៌នោះ មិនលះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយ ៗនូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនោះជាអ្នកនៅ

ដោយធម៌យ៉ាងនេះឯង ។ ភិក្ខុជាអ្នកច្រើនដោយការរៀន តថាគតបានសម្តែងហើយ អ្នកច្រើនដោយការបញ្ញត្តិ តថាគតបានសម្តែងហើយ អ្នកច្រើនដោយស្វាធ្យាយ តថាគតបានសម្តែងហើយ អ្នកមានប្រក្រតីនៅដោយធម៌ តថាគតបានសម្តែងហើយដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុ អំពើណាដែលសាស្តា ជាអ្នកស្វែងរកនូវបយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ គួរធ្វើដល់សាវ័កទាំងឡាយ អំពើនោះតថាគតក៏បានធ្វើហើយដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុ ទីនោះជារុក្ខមូលសេនាសនៈ ទីនោះជាជាសុញ្ញាគារសេនាសនៈ ។ អ្នកទាំងឡាយចូរចំរើន(នូវសមថៈនិងវិបស្សនា) អ្នកទាំងឡាយចូរកុំប្រមាទ អ្នកទាំងឡាយ ចូរកុំមានសេចក្តីក្តៅក្រហាយ[1] ក្នុងកាលជាខាងក្រោយឡើយ នេះជាពាក្យប្រៀនប្រដៅរបស់តថាគតដល់អ្នកទាំងឡាយ ។

---

១. កាលពីដើមខ្លួននៅក្មេង ពុំទាន់មានកេតមកបៀតបៀន ច្រើនតែសប្បាយភ្លេចខ្លួន ដោយការស៊ីផឹក ទោះបានជួបនឹងព្រះសាស្តាជាម្ចាស់ ក៏មិនបានយកចិត្តទុកដាក់ ចូលចិត្តតែខាងដេកទាំងយប់ទាំងថ្ងៃឱ្យសង្កើចទាំងតំអើ ច្រើនធ្វេសប្រហែស(ឥតបានទឹកនាត្រង់ការកុសលណាសោះ) លុះវេលាខាងក្រោយមក ខ្លួនមានវ័យកាន់តែចាស់ទៅ ៗចាស់ជរាគ្រាំគ្រា ទាំងកេតក៏មកបៀតតែខាងកាយ ទើបបានទឹកក្តៅក្រហាយស្តាយក្រោយ ។ អដ្ឋកថា ។

បឋមអនាគតសូត្រ

នៅក្នុងបិដកលេខ ៤៤,ទំព័រ ២០៩ ព្រះអង្គទ្រង់ត្រាស់នូវ **[ភ័យក្នុងអនាគត ៥ ប្រការ]** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅក្នុងព្រៃកាលពិចារណាឃើញនូវអនាគតភ័យ ៥ យ៉ាងនេះ ជាអ្នកមិនប្រមាទ មានព្យាយាមញុាំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានដើម្បីបាននូវគុណវិសេសដែលខ្លួនមិនទាន់បានដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ **ភ័យ ៥ យ៉ាង តើដូចម្តេចខ្លះ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ពស់គប្បីចឹកអាត្មាអញក្តី ខ្យគប្បីទិចអាត្មាអញក្តី ក្អែបគប្បីទាំអាត្មាអញក្តី ដែលនៅក្នុងព្រៃតែម្នាក់ឯង កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ អន្តរាយនោះគប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះអាត្មាអញប្រារព្ធនូវសេចក្តីព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីដល់

នូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃកាលបើពិចារណាឃើញនូវអនាគតទី ១ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញុាំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង គប្បីភ្ញាក់ដួលទៅក្តី ភត្តដែលអាត្មាអញបរិភោគហើយក្តី គប្បីឱ្យទោសក្តី ប្រមាត់របស់អាត្មាអញគប្បីកំរើកឡើងក្តី ស្លេស្មរបស់អាត្មាអញគប្បីកក្រើកឡើងក្តី ខ្យល់ទាំងឡាយដែលមានមុខមុតដូចជាកាំបិតគប្បីកក្រើកឡើងក្តី កាលកិរិយាគប្បីមានដល់អាត្មាអញដោយហេតុនោះ សេចក្តីអន្តរាយនោះគប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះអាត្មាអញប្រារព្ធនូវសេចក្តីព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បាន

ដល់ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃកាលបើពិចារណាឃើញនូវអនាគតទី ២ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញុាំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង គប្បីជួបប្រទះនឹងម្រឹគសាហាវទាំងឡាយគឺ រាជសីហ៍ក្តី ខ្លាធំក្តី ខ្លាជម្បាងក្តី ខ្លាឃ្មុំក្តី ខ្លា ត្រីក្តី ម្រឹគសាហាវទាំងនោះ គប្បីផ្តាច់បង់អាត្មាអញចាកជីវិត កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះសេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះអាត្មាអញប្រារព្ធនូវសេចក្តីព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណ

វិសេសដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃកាលបើពិចារណាឃើញនូវអនាគតទី៣នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង គប្បីជួបប្រទះនឹងពួកចោរដែលធ្វើចោរកម្មហើយក្តី ដែលមិនទាន់បានធ្វើចោរកម្មក្តី ចោរទាំងនោះគប្បីផ្តាច់បង់នូវអាត្មាអញចាកជីវិតទៅ កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាមដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួន

មិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ
កាលបើពិចារណាឃើញនូវអនាគតទី ៤ នេះហើយជាអ្នកមិនប្រមាទ
មានព្យាយាមញុាំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន
ទើបអាចដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ដើម្បីបាន
នូវគុណវិសេស ដែលខ្លួនមិនទាន់បានដើម្បីធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ
ជាអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅ
ក្នុងព្រៃតែម្នាក់ឯង ប្រសិនបើមានអមនុស្សកំណាចនៅក្នុងព្រៃ
អមនុស្សកំណាចទាំងនោះ គប្បីផ្តាច់បង់នូវអាត្មាអញចាកជីវិតទៅ
កាលកិរិយាគប្បីមានដល់អាត្មាអញដោយហេតុនោះ សេចក្តីអន្ត-
រាយនោះគប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះអាត្មាអញ
ប្រារព្ធនូវសេចក្តីព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិន
ទាន់បានដល់ ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បី
ធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់
ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃកាលបើពិចារណា
ឃើញនូវអនាគតទី ៥ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាម

ញុំងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានទើបអាចដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទាំង ៥ យ៉ាងនេះឯង ជាអ្នកមិនប្រមាទ មានព្យាយាម ញុំងកិសេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។

បឋមសេក្ខសូត្រ

នៅក្នុងបិដកលេខ ៤៤,ទំព័រ ២៤០ ព្រះអង្គទ្រង់ត្រាស់នូវ **[ធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ នីងមិនសាបសូន្យរបស់ព្រះសេក្ខ]** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ **ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។**

១- កម្មារាមតា គឺសេចក្តីត្រេកអរនឹងការងារ

២- ភសុប្បារាមតា សេចក្តីត្រេកអរនឹងតិរច្ឆានកថា

៣- និទ្ទារាមតា សេចក្តីត្រេកអរនឹងការដេក

៤- សង្គណិការាមតា សេចក្តីត្រេកអរនឹងការច្រឡូកច្រឡំដោយពួក

៥- យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ មិនពិចារណាចិត្តដែលផុត(ចាកកិលេស)យ៉ាងណា ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។

[ធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យនៃព្រះសេក្ខៈ]

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ **ធម៌៥យ៉ាងគឺអ្វីខ្លះ ។**

១- ន កម្មារាមតា គឺសេចក្តីមិនត្រេកអរនឹងការងារ

២- ន ភសុប្បារាមតា សេចក្តីមិនត្រេកអរនឹងតិរច្ឆានកថា

៣- ន និទ្ទារាមតា សេចក្តីមិនត្រេកអរនឹងការដេក

៤- ន សង្គណិការាមតា សេចក្តីមិនត្រេកអរនឹងការ

ច្រឡូកច្រឡំដោយពួក

៥- **ន យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ** មិនពិចារណាចិត្តដែលផុត(ចាកកិលេស)យ៉ាងណា ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។

អដ្ឋកថា

បទថា សេក្ខស្ស បានដល់ ភិក្ខុអ្នកនៅមានការសិក្សា គឺនៅមានកិច្ចដែលត្រូវធ្វើ ។

បទថា **បរិហានាយ** បានដល់ ដើម្បីសាបសូន្យចាកគុណយ៉ាងខ្ចង់ខ្ចស់ ។

*. សេចក្តីត្រេកអរក្នុងនវកម្ម ការបង្គសាងសង់ ឈ្មោះថា **កម្មារាមតា** ។

*. សេចក្តីត្រេកអរក្នុងការសន្ទនាប្រាស្រ័យ (ជាមួយគ្នា) ឈ្មោះថា **ភស្សារាមតា** ។

*. សេចក្តីត្រេកអរក្នុងការដេកលក់ ឈ្មោះថា **និទ្ទារាមតា** ។

*. សេចក្តីត្រេកអរនៅក្នុងភាពច្រឡូកច្រឡំគ្នា ជាពួក ឈ្មោះថា **សង្គណិការាមតា** ។

បទថា យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ សេចក្តីថា មិនបានពិចារណាចិត្តដែលផុតស្រឡះហើយ ពិចារណានូវទោសដែលខ្លួនលះបាន នឹងគុណដែលខ្លួនបានទាំងនោះហើយ រមែងមិនធ្វើសេចក្តីព្យាយាម ដើម្បីបានគុណយ៉ាងខ្ពស់តទៅទៀត ។ ក្នុងសូត្រនេះ ត្រាស់ហេតុនៃសេចក្តីសាបសូន្យ នឹងហេតុនៃសេចក្តីចំរើនដោយគុណយ៉ាងខ្ពស់របស់ព្រះសេក្ខៈ ៧ ពួក ដោយប្រការយ៉ាងនេះ ។ ក៏សេចក្តីណាជាហេតុនៃសេចក្តីសាបសូន្យរបស់ព្រះសេក្ខៈ សេចក្តីនោះមានន័យដូចរបស់បុថុជ្ជនដែរ ដោយប្រការដូច្នេះ ។

កីសីលសូត្រ

នៅក្នុងបិដកលេខ ៥៤ ទំព័រ ១០៤ ***ព្រះសារីបុត្រដ៏មានអាយុក្រាបទូលសួរព្រះមានព្រះភាគថា ៖***

**. នរជនមានសីលដូចម្តេច មានមារយាទដូចម្តេច ចំរើននូវអំពើទាំងឡាយដូចម្តេច គប្បីជាបុគ្គលប្រតិស្ឋានមាំល្អ (ក្នុងសាសនា) ផង ដល់នូវប្រយោជន៍ខ្ពង់ខ្ពស់ គឺអរហត្តផលផង ។*

ឯ. [ព្រះមានព្រះភាគទ្រង់ត្រាស់ថា] បុគ្គលត្រូវប្រព្រឹត្ត

កោតក្រែងចំពោះបុគ្គលដែលចំពោះ ជាអ្នកមិនមានសេចក្តីច្រណែន ស្គាល់កាលជួបនឹងគ្រូ ស្គាល់ខណៈស្តាប់ធម្មីកថាដែលលោកពោល គប្បីស្តាប់សុភាសិតឯទៀតដោយគោរព ។

៦. បុគ្គលគួរធ្វើការពាំងគ្នីងឱ្យជ្រះស្រឡះ ប្រព្រឹត្តបន្ទាបខ្លួន ហើយចូលទៅកាន់សំណាក់គ្រូតាមកាលគួរ គប្បីរលឹកវឿយ ៗ ទាំងប្រព្រឹត្តដោយប្រពៃនូវអត្ថនៃ(ភាសិត) ធម៌ សីល និង ព្រហ្មចារ្យ(ដ៏សេសដែលគ្រូសម្តែងហើយ) ។

៦. បុគ្គលគួរជាអ្នកមានធម៌ជាទីត្រេកអរ ត្រេកអរក្នុងធម៌ ឋិតនៅក្នុងធម៌ ចេះវិនិច្ឆិយនូវធម៌ មិនគួរប្រព្រឹត្តនូវពាក្យដែលប្រទូស្តចំពោះធម៌ គប្បីញុំាងកាលឱ្យអស់ទៅដោយសុភាសិតទាំងឡាយដែលពិត ។

៦. បុគ្គលគប្បីលះបង់នូវការសើចវីកវាយ ការចរចាឥតប្រយោជន៍ ការរ្បឹកខ្វល ការប្រទូស្ត ការធ្វើនូវមាយា ការកុហក ការជាប់ចិត្ត ការប្រកាន់ ការប្រណាំងប្រជែង សម្តីអាក្រក់ ទឹកអមូត្តគឺរាគាទិក្កិលេសនឹងការជ្រប់នៅដោយតណ្ហា គប្បីជាបុគ្គលប្រាសចាកសេចក្តីស្រវឹង មានចិត្តឋិតនៅមាំ ។

៤. *សុភាសិតទាំង៦ឡាយ (ដែលប្រកបដោយសមថវិបស្សនា) គឺអ្នកប្រាជ្ញដឹងច្បាស់ថាមានសារៈ ឯញាណសំវេចអំពីសុត្តៈគឺអ្នកប្រាជ្ញដឹងច្បាស់ថាមានសមាធិជាសារៈបញ្ញាទីង៦សុត្តៈរមែងមិនចំរើនដល់នរជនដែលជាអ្នកមានចិត្តរហ័ស ជាអ្នកធ្វេសប្រហែស ។*

៥. *មួយទៀត ជនពួកណាត្រេកអរក្នុងធម៌ដែលអរិយបុគ្គលសម្តែងហើយ* ***ជនពួកនោះរមែងប្រសើរដោយវចីកម្ម មនោកម្ម និងកាយកម្ម*** *ជនពួកនោះរមែងបិតនៅក្នុងសេចក្តីស្ងប់ស្ងាត់ ស្ងប់ស្ងៀមនឹងសមាធិ ហើយបានដល់នូវខ្លឹមនៃការស្គាល់ផង នៃប្រាជ្ញាផង ។*

រឿងបរិនិព្វានរបស់ព្រះគោធិកត្ថេរ

ព្រះសាស្តា កាលស្តេចចូលទៅអាស្រ័យក្រុងរាជគ្រឹ ។ ទ្រង់គង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធការបរិនិព្វានរបស់ព្រះគោធិកត្ថេរត្រាស់ធម្មទេសនានេះថា ***"តេសំ សម្បន្នលីលានំ"*** *ជាដើម ។*

[ព្រះថេរៈគិតសម្លាប់ខ្លួនព្រោះសាបសូន្យចាកឈាន]

សេចក្តីពិស្តារថា ព្រះគោធិកៈដ៏មានអាយុនោះ នៅកាឡ-

សិលាគុហា ឱដ្ឋ"សិគិលិ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បាននូវចេតោវិមុត្តិប្រកបតាមកាលវេលា, លំដាប់នោះឯង ព្រះគោធិក:មានអាយុសាបសូន្យចាកចេតោវិមុត្តិ ដែលប្រកបតាមកាលវេលានោះដោយអំណាចនៃរោគមួយប្រភេទ ។ លោកញុំាងឈានទី ២ ខ្លះ ទី ៣ ខ្លះឱ្យកើតឡើងដល់ ៦ ដង ហើយក ។ សាបសូន្យចាកឈាននោះទៀតក្នុងវារៈទី ៧ ក៏ញុំាងឈានឱ្យកើតឡើង ហើយបានគិតថា "យើងសាបសូន្យចាកឈានដល់ ៦ ដងហើយ ក៏គតិរបស់អ្នកមានឈានសាបសូន្យ មិនទៀងទាត់ទេ បើដូច្នោះ យើងនឹងនាំសស្ត្រាមក"លុះគិតដូច្នោះ ហើយក៏កាន់កាំបិតសម្រាប់កោរ-សក់ ដេកលើគ្រែតូច បំណងនឹងកាត់-ក ។

[មារទូលឱ្យព្រះសាស្តាទ្រង់ជ្រាប]

គ្រានោះឯង មារមានចិត្តបាប ដឹងចិត្តរបស់ព្រះថេរៈហើយគិតថា "ភិក្ខុនេះប្រាថ្នានឹងនាំសស្ត្រាមក, ក៏ភិក្ខុទាំងឡាយនាំសស្ត្រាមក រមែងជាអ្នកអស់សេចក្តីអាល័យក្នុងជីវិត, ភិក្ខុទាំងនោះផ្តើមតាំងវិបស្សនាហើយ រមែងបានសម្រេចអរហត្ត, បើនឹងហាម

ឃាត់ភិក្ខុនោះ លោកនឹងមិនធ្វើតាមពាក្យរបស់យើង, យើងនឹងទូលឱ្យព្រះសាស្តាហាម" ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តា ដោយភេទដែលអ្នកដទៃមិនស្គាល់ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គអ្នកមានព្យាយាមធំ មានប្រាជ្ញាច្រើន រុងរឿងដោយឫទ្ធិនិងយសកន្ធងនូវពៀរ និងភ័យគ្រប់ប្រការ ទ្រង់មានចក្ខុ ព្រះអង្គសូមថ្វាយបង្គំព្រះបាទ បពិត្រព្រះអង្គអ្នកមានព្យាយាមធំ សាវករបស់ព្រះអង្គ ត្រូវសេចក្តីស្ងាប់គ្របសង្កត់ ប្រាថ្នាគតដល់សេចក្តីស្ងាប់ បពិត្រព្រះអង្គទ្រទ្រង់នូវអានុភាព សូមព្រះអង្គឃាត់នូវសាវកនោះបពិត្រព្រះមានព្រះភាគអ្នកល្បីក្នុងប្រជុំជន សាវករបស់ព្រះអង្គជាសេក្ខបុគ្គល មានបំណងមិនទាន់សម្រេច នៅត្រេកអរក្នុងសាសនា គប្បីធ្វើមរណកាលដូចម្តេចបាន ។

គ្រានោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ថា បុគ្គលនេះជាមារមានចិត្តបាប ដូច្នេះហើយ ទើបពោលនឹងមារមានចិត្តបាបនោះ ដោយគាថាដូច្នេះថា ៖

ពិតមែន អ្នកប្រាជ្ញទាំងឡាយ តែងធ្វើយ៉ាងនេះឯង រមែងមិននឹកស្តាយនូវជីវិត គោធិកភិក្ខុបានដកតណ្ហា ព្រមទាំងឫស

បរិនិព្វានហើយ ។

គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ មកថា ម្នាលភិក្ខុទាំងឡាយ មកយើងនឹងចូលទៅកោឡសិលា ជិតភ្នំ"សិគិលិ តាំតគោធិកកុលបុត្រយកកាំបិតមកហើយ ។ ពួកភិក្ខុ បានទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ, ទើបព្រះមានព្រះភាគទ្រង់ចូលទៅកាន់កាឡសិលាខាងភ្នំ"សិគិលិ មួយអន្ទើដោយពួកភិក្ខុច្រើនរូប ។ ព្រះមានព្រះភាគ ក៏បានឃើញគោធិកៈមានអាយុកំពុងដេកផ្ងារផ្ងើយ-កលើគ្រែអំពីចម្ងាយ លឹម ៗ ។ សម័យនោះឯង ផ្សែង និងអ័ព្ទក៏បក់ទៅកាន់ទិសខាងកើតខ្លះ បក់ទៅកាន់ទិសខាងលិចខ្លះ បក់ទៅកាន់ទិសខាងជើងខ្លះ បក់ទៅកាន់ទិសខាងត្បូងខ្លះ បក់ទៅកាន់ទិសខាងលើខ្លះ បក់ទៅកាន់ទិសខាងក្រោមខ្លះ បក់ទៅកាន់ទិសខាងខ្លះ ។

គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញនូវផ្សែង និងអ័ព្ទនោះ បក់ទៅកាន់ទិសខាងលិចខ្លះ បក់ទៅកាន់ទិសខាងជើងខ្លះ បក់ទៅកាន់ទិសខាងត្បូងខ្លះ បក់ទៅកាន់ទិសខាងលើខ្លះ បក់ទៅកាន់ទិស

ខាងក្រោមខ្លះ បក់ទៅកាន់ទិសខាងតូចខ្លះ ឬទេ ? ពួកភិក្ខុក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ នោះឯងជាមារមានចិត្តបាប កំពុងស្វែងរកបដិសន្ធិវិញ្ញាណរបស់គោធិកកុលបុត្រថា វិញ្ញាណរបស់គោធិកកុលបុត្របិតនៅក្នុងទីណា ម្នាលភិក្ខុទាំងឡាយ គោធិកកុលបុត្រ មានវិញ្ញាណមិនបានបិតនៅទេ បរិនិព្វានហើយ ។

គ្រានោះឯង មារមានចិត្តបាប យកពិណមានពណ៌លឿងដូចផ្លែឪឡឹក ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ក៏ពោលនឹងព្រះមានព្រះភាគដោយគាថាដូច្នេះថា ៖

ខ្ញុំព្រះអង្គបានស្វែងរក (វិញ្ញាណ)របស់គោធិកកុលបុត្រ ទិសខាងលើផង ខាងក្រោមផង ទិសទទឹងផង ទិសធំ ក្នុងទិសតូចផងមិនបានជួបប្រទះសោះឡើយ ចុះគោធិកៈនោះទៅក្នុងទីណា ? ព្រះមានព្រះភាគត្រាស់ថា គោធិកៈជាអ្នកប្រាជ្ញ បរិបូណ៌ដោយប្រាជ្ញា ជាអ្នកមានឈាន អ្នកត្រេកអរក្នុងឈានសព្វកាល ខំ ប្រឹងប្រែងទាំងថ្ងៃទាំងយប់ មិនគិតស្តាយជីវិត បានឈ្នះសេនារបស់មច្ចុ មិនមកកាន់កំពង់ទៀត ដកតណ្ហា ព្រមទាំងឫស បរិនិព្វាន

ហើយ ។ កាលមារនោះកំពុងត្រូវសោកគ្របសង្កត់ ពិណក៏របូតចេញអំពីក្លៀក តពីនោះមកយក្សនោះ ក៏មានសេចក្តីតូចចិត្តហើយក៏បាត់ចាកទីនោះទៅ ។

សូម្បីព្រះសាស្តាទ្រង់ត្រាស់ថា "មារមានចិត្តបាប អ្នកឯងត្រូវការអ្វី ដោយស្ថានទីដែលកុលបុត្រឈ្មោះ គោធិកៈកើតហើយ, ព្រោះមនុស្សជួចអ្នកទាំងរយទាំងពាន់ ក៏មិនអាចនឹងឃើញទីដែលគោធិកៈនោះកើតដែរ" ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា ៖

តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ
សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។

មារាធិរាជ "ទុកជាទំស្វែងរក" ក៏មិនជួបនូវផ្លូវរបស់លោកអ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ(ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **តេសំ** គឺនៃអ្នកដែលបរិនិព្វានដូចជា កុលបុត្រឈ្មោះគោធិកៈមានវិញ្ញាណមិនតាំងនៅ បរិនិព្វាន

ហើយ ដូច្នោះ ។

បទថា **សម្បន្នសីលានំ** គឺអ្នកមានសីលបរិបូណ៌ហើយ ។ បទថា **អប្បមាទវិហារិនំ** គឺអ្នកនៅដោយសេចក្តីមិនប្រមាទពោល គឺ មិនច្រាសចាកសតិ ។

បាទព្រះគាថាថា **សម្មទញ្ញា វិមុត្តានំ** សេចក្តីថា អ្នករួចផុតពិសេសហើយដោយវិមុត្តិ ៥ យ៉ាងគឺ (**តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ**) ព្រោះដឹងដោយហេតុ គឺដោយនយ ដោយការណ៍ ។

បាទព្រះគាថាថា **មារោ មគ្គំ ន វិន្ទតិ** សេចក្តីថា មារធិរាជសូម្បីស្វែងរកដោយពេញកម្លាំង ក៏រមែងមិនជួបគឺ រមែងមិនបានចំពោះ បានដល់ រមែងមិនឃើញផ្លូវរបស់ព្រះខីណាស្រពទាំងឡាយ បែបនេះធ្វើដំណើរទៅហើយ ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានមានជាប្រយោជន៍ដល់មហាជនដូច្នេះឯង ។

ឧដ្ឋានសូត្រ

នៅក្នុងបិដកលេខ ៥៤ ទំព័រ ១០៦ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់**ជាសង្ឃនាយកភិក្ខុទាំងឡាយកុំឱ្យមានសេចក្តីប្រមាទ** មានសេចក្តីថា ៖

១. អ្នកទាំងឡាយចូរក្រោក (ចូរអង្គុយចម្រើនកម្មដ្ឋាន) ប្រយោជន៍អ្វី ដោយការដេកលក់របស់អ្នកទាំងឡាយ ព្រោះថាអ្នកទាំងឡាយឈឺជានិច្ច ត្រូវសេវគីរាគាទិក្កិលេសចាក់ដោតហើយកំពុងតែលំបាក ម្តេចក៏នៅដេកលក់ ។

២. អ្នកទាំងឡាយចូរក្រោកអង្គុយ ចូរសិក្សាឱ្យមាំមួនដើម្បីសេចក្តីស្ងប់ កុំឱ្យមច្ចុរាជបានដឹងនូវអ្នកទាំងឡាយថា ជាអ្នកប្រមាទហើយធ្វើឱ្យវង្វេង លុះក្នុងអំណាចនៃខ្លួនឡើយ ។

៣. ពួកទេវតានឹងមនុស្ស ត្រូវការនឹងអារម្មណ៍ដើមអាស្រ័យជាប់នៅ(ក្នុងអារម្មណ៍) ព្រោះតណ្ហាណា អ្នកទាំងឡាយចូរឆ្លងនូវតណ្ហាជាគ្រឿងផ្សាយនុ៎ះ កុំឱ្យខណៈកន្លងផុតនូវអ្នកទាំងឡាយឡើយ ព្រោះថា ពួកជនដែលខណៈកន្លងហើយ រមែងសោកស្តាយណាន់ក្នុងនរក ។

៦. សេចក្តីប្រមាទជាធូលី ធូលីធ្លាក់ចុះតាមសេចក្តីប្រមាទ ព្រោះតែសេចក្តីប្រមាទ កុលបុត្រដកចោលនូវសេរ គឺរាគាទិក្កិលេស របស់ខ្លួនបាន ដោយវិជ្ជាគឺអាសវក្ខយញ្ញាណ ព្រោះតែសេចក្តីមិនប្រមាទ ។

សូត្រទី ៥

នៅក្នុងបិដកលេខ ៤០,ទំព័រ ១១០ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងជាមួយភិក្ខុទាំងឡាយអំពី (**គុណធម៌ ២ យ៉ាង**) មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ដឹងនូវធម៌ ២ ប្រការ គឺ ៖

- យា ច អសន្តុដ្ឋិតា កុសលេសុ ធម្មេសុ គឺសេចក្តីមិនសន្តោសក្នុងកុសលធម៌ទាំងឡាយ ១,

- យា ច អប្បដិវាណិតា បធានស្មឹ សេចក្តីមិនរួញរាក្នុងការព្យាយាម ១ ។

ម្នាលភិក្ខុទាំងឡាយ តថាគតផ្គងទុកនូវសេចក្តីមិនរួញរាថា ស្បែក សរសៃ ឆ្អឹង សូមឱ្យសល់នៅចុះ សាច់ឈាមក្នុងសរីរៈ ចូរហួតហែងទៅចុះ ក្នុងគុណវិសេសណា ដែលបុគ្គល

គួរបានដល់ដោយកម្លាំងរបស់បុរស ដោយព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស (បើ)មិនទាន់បានដល់នូវគុណវិសេសនោះទេ នឹងមិនបញ្ឈប់នូវសេចក្តីព្យាយាមទៅវិញឡើយម្នាលភិក្ខុទាំងឡាយ ពោធិញ្ញាណនៃតថាគតបានសម្រេចហើយដោយសេចក្តីមិនប្រមាទ ធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏តថាគតបានសម្រេចដោយសេចក្តីមិនប្រមាទដែរ ។

ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ គប្បីផ្តងទុកនូវសេចក្តីមិនរួញរាថា សៀក សរសៃ ឆ្អឹង សូមឱ្យសល់នៅចុះ សាច់នឹងឈាមក្នុងសរីរៈ ចូរហួតហែងទៅចុះ ក្នុងគុណវិសេសណាដែលបុគ្គលគួរបានដល់ដោយកម្លាំងរបស់បុរស ដោយព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស (បើ)មិនទាន់បានដល់នូវគុណវិសេសនោះទេ នឹងមិនបញ្ឈប់នូវសេចក្តីព្យាយាមទៅវិញឡើយ ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្រចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា សូម្បីអ្នកទាំងឡាយក៏បានធ្វើឱ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយធម៌ដោយប្រាជ្ញាដ៏ឧត្តមដោយ

ខ្លួនឯងក្នុងបច្ចុប្បន្ននេះ ដោយកាលមិនយូរឡើយ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សាក្នុងសាសនានេះយ៉ាងនេះចុះថា យើងទាំងឡាយនឹងផ្គងទុកនូវសេចក្តីមិនរួញរាថា ស្បែក សរសៃ ឆ្អឹង សូមឱ្យសល់នៅចុះ សាច់នឹងឈាមក្នុងសរីរៈ ចូរហួតហែងទៅចុះ ក្នុងគុណវិសេសណាដែលបុគ្គលគួរបានដល់ដោយកម្លាំងរបស់បុរស ដោយព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស (បើ) មិនទាន់បានដល់នូវគុណវិសេសនោះទេ នឹងមិនបញ្ឈប់នូវសេចក្តីព្យាយាមទៅវិញឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះ ។

អដ្ឋកថា

បទថា ទ្វិន្នាហំ កាត់បទជា ទ្វិន្នំ អហំ ។ បទថា ឧបញ្ញាសិ សេចក្តីថា បានចូលទៅដឹង គឺជ្រាបគុណ អធិប្បាយថា ត្រាស់ដឹង ។ ឥទ្បូវនេះ កាលនឹងទ្រង់សម្តែងធម៌ទាំងនោះ ទើបត្រាស់ព្រះពុទ្ធវចនៈថា យាច អសន្តុដ្ឋិតា ជាដើម ។ ព្រោះព្រះដ៏មានព្រះភាគទ្រង់អាស្រ័យធម៌ ២ នេះ សម្រេចព្រះសព្វញ្ញុតញ្ញាណ

ដូច្នោះ កាលនឹងទ្រង់សម្តែងអានុភាពរបស់ធម៌ ២ យ៉ាងនោះ ទើបត្រាស់យ៉ាងនេះ ។ បណ្តាបទពួកនេះ ដោយបទថា **អសន្តុដ្ឋិតា កុសលេសុ ធម្មេសុ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីដូច្នេះថា យើងមិនសន្តោសដោយត្រឹមតែឈាននិមិត្ត ឬដោយត្រឹមតែឱកាសនិមិត្ត ញុំាងអរហន្តមគ្គឱ្យកើតឡើងបានតែម្តង គឺយើងមិនសន្តោសដោយពេលវេលាដែលអរហន្តមគ្គ មិនទាន់កើតឡើង ។ និងយើងមិនទៀបណាយក្នុងសេចក្តីព្យាយាមដោយមិនធូរថយឡើយ បានធ្វើសេចក្តីព្យាយាម កាលនឹងទ្រង់សម្តែងសេចក្តីដូចពោលនេះ ទើបត្រាស់ព្រះពុទ្ធវចនៈថា **យា ច អប្បដិវាណិតា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អប្បដិវាណិតា** បានដល់សេចក្តីមិនឈានត្រឡប់គឺមិនធូរថយ ។ បទថា **សុធំ** ក្នុងបទថា **អប្បដិវាណំសុធាហំ ភិក្ខវេ បទហាសឹ** ត្រឹមតែជានិបាតក្នុងពាក្យនេះមានសេចក្តីដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតតាំងនៅក្នុងសេចក្តីមិនធូរថយ ប្រាថ្នាជាព្រះសព្វញ្ញុបានធ្វើសេចក្តី

ព្យាយាមកាលនៅជាពោធិសត្វ ។ ឥឡូវនេះ កាលនឹងទ្រង់សម្តែងវិធីធ្វើសេចក្តីព្យាយាម ទើបត្រាស់ព្រះពុទ្ធវចនថា កាមំ តចោ ច ជាដើម ។ បណ្តាបទទាំងនោះ ដោយបទថា យន្តំ នេះ ទ្រង់សម្តែងគុណជាតដែលនឹងគប្បីសម្រេច ។ ក្នុងបទថា បុរិសថាមេន ជាដើម ត្រាស់ដល់កម្លាំងដែលឱ្យកើតញាណ សេចក្តីព្យាយាមដែលឱ្យកើតញាណ សេចក្តីព្យាយាមដែលឱ្យកើតញាណរបស់បុរស ។ បទថា សណ្ឋានំ បានដល់ នៅគឺមិនប្រព្រឹត្តទៅ ធូរថយ អធិប្បាយថា រម្ងាប់ ។ ដោយព្រះពុទ្ធវចនត្រឹមតែប៉ុណ្ណេះឈ្មោះថា ព្រះអង្គត្រាស់សេចក្តីតាំងចិត្តមាំក្នុងការបំពេញព្យាយាមដែលប្រកបដោយអង្គ ៤ ។ និងក្នុងទីនេះបទថា កាមំ តចោ ជាអង្គមួយ ។ បទថា ន្ហារុ ច ជាអង្គមួយ ។ បទថា អដ្ឋិ ច ជាអង្គមួយ ។ បទថា មំសលោហិតំ ជាអង្គមួយ ។ អង្គ ៤ ទាំងនេះ ។

បទថា បុរិសថាមេន ជាដើម ជាឈ្មោះរបស់សេចក្តី

ព្យាយាមយ៉ាងក្រៃលែងបំផុត ។ សេចក្តីព្យាយាមដែលប្រកបដោយអង្គ ៤ ខាងដើមដោយប្រការដូច្នេះ តាំងមាំហើយយ៉ាងនេះ គប្បីជ្រាបថា ឈ្មោះថា ការតាំងសេចក្តីព្យាយាមដែលប្រកបដោយអង្គ ៤ ។ ដោយព្រះពុទ្ធវចនត្រឹមតែប៉ុណ្ណេះជាការព្រះអង្គត្រាស់បដិបទាជាហេតុសម្រេចធម៌របស់ព្រះអង្គក្នុងពោធិបល្ល័ង្ក ។

ឥឡូវនេះ ដើម្បីនឹងត្រាស់គុណដែលព្រះអង្គ បានមកដោយបដិបទានោះ ទើបត្រាស់ព្រះពុទ្ធវចនថា **តស្ស មយ្ហំ ភិក្ខវេ** ជាដើម បណ្តាបទទាំងនេះបទថា **អប្បមាទាធិគតា** សេចក្តីថា បានហើយដោយសេចក្តីមិនប្រមាទ ពោលគឺ សេចក្តីមិននៅប្រាសចាកសតិ ។ បទថា **ពោធិ** បានដល់ ចតុមគ្គញ្ញាណនិងសព្វញ្ញុតញ្ញាណ ។ ដោយថា អ្នកដែលស្រឹងប្រមាទមិនអាចសម្រេចចតុមគ្គញ្ញាណ និងសព្វញ្ញុតញ្ញាណនោះបាន ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា **អប្បមាទាធិគតា ពោធិ** ដូច្នេះ ។ បទថា **អនុត្តរោ យោគក្ខេមោ** សេចក្តីថា មិនមែនតែបញ្ជាគ្រឿងត្រាស់ដឹងតែម្យ៉ាងប៉ុណ្ណោះ សូម្បីធម៌ដែលរួចផុតអំពីគ្រឿងដ៏ប្រសើរ ពោលគឺ អរហត្តផល និព្វាន យើងក៏បានសម្រេច

ដោយសេចក្តីមិនប្រមាទនោះឯង ។

ឥឡូវនេះ កាលនឹងទ្រង់ឱ្យភិក្ខុសង្ឃប្រកាន់ក្នុងគុណដែលព្រះអង្គបានមក ទើបត្រាស់ព្រះពុទ្ធវចនថា តុម្ហេ ខេបិ ភិក្ខវេ ជាដើម ។ បណ្តាបទទាំងនេះ បទថា យស្សត្ថាយ សេចក្តីថា ដើម្បីប្រយោជន៍ដល់ផលដែលជាទីបំផុត នៃព្រហ្មចរិយយ៉ាងណា អធិប្បាយថា ជាអ្នកប្រាថ្នាដើម្បីនឹងចូលដល់ផលដ៏ប្រសើរបំផុតនៃព្រហ្មចរិយនោះ ។ បទថា តទនុត្តរំ បានដល់ ផលដ៏កំពូលក្រៃលែង ។ បទថា ព្រហ្មចរិយបរិយោសានំ បានដល់ អរិយផលដែលជាទីបំផុតនៃមគ្គព្រហ្មចរិយ ។ បទថា អភិញ្ញា សច្ឆិកត្វា សេចក្តីថា ធ្វើឱ្យប្រចក្សដោយបញ្ញាដ៏ក្រៃលែង គឺ ដោយបញ្ញាដ៏ខ្ពស់បំផុត ។ បទថា ឧបសម្បជ្ជ វិហរិស្សថ សេចក្តីថា នឹងបានចំពោះគឺ សម្រេច ។ បទថា តស្មា សេចក្តីថា ព្រោះធម្មតាសេចក្តីព្យាយាមយ៉ាងមិនធូរថយនេះមានឧបការៈច្រើនឱ្យសម្រេចប្រយោជន៍ហើយ ។

អដ្ឋកថាមហាសតិប្បដ្ឋានសូត្រ

នៅក្នុងអដ្ឋកថា មហាសតិប្បដ្ឋានសូត្រលេខ ១៤, ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់សម្តែងអំពី **[ធម៌ជាហេតុនាំឱ្យកើតវីរិយសម្ពោជ្ឈង្គ ១១ ប្រការ]** មានសេចក្តីថា ៖

ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃវីរិយសម្ពោជ្ឈង្គ: គឺ ៖

១- ការពិចារណាឃើញភ័យក្នុងអបាយ ។

២- ការឃើញអានិសង្ស ។

៣- ការពិចារណាវិថីនៃដំណើរ ។

៤- ការគោរពកោតក្រែងក្នុងបិណ្ឌបាត ។

៥- ការពិចារណាភាពជាធំនៃការទទួលទ្រព្យមត៌ក ។

៦- ការពិចារណាក្នុងការមានព្រះសាស្តាជាធំ ។

៧- ការពិចារណាការមានជាតិជាធំ ។

៨- ការពិចារណាការមានសព្រហ្មចារីជាធំ ។

៩- ការវៀរចាកបុគ្គលខ្ជិលច្រអូស ។

១០- ការគប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម ។

១១- ការបង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គៈនោះ ។

១- ការពិចារណាឃើញតំយក្ខុងអបាយ

បណ្តាធម៌ ១១ ប្រការនោះ កាលភិក្ខុចម្រើនវីរិយ-សម្ពោជ្ឈង្គៈ សូម្បីពិចារណាឃើញភ័យក្នុងអបាយយ៉ាងនេះថា នរណា ៗ មិនអាចញុំងវីរិយសម្ពោជ្ឈង្គៈឱ្យកើតបាន ក្នុងវេលាដែលសោយទុក្ខធំ ចាប់ផ្តើមពីត្រូវដាក់ទោសដោយគ្រឿងឃុំឃាំង ៥ ប្រការ ក្នុងនរកក្តី ក្នុងវេលាដែលត្រូវគេចាប់ដោយគ្រឿងចាប់មានអន្ទាក់សំណាញ់ និងអួនជាដើមខ្លះ ក្នុងវេលាដេញ កៀង រុកចាក់ដោយគ្រឿងប្រហារ មានជន្លួញជាដើម ឱ្យទាញរទេះខ្លះ ក្នុងកំណើតសត្វតិរច្ឆានក្តី ក្នុងវេលាដែលទុរន់ទុរាដោយការស្រេកឃ្លានក្តៅក្រហាយច្រើនពាន់ឆ្នាំខ្លះ មួយពុទ្ធន្តរខ្លះ ក្នុងប្រេតវិស័យក្តី ក្នុងវេលាដែលត្រូវសោយទុក្ខ ដែលកើតពីខ្យល់និងកំដៅថ្លៃជាដើមដោយផ្ទះដែលខ្ពស់ប្រមាណ ៦០ហត្ថ ៨០ហត្ថនៅសល់តែស្បែកជណ្តប់ឆ្អឹង ក្នុងពួកកាលកញ្ចិកអសុរក្តី ម្នាលភិក្ខុ វេលានេះប៉ុណ្ណោះ

ជាវេលាធ្វើសេចក្តីព្យាយាមរបស់អ្នក ដូច្នេះ **វិរិយសម្ពោជ្ឈង្គៈ** រមែងកើតឡើងបាន ។

២. ការយើញអានិសង្ស

កាលយើញអានិសង្សយ៉ាងនេះថា អ្នកខ្ជិលច្រអូស មិនអាចបាននូវលោកុត្តរធម៌៩អ្នកដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះទើបអាច នេះជាអានិសង្សរបស់សេចក្តីព្យាយាម ដូច្នេះ **វិរិយសម្ពោជ្ឈង្គៈ** ក៏រមែងកើតបាន ។

៣. ការពិចារណាវិថីនៃដំណើរ

កាលពិចារណាវិថីនៃដំណើរយ៉ាងនេះថា គួរដើរតាមផ្លូវដែលព្រះមានព្រះភាគព្រះបច្ចេកពុទ្ធ ព្រះមហាសាវ័កគ្រប់ព្រះអង្គធ្វើដំណើរទៅហើយ ផ្លូវនោះ អ្នកខ្ជិលច្រអូសមិនអាចដើរទៅបាន ដូច្នេះ **វិរិយសម្ពោជ្ឈង្គៈ** ក៏រមែងកើតបាន ។

៤. ការគោរពកោតក្រែងចំពោះបិណ្ឌបាត

កាលពិចាណាដល់ការគោរពកោតក្រែង ចំពោះបិណ្ឌបាតយ៉ាងនេះថា មនុស្សពួកណាទំនុកបម្រុងលោកដោយបច្ច័យ មាន

បិណ្ឌបាតជាដើមមនុស្សទាំងនោះមិនមែនញាតិមិនមែនទាស់ទិង
អ្នកការងារបស់លោកឡើយ ទាំងមនុស្សទាំងនោះ ក៏មិនមែន
ថ្វាយបច្ច័យ មានចីវរជាដើមដែលប្រណីតដល់លោក ដោយគិត
ថា នឹងអាស្រ័យលោកចិញ្ចឹមជីវិតតែដែលពិតគេប្រាថ្នាឱ្យឧបការៈ
ចំពោះខ្លួន ធ្វើហើយមានផលច្រើន ទើបថ្វាយ សូម្បីព្រះសាស្តា ក៏
មិនបានទ្រង់ពិចារណាឃើញយ៉ាងនេះថា ភិក្ខុនេះបរិភោគបច្ច័យ
ទាំងនេះហើយ នឹងមានរាងកាយរឹងមាំច្រើន នៅជាសុខដូច្នេះ ហើយ
ទ្រង់អនុញ្ញាតបច្ច័យដល់លោក ដោយពិត ព្រះអង្គទ្រង់ពិចារណា
ឃើញថា ភិក្ខុបរិភោគបច្ច័យទាំងនេះបំពេញសមណធម៌ នឹងផុត
ចាកទុក្ខក្នុងវដ្តៈបាន ដូច្នេះ ទើបទ្រង់អនុញ្ញាតបច្ច័យទុក ឥឡូវនេះ
លោកវិលច្រអូស មិនគោរពកោតក្រែងក្នុងបិណ្ឌបាតនោះ ដែល
ឈ្មោះថា ការគោរពកោតក្រែងចំពោះបិណ្ឌបាត រមែងមានដល់
អ្នកប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ដូច្នេះ **វីរិយសម្ពោជ្ឈង្គៈក៏កើត**
បានដូចវីរិយសម្ពោជ្ឈង្គៈកើតដល់ព្រះមហាមិត្តត្ថេរ ដូច្នោះ ។

រឿងព្រះមហាមិត្តត្ថេរ

បានឮមកថា ព្រះថេរៈអាស្រ័យនៅក្នុងស្អាងឈ្មោះកសកៈ ។ និងមហាឧបាសិកាម្នាក់ក្នុងស្រុក ជាទីគោចរបស់លោក ទំនុកបម្រុងព្រះថេរៈដូចបុត្រ ។ ថ្ងៃមួយ នាងនឹងទៅព្រៃទើបប្រាប់កូនស្រីថា កូន ! អង្ករនៅឯណោះ ទឹកដោះ ទឹកដោះថ្លា ទឹកអំពៅនៅឯណោះ លោកម្ចាស់មិត្តៈ បងប្រុសរបស់នាងមកហើយ ចូរផ្សំអាហារថ្វាយ ព្រមដោយទឹកដោះ ទឹកដោះថ្លា និងទឹកអំពៅផងណាកូន ។ កូនស្រីសួរថា ក៏ម៉ែនឹងទទួលទានទេថ៎ា ។ មហាឧបាសិកាឆ្លើយថា កាលថ្ងៃម្សិលមិញ ម៉ែហូបអាហារដែលទុក ១ យប់ (បាវិវាសកភត្ត) ដែលផ្សំនឹងទឹកដោះជូរនោះហើយ ។ កូនស្រីសួរថា ម៉ែនឹងពិសារពេលថ្ងៃទេ ។ មហាឧបាសិកាប្រាប់ថា នាងចូរដាក់បន្លែជ្រក់ ហើយយកកញ្ចងអង្ករបបរ មានរសជូរទុកឱ្យម៉ែចុះ ។ ព្រះថេរៈគ្រងចីវរ ហើយកំពុងនាបាត្រចេញ(ពីស្ងោក) បានឮសំឡេងនោះហើយ ក៏ទូន្មានខ្លួនឯងថា បានឮថា មហាឧបាសិកា ហូបតែអាហារដែលទុក ១ យប់ និងទឹកដោះជូរ សូម្បីពេលថ្ងៃ ក៏នឹងទទួលទានបបរជូរ ជាក់បន្លែជ្រក់

នាងប្រាប់អាហារមានបាយ ជាដើម ដើម្បីប្រយោជន៍ដល់លោក ក៏មហាឧបាសិកានោះមិនបានប្រាថ្នាទីស្រែទីសួនអាហារនិងសម្ពត់ ព្រោះអាស្រ័យលោកឡើយ តែប្រាថ្នាសម្បត្តិ ៣ ប្រការ (មនុស្សសម្បត្តិ សួគ៌សម្បត្តិ និព្វានសម្បត្តិ) ទើបប្រគេនលោកនឹងអាចឱ្យសម្បត្តិទាំងនោះ ដល់មហាឧបាសិកានោះ ឬបានទេហ្ន៎ ដូច្នេះ លោកគិតថា បិណ្ឌបាតនេះឯង យើងនៅមានរាគៈ ទោសៈ មោហៈ នៅមិនអាចទទួលបាន ដូច្នេះហើយ ក៏ទុកបាត្រក្នុងស្មោក ដោះកុំចីវរ ត្រឡប់ទៅល្អាងកសកៈ រក្សាបាត្រទុកក្រោមត្រែ ពាក់ចីវរ ទុកត្រង់ស្នួរចីវរ អង្គុយចុះអធិដ្ឋានសេចក្តីព្យាយាមថា បើយើងមិនសម្រេចព្រះអរហត្ត នឹងមិនចេញទៅពីល្អាងដូច្នេះ ។ ភិក្ខុដែលមិនប្រមាទមកអស់កាលជា យូរអង្វែងហើយ ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្តមុន វេលាអាហារព្រឹកជាព្រះមហាខីណាស្រព (អស់អាសវៈហើយ) អង្គុយញញឹមដូចផ្កាបទុមដែលកំពុងរីកដូច្នោះ ។ ទេវតាស្ថិតនៅដើមឈើ ជិតទ្វារល្អាង បន្លឺឧទានថា ៖

ឥមោ តេ បុរិសាជញ្ញ ឥមោ តេ បុរិសុត្តម

យស្ស តេ អាសវា ខីណា ឧក្ខិណោយ្យាសិ មានិស

លោកជាបុរសអាជានេយ្យ ខ្ញុំសូមមនស្ការលោក លោកជាកំពូលបុរស ខ្ញុំសូមនមស្ការលោក ខ្ញុំសូមនមស្ការលោក អ្នកមានអាសវៈអស់ហើយ លោកអ្នកនិរទុក្ខ លោកជាអ្នកគួរដល់ទក្ខិណាទាន ដូច្នេះ ។

ហើយពោលថា លោកម្ចាស់ពួកស្ត្រីថ្វាយអាហារដល់ព្រះអរហន្តទាំងឡាយ ដូចលោកម្ចាស់អ្នកចូលទៅបិណ្ឌបាត និងផុតពីទុក្ខបាន ដូច្នេះ ។

ព្រះថេរៈក្រោកឡើងបើកទ្វារមើលវេលាជ្រាបថានៅព្រឹកទើបកាន់បាត្រ និងចីវរចូលកាន់ស្រុក ចំណែកក្មេងស្រីត្រៀមអាហារសម្រេចហើយ អង្គុយចាំមើលនៅត្រង់ទ្វារ ដោយនឹកថា មួយភ្លែតបងប្រុសយើងគង់និងមក មួយភ្លែតបងប្រុសយើងគង់និងមក ។ កាលព្រះថេរៈមកដល់ទ្វារផ្ទះហើយ ក្មេងស្រីនោះ ក៏ទទួលបាត្រដាក់ពេញដោយអាហារលាយទឹកដោះដែលផ្សំដោយទឹកដោះថ្លា និងទឹកអំពៅហើយដាក់លើដៃ (របស់ព្រះថេរៈ) ។ ព្រះថេរៈធ្វើអនុមោទនាថា ចូរបានសុខចុះ ហើយក៏ចៀសចេញ

ទៅ ។ ក្មេងស្រីនោះឈរសម្លឹងមើលលោកហើយ ។ សេចក្តីពិតក្នុងគ្រានោះ ពណ៌សម្បុរបស់ព្រះថេរៈ បរិសុទ្ធក្រៃលែងណាស់ ឥន្ទ្រិយថ្លាផូរផង់មុខរបស់លោកស្រស់បស់ក្រៃលែងណាស់ ដូចផ្លែត្នោតទុំជ្រះចាកទង ដូច្នោះ ។ មហាឧបាសិកាត្រឡប់មកពីព្រៃសួរថា បង់ប្រុសរបស់នាងមកហើយឬកូន ។ ក្មេងស្រីនោះ ក៏ប្រាប់រឿងទាំងអស់ឱ្យមាតាស្តាប់ ។ មហាឧបាសិកាក៏ដឹងបានថា ថ្ងៃនេះ កិច្ចបព្វជិតនៃបុត្ររបស់យើងដល់ទីបំផុតហើយ ទើបពោលថា កូន ! បង់ប្រុសរបស់នាង ត្រេកអរក្រៃលែងណាស់ក្នុងព្រះពុទ្ធសាសនា មិនអផ្សុក(ចង់សឹក)ឡើយ ដូច្នេះ ។

៥. ការពិចារណាការមានទ្រព្យមតិកជាធំ

កាលពិចារណា ការមានទ្រព្យមត៌កជាធំយ៉ាងនេះថា ក៏ទ្រព្យមត៌ករបស់ព្រះសាស្តាមានច្រើន គឺ អរិយទ្រព្យ ៧ ប្រការ ទ្រព្យមត៌កនោះ អ្នកឰលច្រអូសមិនអាចទទួលបាន ដូចជា មាតាបិតា រមែងកាត់កាឡបុត្រអ្នកប្រព្រឹត្តខុស ធ្វើឱ្យជាអ្នកខាងក្រៅថា អ្នកនេះមិនមែនជាកូនរបស់យើង កាលមាតាបិតាស្លាប់ទៅ គេក៏មិនបានទទួលទ្រព្យមត៌កយ៉ាងណា សូម្បីបុគ្គលអ្នកឰលច្រអូស

ក៏ដូច្នោះ រមែងមិនបានមគ៌ាក គឺអរិយទ្រព្យនេះ អ្នកប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ រមែងបានទទួលដូច្នេះ **វិរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។**

៦. ការពិចារណាការមានព្រះសាស្តាជាធំ

កាលពិចារណា ការមានព្រះសាស្តាជាធំយ៉ាងនេះថា ព្រះសាស្តារបស់យើងជាធំ ព្រោះក្នុងវេលាដែលព្រះសាស្តារបស់យើង ទ្រង់ចាប់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះមាតាក្តី វេលាស្តេចចេញមហាភិនេស្ក្រមក្តី វេលាត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណក្តី វេលាប្រកាសព្រះធម្មចក្រសម្តែងយមកបាដិហារ្យ ស្តេចចុះចាកពីទេវលោកនិងទ្រង់ជាក់អាយុសង្ខារក្តី វេលាស្តេចរលត់ខន្ធបរិនិព្វានក្តី ម៉ឺនលោកធាតុ ក៏ញាប់ញ័រហើយ យើងបួសក្នុងព្រះសាសនារបស់សាស្តាបែបនេះហើយ ជាអ្នកឱ្យលប្រអូសគួរឬទេ ដូច្នេះ **វិរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។**

៧. ការពិចារណាការមានជាតិជាធំ

កាលពិចារណាការមានជាតិជាធំយ៉ាងនេះថា សូម្បីដោយជាតិឥឡូវនេះ យើងមិនមែនជាអ្នកមានជាតិទន់ទាបនោះទេ យើង

ឈ្មោះថា កើតហើយក្នុងវង្សរបស់ព្រះបាទឧក្កាកពាជ ដែលបន្តវង្ស
គ្នាមកដោយមហាសម្មតិបវេណី មិនលាយជាមួយនឹងជនជាតិដទៃ
ជាព្រះនត្តារបស់ព្រះបាទសុទ្ធោទនមហារាជ និងព្រះនាងមហាមា-
យាទេវីជាព្រះអនុជរបស់ព្រះរាហុលពុទ្ធជិនោរសដែលឈ្មោះថា
យើងជាពុទ្ធជិនបុត្រ បែបនេះហើយ នៅជាអ្នកខ្វិលច្រអូស មិន
សមគួរ ដូច្នេះ **វីរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។**

៨. ការពិចារណាការមានសព្រហ្មចារីជាធំ

កាលពិចារណា ការមានសព្រហ្មចារីជាធំ យ៉ាងនេះថា ព្រះ
សារីបុត្រព្រះមោគ្គល្លាន និងព្រះមហាសាវក ៨០ រូប លោកចាក់
ធ្លុះ(គ្រាស់ជីង)លោកុត្តរធម៌ ដោយសេចក្តីព្យាយាមទាំងនោះ
យើងនឹងដើរតាមផ្លូវរបស់សព្រហ្មចារីទាំងនោះ ឬមិនដើរតាមហ្ន៎
ដូច្នេះ **វីរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។**

៩. ការចៀរចាកបុគ្គលអ្នកខ្វិលច្រអូស

១០. ការគប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម

១១. ការបង្ខោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គៈនោះ

កាលចៀរបុគ្គលអ្នកខ្វិលច្រអូសអ្នកលះបង់សេចក្តីព្យា-

យោមផ្លូវកាយ និងផ្លូវចិត្ត ដូចជាពោះថ្ងាន់ស៊ីពេញពោះហើយ ក៏ឈប់នឹងក្តី គប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម អ្នកឧទ្ទិសខ្លួនប្រាថ្នាបដិបត្តិធម៌ក្តី មានចិត្តបង្អោនទៅដើម្បីឱ្យសេចក្តីព្យាយាមកើតឡើង ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើមក្តី **វិរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។**

ភិក្ខុរមែងដឹងច្បាស់ថា វិរិយសម្ពោជ្ឈង្គៈនោះ ដែលកើតហើយដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ ដោយអរិយហត្ថមគ្គ ។

គុណសម្បត្តិរបស់បុគ្គលធ្វើព្រះនិព្វានឱ្យជាក់ច្បាស់

នៅក្នុងគម្ពីរធម្មាវលី ទំព័រ ១៥០ លោកបានសម្តែងអំពីបុគ្គលដែលបានសម្រេចជាសោតាបត្តិផល រមែងប្រសើរជាងរបស់ ៣ គឺ ៖

១~ ប្រសើរ ជាងសេចក្តីជាឯកាធិបតីនៅលើផែនដី ។

២~ ប្រសើរ ជាងដំណើរទៅកាន់ទេវលោក ។

៣~ ប្រសើរ ជាងភាពជាធំនៅក្នុងលោកទាំងពួង ។

ម្យ៉ាងទៀតបុគ្គលដែលបានសម្រេចជាព្រះសោតាបន្ននោះ ឈ្មោះថាជាអ្នកបានធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ហើយ ទោះបីលោកនៅមានជាតិកំណើត ៧ ជាតិក៏ដោយ ។ អង្គរបស់ព្រះសោតាបន្នមាន ៤ គឺ ៖

១- ជ្រើមាំក្នុងគុណព្រះពុទ្ធ ។

២- ជ្រើមាំក្នុងគុណព្រះធម៌ ។

៣- ជ្រើមាំក្នុងគុណព្រះសង្ឃ ។

៤- មានសីល ៥ ពេញបរិបូណ៌ជាសមុច្ឆេទ ។

និងមានព្រះសូត្រដទៃទៀតដូចជា ៖

វិត្ថារសូត្រ

នៅក្នុងបិដកលេខ ៤៣, ទំព័រ ២២ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងជាមួយភិក្ខុទាំងឡាយអំពី **(បដិបទា ៤ យ៉ាង)** ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ ។ **បដិបទា ៤ គឺអ្វីខ្លះ ?**

១- ទុក្ខា បដិបទា ឧត្តាភិញ្ញា គឺប្រតិបត្តិលំបាក ទាំង

គ្រាស់ដឹងដ៏ឃឺតយូរ ១

២- ទុក្ខា បដិបទា **ខិប្បាភិញ្ញា** ប្រតិបត្តិលំបាក តែគ្រាស់ដឹងឆាប់ ១

៣- **សុខា** បដិបទា **ឧន្ធាភិញ្ញា** ប្រតិបត្តិស្រួល តែគ្រាស់ដឹងឃឺតយូរ

៤- **សុខា** បដិបទា **ខិប្បាភិញ្ញា** ប្រតិបត្តិស្រួល ទាំងគ្រាស់ដឹងក៏ឆាប់ ។

➪. ម្នាលភិក្ខុទាំងឡាយ **ចុះប្រតិបត្តិលំបាក ទាំងគ្រាស់ដឹងដ៏ឃឺតយូរ** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្តីបដិកូលក្នុងអាហារ កំណត់សេចក្តីមិនត្រេកអរក្នុងលោកទាំងពួង ឃើញនូវសេចក្តីមិនទៀងក្នុងសង្ខារទាំងពួង មួយទៀតភិក្ខុនោះកំណត់សេចក្តីស្លាប់ ដម្កល់ទុកដោយប្រពៃឰដ៏ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យសេក្ខពល(ធម៌ជាកម្លាំងរបស់ព្រះសេក្ខៈ ៥ នេះគឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះគឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមា-

ឥន្ទ្រិយ បញ្ញិន្ទ្រិយ នៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ ភិក្ខុនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយ បានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងយឺតយូរ ។**

⇨. ម្នាលភិក្ខុទាំងឡាយ **ចុះប្រតិបត្តិលំបាក ទាំងត្រាស់ដឹងឆាប់** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្តីបដិកូលក្នុងអាហារ កំណត់សេចក្តីមិនត្រេកអរក្នុងលោកទាំងពួង ឃើញទូវសេចក្តីមិនទៀងក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះ កំណត់សេចក្តីស្លាប់ ជម្កាល់ទុកដោយប្រពៃព្ធដ៏ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យសេក្ខពល(ធម៌ជាកម្លាំងរបស់ព្រះសេក្ខៈ) ៥ នេះគឺ សទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះគឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ ភិក្ខុនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈ

ទាំងឡាយបានឆាប់ ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា**គឺប្រតិបត្តិលំបាក តែត្រាស់ដឹងឆាប់** ។

➪. ម្នាលភិក្ខុទាំងឡាយ **ចុះប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនឹងវិចារៈ មានបីតិនឹងសុខៈដែលកើតអំពីសេចក្តីស្ងប់ស្ងាត់នោះ ភិក្ខុនោះ ព្រោះស្ងប់ស្ងាត់ចាកវិតក្កៈនឹងវិចារៈ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មានតែបីតិនឹងសុខៈ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ភិក្ខុ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏បានដល់នូវតតិយជ្ឈាននោះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខ

ផង ព្រោះអស់ទៅនៃសោមនស្សនឹងទោមនស្សក្នុងកាលមុន ក៏បានដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខាមានសតិដ៏បរិសុទ្ធិដោយឧបេក្ខា ។ ភិក្ខុនោះតែងអាស្រ័យនូវសេក្ខពល ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជាធម្មជាតទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ ភិក្ខុនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **គឺប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ។**

➪. ម្នាលភិក្ខុទាំងឡាយ **ចុះប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏បានឆាប់** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ (ស្ងាត់ចាកអកុសលទាំងឡាយ បានទូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនឹងវិចារៈ(មានបីតិនឹងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់នោះ ភិក្ខុនោះ ព្រោះស្ងប់ស្ងាត់ចាកវិតក្កៈនឹងវិចារៈ) ក៏ដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺ សទ្ធាមានសភាពជាចិត្ត

ខ្ពស់ឯក មិនមានវិតក្កៈ មានតែបីតិនឹងសុខៈដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ភិក្ខុ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏ដល់នូវតតិយជ្ឈាននោះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្សនឹងទោមនស្សក្នុងកាលមុន ក៏ដល់នូវចតុជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធិដោយឧបេក្ខា ។ ភិក្ខុនោះតែអាស្រ័យនូវសេក្ខពល ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះ ក្លៀវក្លាដែរ ភិក្ខុនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានយ៉ឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **គឺប្រតិបត្តិទន្ទ្រេលតែត្រាស់ដឹងក៏បានឆាប់** ។

អដ្ឋកថា

បទថា អភិក្កណ្ហំ ប្រែថា រឿយ ៗ ។

បទថា អនន្តរិយំ បានដល់ មគ្គសមាធិដែលឱ្យផលជាអនន្តរិយគុណ ។

បទថា អាសវានំ ខយោ បានដល់ ដើម្បីអរហត្តផល ។

បទថា បញ្ចិន្ទ្រិយានិ បានដល់ឥន្ទ្រិយ៥ដែលមានវិបស្សនាជាទី៥ ។ ក៏ក្នុងបទថា បញ្ចិន្ទ្រិយំ នេះ លោកប្រាថ្នាយកវិបស្សនាបញ្ញាប៉ុណ្ណោះថា **បញ្ចិន្ទ្រិយ** ។ ពាក្យដែលនៅសល់ក្នុងសូត្រនេះងាយទាំងអស់ដោយអំណាច ដែលគ្រាស់ទុកហើយក្នុងបាលី ។

ក៏កថាចែកបដិបទាទាំងនេះមានដូច្នេះ ។

ភិក្ខុក្នុងធម្មវិន័យនេះ មិនធ្លាប់ធ្វើការប្រកាន់មកខាងដើម រមែងលំបាកក្នុងការកំណត់រូប រមែងលំបាកក្នុងការកំណត់អរូប រមែងលំបាកក្នុងការកំណត់បច្ចយ រមែងលំបាកក្នុងកាលទាំងបី រមែងលំបាកក្នុងមគ្គាមគ្គៈផ្លូវនិងមិនមែនផ្លូវ កាលលំបាកក្នុងហានៈ៥យ៉ាងនេះ រមែងសម្រេចវិបស្សនា គ្រាសម្រេចវិបស្សនាហើយ

ក៏លំបាកក្នុងវិបស្សនាញាណ ៩ ទាំងនេះគឺ **ក្នុងឧទយព្វយានុបស្សនាញាណ** (ប្រាជ្ញាពិចារណាឃើញទាំងការកើតនិងសេចក្តីរលត់) ១ **ក្នុងភង្គានុបស្សនាញាណ** (ប្រាជ្ញាពិចារណាឃើញសេចក្តីរលត់) ១ **ក្នុងភយឧបដ្ឋានញាណ** (ប្រាជ្ញាពិចារណាឃើញសង្ខារប្រាកដជារបស់គួរខ្លាច) ១ ក្នុងអាទីនវានុបស្សនាញាណ (ប្រាជ្ញាពិចារណាឃើញទោស) ១ **ក្នុងនិព្វិទានុបស្សនាញាណ** (ប្រាជ្ញាពិចារណាដល់សេចក្តីនឿយណាយ) ១ **ក្នុងមុញ្ចិតុកាមតាញាណ** (ប្រាជ្ញាពិចារណាដោយប្រាថ្នានឹងរួចផុតទៅ) ១ **ក្នុងសង្ខារុបេក្ខាញាណ** (ប្រាជ្ញាពិចារណាដោយសេចក្តីព្រងើយក្នុងសង្ខារ) ១ **ក្នុងអនុលោមញាណ** (ប្រាជ្ញាពិចារណាដោយសមគួរដល់ការកំណត់ដឹងអរិយសច្ច) ១ ក្នុងគោត្រភូញាណ (ប្រាជ្ញាកំណត់ដឹងញាណដែលជាលំដាប់អរិយមគ្គ) ១ និងទើបសម្រេចលោកុត្តរមគ្គ លោកុត្តរមគ្គរបស់ភិក្ខុនោះ ឈ្មោះថាបដិបត្តិលំបាក ទាំងដឹងលំបាក ព្រោះធ្វើឱ្យច្បាស់ដោយសេចក្តីទុក្ខយ៉ាងនេះ ក៏ភិក្ខុណាខាងដើមលំបាកក្នុងញាណ ៥ តែខាង

ចុងមិនលំបាកក្នុងវិបស្សនាញាណ ៩ រមែងធ្វើឱ្យច្បាស់នូវមគ្គ មគ្គនោះរបស់ភិក្ខុនោះឈ្មោះថា **បដិបត្តិលំបាក តែដឹងបានរហ័ស** ព្រោះធ្វើឱ្យច្បាស់ដោយមិនធ្ងន់ដោយទុក្ខយ៉ាងនេះ ។ បដិបទាពីរទៀត ក៏គប្បីជ្រាបដោយឧបាយនេះ ។

មួយទៀត បដិបទាទាំងនេះនឹងគប្បីជាក់ច្បាស់ក៏ដោយប្រការឧបមាប្រៀបធៀបដោយអ្នករកគោ ។ គោ ៤ ក្បាលរបស់បុរសម្នាក់គេចដៀសចូលទៅក្នុងព្រៃ ។ គេរកគោទាំងនោះក្នុងព្រៃដែលមានបន្ទាក្រាស់ស្តុក ផ្លូវដែលទាក៏ទៅដោយសេចក្តីលំបាក គោលាក់ខ្លួននៅក្នុងព្រៃដែលក្រាស់ស្តុកដូច្នោះ ក៏ឃើញដោយសេចក្តីលំបាក ។ ប្រុសម្នាក់ទៅដោយសេចក្តីលំបាកគោឈរក្នុងទីវាល ក៏ឃើញបានឆាប់រហ័សភ្លាម ។ ទៀតម្នាក់ទៅផ្លូវខ្វែងមិនក្រាស់ស្តុក គោលាក់ខ្លួននៅចេញក្នុងទីក្រាស់ស្តុក ក៏ឃើញដោយសេចក្តីលំបាក ។ ម្នាក់ទៀតទៅសប្បាយតាមផ្លូវខ្វែង គោឈរក្នុងទីខ្វែងក៏ឃើញបានឆាប់រហ័ស ។ ក្នុងប្រការឧបមានោះ អរិយ-មគ្គ ៤ គប្បីឃើញដូចគោ ៤ តួព្រះយោគាវចរដូចប្រុសរកគោ ការបដិបត្តិលំបាកក្នុងខាងដើម របស់ភិក្ខុដែលលំបាកក្នុងញាណ

៥ ដូចទៅផ្លូវក្រាស់ស្តុកដោយសេចក្តីលំបាក ការយើញអរិយ-មគ្គ ក្នុងខាងចុងរបស់អ្នកនឿយហត់នឿយនាយក្នុងញាណ ៩ ដូចការយើញគោ ដែលលាក់ខ្លួននៅក្នុងព្រៃក្រាស់ស្តុកសេចក្តីលំបាក ។ គប្បីយើញសូម្បីប្រការឧបមាដែលនៅសល់ដោយឧបាយនេះ ។

សេនាសនៈសូត្រ

នៅក្នុងបិដកលេខ ៥០, ទំព័រ ៣២ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងជាមួយភិក្ខុទាំងឡាយអំពី [**ភិក្ខុអ្នកប្រកបដោយអង្គ ៥ សេពសេនាសនៈប្រកបដោយអង្គ ៥ រមែងអស់អាសវៈក្នុងវេលាមិនយូរ**] ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ កាលសេពគប់នូវសេនាសនៈ ដែលប្រកបដោយអង្គ ៥ មិនយូរប៉ុន្មានគប្បីធ្វើឱ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈទាំងឡាយដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ **ភិក្ខុប្រកបដោយអង្គ ៥ តើដូចម្តេច ។**

➲. ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះមានសទ្ធា

ជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គ នោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈជា ព្រះសុគតជ្រាបច្បាស់នូវត្រៃលោក ទ្រង់សរសើរដោយសីលា-ទិគុណរកបុគ្គលណាមួយស្មើគ្មាន ជាសាវជីទូន្មាននូវបុរស ជា សាស្តានៃទេវតានិងមនុស្សទាំងឡាយជាព្រះពុទ្ធមានបុញ្ញាសិរី ១

➲. ជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយ តេជោធាតុបក់កំដៅ ស្មើគឺមិនត្រជាក់ពេក មិនក្តៅពេក យ៉ាង កណ្តាលអត់ធន់នូវសេចក្តីព្យាយាមបាន ១

➲. មិនជាអ្នកអួតអាង មិនមានមាយា គឺប្រព្រឹត្តខ្លួនឱ្យពិត ប្រាកដក្នុងព្រះសាស្តា ឬក្នុងពួកសព្រហ្មចារីជាអ្នកចេះដឹង ១

➲. ជាអ្នកមានព្យាយាមប្រារព្ធ ដើម្បីលះបង់ពួកអកុស-លធម៌ ចូលដល់នូវកុសលធម៌ ១

➲. ជាអ្នកមានកម្លាំងប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុង កុសលធម៌ទាំងឡាយ ១

➲. មានប្រាជ្ញា ប្រកបដោយបញ្ញាយល់ច្បាស់នូវសេចក្តី ចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាប្រសើរមោះមុតប្រព្រឹត្តទៅ

ដើម្បីឱ្យអស់ទុក្ខដោយប្រពៃ ១ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ យ៉ាងនេះ ឯង ។

ម្នាលភិក្ខុទាំងឡាយ **ចុះសេនាសនៈប្រកបដោយអង្គ ៥ តើដូចម្តេច ។**

➥. ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងលោកនេះ មិនឆ្ងាយពេកមិនជិតពេកល្មមទៅមកស្រួល មិនកុះករដោយមនុស្សក្នុងវេលាថ្ងៃ មិនសូវមានសំឡេង មិនសូវគឹកកងក្នុងរាត្រី មិនសូវមានសម្ផស្សដោយរោមមូស ខ្យល់ កំដៅថ្ងៃនឹងពស់តូចពស់ធំ ១

➥. ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ កើតឡើងដល់ភិក្ខុដែលនៅក្នុងសេនាសនៈនោះដោយមិនលំបាក ១

➥. ពួកភិក្ខុជាថេរៈ ដែលនៅក្នុងសេនាសនៈនោះ ជាពហុស្សូតចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិនัย ទ្រទ្រង់មាតិកា ១

➥. ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះម្តង ៗ ហើយសួរប្រឹក្សាថា បពិត្រលោកដ៏ចម្រើន រឿងនេះតើដូចម្តេច សេចក្តីអធិប្បាយនៃរឿងនេះ តើដូចម្តេច ១

➥. លោកដ៏មានអាយុទាំងនោះ រមែងពន្យល់រឿងដែលមិនទាន់ច្បាស់លាស់ផង ធ្វើឱ្យងាយនូវរឿងដែលជ្រៅផង បន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យច្រើនប្រការផង ១ ។

ម្នាលភិក្ខុទាំងឡាយ សេនាសនៈប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ កាលបើសេពគប់នូវសេនាសនៈ ប្រកបដោយអង្គ ៥ ហើយ មិនយូរប៉ុន្មាននឹងបានធ្វើឱ្យជាក់ច្បាស់ (នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះទាំងឡាយដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន) ព្រោះអស់អាសវៈទាំងឡាយ ។

អដ្ឋកថា

បទថា បញ្ចង្គសមន្នាគតោ បានដល់ អ្នកប្រកបដោយអង្គគុណ ៥ ។

បទថា **ឆាតិទូរំ ហោតិ ឆាច្ចាសន្តំ** សេចក្តីថា ស្ថានទីណាឆ្ងាយពេក ភិក្ខុត្រាច់បិណ្ឌបាតទៅក្នុងស្ថានទីកន្លែងនោះ ក៏មានសេចក្តីលំបាកកាយនិងចិត្ត លោកក៏ធ្វើសមាធិដែលនៅមិនកើតឱ្យកើតមិនបាន ឬធ្វើសមាធិដែលកើតហើយឱ្យរឹងមាំមិនបាន ស្ថានទីណាជិតពេកទៅ ក៏ពាសពេញដោយមនុស្សជាច្រើន ។ ក៏ឯស្ថានទីផុតពីទោសទាំងពីរនោះ នៅក្នុងប្រទេសប្រមាណ៤០ ឧសភៈ ក៏ឈ្មោះថា ដល់ព្រមដោយការគមនាគមន៍ ។

បទថា **ឯវ អប្បកិល្លំ** បានដល់ មិនពាសពេញដោយមនុស្សច្រើន ក្នុងវេលាថ្ងៃ ។

ឆិព្វានទៅឯណា?

និព្វាន មិនមានហាន ព្រោះបើមានហាន ត្រូវមានការកើត ចាស់ ឈឺ ស្លាប់ ជាទុក្ខមិនខានឡើយ ។ ការកើតមកនៅក្នុងលោកនេះ មានទុក្ខកង្វល់ខ្វល់ខ្វាយ តាំងពីកើតរហូតដល់ស្លាប់ រីឯព្រះនិព្វានវិញ មានសភាពផុយទាំងស្រុង ព្រោះមិនមានការកើត ជាទុក្ខនោះឡើយ ។

ព្រះនិព្វាន ជាទីដែលសេចក្តីទុក្ខចូលទៅមិនដល់ នៅផុត

ច្បាប់របស់ត្រៃលក្ខណ៍ (**អនិច្ចំ ទុក្ខំ អនត្តា**) មិនមានការវិលកើតវិលស្លាប់ មិនមានចាស់ ឈឺ ស្លាប់ មានលក្ខណៈទៀតពិតប្រាកដ មិនមានសេចក្តីប្រែប្រួល ជាបរមសុខកើតឡើង ដោយអំណាចនៃការខិតខំបដិបត្តិធម៌ដូចជាមានព្រះពុទ្ធវចនៈសម្តែងថា

និព្វានំ បរមំ សុខំ

និព្វានជាបរមសុខដ៏ស្ងប់ ។

និព្វានអត់កើតតើសុខនៅឯណា?

ការកើតជាមូលហេតុ នាំមកនូវបញ្ហាវេទនាជាច្រើនពាន់ជំពូកដែលដោះស្រាយ មិនចេះចប់ មិនចេះហើយ ទោះជាមានពេលខ្លះបានសុខ ពេលខ្លះបានទុក្ខក៏ដោយ ការកើតនោះនៅតែជាទុក្ខព្រោះមានប្រែប្រួលទៅវិញ ។ ព្រោះហេតុនោះបានជាការមិនកើតវាជាសុខដោយសារតែមិនមានបញ្ហាដែលត្រូវដោះស្រាយ ។

ប្រភេទរបស់ព្រះនិព្វាន

និព្វានមាន ២ ប្រភេទធំ ៗគឺ ៖

១- *សឧបាទិសេសនិព្វាន* *ហៅថា* ***និព្វានរស់*** *ចំពោះអ្នកដែលបដិបត្តិទៅតាមមគ្គដែលប្រកបដោយអង្គ ៨ បរិបូណ៌ ហើយ*

អាចចូលដល់និព្វាននេះបាន ក្នុងខណៈដែលមានជីវិតរស់នៅ ជានិព្វានរបស់ព្រះអរិយជាម្ចាស់ ដែលបានអស់កិលេសហើយ តែនៅជីវិតរស់នៅដើម្បីបញ្ចេញ ប្រយោជន៍ដល់សត្វលោកតទៅ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានចូលនិព្វាននេះ ក្នុងកាលថ្ងៃដែលព្រះអង្គបានត្រាស់ដឹង ។

និព្វានរស់នេះ ប្រៀបដូចជារណ្តៅជ្រៃកភ័យក្នុងខ្នងពេលយើងមានទុក្ខសោកភ័យណា ៗហើយយើងបញ្ជូនចិត្តទៅកាន់ព្រះនិព្វាន សេចក្តីទុក្ខសោកផ្សេង ៗក៏របូតចេញទៅអស់ មិនអាចតាមទៅបៀតបៀនចិត្តរបស់យើងបានឡើយ ព្រះអរហត្តដែលមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានគ្រប់ពេល គឺមិនមានទុក្ខឡើយ ។

មគ្គក្ខណេ កិលេសសានំ ខយោស ឧបាធិលេសំ នាម ។

សភាពដែលញុំាងឱ្យអស់ចាកកិលេស ក្នុងមគ្គខណៈមាននាមថា **សឧបាទិសេសនិព្វាន ។** *(បរមត្ថទីបនីដីកា)*

២- អនុបាទិសេសនិព្វាន ហៅថា **និព្វានស្ងាប់** ជាហេតុទំនេរនៅក្នុងភពបី អ្នកដែលអស់កិលេសក្លាយទៅជា ព្រះអរហត្តពេលដែលរលត់នូវបញ្ចខន្ធហើយ នៅសល់តែធម្មក្ខន្ធគឺធម្មកាយ

ឯចិត្តក៏ទៅប្រាកដនៅក្នុងអនុបាទិសេសនិព្វាន ។

ចុតិ អនន្តរេ ខនាតំ អនុបុព្វោ អនុបាទិសេស នាម ។

សភាពដែលមិនកើតនៅខ្ជិ ក្រោយការរលត់បែកធ្លាយ រាងកាយរបស់ព្រះអរិយបុគ្គលជាម្ចាស់នោះ មានឈ្មោះថា ***អនុបាទិសេសនិព្វាន ។*** *(បរមត្ថទីបនីដីកា)*

និព្វានដោយអាការដែលចូលដល់

និព្វាន *ពោលដោយអាការដែលចូលដល់ ឬពោលដោយសភាពដែលសម្រេចឬអាការដែលប្រព្រឹត្តទៅមាន ៣ គឺ ៖*

ក. ***អនិមិត្តនិព្វាន***

ខ. ***អប្បណិហិតនិព្វាន***

គ. ***សុញ្ញតនិព្វាន ។***

អនិមិត្តនិព្វាន

កិលេសានំ ជរាមរណាធីនញ្ច វត្ថុភូតស្ស និមិត្តស្ស អភាវា អនិមិត្តោ នាម ។ *(បរមត្ថទីបនីដីកា)*

ការស្ងប់ស្ងាត់ចាកនិមិត្តអារម្មណ៍ ដែលជាទីតាំងញុំាងឱ្យ

កើតកិលេស តណ្ហា ឬ ជរាមរណធម៌ជាដើមនោះ ហៅថា **អនិមិត្តនិព្វាន** ។

អ្នកចម្រើនវិបស្សនាភាវនា រហូតបានឃើញសាមញ្ញ-លក្ខណៈឬត្រៃលក្ខណ៍គឺ **អនិច្ចំ** ឃើញសេចក្តីមិនទៀង ដែលប្រាសចាកនិមិត្តគ្រឿងគ្រោតគ្រាតដូច្នេះហើយនិងសម្លឹងអនិច្ចតៗទៅរហូតសម្រេចមគ្គផល មាននិព្វានជាអារម្មណ៍ និព្វានដែលជាអារម្មណ៍ដល់អ្នកដែលឃើញ អនិច្ចនោះ មានឈ្មោះថា **អនិមិត្ត-និព្វាន** អ្នកមានអនិមិត្តជាអារម្មណ៍បុញ្ញាធិការមុនដំបូង ដោយសីល ។

អប្បណិហិតនិព្វាន

សព្វទុក្ខានំ និធានភូស្ស អាសាទុក្ខស្ស អភាវា អប្បណិហិតោ នាម ។ (បរមត្ថទីបនីដីកា)

ការស្ងប់ចាកសេចក្តីរើបម្រែ ដែលជាហេតុឱ្យកើតសព្វទុក្ខនោះ ហៅថា **អប្បណិហិតនិព្វាន** ។

អ្នកចម្រើនវិបស្សនាភាវនារហូតឃើញត្រៃលក្ខណ៍គឺ **ទុក្ខ** សេចក្តីឃើញទ្រាំនៅមិនបាន ត្រូវប្រែប្រួលទៅដែលជា**បណិធិ**

ដែលតាំងនៅមិនបាន ដូច្នេះហើយ និងសម្ថីងទុក្ខតទៅរហូតបាន សម្រេចមគ្គផល មាននិព្វានជាអារម្មណ៍ និព្វានដែលជាអារម្មណ៍ ដល់អ្នកដែលឃើញទុក្ខនោះ មានឈ្មោះថា **អប្បណិហិតនិព្វាន** អ្នកមានអប្បណិហិតនិព្វានជាអារម្មណ៍ បុញ្ញាធិការមុនជំបូងដោយ **សមាធិ** ។

សុញ្ញតនិព្វាន

សព្វូបលិពោធេហិ រិត្តតា សុញ្ញតំ ។ *(បរមត្ថទីបនីដីកា)*

ការស្ងប់ចាកបលិពោធនោះ ហៅថា **សុញ្ញតនិព្វាន** ។

បលិពោធ *សេចក្តីកង្វល់* { **រាគៈមូល** **ទោសៈមូល** **មោហៈមូល,**

អ្នកចម្រើនវិបស្សនាភាវនា រហូតឃើញត្រៃលក្ខណ៍គឺ **អនត្តា** *ជាសេចក្តីមិនមែនតួខ្លួន បង្គាប់បញ្ជាមិនបានដែលជាសេចក្តីសោះសូន្យទទេ ដូច្នេះហើយនិងសម្ថីងទុក្ខតទៅទៀត រហូតបានសម្រេចមគ្គផល មាននិព្វានជាអារម្មណ៍, និព្វានដែលជាអារម្មណ៍ដល់អ្នកដែលឃើញអនត្តានោះ មានឈ្មោះថា* **សុញ្ញតនិព្វាន** *អ្នកដែលមាន*

សុញ្ញតនិព្វាន និព្វានជាអារម្មណ៍នេះ បុញ្ញាធិការមុនជំបូងដោយ**បញ្ញា** ។

អ្នកដែលឃើញសាមញ្ញលក្ខណៈ ឬត្រៃលក្ខណ៍ គឺ**អនិច្ចំ** និង**អនត្តា**ហើយ ឈានទៀងកាន់មគ្គផលនោះ មានចំនួនច្រើនជាងអ្នកដែលឃើញ **ទុក្ខ** ។

គុណនាមរបស់និព្វាន

ដូចដែលពោលរួចមកហើយ និងឃើញបានថា **និព្វាន**នោះគឺ ៖

ក- បើពោលដោយសភាពមានត្រឹមតែ ១ គឺ **សន្តិសុខ** ស្ងប់ចាកកិលេសនិងខន្ធ ៥ ។

ខ- បើពោលដោយបរិយាយនៃហេតុ មានត្រឹមតែ ២ **សឧបាទិសេសនិព្វាន** និង **អនុបាទិសេសនិព្វាន** ។

គ- បើពោលដោយអាការដែលចូលដល់មានត្រឹមតែ ៣ គឺ**អនិមិត្តនិព្វាន អប្បណិហិតនិព្វាន** និង**សុញ្ញតនិព្វាន** ។

ឃ- បើពោលដោយប្រភេទនៃមគ្គមាន ៤ គឺ **និព្វាននៃ**

សោតាបត្តិមគ្គ នៃសកទាគាមិមគ្គ នៃអនាគាមិមគ្គ នៃអរហន្តមគ្គ ។

ង- បើពោលដោយការរលត់កាមគុណ មាន ៥ គឺ **រលត់សេចក្តីត្រេកអរក្នុងរូប, ក្នុងសម្លេង, ក្នុងក្លិន, ក្នុងរស, និងក្នុងការសម្ផស្សពាល់ត្រូវ ។**

ច- បើពោលដោយការរលត់តណ្ហា មាន ៦ គឺ **ការរលត់តណ្ហាកងរូប គឺការរលត់រូបតណ្ហា, សទ្ទតណ្ហា, គន្ធតណ្ហា, រសតណ្ហា, ផោដ្ឋព្វតណ្ហា, និងធម្មតណ្ហា ។**

ឆ- បើពោលដោយឈ្មោះ គឺនាមនៃគុណរបស់និព្វាន មានច្រើនណាស់ ត្រឹមតែឈ្មោះរបស់និព្វាន យើងក៏អាចដឹងបាន ដូច្នេះសូមលើកយកឈ្មោះរបស់និព្វានខ្លះ ៗ ដូចជា ៖

១- អសេសវិរាគនិរោធោ ជាធម៌ដែលរលត់ទុក្ខ ដោយចាករាគៈមិនមានសេសសល់

២- អសេសភវនិរោធោ ជាធម៌ដែលរលត់ភពមិន មានសេសសល់

៣- ចាគោ ជាធម៌លះចោលតណ្ហាទាំងពួង

៤- បដិនិស្សគ្គោ ជាធម៌ដែលផុតចាកភពផ្សេង ៗ

៥- មុត្តិ ជាធម៌ដែលផុតចាកកិលេស

៦- អនាលយោ ជាធម៌ដែលមិនមានសេចក្តីអាល័យ

៧- រាគក្ខយោ ជាធម៌ដែលអស់រាគៈ

៨- ទោសក្ខយោ ជាធម៌ដែលអស់ទោសៈ

៩- មោហក្ខយោ ជាធម៌ដែលអស់មោហៈ

១០- តណ្ហាក្ខយោ ជាធម៌ដែលអស់តណ្ហា

១១- អនុប្បាទោ ជាធម៌ដែលរលត់ខន្ធ ៥

១២- អបវត្តំ ជាធម៌ដែលរលត់រូបនាម

១៣- អនិមិត្តំ ជាធម៌ដែលមិនមានសង្ខារនិមិត្ត

១៤- អប្បណិហិតំ ជាធម៌ដែលប្រាសចាកសេចក្តីត្រេកអរ

១៥- សុញ្ញតំ ជាធម៌ដែលសូន្យចាកទុក្ខ

១៦- អប្បដិសន្ធិ ជាធម៌ដែលមិនបដិសន្ធិទៀត

១៧- អនុប្បត្តិ ជាធម៌ដែលមិនឧប្បត្តិឡើង

១៨- អនាយូហនំ ជាធម៌ដែលមិនមានសេចក្តីព្យាយាមទៀត

១៩- អជាតំ ជាធម៌ដែលមិនមានការកើត

២០- អជរំ ជាធម៌ដែលមិនមានការចាស់

២១- អព្យាធិ ជាធម៌ដែលមិនមានការឈឺ

២២- អគតិ ជាធម៌ដែលមិនមានទីទៅ

២៣- អមតំ ជាធម៌ដែលមិនមានការស្លាប់

២៤- អសោកំ ជាធម៌ដែលមិនមានការសោក

២៥- អបវិទេវ ជាធម៌ដែលមិនមានការស្រែកឱ្យជួយ

២៦- អនុបាយាស ជាធម៌ដែលមិនមានរៀបរាប់

២៧- អសង្កិលិដ្ឋ ជាធម៌ដែលមិនមានការសៅហ្មង

២៨- អសង្ខតំ ជាធម៌ដែលមិនមានបច្ច័យផ្សំបង្កើត

២៩- និវានំ ជាធម៌ដែលផុតចាកគ្រឿងស្រោច

៣០- សន្តិ ជាធម៌ដែលស្ងប់ចាកទុក្ខទាំងពួង ។

<u>នយមួយទៀត</u> ៖

គុណរបស់ព្រះនិព្វានមាន ២៩ យ៉ាង

១- មធនិម្មទ្ទនោ ព្រះនិព្វានជាធម៌ញ៉ាំញីនូវសេចក្តីស្រវឹងផ្សេង ៗ

២- បិបាសវិនយោ ព្រះនិព្វានជាធម៌ដែលបន្ទោបង់ចេញនូវការស្រេក ក្នុងអារម្មណ៍ជាកាមគុណ

៣- អាលយសមុគ្ឃាតោ ព្រះនិព្វានជាធម៌ដែលដកចេញនូវសេចក្តីអាល័យ ក្នុងអារម្មណ៍ជាកាមគុណ

៤- វដ្ដូបច្ឆេទោ ព្រះនិព្វានជាធម៌កាត់ចេញនូវការវិលទៅក្នុងវដ្ដទាំង ៣ ឱ្យដាច់

៥- តណ្ហាក្ខយោ ព្រះនិព្វានជាធម៌ដែលអស់តណ្ហា

៦- វិរាគោ ព្រះនិព្វានជាធម៌ដែលប្រាសចាករាគៈ

៧- និរោធោ ព្រះនិព្វានជាធម៌ដែលរំលត់នូវតណ្ហា

៨- ធុវំ ព្រះនិព្វានជាធម៌ដែលតាំងនៅមាំជានិច្ច

៩- *អជរំ ព្រះនិព្វានជាធម៌ដែលមិនមានជរា*

១០- *និប្បបញ្ចំ ព្រះនិព្វានជាធម៌ដែលប្រាសចាកប-បញ្ចធម៌គឺតណ្ហា ទិដ្ឋិ មានះ ដែលធ្វើវដ្តសង្សារឱ្យវែងឆ្ងាយ*

១១- *សច្ចំ ព្រះនិព្វានជាធម៌ដែលមានសភាពពិតប្រាកដ*

១២- *ថារំ ព្រះនិព្វានជាធម៌ដែលឆ្ងងផុតចាកច្រាំងនៃវដ្តទុក្ខ*

១៣- *សុទុទ្ទសំ ព្រះនិព្វានជាធម៌ដែលអ្នកមានបញ្ញាតិចឃើញបានដោយកម្រក្រៃលែង*

១៤- *សិវំ ព្រះនិព្វានជាធម៌ដែលសប្បាយ ប្រាសចាកកិលេស*

១៥- *អមតំ ព្រះនិព្វានជាធម៌មិនមានសេចក្តីស្លាប់*

១៦- *ខេមំ ព្រះនិព្វានជាធម៌ដែលប្រាសចាកភ័យ*

១៧- *អព្ភុតំ ព្រះនិព្វានជាធម៌មហស្ចារ្យក្រៃលែង*

១៨- *អឈតិតិកំ ព្រះនិព្វានជាធម៌ដែលមិនមានភ័យដ៏ខ្លាំងក្លា ដែល(ភ័យនោះ)នាំនូវសេចក្តីវិនាសមកឱ្យ*

១៩- តាណំ ព្រះនិព្វានជាធម៌ជួយរក្សាសត្វ មិនឱ្យធ្លាក់ក្នុងសង្សារ

២០- លេណំ ព្រះនិព្វានជាធម៌ពួនពីភ័យផ្សេង ៗ

២១- ទីបំ ព្រះនិព្វានជាកោះ ដែលផុតចាកការលិចលង់របស់ឱឃៈទាំង ៤

២២- វិសុទ្ធិ ព្រះនិព្វានជាធម៌ដែលបរិសុទ្ធប្រាសចាកកិលេស

២៣- វរំ ព្រះនិព្វានជាធម៌ដែលសប្បុរសទាំងឡាយគប្បីប្រាថ្នា

២៤- និបុណំ ព្រះនិព្វានជាធម៌ដែលសុខុមល្អិត

២៥- អសង្ខតំ ព្រះនិព្វានជាធម៌ដែលមិនត្រូវកាត់តែងដោយបច្ច័យ

២៦- មោក្ខោ ព្រះនិព្វានជាធម៌ដែលផុតចាកកិលេស

២៧- សេដ្ឋោ ព្រះនិព្វានជាធម៌ដែលប្រសើរ ដោយវិសេស

២៨- អនុត្តរោ ព្រះនិព្វានជាធម៌ដែលប្រសើរក្រៃលែង

រកអ្វីមកប្រៀបមិនបាន

២៩- លោកសប្បញ្ញោ ព្រះនិព្វានជាធម៌ដែលផុតស្រឡះចាកអំពីលោកទាំង ៣ ។

សុខំ ទិដ្ឋិមរិយេកិ សក្កាយស្ស ឯរោធំ
បច្ចនីកមិទំ ហោតិ សព្វលោកេន បស្សតំ ។

ក៏ឯសេចក្តីរលត់នូវសក្កាយទិដ្ឋិ ព្រះអរិយទាំងឡាយបានឃើញច្បាស់ថា ជាសុខ សេចក្តីសុខនេះ តែងមានដល់បណ្ឌិតទាំងឡាយ ដែលឃើញច្បាស់(ដោយប្រាជ្ញា) ប៉ុន្តែសត្វនៅទីងលោកទាំងមូល ។

អ្នកដែលអាចធ្វើនិព្វានឱ្យច្បាស់បាន

អ្នកដែលអាចធ្វើនិព្វានឱ្យច្បាស់បាន គឺ បានដល់ ***ព្រះអរិយបុគ្គលគ្រប់លំដាប់ ទាំងព្រះអរហត្ត ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន រួមទាំងគោត្រភូបុគ្គល*** ដែលជាអ្នកបដិបត្តិធម៌ រហូតមានកិលេសស្រាលស្តើង ជិតចូលដល់ឋានៈជាព្រះសោតាបន្នហើយ ដោយត្រូវហ៊ឹកហាត់នូវសមាធិបន្តែមតទៅទៀត និងអាចអស់នូវអាសវៈកិលេសបាន ។

ខ្លួនរបស់យើងអាចចូលទៅនិព្វានបានឬទេ?

ចំលើយ គឺ **បាន** ដោយត្រូវតាំងចិត្តចម្រើនសមាធិភាវនាទៅរហូតដល់គោត្រភូញ្ញាណជាមុនហើយ ត្រូវហ៊ឹកហាត់បន្តទៅទៀត រហូតចូលដល់ធម៌ដែលល្អិតពេលនោះ និងបានឃើញនូវអរិយសច្ចបាន ។

និព្វានប្រៀបដោយលក្ខណៈរបស់អាកាស ១០ ប្រការ

តើអ្នកចង់ទៅព្រះនិព្វានទេ ? ព្រះនិព្វានជាគឺជាបរមសុខដូចពុទ្ធភាសិតថា **និព្វានំ បរមំ សុខំ** ព្រះនិព្វានជាបរមសុខយ៉ាងក្រៃលែង សុខណា ៗស្មើដោយព្រះនិព្វាននោះមិនមានឡើយ ។ មានបុគ្គលពួកខ្លះនៅក្នុងលោកនេះដែលជាអ្នកវង្វេង វាក់វិនជ្រុបងប់នៅក្នុងកិលេសតណ្ហា ជាប់ជំពាក់នៅក្នុងលោកនេះ មានសេចក្តីយល់ឃើញថា កំណើតមនុស្សនេះវាបានសុខហើយព្រោះនៅក្នុងមនុស្សលោកនេះ មានស្រី មានប្រុស មានកូន មានចៅ មានធុង ប៉ាសរ៉ំ មានលុយ ឡាន វិឡា ដើរលេងសប្បាយហ៊ីសហារ ជាដើមធ្វើបុណ្យទៅព្រះនិព្វាន ធ្វើអីទេ បើឮគេនិយាយ

ថា ព្រះនិព្វានសូន្យស្ងាត់ឈឹង អត់មានស្រីប្រុស កូនចៅ លុយ ទ្បាន វិទ្បាអីផង ទៅធ្វើអី មិនសប្បាយទេ អួយ មិនចង់ទៅទេ សូមកើតនៅក្នុងហានមនុស្សនេះវិញល្អជាង, មានអ្នកខ្លះទៀត និយាយថា បើបានទៅដល់ព្រះនិព្វានហើយ តើមានវិធីអ្វីអាច ចេញពីកន្លែងនោះវិញបានទេ នេះជាទស្សនៈរបស់បុគ្គលដែល ស្រឹងនៅក្នុងលាភ យស សរសើរ សុខ ស្ថិតនៅក្នុងអំណាច កិលេស តណ្ហា ត្រូវកិលេស តណ្ហាដឹកនាំបុគ្គលបែបនេះ ត្រូវ ជ្ឈាក់នរក ជ្ឈាក់ ប្រេត តិរច្ឆាន អសុរកាយ រស់រង់ទុក្ខវេទនាគ្មាន ថ្ងៃបញ្ចប់ឡើយ ។ **បើអ្នកមិនឃើញសេចក្តីទុក្ខក្នុងបច្ចុប្បន្នទេ អ្នកមិនអាចរកព្រះនិព្វានឃើញឡើយ ។** បើអ្នកចង់ដឹងថា ព្រះនិព្វានសុខយ៉ាងណានោះ ចូរអ្នកពិចារណាអំពីអាកាស វេហាស៍ និងធម៌ជទៃ ។ ទៀតដែលទាក់ទងនឹងព្រះនិព្វាន ។

១- ន ជីយតិ មិនចាស់ គឺគ្រាំគ្រាឬទ្រេខ្ចោម,យ៉ាង ណាមិញ អាកាសវេហាស៍ ក៏មិនដល់នូវសភាពទ្រេខ្ចោមគ្រាំគ្រា ចាស់ជរា ដូចជារូបកាយឡើយនៅថ្កុំល្អជានិច្ច ។

២- ន មីយតិ មិនស្លាប់ គឺមិនសូន្យ, ធម្មតាអាកាស

វេហាស៍មិនបាត់ទៅណាទេ មិនសូន្យទេ មិនឃ្លាតទៅទីណាទេ ដូចយើងគ្រប់គ្នាបានឃើញផ្កាល់ភ្នែកហើយ ។

៣- ន ចវតិ មិនចុតិ គឺមិនវិនាសទៅណាទេ នៅជដែលឋិតថេរជដែល ។

៤- ន ឧប្បជ្ជតិ មិនកើត គឺមិនវិលកើតវិលស្លាប់ ដូចជាមនុស្សយើងឡើយ ហើយទោះបីយើងស្លាប់ប៉ុន្មានត ប៉ុន្មានជាតិ ក៏អាកាសវេហាស៍នេះនៅជដែលកើតហើយ កាលណាបើកភ្នែកឃើញអាកាសវេហាស៍កាលនោះជានិច្ច ។

៥- អប្បសយ្ហំ មិនមានអ្នកគម្រាមកំហែង គឺមិនមានអ្វីនឹងញ៉ាំញីបានសង្កត់សង្កិនបានបៀតបៀនបាន ឬក៏ទៅចាប់យកមកធ្វើបាបបានឡើយ ។

៦- អចោរគហណីយំ ចោរមិនអាចទៅបៀតបៀនលួចយកបាន ដូចជាទ្រព្យឡើយ ព្រោះជារបស់ដែលចាប់ប៉ះពាល់មិនបាន ។

៧- អនិស្សិតំ មិនមានទីអាស្រ័យ ដូចជាផ្ទះ មាស

ប្រាក់ កែវកងឡើយ ។

៨-វិមាគ្គគមនំ ក្រៅអំពីមនុស្សមានវិទ្ធី ទេវតា និងយក្ខ មានវិទ្ធីហើយមនុស្សធម្មតា ៗមិនអាចទៅរស់នៅបានឡើយ ។

៩- និភាវណំ មិនមានអ្វីនឹងរាំង ឃាត់ឃាំងបានឡើយ ។

១០-អនន្តំ មិនមានទីបំផុត(គឺធំទូលាយរកទីបំផុតគ្មានដូចដែលយើងគ្រប់គ្នាបានឃើញហើយ មើលទៅណាក៏ឃើញដែរ ។

៦. ប្រៀបព្រះនិព្វានប្រកបដោយគុណ ១០ ប្រការ គឺ ១ ន ជីយតិ បានដល់ ។ល។ ១០ អនន្តំ រកទីបំផុតគ្មាន ។ (ចាក.គម្ពីរឃ្លាំងបរិយត្តិភាគ ២ ទំព័រ ១៤០)

សភាពរបស់និព្វាន

សភាពរបស់និព្វានមានត្រឹមតែគឺ **អនត្តលក្ខណៈ** ព្រោះនិព្វានជាវត្ថុដែលសោះសូន្យប្រាសចាកតួខ្លួន បង្គាប់បញ្ជាមិនបាន ឬសូម្បីតែនឹងសូមស្រែកអង្វរឱ្យកើតមានដល់នរណា ៗ

ក៏មិនបានទាំងអស់ ។

តែ **និព្វាន** មិនមានអនិច្ចលក្ខណៈ ព្រោះនិព្វានជាវត្ថុដែលទៀង គង់វង្ស ឋិតនៅ មិនប្រែប្រួល ។

និង **និព្វាន** មិនមានទុក្ខលក្ខណៈ ព្រោះនិព្វានជាវត្ថុដែលទ្រាំនៅបាន ដោយថា មិនមានការកើត មិនមានការរលត់ និងដោយហេតុដែលនិព្វាន ជាវត្ថុដែលសោះសូន្យទទេរ រហូតទៅមិនមានអ្វីដែលនឹងមកសង្កត់សង្កិន ឱ្បីក្លាយជាមិនទំនេរបាន ។

កាលពោលដោយវិសេសលក្ខណៈហើយ សភាពរបស់និព្វានមានត្រឹមតែ ៣ ប្រការគឺ **លក្ខណៈ រស បច្ចុបដ្ឋាន** ប៉ុណ្ណោះ មិនមានបទដ្ឋានទេ មានព្រះបាលីសម្តែងទុកដូច្នេះថា

សន្តិលក្ខណមច្ចុតរស និព្វាន អមតំ អនិមិត្តំ ឧបដ្ឋានំ បទដ្ឋានំ ន លព្ភតិ ។

- **សន្តិ លក្ខណា** មានសេក្តីសុខស្ងប់ចាកភ្លើងទុក្ខជាលក្ខណៈ

- **មច្ចុត រសា** មានសេចក្តីមិនបែកធ្លាយ ជាកិច្ច (**សមបត្តិរស**)

- **អនិមិត្ត ឧបដ្ឋានា** មិនមាននិមិត្តគ្រឿងសំគាល់ជាអាការប្រាកដ

- **(វា) និស្សរណា បច្ចុបដ្ឋានា** (ឬ)មានសេចក្តីចេញចាកភព ជាផល

- **បទដ្ឋានំ ន លព្ភតិ** មិនមានហេតុជិតឱ្យកើត (ព្រោះនិព្វាន ជាធម៌ដែលផុតចាកបច្ច័យទាំងពួង) ។

ម្យ៉ាងទៀត ព្រះអនុរុទ្ធាចារ្យបានពណ៌នាសភាពរបស់និព្វាន ដើម្បីសម្តែងឱ្យដឹងថា **និព្វាន** គឺអ្វីទុក ៥ ប្រការ ដោយប្រព័ន្ធគាថាសង្គហៈថា ៖

បទមច្ចុតមច្ចន្តំ អសង្ខតមនុត្តរំ
និព្វានមិតិ ភាសន្តិ វានមុត្តា មហេសយោ ។

ប្រែថា សម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ អ្នកស្វែងរកគុណដ៏ធំក្រៃលែងបំផុត ហើយចាកតណ្ហាគ្រឿងស្រោចត្រាស់ដឹងធម៌មួយចំណែក គឺធម៌ដែលមិនស្លាប់ ។

ធម៌ដែលទៀងផុតចាកកាលទាំង៣ គឺអតីត បច្ចុប្បន្ននិងអនាគត, ធម៌ដែលមានបច្ច័យផ្សែបផ្សំមិនបាន, ធម៌ដែលមិន

មានវត្តុណាមួយ នឹងប្រសើរជាង ធម៌នោះគឺ **និព្វាន** ។

សភាពរបស់និព្វាន ៥ ប្រការ ដែលពោលទុកនៅក្នុងគាថាសង្គហៈនេះ មានសេចក្តីសំគាល់ដូច្នេះគឺ ៖

១- **បទំ** ប្រែថា ចំណែកមួយ, សំដៅសេចក្តីថា និព្វានជាធម៌មួយប្រភេទ, ចំណែកមួយ បទមួយ ដែលអាចបួលដល់បាន នឹងមាននៅដោយចំពោះ ។ នៅក្នុងបរមត្ថទីបនីដីកា បានពន្យល់សេចក្តីថា ៖

ឯសុំ អសំមិស្សេ្រ កេវលោ ឧបលព្ភមានោ ឯកោ-បរមត្ថធម្មោ បទំ នាម ។

សភាវៈធម៌ដែលជាចំណែកមួយ របស់បរមត្ថធម៌ មិនច្រឡូកច្រឡំដោយលោកីយធម៌នោះ ឈ្មោះថា **បទ**, បានដល់**និព្វាន** ។

២- **អច្ចុតំ** ប្រែថា ធម៌ដែលមិនស្លាប់ សំដៅសេចក្តីថាមិនមានកើតទៀត កាលមិនកើត ក៏មិនត្រូវស្លាប់ ។ នៅក្នុងបរមត្ថទីបនីដីកា បានពន្យល់សេចក្តីថា ៖

ចវនាភាវេន អច្ចុតំ

សភាវៈធម៌ដែលមិនបែកធ្លាយនោះ ឈ្មោះថា ***អច្ចុត*** *បានដល់* ***និព្វាន*** ។

៣- អច្ចុតំ ប្រែថា ធម៌ដែលទៀង គឺឈានកន្ធ៦ខ្ទង ៥ និង៦អនាគត សំដៅសេចក្តីថា ជាធម៌ដែលផុតចាកកាលទាំង៣ ។ នៅក្នុងបរមត្ថទីបនីដីកា បានពន្យល់សេចក្តីថា ៖

បុព្ពន្តា បរន្តេ អតិក្កម បវត្តតា អច្ចន្តំ ។

សភាវៈធម៌ដែលកើតដោយផុតចាកធម៌ខាងដើម និងខាងក្រោយនោះ ឈ្មោះថា ***អច្ចន្ត*** *បានដល់* ***និព្វាន*** ។

៤- អសង្ខតំ ប្រែថា មិនបានត្រូវផ្សែបផ្សំដោយបច្ច័យ សំដៅសេចក្តីថានិព្វាននេះមិនមែនចិត្ត ចេតសិក រូបទេ ព្រោះចិត្ត ចេតសិក រូបនោះជាធម៌ដែលកើតឡើង ដោយមានបច្ច័យផ្សែបផ្សំ ។ នៅក្នុងបរមត្ថទីបនីដីកា បានពន្យល់សេចក្តីថា ៖

សង្ខរណាកិច្ចរហិត្តតា អសង្ខតំ ។

សភាវៈធម៌ដែលប្រាសចាកការផ្សែបផ្សំនោះ ឈ្មោះថា ***អសង្ខត*** *បានដល់* ***និព្វាន*** ។

បញ្ញត្តិ ក៏ជាអសង្ខតធម៌ដូចគ្នា តែក្នុងទីនេះពោលចំពោះធម៌ដែលជាបរមត្ថ បញ្ញត្តិមិនមែនបញ្ញត្តិ ដូច្នោះ អសង្ខតធម៌ក្នុងទីនេះ ទើបសំដៅដល់ និព្វានតែម្យ៉ាង ។

៥- អនុត្តរំ ប្រែថា ធម៌ដែលប្រសើរក្រៃលែងដែលមិនមានធម៌ណា ៗនិងប្រៀបផ្ទឹមបាន សំដៅដល់ **និព្វាន** នៅក្នុងបរមត្ថទីបនីដីកា បានពន្យល់សេចក្តីថា ៖

អត្តោ ឧត្តរិតស្ស កស្សចិ ធម្មស្ស អភាវតោ អនុត្តរំ ។

សភាវៈធម៌ដែលលើស ជាងធម៌ដទៃណាទាំងអស់នោះ ឈ្មោះថា **អនុត្តរ** *បានដល់* **និព្វាន ។**

លោកុត្តរចិត្ត ៨ ចេតសិកដែលប្រកប ៣៦ ក៏ជាអនុត្តរធម៌ដូចគ្នា តែងក្នុងទីនេះពោលចំពោះរឿងរបស់និព្វាន មិនបានពោលដល់រឿងចិត្ត និងចេតសិកផងទេ ព្រោះបានពោលមកហើយ ដូច្នោះ ពាក្យថា **អនុត្តរ** ក្នុងទីនេះ ទើបសំដៅដល់ **និព្វាន** តែម្យ៉ាង ។

បុគ្គលដល់ព្រះនិព្វានរមែងមិនកន្លងបាន: ៩ យ៉ាងគឺ

១- មិនសម្លាប់សត្វគ្រប់ប្រភេទ,

២- មិនកាន់យកទ្រព្យដែលគេមិនបានឱ្យ,

៣- មិនសេពមេថុនធម្មជាជាប់ខាត,

៤- មិនពោលពាក្យកុហកដោយចេតនា,

៥-មិនបរិភោគកាមដូចជាគ្រហស្ថអ្នកមានស្វាមីភរិយា កូនចៅ មានផ្ទះសម្បែងគ្រប់គ្រង,

៦- មិនមានសេចក្តីលំអៀង ព្រោះស្រឡាញ់,

៧- មិនមានលំអៀងព្រោះភ័យដោយហេតុអ្វីមួយ,

៨-មិនមានសេចក្តីលំអៀងព្រោះវង្វេងមិនមានមោហៈ

៩- មិនមានសេចក្តីលំអៀង ព្រោះខ្លាចដោយមូលហេតុណាមួយ ។

ធម៌ទាំង ៩ ខាងលើនេះ តែងមានស្ថិតនៅក្នុងសន្តានចិត្តនៃព្រះអរហន្តដែលអស់នូវអាសវៈកិលេសហើយ ។

(ចាក. គម្ពីរឃ្លាំងបរិយត្តិភាគ ២ ទំព័រ ១១៣)

តួយ៉ាងអ្នកដែលធ្វើព្រះនិព្វានឱ្យជាក់ច្បាស់

រឿងព្រះនិព្វាននេះវាគឺជារបស់មួយសម្រាប់យើងគ្រប់គ្នា ដែលជាពុទ្ធមាមកជន អ្នករាប់អានព្រះពុទ្ធសាសនា ដល់នូវព្រះរតនត្រៃជាទីពឹងទីរឭកស្មើដោយជីវិតនោះ ។ សម្រាប់ពុទ្ធបរិស័ទដែលជាអ្នកវិតវំ ប្រឹងប្រែងបំពេញបុណ្យកុសល ហើយវិតវំគោរពបដិបត្តិទៅតាមពាក្យទូន្មាន ប្រៀនប្រដៅរបស់ព្រះបរមសាស្តាសម្មាសម្ពុទ្ធនោះ មិនយូរប៉ុន្មានឡើយនឹងដល់ព្រះនិព្វានជាមិនខាន ។

នៅក្នុងគម្ពីរឃ្លាំងបរិយត្តិភាគ ១ ទំព័រ ៥៥១ លោកបានសម្តែងអំពីបុគ្គលដែលមិនបានជួបព្រះសិអារ្យមេត្រីមាន ៦ គឺ

១- បុគ្គលដែលធ្វើអនន្តរិយកម្ម ៥

២- បុគ្គលដែលជានិយតមិច្ឆាទិដ្ឋិ

៣- បុគ្គលដែលមិនមានសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ

៤- បុគ្គលដែលមានបុណ្យតិចតួច

៥- ពួកអន្យតិ្ថរ្យ៍ និគ្រន្ថ

៦- បុគ្គលដែលលួចរបស់សង្ឃ ។

បុគ្គលទាំងអស់នេះ លោកសម្តែងថាមិនបានជួបព្រះសិ-អារ្យមេត្រីទេ ។ ហេតុដូច្នេះ យើងគ្រប់កាលបើបានដឹងហើយ ត្រូវវៀរចាកនូវអំពើទាំងអស់នេះ ហើយខិតខំធ្វើនូវសេចក្តីល្អឱ្យបានច្រើន ព្រោះព្រះនិព្វាននេះ គឺជាកន្លែងសម្រាប់ទទួលបុគ្គលអ្នកមានបុណ្យបារមីដែលបានសន្សំទុកល្អហើយ ។

មោគ្គល្លានសូត្រ

នៅក្នុងបិដកលេខ ៤៧,ទំព័រ ១៥៧ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងជាមួយភិក្ខុទាំងឡាយអំពី ***(វិធីកម្ចាត់បង់នូវសេចក្តីងោកងក់ដល់ព្រះមោគ្គល្លាន)*** *មានសេចក្តីថា ៖*

សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងសុំសុមា-រគិរនាភេសកឡាវន ជាទីឱ្យនូវអភ័យដល់ម្រឹគ ជិតក្រុងភគ្គៈ ។ សម័យនោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយងោកងក់ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ ។ ព្រះដ៏មានព្រះភាគទ្រង់មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ទ្រង់បានឃើញនូវព្រះមហាមោគ្គល្លានដ៏មានអាយុ កំពុងអង្គុយងោកងក់ ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ លុះឃើញហើយ ក៏

ទ្រង់បាត់អំពីភេសកឡាវនៃ ជាទីឱ្យនូវអភ័យដល់ម្រឹគ ជិតក្រុងសុំសុមារគិរី ក្នុងដែនភគ្គៈ ទៅប្រាកដក្នុងទីចំពោះមុខនៃមហាមោគ្គល្លានដ៏មានអាយុ ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ ប្រៀបដូចបុរសមានកម្លាំង គប្បីលាន់នូវដៃដែលបត់ចូល ឬគប្បីបត់ចូលនូវដៃដែលលាចេញ ក៏យ៉ាងនោះដែរ ។ ព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ក៏ត្រាស់ទៅនឹងព្រះមហាមោគ្គល្លានដ៏មានអាយុដូច្នេះថា នែមោគ្គល្លាន អ្នកងោកងក់ឬ នែមោគ្គល្លាន អ្នកងោកងក់ឬ ។ ព្រះមោគ្គល្លានតបថា ព្រះករុណាព្រះអង្គ ។

➪. នែមោគ្គល្លាន ព្រោះហេតុនោះ ក្នុងសាសនានេះ កាលបើអ្នកមានសញ្ញាយ៉ាងណាហើយ សេចក្តីងងុយងោកនៅតែគ្រប់សង្កត់អ្នក អ្នកគប្បីធ្វើទុកក្នុងចិត្តនូវសញ្ញានោះ គប្បីធ្វើនូវសញ្ញានោះឱ្យក្រាស់ក្រែលឡើង ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះហើយនឹងលះសេចក្តីងងុយងោកនោះបានមិនខាន ។

➪. បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លានតពីនោះទៅ អ្នកគប្បីត្រិះរិះរឿយ ៗ គប្បីពិចារណារឿយ ៗគប្បីរំពឹងរឿយ ៗនូវធម៌ដែល

ធ្លាប់ស្តាប់ហើយ ធ្លាប់រៀនសូត្រហើយដោយចិត្ត ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយងោកនោះបានមិនខាន ។

⇨. បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លានតពីនោះទៅ អ្នកគប្បីស្វាធ្យាយនូវធម៌ដែលអ្នកធ្លាប់ស្តាប់ហើយ ធ្លាប់រៀនសូត្រហើយ ដោយពិស្តារ ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយងោកនោះបានមិនខាន ។

⇨. បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីឧឡៃនូវប្រហោងត្រចៀកទាំងពីរ ហើយគប្បីស្ទាបអង្វែលខ្លួនដោយដៃ ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយងោកនោះបានមិនខាន ។

⇨. បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីក្រោកពីអាសនៈ ហើយយកទឹកលាបភ្នែក រួចគប្បីក្រឡេកមើលទិស

ទាំងឡាយ គប្បីក្រឡេកមើលផ្កាយនក្ខត្តឫក្ស ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយងោកនោះបានមិនខាន ។

⇨. បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា(សេចក្តីសម្គាល់នូវពន្លឺ) គប្បីអធិដ្ឋាននូវសញ្ញាថា វេលាថ្ងៃ គឺអធិដ្ឋានថា វេលាថ្ងៃ យ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃ ក៏យ៉ាងនោះដែរ គប្បីមានចិត្តបើកស្រឡះដូច្នេះ មិនមានអ្វីរបរឹត ចំរើនទូវចិត្តប្រកបដោយពន្លឺ ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយងោកនោះបានមិនខាន ។

⇨. បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីមានសេចក្តីសម្គាល់ក្នុងខាងក្រោយ នឹងខាងមុខ មានឥន្ទ្រិយតាំងនៅខាងក្នុង មានចិត្តមិនប្រព្រឹត្តទៅខាងក្រៅ ហើយគប្បីអធិដ្ឋាននូវទីចង្រ្កម ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ

នឹងអាចលះសេចក្តីងងុយងោកនោះបានមិនខាន ។

➪. បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីសម្រេចនូវសូហាសេយ្យ គឺដេកដូចសត្វសីហៈ ផ្អៀងទៅខាងស្តាំ គប្បីតម្រួតជើងដោយជើង ជាអ្នកមានសតិ មានសម្បជញ្ញៈ គប្បីធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា គឺសេចក្តីសម្គាល់ថា នឹងក្រោកឡើង នែមោគ្គល្លាន កាលបើអ្នកភ្ញាក់ហើយ គប្បីក្រោកឡើងឱ្យឆាប់ ដោយគិតថា អាត្មាអញនឹងមិនប្រកបរឿយ ៗនូវសេចក្តីសុខ ព្រោះការដេកមិនប្រកបរឿយ ៗនូវសេចក្តីសុខ ព្រោះការទំរេត មិនប្រកបរឿយ ៗនូវសេចក្តីសុខ ព្រោះសេចក្តីងងុយងោកទេ ។ នែមោគ្គល្លាន អ្នកត្រូវសិក្សាយ៉ាងនេះឯង ។

នែមោគ្គល្លាន ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញមិនលើកឡើងនូវប្រមោយគឺចិត្តឱ្យខ្ជិលច្រអូសចូលទៅរកត្រកូលទាំងឡាយហើយ នែមោគ្គល្លាន ព្រោះក្នុងត្រកូលទាំងឡាយ រមែងមានកិច្ចដែលគួរធ្វើច្រើនមនុស្សទាំងឡាយ រមែងមិនយកចិត្តទុកដាក់នឹងភិក្ខុដែលមកដល់ទេ ។ ក្នុង

រឿងនោះ ភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា បានជាមនុស្សទាំងនេះ មានសេចក្តីធុញទ្រាន់ក្នុងអាត្មាអញ ។ សេចក្តីអៀនខ្មាសរមែងមានដល់ភិក្ខុនោះ ដោយមិនមានលាភក៏កើតឡើង កាលបើភិក្ខុមានសេចក្តីអៀនខ្មាសកើតឡើងហើយ សេចក្តីរាយមាយក៏កើតឡើង កាលបើភិក្ខុមានសេចក្តីរាយមាយកើតឡើងហើយ សេចក្តីមិនសង្រួមក៏កើតឡើង កាលបើសេចក្តីមិនសង្រួមកើតឡើងហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ។

នែមោគ្គល្លាន ព្រោះហេតុនោះ ក្នុងសាសនានេះអ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនពោលនូវពាក្យទាស់ទែង ។ នែមោគ្គល្លាន អ្នកគប្បីសិក្សាយ៉ាងនេះចុះ នែមោគ្គល្លាន កាលបើពាក្យទាស់ទែងមានហើយ ការល្មោភនិយាយច្រើន ក៏ប្រាកដឡើង កាលបើសេចក្តីរាយមាយមានហើយ សេចក្តីមិនសង្រួមក៏ប្រាកដឡើង កាលបើសេចក្តីរាយមាយមានហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ។

នែមោគ្គល្លាន តថាគតមិនបានសរសើរនូវការជាប់ជំពាក់ដោយវត្ថុទាំងអស់ នែមោគ្គល្លាន ប៉ុន្តែ តថាគតមិនមែនជាមិន

សរសើរការជាប់ជំពាក់ដោយវត្ថុទាំងអស់ទេ នែមោគ្គល្លាន ត-
ថាគតមិនបានសរសើរ តែនូវការជាប់ជំពាក់ដោយគ្រហស្ថ នឹង
បព្វជិតទាំងឡាយប៉ុណ្ណោះឯសេនាសនៈណា មានសម្ងួតិច មិន
មានសម្ងួគឺកកង មានខ្យល់បក់ហើយ គួរជាទីធ្វើនូវការកំបាំង
របស់មនុស្ស សមគួរដល់ការពួនសម្ងំ តថាគតរមែងសរសើរ
នូវការជាប់ជំពាក់ដោយសេនាសនៈ មានសភាពដូច្នោះ ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះ
មហាមោគ្គល្លានដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ
ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុមានចិត្តផុតស្រឡះពិត ក្នុង
ការរស់នៅនៃតណ្ហា មានសេចក្តីសម្រេចដ៏ទៀង មានសេចក្តីក្សេម
ចាកយោគៈដ៏ទៀង មានព្រហ្មចារ្យដ៏ទៀង មានទីបំផុតដ៏ទៀង ជា
បុគ្គលប្រសើរជាងទេវតានឹងមនុស្សទាំងឡាយយ៉ាងសង្ខេប តើ
ដោយហេតុប៉ុន្មានហ្ន៎ ។

នែមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ មានការចេះដឹងថា
ធម៌ទាំងអស់ មិនគួរប្រព្រឹត្តទៅដើម្បីសេចក្តីប្រកាន់មាំឡើយ នែ
មោគ្គល្លាន ភិក្ខុមានការចេះដឹងនុ៎ះថា ធម៌ទាំងអស់មិនគួរប្រព្រឹត្ត

ទៅដើម្បីសេចក្តីប្រកាន់មាំយ៉ាងនេះឡើយ ។ ភិក្ខុនោះរមែងដឹងច្បាស់នូវធម៌ទាំងអស់ លុះដឹងច្បាស់នូវធម៌ទាំងអសហើយ ក៏កំណត់ដឹងនូវធម៌ទាំងអស់ លុះកំណត់ដឹងនូវធម៌ទាំងអស់ហើយ ក៏ទទួលនូវវេទនាណាមួយ គឺវេទនាជាសុខ ឬជាទុក្ខ ឬមិនមែនជាទុក្ខមិនមែនជាសុខ ។ ភិក្ខុនោះជាអ្នកពិចារណាឃើញរឿយ ៗ ថា មិនទៀងក្នុងវេទនាទាំងនោះ ពិចារណាឃើញរឿយ ៗនូវការប្រាសចាកតម្រេក ពិចារណាឃើញរឿយ ៗនូវការរំលត់ទុក្ខ ពិចារណាឃើញរឿយ ៗនូវកិរិយាលះបង់ ។ កាលភិក្ខុនោះពិចារ-ណាឃើញរឿយ ៗនូវការប្រាសចាកតម្រេក ពិចារណាឃើញរឿយ ៗនូវការរំលត់ទុក្ខ ពិចារណាឃើញរឿយ ៗនូវកិរិយាលះបង់ ក៏លែងប្រកាន់មាំនូវវត្តុណាមួយក្នុងលោក កាលបើមិនប្រកាន់មាំហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ ក៏រមែងបរិនិព្វានដោយពិត(ភិក្ខុនោះ)ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានអប់រំហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលមោគ្គល្លាន

ភិក្ខុមានចិត្តផុតស្រឡះ ព្រោះធ្វើធម៌នោះឱ្យជាអារម្មណ៍ក្នុងការអស់ទៅនៃតណ្ហា មានសេចក្តីសម្រេចដ៏ទៀង មានសេចក្តីក្សេមចាកយោគៈដ៏ទៀង មានព្រហ្មចារ្យដ៏ទៀង មានបីតិបំផុតដ៏ទៀង ជាបុគ្គលប្រសើរជាងទេវតា និងមនុស្សទាំងឡាយយ៉ាងសង្ខេបដោយហេតុដូច្នេះឯង ។

អដ្ឋកថា

បទថា ចបលាយមានោ សេចក្តីថា ព្រះមហាមោគ្គល្លាន ចូលទៅអាស្រ័យពួកស្រុកនោះ ធ្វើសមណធម៌ក្នុងព្រៃស្រោងមួយកន្លែង មានរាងកាយលំបាក ព្រោះត្រូវសេចក្តីព្យាយាមក្នុងការចង្រ្កមរហូតដល់អស់ ៧ ថ្ងៃ ហៀតហៀន ទើបអង្គុយផោកងក់នៅក្នុងចុងទីចង្រ្កម ។

បទថា ចបលាយមានោ កែជាជា និទ្ទាយសិ នុ ប្រែថា លោកផោកឬ ។

បទថា អនុមជ្ជិត្វា ប្រែថា ស្ទាបអង្អែលហើយ ។

បទថា អាលោកសញ្ញំ បានដល់ សេចក្តីសម្គាល់ក្នុងសេចក្តីភ្ញើជើម្បីបន្ទោបង់សេចក្តីងោក ។

បទថា ឯវាសញ្ញំ បានដល់ សេចក្តីសម្គាល់ថា ជាពេលថ្ងៃ ។

បទថា យថា ឯវា តថា រត្តិ សេចក្តីថា លោកតាំងសេចក្តីសម្គាល់ថាពន្លឺក្នុងពេលថ្ងៃយ៉ាងណា លោកតាំងសេចក្តីសម្គាល់ថា ពន្លឺនោះ សូម្បីក្នុងវេលាយប់ក៏ដូច្នោះ ។ ពាក្យថា យថា រត្តំ តថា ឯវា លោកតាំងសេចក្តីសម្គាល់ថា ភ្លឺក្នុងពេលយប់យ៉ាងណា លោកតាំងសេចក្តីសម្គាល់ថា ពន្លឺនោះសូម្បីក្នុងវេលាថ្ងៃដូច្នោះ ។

បទថា សប្បភាសំ លោកគប្បីឱ្យចិត្តប្រព្រឹត្តទៅព្រមនឹងពន្លឺ ដើម្បីប្រយោជន៍ដល់ទិព្វចក្ខុញ្ញាណ ។

បទថា បច្ចាបុរេសញ្ញី សេចក្តីថា អ្នកមានសញ្ញាដោយសញ្ញាដែលនាំទៅខាងមុខនិងខាងក្រោយ ។

បទថា អន្តោគតេហិ ឥន្ទ្រិយេហិ បានដល់ ដោយឥន្ទ្រិយ ៥ ដែលមិនរវើរវាយទៅក្នុងខាងក្រៅដែលចូលមកតាំងនៅក្នុងខាងក្នុងប៉ុណ្ណោះ ។

បទថា **មិទ្ធសុខំ** បានដល់ សេចក្តីសុខដែលកើតពីសេចក្តីលក់ ។ ព្រះមានព្រះភាគសម្តែងកម្មដ្ឋានគ្រឿងបន្ទោបង់សេចក្តីងោកដល់ព្រះថេរៈ ដោយហានៈមានប្រមាណប៉ុណ្ណេះ ។

បទថា **សោណ្ឌំ** បានដល់ ងោកគឺ មានះ ។ ក្នុងបទថា **កិច្ចករណីយានិ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

កម្មដែលខ្លួននឹងគប្បីធ្វើពិតប្រាកដ ឈ្មោះថា **កិច្ចានិ** កិច្ចប្រតិបត្តិដែលជាតួនាទីទាំងឡាយ ។ ចំណែកកិច្ចក្រៅនេះ ឈ្មោះថា **ករណីយានិ** កិច្ចគួរធ្វើទាំងឡាយ ។

បទថា **មច្ចុភាវោ** បានដល់ សេចក្តីជាអ្នកគ្មានអំណាចសេចក្តីទោមនស្ស ខូចចិត្ត ។ ព្រះសាស្តាត្រាស់កិក្ខាចារវត្តដល់ព្រះថេរៈដោយហានៈមានប្រមាណប៉ុណ្ណេះ ។ ឥឡូវនេះដើម្បីនឹងទ្រង់នាំសេចក្តីឱ្យដល់ទីបំផុត ព្រះអង្គទើបត្រាស់ពាក្យជាដើមថា **តស្មាតិហ** ដូច្នេះ ។ បណ្តាបទទាំងនោះបទថា **វិគ្គហិកកថំ** សេចក្តីថា ពាក្យដែលជាហេតុឱ្យកាន់យកខុស ប្រព្រឹត្តទៅដោយន័យជាដើមថា លោករមែងមិនដឹងធម៌និងវិន័យនេះ ដើម្បី

នឹងវៀរចាកការច្របូកច្របល់នឹងបាបមិត្ត ព្រះសាស្តាទើបត្រាស់ពាក្យមានជាដើមថា **នាហំមោគ្គល្លាន** ដូច្នេះ ។

បទថា **កិត្តាវតា នុ ខោ** សេចក្តីថា ដោយខបជិបត្តិត្រឹមតែណាហ្ន៎ ។

បទថា **តណ្ហាសង្ខយវិមុត្តោ ហោតិ** សេចក្តីថា ភិក្ខុឈ្មោះថា **តណ្ហាសង្ខវិមុត្ត** ព្រោះជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វានដែលជាទីអស់តណ្ហា ធ្វើព្រះនិព្វាននោះជាអារម្មណ៍ ព្រះមហាមោគ្គល្លានទូលសួរដោយសង្ខេប ដោយខបជិបត្តិប៉ុណ្ណោះ ភិក្ខុរមែងឈ្មោះថា តណ្ហាសង្ខវិមុត្ត សូមព្រះអង្គមេត្តាទ្រង់សម្តែងខបជិបត្តិនោះឯង ដែលជាបជិបទាខាងដើមរបស់ភិក្ខុដែលជាព្រះខីណាស្រព ដោយសង្ខេបចុះ ព្រះអង្គ ។

បទថា **អច្ចន្តនិដ្ឋោ** សេចក្តីថា ឈ្មោះថា **អច្ចន្ត** ព្រោះប្រព្រឹត្តទៅ ពោលគឺ ការអស់ទៅនិងសេចក្តីសាបសូន្យទៅ ។ ភិក្ខុឈ្មោះថា **អច្ចន្តនិដ្ឋោ** ព្រោះមានសេចក្តីសម្រេចកន្លងចំណែក អធិប្បាយថា មានសេចក្តីសម្រេចដោយចំណែកតែមួយ មានសេចក្តីសម្រេចជាប់តគ្នា ។

បទថា អច្ចន្តយោគ្គក្ខេមី មានសេចក្តីថា អ្នកមានធម៌ជាដែនក្សេមចាកពីយោគៈ អធិប្បាយថា មានធម៌ជាដែនក្សេមចាកពីយោគៈជានិច្ច ។

បទថា អច្ចន្តព្រហ្មចារី សេចក្តីថា ជាព្រហ្មចារីកន្លងចំណែកអធិប្បាយថា ជាព្រហ្មចារីជានិច្ច ។

បទថា អច្ចន្តបរិយោសានោ សេចក្តីថា មានទីបំផុតដោយន័យមុនន៏ុះឯង ។

បទថា សេដ្ឋោ នេវមនុស្សានំ សេចក្តីថា ប្រសើរបំផុតគឺខ្ពស់បំផុតជាងទេវតានិងមនុស្សទាំងឡាយ ។ ព្រះមហាមោគ្គល្លានទូលសូមថាភិក្ខុឈ្មោះថា បែបនេះ ដោយខ្លួនឯងតែម្តង សូមព្រះអង្គមេត្តាទ្រង់សម្តែងសម្រាប់ភិក្ខុនោះដោយសង្ខេបចុះ ព្រះអង្គ ។

ក្នុងបទថា សព្វេ ធម្មា ន លំ អភិនិវេសាយ នេះមានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា ធម៌ទាំងពួងគឺ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ធម៌ទាំងអស់នោះមិនគួរគឺមិនត្រូវមិនប្រពៃមិនសមគួរដែលនិង

ប្រកាន់មាំដោយអំណាចតណ្ហានិងទិដ្ឋិ ។ ព្រោះហេតុអ្វី ធម៌ទើប
មិនគួរប្រកាន់មាំ ព្រោះធម៌ទាំងនោះ មិនតាំងនៅដោយអាការ
ដែលនិងប្រកាន់ទុក ពិតមែន ធម៌ទាំងនោះសូម្បីខ្លួននឹងប្រកាន់យក
ថា សង្ខារទាំងឡាយជារបស់ទៀង ជាសុខ និងជាអត្តា ក៏រមែង
សម្រេចផលថា ជារបស់មិនទៀង ជាទុក្ខ និងជាអនត្តានៅនុ៎ះឯង
ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មិនគួរប្រកាន់មាំ
ដូច្នេះ ។

បទថា **អភិជានាតិ** សេចក្តីថា រមែងដឹងក្រៃលែង គឺ
ដឹងដោយញាតបរិញ្ញាថា សង្ខារទាំងឡាយមិនទៀង ជាទុក្ខធម៌
ទាំងពួងជាអនត្តា ។

បទថា **បរិជានាតិ** សេចក្តីថា រមែងកំណត់ដឹងដោយ
តីរណបរិញ្ញា ដូចយ៉ាងនោះឯង ។

បទថា **យំកិញ្ចិវេទនំ** សេចក្តីថា រមែងសោយវេទនាយ៉ាង
ណាមួយ សូម្បីមានប្រមាណតិចដោយទីបំផុត សូម្បីប្រកបដោយ
បញ្ចវិញ្ញាណ ។

ដោយបទនេះ ព្រះមានព្រះភាគទ្រង់បង្ហែរដោយអំណាចវេទនា ទើបសម្តែងការកំណត់អរូបធម៌(នាមធម៌)ជាអារម្មណ៍ដល់ព្រះថេរៈ បទថា **អនិច្ចានុបស្សី ជាន**ដល់ ពិចារណាឃើញដោយសេចក្តីមិនទៀង ។ វិភគៈក្នុងបទថា **វិភគានុបស្សី** នេះមាន ២ គឺ **ខយវិភគៈ** សេចក្តីបំបាត់តម្រេកព្រោះអស់ទៅ ១ **អច្ចន្តវិភគៈ** សេចក្តីបំបាត់តម្រេកព្រោះកន្លងចំណែក ១ ក្នុងពីរយ៉ាងនេះ វិបស្សនាដែលឃើញការអស់ទៅនៃសង្ខារទាំងឡាយដោយការអស់ក្តី មគ្គញ្ញាណ គឺ ការឃើញសេចក្តីបំបាត់តម្រេកកន្លងចំណែកគឺ ព្រះនិព្វាន ដោយសេចក្តីបំបាត់តម្រេកក្តី ឈ្មោះថាវិភគានុបស្សនាការពិចារណាឃើញដោយសេចក្តីបំបាត់តម្រេក ។ បុគ្គលដែលព្រមប្រៀនដោយវិភគធម៌ទាំង ២ នោះ ឈ្មោះថា **វិភគានុបស្សី** អ្នកតាមឃើញសេចក្តីបំបាត់តម្រេក ។ ព្រះមានព្រះភាគ ទ្រង់សំដៅដល់វិភគៈនោះ ទើបត្រាស់ថា វិភគានុបស្សី អធិប្បាយថា បុគ្គលដែលពិចារណាឃើញសេចក្តីបំបាត់តម្រេក សូម្បីក្នុង **និរោធានុបស្សីបុគ្គល** ក៏នយនេះដូចគ្នា ។ ព្រោះសូម្បីនិរោធ សេចក្តីរលត់ក៏មាន ២ ដូចគ្នា គឺ **ខយនិរោធ** សេចក្តីរលត់

ព្រោះអស់ទៅអច្ចន្តនិរោធ សេចក្តីរលត់កន្លងចំណែក ។ ក្នុងបទថា ***បជិនិស្សគ្គានុបស្សីនេះ វោស្សគ្គៈ*** សេចក្តីលះបង់ លោកហៅថា ***បជិនិស្សគ្គៈ*** សេចក្តីលះបង់ឃើញ ។ សេចក្តីលះបង់នោះ ក៏មាន ២ យ៉ាងគឺ ***បរិចាគវោសសគ្គៈ*** សេចក្តីលះបង់ដោយការបរិច្ចាគ បក្ខន្ទនវោសសគ្គៈ សេចក្តីលះបង់ដោយការគ្រាច់ទៅ ។ បណ្តា សេចក្តីលះបង់ទាំង ២ នោះ វិបស្សនា ឈ្មោះថា បរិចចាគវោស-សគ្គៈ សេចក្តីលះបង់ដោយអំណាចតទង្គបហាន ។ មគ្គ ឈ្មោះ ថា បក្ខន្ទនវោសសគ្គៈ សេចក្តីលះបង់ដោយការគ្រាច់ទៅ ដោយ ថា មគ្គនោះរមែងគ្រាច់ទៅកាន់ព្រះនិព្វានជាអារម្មណ៍ ។ ម្យ៉ាង ទៀត មគ្គនោះ ឈ្មោះថា វោស្សសគ្គៈ ព្រោះហេតុសូម្បីទាំង ២ គឺព្រោះលះខន្ធនិងកិលេស ដោយអំណាចសមុច្ឆេទបហាននិង ព្រោះការគ្រាច់ទៅក្នុងព្រះនិព្វាន ព្រោះហេតុនោះ វិបស្សនាទើប ឈ្មោះថា បរិចចាគវោសគ្គៈ លះបង់ដោយការបរិច្ចាគ ព្រោះ វិបស្សនា រមែងលះកិលេសនិងខន្ធ និងមគ្គដែលឈ្មោះថា បក្ខន្ទ-វោសសគ្គៈសេចក្តីលះបង់ដោយការគ្រាច់ទៅ ព្រោះចិត្ត រមែង គ្រាច់ទៅក្នុងសេចក្តីរលត់ស្និទ្ធគឺ និព្វានហេតុ ក៏ព្រោះហេតុនេះ

ពាក្យទាំង៨ពីរនេះ ទើបចាត់ចូលបានក្នុងមគ្គបុគ្គលដែលព្រមប្រៀនដោយវិបស្សនានិងមគ្គទាំង៨ពីរនោះ រមែងជាអ្នកឈ្មោះថា បដិនិស្សគ្គានុបស្សី អ្នកតាមឃើញសេចក្តីលះបង់យប់ ព្រោះប្រកបដោយបដិនិស្សគ្គានុបស្សនានេះ ។ ព្រះមានព្រះភាគទ្រង់សំដៅដល់បុគ្គលនោះ ទើបត្រាស់យ៉ាងនេះ ។

ពាក្យថា **ន ច កិញ្ចិ លោកេ ឧបាទិយតិ** សេចក្តីថា ភិក្ខុនោះរមែងមិនគោង មិនកាន់យក មិនចាប់ត្រូវធម្មជាតិអ្វី គឺសង្ខារសូម្បីយ៉ាងមួយដោយអំណាចតណ្ហា ។

ពាក្យថា **អនុបាទិយំ ន បរិតស្សតិ** សេចក្តីថា កាលមិនប្រកាន់មាំ បានដល់ ភិក្ខុនោះរមែងមិនប្រកាន់ខ្ជាប់ មិនប្រកាន់យក មិនចាប់ពាល់ធម្មជាតិ ទីងអ្វីដែលជាសង្ខារសូម្បីតែម្យ៉ាង ព្រោះដោយអំណាចតណ្ហា ។

បទថា **បច្ចត្តំយេវ បរិនិព្ពាយតិ** សេចក្តីថា រមែងបរិនិព្វានដោយកិលេសបរិនិព្វានដោយខ្លួនតែម្តង ។ ក៏បច្ចវេក្ខណញ្ញាណរបស់ភិក្ខុនោះ ព្រះមានព្រះភាគទ្រង់សម្តែងដោយនយជាដើមថា ខីណាជាតិ ជាតិអស់ហើយ ដូច្នេះ ។ ដូចនោះព្រះ

មានព្រះភាគ ត្រូវព្រះមោគ្គល្លានទូលសួរដល់បដិបទាដែលជាចំណែកខាងដើម របស់ព្រះខីណាស្រពដោយសង្ខេបហើយ ទើបត្រាស់ដោយសង្ខេបដូចគ្នា ។ តែព្រះសូត្រនេះ ទាំងជាព្រះឱវាទ ទាំងជាវិបស្សនាសម្រាប់ព្រះថេរៈព្រះថេរៈនោះចម្រើនវិបស្សនាក្នុងព្រះសូត្រនេះហើយសម្រេចព្រះអរហន្ត ដូច្នេះឯង ។

គយាសូត្រ

នៅក្នុងបិដកលេខ ៤៨,ទំព័រ ២៨១ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងជាមួយភិក្ខុទាំងឡាយអំពី **(បរិវដ្ដៈ ៨ ប្រការរបស់ព្រះអង្គ)** មានសេចក្តីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងគយាសីសប្រទេស ទៀបស្រុកគយា ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ កាលមុនអំពីការត្រាស់ដឹង តថាគតនៅពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ ស្គាល់នូវពន្លឺដោយច្បាស់លាស់ តែមិន

ឃើញនូវរូបទាំងឡាយ ។

⇨. ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើតថាគតស្គាល់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ញាណទស្សនៈរបស់តថាគតនេះ គប្បីបរិសុទ្ធយ៉ាងក្រៃលែងយ៉ាងនោះដែរ ។

⇨. ម្នាលភិក្ខុទាំងឡាយ សម័យដទៃទៀត តថាគតនោះជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង តែមិនឋិតនៅជាមួយ មិនចរចាជាមួយ មិនដល់នូវការសាកច្ចាជាមួយនឹងទេវតាទាំងឡាយនោះ ។

⇨. ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើតថាគតស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង គប្បីឋិតនៅជាមួយ គប្បីចរចាជាមួយ គប្បីដល់នូវការសាកច្ចាជាមួយនឹងទេវតាទាំងឡាយផង ញាណទស្សនៈរបស់តថាគតនោះ គប្បីបរិសុទ្ធក្រៃលែងយ៉ាងនោះដែរ ។

⇨. ម្នាលភិក្ខុទាំងឡាយ សម័យមួយទៀត តថាគតនោះ

ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង តែមិនឋិតនៅជាមួយ មិនចរចាជាមួយដល់នូវការសាកច្ចាជាមួយនឹងទេវតាទាំងឡាយនោះផង តែមិនស្គាល់ទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះមកអំពីទេវនិកាយឯណ្ណោះ ៗដូច្នេះផង ។

⇨. ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើតថាគតស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ក៏ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ចាជាមួយនឹងទេវតាទាំងឡាយផង តថាគតស្គាល់នូវទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណ្ណោះ ៗដូច្នេះផង ។ ញាណទស្សនៈរបស់តថាគតនោះ គប្បីបរិសុទ្ធក្រៃលែងយ៉ាងនេះ ។

⇨. ម្នាលភិក្ខុទាំងឡាយ សម័យខាងក្រោយមក តថាគតនោះឯង ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញ

ច្បាស់នូវរូបទាំងឡាយផង ក៏ឋិតនៅជាមួយ ចរចាជាមួយដល់នូវការសាកច្ចាជាមួយនឹងទេវតាទាំងឡាយនោះផង ស្គាល់ទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះមកអំពីទេវនិកាយឯណ្ណោះ ៗ ដូច្នេះផង ។ តែមិនស្គាល់ទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះដោយផលកម្មនេះ ដូច្នេះផង ស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះទៅកើតក្នុងទីនោះ ដោយផលកម្មនេះដូច្នេះផង តែមិនស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះមានអាហារយ៉ាងនេះសោយសុខទុក្ខយ៉ាងនេះដូច្នេះផង ស្គាល់នូវទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះដូច្នេះផង តែមិនស្គាល់ទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង តែមិនស្គាល់ទេវតាទាំងនោះថា ទេវតាទាំងនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះដូច្នេះផង តែ

មិនស្គាល់ទេវតាទាំងនោះថា អាត្មាអញធ្លាប់នៅជាមួយនឹងទេវតាទាំងឡាយនេះ ឬថា មិនធ្លាប់នៅជាមួយដូច្នេះផង ។

⇨. ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះយ៉ាងនេះថា ប្រសិនបើតថាគតស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង បឹតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ចាជាមួយនឹងទេវតាទាំងឡាយផង គប្បីស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះមកអំពីទេវនិកាយឯណោះ ។ ដូច្នេះផងគប្បីស្គាល់ទេវតាទាំងនោះថាទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះដោយផលកម្មនេះដូច្នេះផង គប្បីស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះដូច្នេះផង គប្បីស្គាល់នូវទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ មានអាយុវែងយ៉ាងនេះ បឹតនៅអស់កាលយូរយ៉ាងនេះដូច្នេះផងគប្បីស្គាល់នូវទេវតាទាំងនោះថា អាត្មាអញធ្លាប់នៅជាមួយនឹងទេវតាទាំងឡាយ ឬថា មិនធ្លាប់នៅជាមួយទេ ដូច្នេះផង ញាណទស្សនៈរបស់តថាគតនោះ គប្បីបរិសុទ្ធក្រៃលែងយ៉ាងនេះ ។

⇨. ម្នាលភិក្ខុទាំងឡាយ សម័យដទៃទៀត តថាគតនោះជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ចាជាមួយនឹងទេវតាទាំងឡាយនោះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណ្ណោះ ៗ ដូច្នេះផង ស្គាល់ទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះទៅកើតក្នុងទីនោះដោយផលកម្មនេះដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះដូច្នេះផង ស្គាល់នូវទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ ទេវតាទាំងនេះមានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា អាត្មាអញធ្លាប់នៅជាមួយនឹងទេវតាទាំងឡាយនោះឬថាមិនធ្លាប់នៅជាមួយទេ ដូច្នេះផង ។

ម្នាលភិក្ខុទាំងឡាយ **អធិទេវញ្ញាណទស្សនៈ** (ការដឹងនឹងការឃើញនូវទេវតាដ៏ក្រៃលែង) របស់តថាគតមានបរិវដ្ដ

៨ ប្រការយ៉ាងនេះ មិនបរិសុទ្ធដរាបណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក និងព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្សដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលណាអធិទេវញ្ញាណទស្សនៈរបស់តថាគតមានបរិវដ្ត ៨ ប្រការយ៉ាងនេះ បរិសុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ កាលនោះតថាគតប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក និងព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតានិងមនុស្ស ។ មិនតែប៉ុណ្ណោះ សោត ញ្ញាណទស្សនៈក៏កើតឡើងដល់តថាគតថា ចេតោវិមុត្តិរបស់តថាគតមិនកម្រើក ជាតិនេះជាតិទីបំផុតក្នុងកាលឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។

អដ្ឋកថា

បទថា ឯតទវោ ច សេចក្តីថា ដើម្បីនឹងត្រាស់ប្រាប់វិតក្កដែលកើតឡើង ដែលធ្វើសេចក្តីព្យាយាមរបស់ខ្លួនដល់

ភិក្ខុសង្ឃ ទើបត្រាស់ពាក្យមានជាដើមថា **បុព្ពហំ ភិក្ខវេ** ។

បទថា **ឱភាសំ បាន**ដល់ ពន្លឺនៃទិព្វចក្ខុញ្ញាណ ។

បទថា ញាណទស្សនំ បានដល់ ទស្សនៈពោលគឺ ញាណ **ដែល**ជាតួទិព្វចក្ខុ ។

បទថា **សន្និវុដ្ឋបុព្ពំ** ប្រែថា ធ្លាប់នៅរួមគ្នា ។ តែ**ក្នុង**ព្រះសូត្រនេះញាណ ៨ នេះប៉ុណ្ណោះ**មក**ចំពោះ**ក្នុង**ព្រះបាលីមុន គឺ ទិព្វចក្ខុញ្ញាណ ឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ យថាកម្មូបគ-ញ្ញាណ អនាគតំសញ្ញាណ បច្ចុប្បន្នសញ្ញាណ អតីតំសញ្ញាណ បុព្វេនិវាសញ្ញាណ ។ តែត្រាស់រួមញាណ**ទាំង**នេះ គឺវិបស្សនា-ញ្ញាណ មគ្គញ្ញាណ ផលញ្ញាណ ៤ បច្ចវេក្ខណញ្ញាណ ៤ បដិសម្ភិ-ទាញ្ញាណ ៤ អសាធារណញ្ញាណ ៦ ន័យញ្ញាណ ៨ នោះរមែង ជា**ដែល**ឈ្មោះថាត្រាស់ព្រះសូត្រនេះ**ដោយ**ប្រការដូច្នេះ ។

បរិនិព្វាន ៣ យ៉ាង

ក្នុងបរិនិព្វាន ៣ យ៉ាងនោះ***កិលេសបរិនិព្វាន បានមានហើយ លើពោធិបល្ល័ង្ក ខន្ធបរិនិព្វានបានមានហើយក្នុងក្រុងកុសិនារា ធាតុបរិនិព្វាន នឹងមានក្នុងអនាគត ។***

បានឮថា ក្នុងកាលព្រះសាសនាសាបសូន្យ ព្រះធាតុទាំង
ឡាយ នឹងស្តេចប្រជុំគ្នាលើកោះលង្កានេះ ហើយស្តេចទៅកាន់
មហាចេតិយ អំពីមហាចេតិយ ស្តេចយាងទៅកាន់រាជាយតនៈ
ចេតិយក្នុងនាគទ្វីប អំពីរាជាយតនចេតិយ ស្តេចទៅកាន់មហា-
ពោធិបល្ល័ង្ក ។ ព្រះធាតុទាំងឡាយអំពីនាគពិភពក្តី អំពីទេវលោកក្តី
អំពីព្រហ្មលោកក្តី នឹងស្តេចទៅកាន់មហាពោធិបល្ល័ង្កប៉ុណ្ណោះ ។
ព្រះធាតុសូម្បីខ្នាតប៉ុនគ្រាប់ស្ពៃ នឹងមិនវិនាសទៅក្នុងចន្លោះ ៗ
កាល ។ ព្រះធាតុទាំងអស់ (នឹងរួម)ជាគំនរនៅលើមហាពោធិ-
បល្ល័ង្ក ជិតគ្នាតែមួយដូចដុំមាសបញ្ចេញព្រះឆព្វណ្ណរង្សី (មាន
ពណ៌ ៦ប្រការ) ព្រះឆព្វណ្ណរង្សីទាំងឡាយនោះ នឹងផ្សាយ
ទៅមួយម៉ឺនលោកធាតុ ។ តអំពីនោះ ទេវតាទាំងឡាយក្នុងមួយ-
ម៉ឺនចក្រវាឡនឹងប្រជុំគ្នា សម្តែងសេចក្តីកុណាយ៉ាងធំក្រៃលែង
ជាងក្នុងថ្ងៃស្តេចបរិនិព្វានរបស់ព្រះទសពលថា ថ្ងៃនេះព្រះសា-
ស្តានឹងស្តេចបរិនិព្វានថ្ងៃនេះ ព្រះសាសនានឹងសាបសូន្យ នេះជា
ការឃើញគ្រាចុងក្រោយរបស់ពួកយើងក្នុងកាលនេះ ។ លុះលែង
តែព្រះអនាគាមី និងព្រះខីណាស្រព ពួកដ៏សេសមិនអាចតាំងនៅ

តាមសភាវៈរបស់ខ្លួនបាន ។ តេជោធាតុតាំងឡើងក្នុងធាតុទាំងឡាយ ហើយហុយជះឡើងទៅដរាបដល់ព្រហ្មលោក ។ កាលព្រះធាតុសូម្បីមានប្រមាណប៉ុនគ្រាប់ស្ពៃនៅមាន ក៏នឹងរុងរឿងជាប់នៅតែមួយ កាលព្រះធាតុទាំងឡាយអស់ទៅ អណ្តាតភ្លើងក៏អស់ទៅ ។ កាលព្រះធាតុទាំងឡាយ សម្តែងអានុភាពយ៉ាងនេះ ហើយអន្តរធានបាត់ទៅ ។ ព្រះសាសនាឈ្មោះថា ជាការអន្តរធានទៅ ។ ព្រះសាសនាឈ្មោះថា ជារបស់អស្ចារ្យដរាបដែលនៅមិនទាន់អន្តរធានទៅយ៉ាងនេះ ។ កាលដែលព្រះពុទ្ធទាំងឡាយស្តេចឧប្បត្តិ មិនមុនមិនក្រោយគ្នាយ៉ាងនេះនោះ មិនជាហានៈដែលនឹងមានបានទេ ។ (ចាកអដ្ឋកថាបបញ្ចសូទនីពហុធាតុកសូត្រ) ។

អានិសង្សការធ្វើនិព្វានឱ្យជាក់ច្បាស់

១- ធ្វើឱ្យចិត្តមិនញាប់ញ័រក្នុងលោកធម៌
២- ធ្វើឱ្យមិនមានសេចក្តីសោកសៅ
៣- ធ្វើឱ្យចិត្តប្រាសចាកធូលី
៤- ធ្វើឱ្យចិត្តក្សេមក្សាន្តជាដើម ។

ព្រះពុទ្ធវចនៈ

- ភ្លើងអ្វីស្មើដោយរាគៈមិនមាន
- ទោសអ្វីស្មើដោយទោសៈមិនមាន
- ទុក្ខណា ៗស្មើដោយបញ្ចខន្ធមិនមាន
- សុខណា ៗស្មើដោយការស្ងប់មិនមាន
- សេចក្តីស្រេកឃ្លានជារោគយ៉ាងក្រៃលែង
- សង្ខារជាទុក្ខយ៉ាងក្រៃលែង
- ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ។

និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តំ ។

៣៤.កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន នេះជា មង្គលដ៏ឧត្តម ។

សរុបសេចក្តីនៃព្រះគាថាក្នុងអដ្ឋកថា

ពណ៌នាគាថា ថា តថោ ច

ឥទ្ឋវនេះ នឹងពណ៌នាក្នុងគាថាថា តថោ ច នេះ ។ ឈ្មោះ ថា **តបៈ** *ព្រោះដុតបាបធម៌ ។ ការប្រព្រឹត្តដូចព្រហ្ម ឬការប្រព្រឹត្ត របស់ព្រហ្ម ឈ្មោះថា* **ព្រហ្មចរិយៈ** *លោកអធិប្បាយថា* ***ការប្រព្រឹត្ត ដ៏ប្រសើរ*** *។ ការឃើញអរិយសច្ចៈទាំងឡាយ ឈ្មោះថា* **អរិយ-** *សច្ចានទស្សនំ ។ អាចារ្យពួកខ្លះពោលថា* **អរិយសច្ចានិ ទស្សនំ** *ដូច្នេះក៏មាន បទថា* **អរិយសច្ចានិ ទស្សនំ** *ពាក្យនេះមិនពីរោះ សោះ ។ ឈ្មោះថា* **និព្វាន** *ព្រោះចេញចាកវានៈ គឺតណ្ហាជាគ្រឿង រួបរឹត ។ ការធ្វើឱ្យជាក់ច្បាស់ ឈ្មោះថា* **សច្ឆិកិរិយា** *។ ការធ្វើ ឱ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា* **និព្វានសច្ឆិកិរិយា** *។ ពាក្យដ៏សេស មានន័យដូចដែលពោលទាំងនោះឯង ។ នេះជា ការពណ៌នាសេចក្តីនៃបទ ។*

ចំណែកការពណ៌នាសេចក្តីគប្បីជ្រាបដូច្នេះ ឥន្ទ្រិយសំវរៈ ឈ្មោះថា **តបៈ** *ព្រោះដុតអកិរិយា និងទោមនស្សជាដើម ។ ម្យ៉ាង ទៀត សេចក្តីព្យាយាមឈ្មោះថា* **តបៈ** *ព្រោះដុតសេចក្តីខ្ជិល*

ច្រអូស ។ បុគ្គលដែលប្រកបដោយតបៈនោះ លោកហៅថា **អាតាបី** ។ តបៈនោះ គប្បីជ្រាបថា ជាមគ្គ ព្រោះជាហេតុលះអកិរិយាជាដើម និងការបានចំពោះនូវឈានជាដើម ។

ឈ្មោះថា **ព្រហ្មចរិយៈ** ជាឈ្មោះ **របស់មេថុនវិរតិ** សមណធម៌ សាសនានិងមគ្គ ។ ពិតយ៉ាងនោះមែន **មេថុនវិរតិ** លោកហៅថា **ព្រហ្មចរិយៈ** ដូចក្នុងប្រយោគជាដើមថា "**អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ** ភិក្ខុលះបង់អព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ" ។ សមណធម៌ ហៅថា **ព្រហ្មចរិយៈ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "**ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតិ** ម្នាលអាវុសោ លោកដ៏មានអាយុប្រព្រឹត្តសមណធម៌ក្នុងសំណាក់ព្រះដ៏មានព្រះភាគរបស់យើងដែរឬ" ។

សាសនា ហៅថា **ព្រហ្មចរិយៈ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "**ន តាវាហំ ចាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពហុជុញ្ញំ** ម្នាលមារ មានចិត្តបាប ព្រហ្មចារ្យ(សាសនា)របស់តថាគតនេះនៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិសគេមិនទាន់ដឹងច្រើនគ្នានឹងមិនទាន់ពេញបរិបូណ៌ដរាប

ណា មួយទៀតពួកទេវតានឹងមនុស្សមិនទាន់ចេះសម្តែងបានដោយប្រពៃដរាបណាតថាគតនឹងមិនទាន់បរិនិព្វានដរាបនោះដូច្នេះ" ។

មគ្គ ហៅថា **ព្រហ្មចរិយៈ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "**អយមេវ ខោ ភិក្ខុ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ សេយ្យថីទំ សម្មាទិដ្ឋិ** ម្នាលភិក្ខុ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯងហៅថា **ព្រហ្មចរិយៈ** ។ មគ្គទាំង ៨ តើដូចម្តេច គឺ សម្មាទិដ្ឋិជាដើម" ។ តែក្នុងទីនេះ ព្រហ្មចរិយៈសូម្បីទាំងអស់ រមែងគួរ ព្រោះមគ្គលោកសង្គ្រោះដោយអរិយ-សច្ចានទស្សនៈ ខាងមុខហើយ ។ ក៏ព្រហ្មចរិយៈនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុសម្រេចនូវគុណវិសេសនានា មានប្រការផ្សេង ៗខាងលើ ៗ ។

ការឃើញអរិយមគ្គ ដោយអំណាចនៃការចាក់ធ្លុះនូវ អរិយសច្ចៈទាំង ៤តាមដែលបានពោលមកហើយក្នុងកុមារបញ្ហា ឈ្មោះថា ***អរិយសច្ចានទស្សនៈ*** ។ អរិយសច្ចានទស្សនៈនោះ ព្រះដ៏មានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាហេតុកន្ទងបង់នូវសង្សារទុក្ខបាន ។

អរហត្តផល លោកបំណងយកព្រះនិព្វាន ក្នុងទីនេះ ។

ឈ្មោះថា **និព្វានសច្ឆិកិរិយាការធ្វើឱ្យជាក់ច្បាស់ក្នុងព្រះនិព្វាន** ។ *មែនពិតអរហត្តផលនោះលោកពោលថា និព្វាន ព្រោះចេញចាកតណ្ហាដែលសត្វសម្គាល់ថា* **វាន:** *ព្រោះចងទុកក្នុងគតិ ៥* ។ *ការដល់ ឬការពិចារណាព្រះនិព្វាននោះ ហៅថា* **សច្ឆិកិរិយា** *តែការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ក្រៅពីនេះសម្រេចបានដោយការយើញអរិយសច្ច:៤ នោះឯង* ។ *ព្រោះហេតុនោះ ការយើញអរិយសច្ច:នោះ ទើបលោកមិនបំណងទុកក្នុងទីនេះ* ។ *ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះ គប្បីជ្រាបថា* **ជាមង្គល** *ព្រោះជាហេតុនៅជាសុខក្នុងបច្ចុប្បន្នជាដើម ដោយប្រការដូច្នេះ* ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺតប: ១ ព្រហ្មចរិយ: ១ អរិយសច្ចានទស្សន: ១ និង និព្វានសច្ឆិកិរិយា ១ ដោយប្រការដូច្នេះ ។ *ក៏សេចក្តីនៃមង្គលទាំងអស់នោះជាមង្គលបានពន្យល់ទុកក្នុងមង្គលនោះ* ។ *ហើយទាំងអស់នោះឯង* ។

មង្គលកថាមង្គលទី ៣៥ ចប់

គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

-គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស ២៤៩៩

-អដ្ឋកថាពន្យល់សេចក្តីនៃគម្ពីរព្រះត្រៃបិដក ព.ស ២៥២២

- មង្គលត្ថទីបនី ភាគ ៤ របស់ព្រះមហាយិន ឆ្មើន ព.ស ២៥៣៨
- គម្ពីរឃ្លាំងបរិយត្តិភាគ ១-២
- គម្ពីរធម្មាវលី
- គម្ពីរមិលិន្ទបញ្ហា ភាគ ១
- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ព.ស ២៥១១
- ព្រមទាំងឯកសារមួយចំនួនទៀត

ថ្ងៃល្អនៃជីវិត

នៅក្នុងបិដកលេខ ៤១ ទំព័រ ៤៧៩ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ជាមួយនឹងភិក្ខុថាម្នាលភិក្ខុទាំងឡាយសត្វទាំងឡាយណាប្រព្រឹត្តសុចរិតដោយកាយប្រព្រឹត្តសុចរិតដោយវាចាប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាព្រឹកវេលាថ្ងៃវេលាល្ងាចសត្វទាំងនោះឈ្មោះថាមានវេលាព្រឹត្តដ៏ល្អវេលាថ្ងៃដ៏ល្អវេលាល្ងាចដ៏ល្អ។ សមដូចព្រះគាថាថា៖

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ។

ថ្ងៃណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ថ្ងៃនោះឈ្មោះថា នក្ខត្តបឫក្សល្អ មង្គលល្អ ថ្ងៃក្លឹស្វាងល្អ ថ្ងៃនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជាហើយ)ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះឈ្មោះថាជាគ្រឿងបូជាល្អ។